លេខ៖ D308/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| | |
|---|---|
| ឯកសារដើម | |
| ORIGINAL DOCUMENT/DOCUMENT ORIGINAL | |
| ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): | 10 / 07 / 2017 |
| ម៉ោង (Time/Heure): | 13:00 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: | SANN RADA |

សំណុំរឿងលេខ៖ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ៖ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧

ភាសា៖ ខ្មែរ/អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ/Public

# ដីកាដំណោះស្រាយ (សំអាងហេតុ)

**ផ្ញើជូន៖**

សហព្រះរាជអាជ្ញា
ជា លាង
Nicholas KOUMJIAN

មេធាវីការពារក្ដី អ៊ុម ថែម
ប៊ិត សីឯលីម
Wayne JORDASH

សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ
Laure DESFORGES NZEPA
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN

## មាតិកា


I. សេចក្ដីផ្ដើម ........ 5

II. ច្បាប់ជាធរមាន ........ 6

ក. យុត្តាធិការបុគ្គលនៅ អ.វ.ត.ក ........ 6

i. ជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា៖ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និង យុត្តាធិការបទល្មើស ........ 9

ii. គោលការណ៍ច្បាប់ព្រហ្មទណ្ឌ៖ ប្រសិទ្ធភាពនៃគោលការណ៍ "*វិមតិសង្ស័យបានប្រយោជន៍ដល់ជនជាប់ចោទ*" ការបកស្រាយក្នុងន័យចង្អៀត យុត្តាធិការបែបជ្រើសរើស និងការជំនុំជម្រះបែបជ្រើសរើស ........ 16

iii. លក្ខណៈវិនិច្ឆ័យក្នុងការអនុវត្តឆន្ទានុសិទ្ធិ៖ ការធ្វើសេចក្ដីសម្រេចនៅក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ ........ 22

ខ. ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក ........ 24

i. ឧក្រិដ្ឋកម្មជាតិ (ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦) ........ 24

ii. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ........ 29

គ. ទម្រង់នៃការទទួលខុសត្រូវ ........ 44

i. ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ........ 44

ii. ទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តបានសម្រាប់ឧក្រិដ្ឋកម្មជាតិ (ការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦) ........ 57

III. ការពិចារណាទៅលើភស្តុតាង ........ 58

ក. ការធ្វើសម្ភាសន៍ដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយ ដែលបង្កើតឡើងដោយ ក.ស.ច.ស ........ 58

ខ. ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ........ 61

គ. របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៨ ........ 63

i. វិធីសាស្ត្រ ........ 64




CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

01508277




ii. របាយការណ៍រដ្ឋាភិបាល ចុះឆ្នាំ ១៩៨៤ និងការប្រើប្រាស់របាយការណ៍នេះដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ....67

iii. ចំនួនមនុស្សស្លាប់ ....70

iv. សេចក្តីសន្និដ្ឋាន ....74

ឃ . កិច្ចសម្ភាសន៍ អ៊ឹម ចែម ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គភាពផ្សេងទៀត..75

IV. ការវិភាគអង្គហេតុ និងសេចក្តីសន្និដ្ឋាន ....77

ក. អ៊ឹម ចែម មុនខែ មេសា ឆ្នាំ ១៩៧៥ និងក្រោយថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩....77

ខ. តួនាទី និង សិទ្ធិអំណាចរបស់ អ៊ឹម ចែម នៅភូមិភាគពាយ័ព្យ....78

គ. ការចូលគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតីទៅលើភូមិភាគពាយ័ព្យ ....83

ឃ. តួនាទី និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម នៅភូមិភាគពាយ័ព្យ....90

i. ការបញ្ជូន អ៊ឹម ចែម ទៅភូមិភាគពាយ័ព្យ ....90

ii. លេខាស្រុកព្រះនេត្រព្រះ....91

iii. តួនាទីជាសមាជិកគណៈតំបន់ ៥ ....93

iv. ការទទួលខុសត្រូវ សិទ្ធិអំណាច និងប្រភពនៃការទទួលបានព័ត៌មានរបស់ អ៊ឹម ចែម នៅតំបន់ ៥ នៃភូមិភាគពាយ័ព្យ ....100

ង. ភ័ស្តុតាងអំពីការប្រព្រឹត្តិរបស់ អ៊ឹម ចែម នៅភូមិភាគពាយ័ព្យ ....110

ច. ឧក្រិដ្ឋកម្មដែលបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ....115

i. មន្ទីរសន្តិសុខភ្នំទ្រយោង....115

ii. ការដ្ឋានប្រឡាយស្ពានស្រែង....146

V. ភ័ស្តុតាងបទឧក្រិដ្ឋដែលបានចោទប្រកាន់ដោយ ស.ព.អ ប៉ុន្តែពុំបានចោទប្រកាន់ដោយ ស.ច.ស.អ ....160

ក. ការពិចារណាបឋម ....160

ខ. ការពិនិត្យមើលដោយសង្ខេបលើភ័ស្តុតាងអំពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ ដោយ ស.ព.អ ប៉ុន្តែពុំត្រូវបានចោទប្រកាន់ដោយ ស.ច.ស.អ លើ អ៊ឹម ចែម ....162

i. ការពិចារណាបឋមលើលទ្ធភាពដែល អ៊ឹម ចែម អាចជាប់ពាក់ព័ន្ធជាមួយនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានពិនិត្យនៅក្នុងផ្នែកនេះ....162




E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01508278



ii. វាលពិឃាតវត្តអង្គស្រីមុន្នី និងព្រៃស្មុខុន ....... 163
iii. វត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ ....... 165
iv. មន្ទីរសន្តិសុខភូមិចក្រី ....... 170
v. វាលពិឃាតព្រៃតាវ៉ុត ....... 173
vi. វត្តចំការខ្នុរ ....... 175
vii. ការដ្ឋានទំនប់ត្រពាំងថ្ម ....... 178
viii. ការរំលោភសេពសន្ថវៈ ការធ្វើមនុស្សឃាតស្ត្រីជាប់ខ្សែស្រឡាយវៀតណាមពីររូបនៅព្រះនេត្រព្រះ ....... 188
VI. សំអាងច្បាប់លើឧក្រិដ្ឋកម្ម ....... 189
ក . ធាតុផ្សំ "មូលដ្ឋាន" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ....... 189
ខ . ការកំណត់ប្រភេទនៃបទល្មើសដែលត្រូវបានរកឃើញថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង ....... 191
i. មន្ទីរសន្តិសុខភ្នំត្រយោង ....... 191
ii. ការដ្ឋានប្រឡាយស្ពានស្រែង ....... 195
គ . ការកត់សម្គាល់ទៅលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ប៉ុន្តែមិនត្រូវបានចោទប្រកាន់ដោយចៅក្រមប្រឆាំង អ៊ឹម ចែម ....... 198
VII. ការសន្និដ្ឋានលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទៅលើ អ៊ឹម ចែម ....... 198
ក . ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង នៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង ....... 198
ខ. សំអាងហេតុដែល អ៊ឹម ចែម មិនស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ....... 201
ឧបសម្ព័ន្ធ I- តារាង ១
ឧបសម្ព័ន្ធ II- បញ្ជីអក្សរកាត់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## I. សេចក្តីផ្តើម

១. យើងសូមផ្តល់សំអាងហេតុចំពោះដីកាសម្រេចរបស់យើងដែលលើកលែងការចោទប្រកាន់លើ **អ៊ឹម ចែម** ដោយសារមិនមានយុត្តាធិការបុគ្គលគ្រប់គ្រាន់[1]។ យើងនឹងបង្ហាញពីច្បាប់ជាធរមានស្តីពីយុត្តាធិការបុគ្គល និងស្តីពីបទឧក្រិដ្ឋដែលដាក់ **អ៊ឹម ចែម** ឲ្យស្ថិតក្រោមការពិនិត្យ ព្រមទាំងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។ បន្ទាប់មក យើងពន្យល់អំពីរបៀបដែលយើងបានវាយតម្លៃភ័ស្តុតាង។ យើងនឹងវិភាគភ័ស្តុតាងដែលពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងអស់ និងបទចោទលើ **អ៊ឹម ចែម** ព្រមទាំងការកំណត់ប្រភេទបទល្មើស។ ដោយផ្អែកតាមមូលដ្ឋានខាងលើនេះ យើងយល់ឃើញថា ទោះបីជាមានភ័ស្តុតាងបង្ហាញពីការចូលរួមរបស់ **អ៊ឹម ចែម** នៅក្នុងអំពើឧក្រិដ្ឋធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏គាត់មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរ។

២. នៅក្នុងដីកាដំណោះស្រាយនេះ (សំអាងហេតុ) ការកត់សម្គាល់អង្គហេតុអំពីការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មដែលបានរកឃើញថាបានប្រព្រឹត្ត គឺផ្អែកលើបទដ្ឋានលក្ខខណ្ឌភវនីយភាពសម្រាប់ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនលើលក្ខខណ្ឌបទដ្ឋាន "ដោយគ្មានវិមតិសង្ស័យ" សម្រាប់សេចក្តីសម្រេចផ្តន្ទាទោស បន្ទាប់ពីការជំនុំជម្រះក្តីទេ[2]។ ប៉ុន្តែ សេចក្តីសន្និដ្ឋានជាទូទៅរបស់យើងថា គាត់មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ត្រូវបានធ្វើឡើង ទោះបីជាពិចារណាលើភ័ស្តុតាងក្នុងកម្រិតខ្ពស់បំផុតក៏ដោយ។ ហេតុនេះ យើងជឿថា គាត់មិនស្ថិតក្រោមលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការនេះទេ។

---

[1] សំណុំរឿង ០០៤/១-ឯកសារ D308 *ដីកាដំណោះស្រាយ (ផ្នែកសេចក្តីសម្រេច)* ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧។

[2] *សូមមើល* សំណុំរឿង ០០២-ឯកសារ D427 *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣២៣-១៣២៦ និងវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

01508280



## II. ច្បាប់ជាធរមាន

### ក. យុត្តាធិការបុគ្គលនៅ អ.វ.ត.ក

៣. តាមមាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក. ចុះហត្ថលេខានៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")

"គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ០៦ មករា ១៩៧៩"។

៤. មាត្រា ១ នៃច្បាប់ អ.វ.ត.ក ប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង អ.វ.ត.ក[3] ចែងថា៖

"ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"។

៥. មាត្រា ២ នៃច្បាប់ អ.វ.ត.ក រំឭកឡើងវិញជាថ្មីថា អ.វ.ត.ក ត្រូវបង្កើតឡើងដើម្បីជំនុំជម្រះ *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវ*

---

[3] មាត្រា ២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក។

*ខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម [...]ដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ០៦ មករា ១៩៧៩"*។

៦. អ.ជ.ត.ក បានបកស្រាយពាក្យថា *"មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"* សំដៅលើជនពីរប្រភេទ គឺ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងជនដែលមិនមែនជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ប៉ុន្តែក៏ជាជនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។ ជនទាំងពីរប្រភេទនេះ ត្រូវតែជាមន្ត្រីខ្មែរក្រហម *និង* ស្ថិតនៅក្នុងប្រភេទជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដើម្បីឱ្យតុលាការអនុវត្តយុត្តាធិការបុគ្គលឱ្យបានត្រឹមត្រូវ ហេតុនេះ លក្ខណៈវិនិច្ឆ័យទាំងនេះមានលក្ខណៈត្រួតលើគ្នាមិនមែនដាច់ដោយឡែកពីគ្នាទេ[4]។

៧. អ.ជ.ត.ក បានប្រកាសដោយខ្លួនឯងស្តីពីលក្ខណៈយុត្តាធិការនៃមាត្រា ១ នៃច្បាប់ អ.វ.ត.ក។ ទាក់ទិននឹងចំណុចនេះ អ.ជ.ត.ក បានសន្និដ្ឋានថា បញ្ហាថាតើជនជាប់ចោទជាកម្មាភិបាលខ្មែរក្រហម ឬយ៉ាងណានោះវា *"ពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុជាប្រវត្តិសាស្ត្រ ដែលមាន លក្ខណៈងាយយល់ និងច្បាស់លាស់ ហើយផ្តល់ឆន្ទានុសិទ្ធិតិចតួច ឬមិនបានផ្តល់ឆន្ទានុសិទ្ធិទាល់តែសោះដល់អង្គជំនុំជម្រះសាលាដំបូង"* ហេតុនេះជាបញ្ហាដែលអាចវិនិច្ឆ័យបានដែលគ្របដណ្តប់ដោយយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[5]។

៨. ផ្ទុយទៅវិញ ទាក់ទិននឹងពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អ.ជ.ត.ក បានសន្និដ្ឋានថា ប្រភេទទាំងពីរនេះពុំមែនជាលក្ខណៈវិនិច្ឆ័យផ្នែកយុត្តាធិការ *តាមន័យចង្អៀត (stricto sensu)* ទេ វាគ្រាន់តែពិពណ៌នាអំពីទម្រង់នៃគោលនយោបាយស្តីពីការចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងការស៊ើបអង្កេតដោយឯករាជ្យពី ក.ស.ច.ស ប៉ុណ្ណោះ។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ជាគោលការណ៍ ប្រភេទទាំងពីរនេះមិនត្រូវបានកំហិតដោយវិធាននៃការបកស្រាយបែបតឹងរ៉ឹងទេ ហើយជាខ្លឹមសារ វា

[4] សំណុំរឿងលេខ ០០១-ឯកសារ F28 *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៥៧។

[5] សំណុំរឿងលេខ ០០១-ឯកសារ F28 *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦១។



* សហចៅក្រមស៊ើបអង្កេត * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ពុំអាចធ្វើការវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អ.ជ.ត.ក បានទេ ប្រសិនបើពុំមានបង្ហាញអំពីការបំពានឆន្ទានុសិទ្ធិពុំសុចរិត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈនោះឡើយ[6]។

៩. ទោះជាយ៉ាងនេះក្តី នៅក្នុងបរិបទនៃតុលាការ លក្ខណៈវិនិច្ឆ័យដ៏សំខាន់បែបនេះមិនអាចបកស្រាយដោយពុំបានពិចារណាទៅដល់ចំណុចជាមូលដ្ឋាននានាបានទេ ទោះបីវាមានលក្ខណៈផ្លូវច្បាប់ជាក់លាក់បែបណាក៏ដោយ។ តាមពិត ការយោងទៅការបំពានឆន្ទានុសិទ្ធិ ដោយផ្អែកលើភាពពុំសុចរិត ឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ជាការសន្មតជាមុនថា មានរង្វាស់ដែលអាចវាស់វែង និងត្រូវតែវាស់វែងលើការអនុវត្តឆន្ទានុសិទ្ធិ ពោលគឺអ្វីដែលបង្កើតជាព្រំដែននៃសុចរិតភាព និងការវិនិច្ឆ័យត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ មុនពេលសេចក្តីសម្រេចស្ថិតនៅក្នុងលក្ខណៈបំពារបំពាន។ អ.ជ.ត.ក មិនអាចគិតថា ក.ស.ព ឬ ក.ស.ច.ស មានឆន្ទានុសិទ្ធិដោយគ្មានកំណត់ ក្នុងការជ្រើសរើសបុគ្គលណាមួយយកមកចោទប្រកាន់។ ជាគោលការណ៍ យើងក៏មិនយល់ស្របផងដែរទៅនឹងទឡ្ហីករណ៍ដែលថា ការប្រៀបធៀបទៅនឹងបុគ្គលផ្សេងទៀតជាការមិនសមរម្យ ឬសក្តិសមនោះ[7]។ ទោះបីជាយ៉ាងណាក៏ដោយ វាក្លាយជាបញ្ហាបន្ទាប់បន្សំនៃពាក្យពេចន៍ថា តើគេហៅលក្ខណៈវិនិច្ឆ័យនោះថាជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ឬ ជាការណែនាំសម្រាប់ចោទប្រកាន់។ តាមពិត វាតម្រូវឱ្យមានការវិនិច្ឆ័យបានខ្លះផងដែរ លើសេចក្តីសម្រេចរបស់ ក.ស.ព និង ក.ស.ច.ស នោះទេ។

---

[6] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៧៩-៨១។ ទោះជាយ៉ាងណា យើងកត់សម្គាល់ថា សាលក្រមក្នុងសំណុំរឿង ០០១ និង សាលក្រមក្នុងសំណុំរឿង ០០២/០១ ពុំបានយោងដល់វិធាន ៥៨(៧) នៃវិធានផ្ទៃក្នុងទេ។

[7] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦២ "*ទីមួយ ពុំមានវិធីសាស្ត្រជាសត្យានុម័តសម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច ធ្វើការប្រៀបធៀប និងធ្វើការកំណត់ចំណាត់ថ្នាក់នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កម្មាភិបាលខ្មែរក្រហមទាំងអស់បានឡើយ ហើយ ទីពីរ សញ្ញាណនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលយកមកប្រៀបធៀបគ្នានេះ គឺផ្ទុយទៅនឹងមាត្រា ២៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងថា "តួនាទី ឬឋានៈរបស់ជនសង្ស័យមិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ*""។ យើងក៏បានចោទសួរពីភាពត្រឹមត្រូវនៃការយោងទៅមាត្រា ២៩ នៅក្នុងបរិបទនេះដែរ។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១០. ទោះបីយើងបានប្រកាសនៅទីនេះ (ហើយ ស.ច.ស.អ បានប្រកាសដោយឡែកនៅកន្លែងផ្សេង)[8] ថា យើងមិនយល់ស្របទៅនឹងការធ្វើចំណាត់ថ្នាក់របស់ អ.ជ.ត.ក អំពី "យុត្តាធិការបុគ្គល" ថា លក្ខណៈវិនិច្ឆ័យមិនមែនយុត្តាធិការក៏ដោយ តែយើងយល់ថា ដោយសារមូលហេតុនៃការគោរពតាមផ្លូវតុលាការចំពោះស្ថាប័នកំពូលដែលពិនិត្យមើលបណ្ដឹងសាទុក្ខ យើងមានកាតព្វកិច្ចក្នុងការអនុវត្តតាមខ្លឹមសារនៃច្បាប់យុត្តិសាស្ត្ររបស់ អ.ជ.ត.ក លុះត្រាតែមានសំអាងហេតុពិសេសក្នុងការមិនយល់ស្រប និងប្រកាន់ជំហរជំទាស់ជាចំហ។ នេះជាករណី ដែលថា អ.ប.ជ ជាស្ថាប័នតែមួយគត់ដែលទទួលពិនិត្យមើលបណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស ហើយថា នៅក្នុងប្រព័ន្ធស៊ីវិលឡដូចនៅកម្ពុជា ពុំមានទ្រឹស្ដី*ប្រកាន់តាមអ្វីដែលបានសម្រេចមក* (*stare decisis)* ក៏ដោយ។ ទោះជាយ៉ាងណាក្ដី ពាក់ព័ន្ធនឹងភាពច្បាស់លាស់ និងភាពដូចគ្នានៃច្បាប់ នៅក្នុងបរិយាកាសផ្លូវច្បាប់ដែលស្រដៀងនឹង អ.វ.ត.ក វាជាការមិនអាចទទួលយកបានទេ ដែលតម្រូវឱ្យចៅក្រមថ្នាក់ក្រោមនៅក្នុងឋានានុក្រមតុលាការបដិសេធច្បាប់យុត្តិសាស្ត្ររបស់ អ.ជ.ត.ក ប្រសិនបើមិនមានសំអាងហេតុ ពិសេស។

i. <u>ជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា៖ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និង យុត្តាធិការបទល្មើស</u>

១១. ទោះជាយ៉ាងណាក្ដី លក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នាំឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរមួយទៀតផ្នែកគោលនយោបាយ ដែលតម្រូវឱ្យមានការឆ្លើយតបនៅក្នុងបរិបទនេះ ដើម្បីបង្ហាញអំពីផលវិបាកនៃការសន្និដ្ឋានថា ពុំមានយុត្តាធិការបុគ្គល និងផលប៉ះពាល់អ្វីខ្លះដែលអាចកើតមានចំពោះការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស នៅពេលសម្រេចលើកលែងការចោទប្រកាន់ក្នុងរឿងក្ដីមួយ ដោយផ្អែកលើយុត្តាធិការបុគ្គលតែមួយមុខ។

---

[8] **សំណុំរឿងលេខ ០០៣-ឯកសារ D181** *ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្ដីពីយុត្តាធិការបុគ្គល* ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ៣០។

១២. បញ្ហាដែលកំពុងពិភាក្សាគឺកង្វះយុត្តាធិការ បំពេញបន្ថែមដោយតុលាការកម្ពុជាទៅលើឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយមនុស្សដែលស្ថិតក្នុងប្រភេទ "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ បន្ទាប់ពីបានពិនិត្យយ៉ាងល្អិតល្អន់ទៅលើប្រវត្តិនៃការចរចាមុនពេលបង្កើត អ.វ.ត.ក និងការវិវឌ្ឍចាប់តាំងពីពេលនោះមក ជាពិសេសដូចដែល អ.ជ.ត.ក បានលើកឡើង យើងយល់ឃើញថា នាពេលបច្ចុប្បន្ននេះ តុលាការកម្ពុជាផ្សេងទៀតពុំមានយុត្តាធិការបុគ្គល ឬអង្គហេតុនានាដែលស្ថិតនៅក្នុងយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការបទល្មើសរបស់ អ.វ.ត.ក ទេ។ ហេតុនេះ អាចមានទឡ្ហីករណ៍ថា យើងគួរឆ្លើយតបទៅនឹង ផលវិបាកជាក់ស្តែងចេញពីទស្សនៈ និងការអនុវត្តន៍ទ្ធានុសិទ្ធិរបស់យើងឱ្យបានទូលំទូលាយតាមតែអាចធ្វើទៅបាន ដើម្បីជាប្រយោជន៍នៃការសន្និដ្ឋានអំពីយុត្តាធិការបុគ្គល ព្រមទាំងបញ្ចៀសនូវគម្លាតនៃនិទណ្ឌភាពដែលពុំសមរម្យ។ យើងពុំយល់ស្របទៅនឹងសំអាងហេតុនោះទេ ផ្អែកតាមមូលហេតុដែលបង្ហាញដូចខាងក្រោម។

១៣. នៅពេលលើកឡើងអំពីគោលការណ៍នានាខាងលើ អ.ជ.ត.ក បានដឹងថា វាខុសពីយុត្តាធិការ (ដែលមានលក្ខណៈ) អន្តរជាតិនានា ដែលអង្គជំនុំជម្រះបានដកស្រង់នៅក្នុងទឡ្ហីករណ៍របស់ខ្លួន ក្នុងអំឡុងពេលនៃការចរចារវាង អ.ស.ប និង កម្ពុជា នូវទម្រង់ឯកភាពនៃច្បាប់ស្តីពី អ.វ.ត.ក ដោយបានដឹងថានឹងមិនមានយុត្តាធិការបំពេញបន្ថែមដោយតុលាការកម្ពុជា ឬដូចនឹងប្រព័ន្ធដែលមានលក្ខណៈអន្តរជាតិដែលដំណើរការនៅតុលាការផ្សេងទៀត ឧទាហរណ៍ នៅបូស្នៀ និង កូសូវ៉ូ ឬតុលាការយោធាក្រោយសង្គ្រាមលោកលើកទី ២ ចំពោះចារីនានាដែលនៅសេសសល់ ដែលស្ថិតនៅទាបជាងលក្ខខណ្ឌនៃការទទួលខុសត្រូវដែលបានកំណត់សម្រាប់ អ.វ.ត.ក នោះឡើយ។

១៤. ជាការពិត អ.ជ.ត.ក បានទទួលស្គាល់យ៉ាងច្បាស់អំពីជំហរពិសេសរបស់ អ.វ.ត.ក ដោយប្រៀបធៀបទៅនឹងតុលាការផ្សេងទៀត ឧទាហរណ៍ តុលាការ ICTY ដោយលើកឡើងថា៖



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

"[...] អ.វ.ត.ក មានអត្ថិភាពនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែល អ.វ.ត.ក អនុវត្តនូវសមត្ថកិច្ចផ្ដាច់មុខ និងពុំមានការបញ្ជូនរឿងក្ដីណាមួយទៅតុលាការមួយផ្សេងទៀតឡើយ"[9]។

១៥. ស្រដៀងគ្នាដែរ នៅឆ្នាំ ២០១១ អ.ប.ជ បានសម្រេចរួចហើយថា រាជរដ្ឋាភិបាលកម្ពុជាអាចប្រើប្រាស់តុលាការធម្មតារបស់ខ្លួនក្នុងការជំនុំជម្រះពួកខ្មែរក្រហម តែផ្ទុយទៅវិញ រាជរដ្ឋាភិបាលបានជ្រើសរើសការបង្កើត អ.វ.ត.ក៖

"[...] រដ្ឋាភិបាលមាន [...] សេរីភាពក្នុងការចោទប្រកាន់បទល្មើសបែបនេះ [...] នៅក្នុងការអនុវត្តយុត្តាធិការមូលដ្ឋានរបស់ខ្លួន [...]។ ទោះបីជាយ៉ាងនេះក្ដី *ជាជាងការប្រើប្រាស់រចនាសម្ព័ន្ធតុលាការរបស់ខ្លួនដែលមានស្រាប់* រដ្ឋាភិបាល [...] បានព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ បង្កើត អ.វ.ត.ក [...] ហើយ*បានផ្ទេរយុត្តាធិការទៅឱ្យ អ.វ.ត.ក* ធ្វើការជំនុំជម្រះលើរឿងក្ដីទាំងនេះ" [គូសបញ្ជាក់បន្ថែម][10]។

១៦. រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិមិនបានព្យាយាមកំណត់ឱ្យមានការស៊ើបអង្កេត និងការជំនុំជម្រះទៅលើបុគ្គលដែលមិនស្ថិតនៅក្នុងលក្ខខណ្ឌនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ដោយសារពួកគេមិនស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត។ នេះដោយសារ ការធ្វើសមាហរណកម្មពួកខ្មែរក្រហមចូលមកក្នុងសង្គម គឺជាមូលហេតុសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងថែរក្សាសន្តិភាព និងការផ្សះផ្សាជាតិ[11]។ គេគួរកត់សម្គាល់ថា តុលាការយោធាកម្ពុជាបានឃុំខ្លួន កាំង ហ្គេកអ៊ាវ ហៅ ឌុច ដោយខុសច្បាប់ មុនពេលច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចូលជាធរមាននៅថ្ងៃទី

---

[9] សំណុំរឿងលេខ ០០១-ឯកសារ F28 *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៧១។

[10] សំណុំរឿងលេខ ០០២-ឯកសារ D427/2/15 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១០៣។

[11] David Scheffer, "The Extraordinary Chambers in the Courts of Cambodia" នៅក្នុង M. Cherif Bassiouni (ed.), *International Criminal Law, Volume III: International Enforcement* ឆ្នាំ ២០០៨ បោះពុម្ពលើកទី៣ Koninklijke Brill NV ទំព័រ ២២៤-២២៥, ២៤០។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

១០ ខែ សីហា ឆ្នាំ ២០០១[12]។ "គម្លាតនៃនិទណ្ឌភាព" នេះ និងទំនាក់ទំនងរបស់វាទៅនឹងគោលនយោបាយនៃការធ្វើសមាហរកម្មត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ឧទាហរណ៍ នៅដើមឆ្នាំ ២០០៨ ដោយអតីតប្រធានអង្គភាពគាំពារការការពារក្តី Rupert Skilbeck ថា មានភាពខុសប្រក្រតី បើប្រៀបធៀបទៅនឹងតុលាការផ្សេងទៀត[13]។

១៧. ជាពិសេស ខុសពីតុលាការ ឬសាលាក្តីផ្សេងទៀតដែលត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ ឬជាតុលាការ (ជាតិ) ចម្រុះ[14] កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ពុំមានខចែងអំពីគោលការណ៍*គ្មានការកាត់ទោសពីរដងលើរឿងក្តីតែមួយ (ne bis in idem)* តាមខ្សែបណ្តោយ ឬប្រការស្តីពីយុត្តាធិការផ្តាច់មុខ (primacy clause) ពោលគឺ បញ្ញត្តិមួយដែលគ្រប់គ្រងទំនាក់ទំនងរវាងការស៊ើបអង្កេត ការជំនុំជម្រះ និងសេចក្តីសម្រេចនៅថ្នាក់ជាតិ ក្នុងតុលាការធម្មតា និងការស៊ើបអង្កេត ការជំនុំជម្រះ និងសេចក្តីសម្រេចនៅកម្រិតតុលាការពិសេស។ ហេតុនេះ ច្បាប់ជាធរមាននៅ អ.វ.ត.ក មិនបានប្រមើលមើល*ជាមុនទូវ*ស្ថានភាពមួយដែលអាចមានទំនាស់ផ្នែកយុត្តាធិការ ដែលតម្រូវឲ្យមានបញ្ញត្តិបែបនេះទេ។

១៨. ហេតុនេះ ឧទាហរណ៍ ការប្រៀបធៀបដោយមិនត្រឹមត្រូវទៅនឹងច្បាប់យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះលើសមត្ថកិច្ច (referral bench) នៃតុលាការ ICTY អនុលោមតាមវិធាន ១១*ស្ទួន* នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ដើម្បីវាស់ស្ទង់នូវកម្រិតធ្ងន់ធ្ងរ និងការទទួលខុសត្រូវពុំមានប្រយោជន៍ទេ ដោយសារ*បរិបទនៃការចរចា* នៅក្នុងករណី អ.វ.ត.ក មានភាពខុសគ្នាទាំងស្រុង៖ បណ្តាអ្នកតាក់តែងច្បាប់ចង់កំហិតយុត្តាធិការបុគ្គលចំពោះអ្នកដែលមានការទទួលខុសត្រូវខ្ពស់ជាងគេបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

[12] សំណុំរឿងលេខ ០០១-ឯកសារ E39/5 *សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ* ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩។

[13] Rupert Skilbeck, "Defending the Khmer Rouge", *International Criminal Law Review*, Vol. 8(3) ឆ្នាំ ២០០៨ ទំព័រ ៤៣៣-៤៣៤។

[14] មាត្រា ៩ និង ១០ នៃលក្ខន្តិកៈតុលាការ ICTY។ មាត្រា ៨ និង ៩ នៃលក្ខន្តិកៈតុលាការ ICTR។ មាត្រា ៨ និង ៩ នៃលក្ខន្តិកៈតុលាការ SCSL។ មាត្រា ៤ និង ៥ នៃលក្ខន្តិកៈតុលាការ STL។

ហើយពួកគេបានដឹងយ៉ាងច្បាស់ពីចំនួនសរុបនៃការស្លាប់ដែលត្រូវបានស្មានយ៉ាងតិចមានចំនួន ១,៧ លាននាក់។[15] ចំនួនអ្នកស្លាប់អាចមានចំនួនស្មើនឹងចំនួនអ្នកស្លាប់នៅក្នុងជម្លោះធំៗក្នុងពេលបច្ចុប្បន្ន រួមទាំងករណីផ្សេងៗទាំងអស់នៅចំពោះមុខតុលាការ ICC មកដល់សព្វថ្ងៃ (*សូមមើល* តារាងទី១ នៅក្នុងឧបសម្ព័ន្ធ ១)។ ពួកគេក៏បានដឹងដែរថា មានបុគ្គលអាចជាចារីជាច្រើន[16] ដែលម្នាក់ៗអាចទទួលខុសត្រូវក្នុងការស្លាប់មនុស្សរាប់រយ ឬរាប់ពាន់នាក់ ជាសេណារីយ៉ូដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសមត្ថកិច្ច ដោយសារអង្គជំនុំជម្រះយល់ថា *នៅក្នុងចំណោមចំណុចផ្សេងទៀត* ជនល្មើសអាចមានការទទួលខុសត្រូវចំពោះការស្លាប់ជនរងគ្រោះចំនួន ១៤០ នាក់[17]។

១៩. វិសាលភាពដោយឡែកនៃការស្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហម ប្រវត្តិនៃការចរចាបង្ហាញដោយ អ.ជ.ត.ក[18] ព្រមទាំងភស្តុតាងដែលបានមកពីការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤/១ តែមួយ មិនអាចប្រកាន់យកវិធីសាស្ត្រស្រដៀងគ្នាបានទេ ដោយសារ ការវាស់វែងទៅតាមប្រភេទនៃចំនួនទាំងនេះនឹងធ្វើឱ្យទាហានធម្មតាជាច្រើននាក់ដែលបានសម្លាប់មនុស្សជាទ្រង់ទ្រាយធំជាប្រចាំក្នុងរយៈពេលជាយូរ ឬថ្នាក់លើផ្ទាល់របស់ពួកគេដែលបានបញ្ជាពួកគេ អាចស្ថិតក្នុងប្រភេទបុគ្គលទទួលខុសត្រូវខ្ពស់បំផុត ដែលអាចនាំឱ្យមានការស៊ើបអង្កេតថ្មីៗជាច្រើនទៀត ទៅតាមវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង។ នេះវាច្បាស់ហើយថាពុំមែនជាអ្វីដែលអ្នកតាក់តែងច្បាប់គ្រប់គ្រង អ.វ.ត.ក បានប្រមើលមើលនោះទេ ទោះបីពួកគេបានដឹងថា នៅមានចារីប្រភេទនេះជាច្រើនសន្ធឹកសន្ធាប់ទៀត ហើយ

[15] *សូមមើល* David Scheffer, "The Extraordinary Chambers in the Courts of Cambodia" នៅក្នុង M. Cherif Bassiouni (ed.), *International Criminal Law* ឆ្នាំ ២០០៨ បោះពុម្ពលើកទី៣ Koninklijke Brill NV ទំព័រ ២១៩។

[16] David Scheffer, "The Extraordinary Chambers in the Courts of Cambodia" នៅក្នុង M. Cherif Bassiouni (ed.), *International Criminal Law* ឆ្នាំ ២០០៨ បោះពុម្ពលើកទី៣ Koninklijke Brill NV ទំព័រ ២៤០។

[17] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lukić និង Lukić* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Milan Lukić ទាក់ទិននឹងការផ្ទេរសមត្ថកិច្ច អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY Appeals Chamber (IT-98-32/1-AR11bis. 1) ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ២៥។

[18] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៤៦-៥៧។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ពួកគេនឹងមិនត្រូវបាននាំមកកាត់ទោសទេ។ ទាក់ទិននឹងចំណុចនេះ ចាប់ពីខែ ឧសភា ដល់ខែ សីហា ឆ្នាំ ២០១៦ និងក្នុងគោលបំណងដើម្បីបំភ្លឺឱ្យបានកាន់តែច្បាស់នូវឆន្ទៈរបស់ភាគីកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Bohlander បានស្នើសុំកំណត់ហេតុនៃការចរចារវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើត អ.វ.ត.ក ពីបណ្ណសារដ្ឋានអង្គការសហប្រជាជាតិ។ ទោះជាយ៉ាងណាក្តី អង្គការសហប្រជាជាតិបានបដិសេធមិនដាក់បង្ហាញឯកសារភាគច្រើនដែលបានស្នើសុំទេ ដោយសារមូលហេតុនៃភាពសម្ងាត់[19]។

២០. ការណ៍ដែលថា ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មានចែងអំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងមាត្រា ១៨៣-១៩៨ និងបទប្បញ្ញត្តិទូទៅនៅក្នុងមាត្រា ៨ នៃក្រមព្រហ្មទណ្ឌ ប្រកាសថា ក្រមព្រហ្មទណ្ឌ

> "ពុំ *អាចនាំឱ្យមានការបង្កើតនូវស្ថានភាពបដិសេធយុត្តិធម៌ ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ*" (គូសបញ្ជាក់បន្ថែម)

មិនអនុញ្ញាតឱ្យមានការសន្និដ្ឋានដែលថា មានយុត្តាធិការសម្រាប់តុលាការធម្មតាទេ៖ ការយោងខាងលើ សំដៅដល់ច្បាប់ អ.វ.ត.ក ពុំសំដៅដល់ច្បាប់នានាដែលផ្តល់អំណាចបែបប្រតិសកម្មដល់តុលាការធម្មតាឡើយ។

២១. មាត្រា ៣ និង ១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ជារួមមានចែងពី *គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង (nullum crimen)* និងវិធាននៃច្បាប់ដាក់ទោសស្រាលជាងមុន *(lex mitior)* ពោលគឺថា ត្រូវយកច្បាប់ដែលមានលក្ខណៈបន្ធូរបន្ថយជាងគេមកអនុវត្ត ប្រសិនបើមានការកែប្រែច្បាប់នៅពេលប្រព្រឹត្តបទល្មើស និងពេលជំនុំជម្រះក្តី។ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ពុំមានចែងបទប្បញ្ញត្តិស្តីអំពីឧក្រិដ្ឋកម្មនានាដែលបានលើក

---

[19] *សូមមើល* សំណុំរឿងលេខ 00៣-D181/2 *សេចក្តីជូនដំណឹងអំពីការដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវឯកសារដែលទាក់ទងនឹងការបង្កើត អ.វ.ត.ក* ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ១៩។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ឡើងខាងលើ ដែលមានកំណត់ត្រឹមតែបទល្មើសថ្នាក់ជាតិជាប្រភេទបំពេញបន្ថែមផ្អែកតាមទ្រឹស្តី។

២២. ពុំមានភាពច្បាស់លាស់ផងដែរថា តើច្បាប់រដ្ឋធម្មនុញ្ញកម្ពុជានឹងអនុញ្ញាតឱ្យមានការអនុវត្តដោយផ្ទាល់ចំពោះបទល្មើសនានាដែលត្រូវបានទទួលស្គាល់ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្រៅពីវិសាលភាពនៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ឬយ៉ាងណាទេ ដោយសារមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ត្រឹមតែយោងដល់បទដ្ឋាន*សិទ្ធិមនុស្ស*ដែលអាចអនុវត្តដោយផ្ទាល់តែប៉ុណ្ណោះ។ ដូចដែល ស.ច.ស បានពន្យល់នៅក្នុងបរិបទផ្សេងថា ការរំលោភទៅលើបទដ្ឋានសិទ្ធិមនុស្សបែបនោះ ពុំចាំបាច់សុទ្ធតែបណ្តាលឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ[20]។

២៣. សរុបមក យើងយល់ឃើញថា ផលវិបាកនៃច្បាប់ អ.វ.ត.ក ទៅលើយុត្តាធិការបុគ្គលមានទិដ្ឋភាពពីរ៖

ក. វាកំហិតនូវយុត្តាធិការបុគ្គល*ផ្ទាល់*របស់ អ.វ.ត.ក ត្រឹមតែចំពោះអ្នកទទួលខុសត្រូវខ្ពស់បំផុត និង

ខ. វាមិនរាប់បញ្ចូលយុត្តាធិការបុគ្គល ឬយុត្តាធិការបទល្មើសរបស់តុលាការកម្ពុជា*ធម្មតា* ទៅលើព្រឹត្តិការណ៍នានាដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ។

២៤. សេចក្តីសន្និដ្ឋានបែបទ្រឹស្តីនេះក៏ត្រូវបានបញ្ជាក់ដោយអង្គហេតុជាក់ស្តែងដែលថា ពុំមានការស៊ើបអង្កេត ឬ ការជំនុំជម្រះទៅលើរឿងក្តីប្រភេទនេះចំពោះចារីថ្នាក់ក្រោមនៅចំពោះមុខតុលាការកម្ពុជាធម្មតា *ក្រោយពេល* បង្កើត អ.វ.ត.ក ទេ ទោះបីសម័យកម្ពុជាប្រជាធិបតេយ្យបានបន្សល់ទុកការប៉ះទង្គិចផ្លូវចិត្តនៅក្នុងសង្គមកម្ពុជា ហើយមានបុគ្គលរាប់

[20] **សំណុំរឿងលេខ ០០៣-ឯកសារ D191/18** *ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ* ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ កថាខណ្ឌ ៦១។

ពាន់នាក់អាចជាចារី ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដោយផ្ទាល់ ឬក្នុងនាមជាថ្នាក់លើ នៅរស់រានមានជីវិតក៏ដោយ។

២៥. ហេតុនេះមានគម្លាតនិទណ្ឌភាពជាខ្លាំងសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក្តី ការធ្វើសេចក្តីសន្និដ្ឋាននេះមិនត្រូវមានឥទ្ធិពលផ្នែកគោលនយោបាយមកលើការអនុវត្តឆន្ទានុសិទ្ធិរបស់យើង ពាក់ព័ន្ធទៅនឹងយុត្តាធិការបុគ្គលទេ ដោយផ្អែកលើសំអាងហេតុនានាដែលនឹងរៀបរាប់នៅផ្នែកបន្ទាប់។

ii. <u>គោលការណ៍ច្បាប់ព្រហ្មទណ្ឌ៖ ប្រសិទ្ធភាពនៃគោលការណ៍“*វិមតិសង្ស័យបានប្រយោជន៍ដល់ជនជាប់ចោទ*” ការបកស្រាយក្នុងន័យចង្អៀត យុត្តាធិការបែបជ្រើសរើស និងការជំនុំជម្រះបែបជ្រើសរើស</u>

២៦. ក្នុងចំណោមកត្តានានាដែលត្រូវយកមកពិចារណា ដើម្បីអនុវត្តឆន្ទានុសិទ្ធិមានគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ។ ស្របទៅនឹងការបកស្រាយគោលការណ៍នេះដោយ អ.ជ.ត.ក យើងយល់ថា គោលការណ៍*វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* មានតួនាទីមួយក្នុងការបកស្រាយបទប្បញ្ញត្តិច្បាប់ ហើយការអនុវត្តគោលការណ៍នេះកំហិតត្រឹមតែវិមតិសង្ស័យដែលនៅមាន ក្រោយពេលអនុវត្តវិធានបទដ្ឋាននៃការបកស្រាយ[21]។ នៅក្នុងយុត្តាធិការមួយចំនួន ផលវិបាកកើតមានដូចគ្នា តាមរយៈការអនុវត្តនូវការបកស្រាយក្នុងន័យចង្អៀត ឧទាហរណ៍ នៅក្នុងច្បាប់កម្ពុជា[22] និងនៅតុលាការ ICC[23]។

---

[21] **សំណុំរឿងលេខ ០០៣-ឯកសារ D191/18** *ការជូនដំណឹងស្តីពីការបកស្រាយ “ការវាយប្រហារទៅលើប្រជាជនស៊ីវិល” នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ* ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ កថាខណ្ឌ ២១។

[22] *សូមមើល* មាត្រា ៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[23] មាត្រា ២២(២) នៃលក្ខន្តិកៈតុលាការ ICC៖

២៧. ការអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ*ការបកស្រាយក្នុងន័យចង្អៀត មានសារៈសំខាន់ជាងគេនៅក្នុងប្រព័ន្ធដែលច្បាប់មិនបានចែងពេញលេញ ហើយដែលនៅតែកើតមាននៅក្នុងវិស័យច្បាប់ព្រហ្មទណ្ឌ(ដែលមានលក្ខណៈ)អន្តរជាតិ។ ជាពិសេស មិនត្រឹមតែប៉ុណ្ណោះទេ តាមការយល់ឃើញរបស់មេធាវីការពារក្តីដែលថា បទចោទនានាដែលពួកគេត្រូវតទល់ ព្រមទាំងខ្លឹមសារផ្លូវច្បាប់នៃបទចោទទាំងនោះ ដែលជាញឹកញយមានរូបភាព និងលក្ខណៈប្រែប្រួល៖ ករណីនានានៃការបកស្រាយផ្សេងៗគ្នាទៅលើទស្សនៈច្បាប់ដូចគ្នាបេះបិទនៅ អ.វ.ត.ក និង តុលាការផ្សេងៗទៀត ជាពិសេសទៅលើបញ្ហាយុត្តាធិការបុគ្គលតែម្តង[24] ជាភ័ស្តុតាងយ៉ាងច្បាស់ដែលបញ្ជាក់ពីបញ្ហានេះ[25]។

---

និយមន័យនៃឧក្រិដ្ឋកម្មត្រូវតែបកស្រាយបែបតឹងរ៉ឹង និងមិនត្រូវពង្រីកតាមការពន្យល់ប្រៀបធៀបទេ។ ក្នុងករណីមានភាពស្រពិចស្រពិល និយមន័យត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលត្រូវស៊ើបអង្កេត ជំនុំជម្រះ ឬផ្តន្ទាទោស។

[24] *សូមមើល* **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៦៩។

[25] ជាឧទាហរណ៍ នៅ អ.វ.ត.ក អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ តម្រូវឱ្យមានចំណងទាក់ទងរវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ។ *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ D427/2/12** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៩។ ដីកាដំណោះស្រាយដែលបានកែតម្រូវ **សំណុំរឿងលេខ ០០២-ឯកសារ D427/4/14** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤-៥។ និង **សំណុំរឿងលេខ ០០២-ឯកសារ D427/1/26** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៥-៦។ ទោះជាយ៉ាងណាក្តី បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានបដិសេធលក្ខខណ្ឌតម្រូវនៃចំណងទាក់ទង ថាពុំមែនជាផ្នែកនៃនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ទេ។ *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ E95/8** *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ៣៣។ ស្រដៀងគ្នាដែរ ទោះបីអង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់ថាជាបទល្មើសតាមច្បាប់ អ.វ.ត.ក ក៏ដោយ តែអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការរំលោភសេពសន្ថវៈពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយឡែកស្ថិតក្នុងយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក ទេ។ *សូមមើល* **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦៦។ និង **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកាសំណុំរឿង ០០១* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០៧-២១៣។ ចាប់ពីពេលនោះមក អង្គបុរេជំនុំជម្រះបានអនុវត្តតាម...



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ករណីរបស់តុលាការពិសេសដែលមានយុត្តាធិការបុគ្គល យុត្តាធិការបទល្មើស និងយុត្តាធិការពេលវេលាដែលចង្អៀត ដោយផ្អែកលើការចរចាយ៉ាងតឹងតែងរវាងរដ្ឋាភិបាលជាតិ និងសហគមន៍អន្តរជាតិ នៅក្នុងសេណារីយ៉ូអន្តរកាលក្រោយពេលមានជម្លោះ ដែលបានចាប់ផ្តើមដំណើរការជិត ៣០ ឆ្នាំ ក្រោយពេលមានព្រឹត្តិការណ៍នោះ គឺជាឧទាហរណ៍ចម្បងមួយដែលចាំបាច់តម្រូវឱ្យមានការកំហិតចំពោះការបកស្រាយ តាមផ្លូវតុលាការ។

២៨. នេះជាការពិត ជាពិសេស ដោយសារមានសម្ពាធពីការរំពឹងរបស់សាធារណជន ពីសារព័ត៌មាន ដែលព្រួយបារម្ភជុំវិញទស្សនៈនិទណ្ឌភាពចំពោះអំពើឃោរឃៅជាទ្រង់ទ្រាយធំរបៀបវារៈនយោបាយ ព្រមទាំងការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រទៅលើព្រឹត្តិការណ៍សំខាន់នេះកន្លងមក។ និយាយម្យ៉ាងទៀត ជាញឹកញយ នៅក្នុងសេណារីយ៉ូរបៀបនេះ ពិរុទ្ធភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទហាក់ដូចជាមិនចាំបាច់ពិភាក្សាដេញដោល *តាំងពីដំបូង (ab initio)* ទោះបីជាយ៉ាងនេះក្តីកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការពុំមែនគ្រាន់តែជាការយល់ស្រប និងការបញ្ជាក់ជាផ្លូវការគាំទ្រចំពោះទស្សនៈយល់ឃើញជាទូទៅដែលមានស្រាប់ប៉ុណ្ណោះទេ។

២៩. វាជាការសមស្របដែលត្រូវរំឭកឡើងវិញនូវពាក្យពេចន៍របស់ Robert H. Jackson នៅសន្និសីទនៃសមាគមអាមេរិកកាំងនៃច្បាប់អន្តរជាតិកាលពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៤៥ ស្តីពីវិធីសាស្ត្រតុលាការក្នុងការដាក់ទោសលើឧក្រិដ្ឋជនសង្គ្រាម នៃរបបណាហ្ស៊ីនៅមុនពេលចាប់ផ្តើមការជំនុំជម្រះនូរ៉ែមប៊ឺក៖

---

សម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។ *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ៣៧១-៣៧២។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាបានស្វែងរកការកំណត់បទល្មើសរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយឡែក ហើយរំពឹងថា អង្គជំនុំជម្រះសាលាដំបូងនឹងដោះស្រាយបញ្ហានៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០២។ *សូមមើល* **សំណុំរឿងលេខ ០០២-ឯកសារ E99** *សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១។ និង **សំណុំរឿងលេខ ០០២-ឯកសារ E124** *ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ទំព័រ ៨។

*"នោះគឺជាហានិយភ័យមួយក្នុងចំណោមហានិយភ័យនានាដែលត្រូវមាននៅពេលណាដែលការជំនុំជម្រះបានចាប់ផ្ដើម។ គោលការណ៍ចុងក្រោយគឺ តុលាការមិនត្រូវយកបុគ្គលណាម្នាក់មកជំនុំជម្រះ ក្រោមទម្រង់នៃកិច្ចដំណើរការនីតិវិធីតុលាការ ប្រសិនបើតុលាការមិនចង់មើលឃើញបុគ្គលរូបនោះមានសេរីភាព ក្នុងករណីរកមិនឃើញពិរុទ្ធភាព"*[26]។

៣០. ការច្រានចោលការពិត ទោះវាមានន័យសាមញ្ញក៏ដោយ វាដូចនឹងការគាំទ្រលើសេចក្ដីថ្លែងការណ៍ដ៏មិនសមរម្យរបស់ Benedict Carpzov តាំងពីឆ្នាំ១៦៥២ ថា៖

*"គេដឹងឮទូទៅថា នៅក្នុងរឿងក្ដីជំនុំជម្រះលើបទល្មើសធ្ងន់ធ្ងរបំផុត ព្រំដែននៃច្បាប់អាចត្រូវបានច្រានចោលដោយសារលក្ខណៈព្រៃផ្សៃនៃឧក្រិដ្ឋកម្ម"*[27]។

៣១. ច្បាស់ណាស់ថា អ.វ.ត.ក គឺជាតុលាការមួយដែលស្វែងរកយុត្តិធម៌តាមបែបជ្រើសរើសយោងតាមគោលបំណងនៃពាក្យពេចន៍ដែលបានចែង ពីព្រោះមានតែមនុស្សមួយក្រុមតូចតែប៉ុណ្ណោះដែលនឹងត្រូវយកមកចោទប្រកាន់នៅក្នុង អ.វ.ត.ក ចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺ អ្នកទាំងឡាយដែលស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់តុលាការ។

៣២. ការចុះកិច្ចព្រមព្រៀងដោយមិនមានចែងយុត្តាធិការបំពេញបន្ថែមផ្សេងទៀត នៅក្នុងតុលាការជាតិកម្ពុជាគឺជាជម្រើសមនសិការនយោបាយ នៅក្នុងអំឡុងពេលនៃការចរចាដោយបានថ្លឹងថ្លែងលើការអំពាវនាវឱ្យមានការធ្វើសមាហរណកម្មខ្មែរក្រហម ដែលនៅសេសសល់ចូលក្នុងសង្គមជាមួយនឹងគោលបំណងចង់បានការបញ្ចប់តាមផ្លូវតុលាការនូវការឈឺចាប់ខ្លោចផ្សារបស់ជនរងគ្រោះ ទោះបីជាពួកគេបានស្លាប់ ឬ នៅរស់រានមានជីវិតនៅឡើយ ព្រមទាំងសម្រាប់គ្រួសារ និងសង្គមរបស់ពួកគេទាំងមូល។

---

[26] ដកស្រង់នៅក្នុងសៀវភៅ Christoph Safferling, "Nürnberg und die Zukunft des Völkerstrafrechts", *Juristenzeitung*, វ៉ុល ៧០(២២) ឆ្នាំ ២០១៥ ទំព័រ ១០៦៣ លេខយោងជើងទំព័រ ៣៩។

[27] *Notissimum est, quod in delictis atrocissimis propter criminis enormitatem jura transgredi liceat.* Benedict Carpzov, Practica nova imperialis Saxonica rerum criminalium, 1652, Pars III, Quaestio C III.



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៣៣. នៅក្នុងន័យនេះ ស.ព.អ ខ្លួនឯងកាលពីថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩[28] និងកាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤[29] ជាថ្មីម្តងទៀត បានចង្អុលបញ្ជាក់ជាសាធារណៈរួចហើយថា សហព្រះរាជអាជ្ញាពុំចាំបាច់ផ្តួចផ្តើមឱ្យមានការស៊ើបអង្កេតបន្ថែមទៀតក្រោយសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ នោះទេ។ អនុលោមតាមច្បាប់ ទោះបីជាគ្មានជនល្មើសណាម្នាក់អាចអះអាងថា ពួកគេទទួលរងនូវការប្រព្រឹត្តិដោយពុំយុត្តិធម៌ ពីព្រោះមានបុគ្គលជាច្រើនទៀតពុំត្រូវបានចោទប្រកាន់ដែលបុគ្គលទាំងនេះអាចមានការទទួលខុសត្រូវដូចពួកគេក៏ដោយ ដរាបណាពួកគេទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការចោទប្រកាន់តាមបែបជ្រើសរើសនៅក្នុងក្របខ័ណ្ឌយុត្តាធិការជ្រើសរើសបែបនេះអាចបង្ហាញនូវភាពយុត្តិធម៌តាមផ្លូវសីលធម៌[30]។ ចំណុចនេះ គាំទ្រនូវភាពចាំបាច់ក្នុងការទទួលស្គាល់ថា ការវាយតម្លៃដ៏ហ្មត់ចត់ និងរឹងប៉ឹងមួយលើភ័ស្តុតាងប្រឆាំងនឹងបុគ្គលមួយចំនួនតូចនោះដែល *កំពុងត្រូវបាន*ស៊ើបអង្កេតគឺជាការចាំបាច់។

៣៤. យោងតាមទស្សនៈនៃគោលនយោបាយព្រហ្មទណ្ឌទូទៅ វាពិបាកឱ្យសាធារណជន និងជនរងគ្រោះទទួលយកក្នុងន័យនៃពាក្យពេចន៍ទូលាយជាងនេះ ក្នុងការទទួលយកឧទាហរណ៍នូវករណី ទាហានដែលធ្លាប់បានសម្លាប់ក្មេងតូចៗដោយបោកនឹងគល់ឈើ[31]

---

[28] សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី - ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីចំនួនពីរ ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ អាចរកមើលបាននៅលើគេហទំព័រ https://www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf (ចូលមើលចុងក្រោយកាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៧)។

[29] "សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង" ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ អាចរកមើលបាននៅលើគេហទំព័រ KHhttps://www.eccc.gov.kh/articles/30995 (ចូលមើលចុងក្រោយកាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៧)។

[30] *សូមមើល ឧ.* Robert Cryer, *Prosecuting International Crimes- Selectivity and the International Criminal Law Regime,* 2005, Cambridge University Press។

[31] **ឯកសារ D219/80** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធូ លាង ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ KH ERN 01039230 ឆ.៣៤។



ECCC * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01508295



ឬដែលបានប្រណាំងប្រជែងគ្នាថាតើនរណាអាចសម្លាប់មនុស្សបានច្រើនជាងគេ[32] មិនយកមកប្រឈមនឹងការកាត់ទោស។ ករណីនេះដូចគ្នានឹងបុគ្គលដែលបានប្រព្រឹត្តអំពើឃោរឃៅសាហាវយង់ឃ្នងជាច្រើនទៀត ឧទាហរណ៍ ដូចជា អំពើរំលោភជនរងគ្រោះនៅមុនពេលសម្លាប់ពួកគេយកប្រមាត់ ឬថ្លើម និងនៅក្នុងករណីខ្លះយកគ្រឿងក្នុងមកចម្អិនសម្រាប់ហូបទៀតផង[33]។ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាច្រើន ទង្វើបែបនេះនឹងនាំដល់ការដាក់ទោសអស់មួយជីវិតដោយពុំមានការលើកលែងទោស ហើយនៅក្នុងប្រទេសខ្លះ អាចមានទោសប្រហារជីវិតចំពោះ*អំពើនីមួយៗ*របស់ជនល្មើសម្នាក់ៗ។

៣៥. ដើម្បីបញ្ជាក់ឡើងវិញនូវសម្ដីដែលបានលើកឡើងខាងលើ គេបានដឹងអំពីចន្លោះប្រហោងនេះនៅក្នុងអំឡុងពេលចរចារវាងភាគីជាតិ និងភាគីអន្តរជាតិ។ វាក៏ជាលក្ខណៈទូទៅនៃប្រព័ន្ធយុត្តាធិការ (ដែលមានលក្ខណៈ) អន្តរជាតិ ដែលបានបង្កើតឡើងដើម្បីបញ្ចប់ស៊ីណារីយ៉ូ ក្រោយជម្លោះតាមផ្លូវតុលាការ។ វិធីសាស្ត្របែបជ្រើសរើស ជាមួយនឹងការចរចារយុត្តាធិការ ហាក់ដូចជាផ្ដល់ និទណ្ឌភាពចំពោះអតីតពួកខ្មែរក្រហមទាំងមូល នឹងទំនងជាពុំពេញចិត្ត និងអយុត្តិធម៌សម្រាប់មនុស្សភាគច្រើន។ ទោះបីជាយ៉ាងនេះក្ដី ចៅក្រមនៃ អ.វ.ត.ក ត្រូវគោរពតាមសេចក្ដីសម្រេចតាមផ្លូវនយោបាយរបស់អ្នកតាក់តែងច្បាប់ ក្រោយទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ហើយម្យ៉ាងទៀត ការងារនេះមិនត្រូវ និងមិនអាចប្រដូចនឹងសច្ចធារណ៍មានទោស ឬ សច្ចធារណ៍ដោយស្វ័យប្រវត្តិនៃការ

---

[32] **ឯកសារ D119/30** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN00895172 ធ.៣១។ *សូមមើលផងដែរ* អ្នកយាមអួតអាង **ឯកសារ D219/153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុម សឿន ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ KH ERN01058768 ធ.៣២។

[33] **ឯកសារ D118/240** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយ សាន្ត ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN00988052 ធ.៧១។ **ឯកសារ D118/155** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហោ យ៉ន ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១៣ KH ERN00968070, 00968072 ធ.២២-ធ.៣៥។ **ឯកសារ D219/55** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហោ យ៉ន ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ KH ERN01034062-01034063 ធ.១០-ធ.១១។ *សូមមើលផងដែរ* **ឯកសារ D219/269** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យន់ សារឿន ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ KH ERN01088855-01088856 ធ.៤៤។ **ឯកសារ D219/125** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ក់ វន្នី ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN01047382 ធ.៩-ធ.១០។



C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ទទួលខុសត្រូវខ្ពស់ចំពោះបុគ្គលដែល *ត្រូវបាន*នាំមកចំពោះមុខតុលាការដោយសារការចោទប្រកាន់របស់ ក.ស.ព នោះឡើយ។

៣៦. សច្ចធារណ៍បែបនេះ ប្រសិនបើសន្មតមែននោះ ត្រូវធ្វើឡើងក្នុងលក្ខណៈផ្សេងពីនេះ។ ក្រោយរយៈពេលកន្លងហួសយូរមក ភ័ស្តុតាងសំខាន់ខ្លះតាមរយៈសាក្សី ឬប្រភពផ្សេងទៀត អាចបាត់បង់ ដល់កម្រិតមួយដែលពិបាករកព័ត៌មានលម្អិតអាចទុកចិត្តបាន ហើយតាមពិតសាក្សីអាចពិបាកនឹងមកផ្តល់សក្ខីកម្ម។ ករណីនេះគឺពុំមែនការងារដែលត្រូវទម្លាក់ការទទួលខុសត្រូវឱ្យមេធាវីការពារក្តីនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌនោះទេ ឬនាំឱ្យក្លាយជាបទដ្ឋាននៃការបង្ហាញភ័ស្តុតាងក្នុងកម្រិតទាបសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬការផ្តន្ទាទោសនោះឡើយ។ មេធាវីការពារក្តីមានសិទ្ធិទទួលបាននូវការវាយតម្លៃឱ្យបានសមហេតុផលលើភ័ស្តុតាង និងការបកស្រាយច្បាប់នៅក្នុងឋានានុក្រមតុលាការនៃ អ.វ.ត.ក គ្រប់ជាន់ថ្នាក់ ដោយគិតចាប់ផ្តើមពី ក.ស.ច.ស។

### iii. <u>លក្ខណៈវិនិច្ឆ័យក្នុងការអនុវត្តឆន្ទានុសិទ្ធិ៖ ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ</u>

៣៧. យើងកត់សម្គាល់ឃើញថា ដោយទទួលយកនូវនិយមន័យដែលបានកំណត់នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០១ អ.ជ.ត.ក ក៏បានសម្រេចដោយប្រយោលថា វាពុំមានប្រយោជន៍អ្វីត្រូវអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាជុំវិញការបង្កើត អ.វ.ត.ក នាំឱ្យមានការយល់ឃើញតាមផ្លូវច្បាប់រួមថា មានតែបុគ្គល (មានឈ្មោះ) មួយចំនួនប៉ុណ្ណោះដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។ ការជ្រើសយកបុគ្គលមួយចំនួនដែលនឹងនឹងត្រូវធ្វើការស៊ើបអង្កេត និងចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ជាបញ្ហាឆន្ទានុសិទ្ធិទាំងស្រុងរបស់ ក.ស.ព និង ក.ស.ច.ស ហើយផ្អែកទាំងស្រុងលើអង្គសេចក្តីនៃរឿងក្តីនីមួយៗ។

៣៨. តាមទ្រឹស្តី មេដឹកនាំជាន់ខ្ពស់ដែលពុំបានចូលរួមអ្វីជាធំដុំនៅក្នុងសកម្មភាពល្មើសនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចស្ថិតនៅក្រៅក្របខ័ណ្ឌនៃយុត្តាធិការរបស់តុលាការថាពុំមែនជាអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ ផ្ទុយមកវិញ បុគ្គលណាម្នាក់



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * C.C.C * C.E.T.C

ដែលស្ថិតនៅក្នុងឋានានុក្រមថ្នាក់ក្រោមអាចត្រូវបានចាត់ទុកជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត អាស្រ័យលើការចូលរួមចំណែកដោយឡែកៗរបស់បុគ្គលនោះចំពោះអំពើឃោរឃៅ។ ភាពធ្ងន់ធ្ងរនៃសកម្មភាពផ្ទាល់របស់បុគ្គលម្នាក់ និងផលវិបាកនៃអំពើទាំងនោះគឺជាចំណុចត្រូវពិនិត្យមើលដ៏ត្រឹមត្រូវមួយលើកលែងតែដូចអ្វីដែលត្រូវបានលើកឡើងខាងលើ ផលប៉ះពាល់រួមដែលគ្រាន់តែជាបរិមាណ។ ដូច្នេះ ការពិចារណាដែលត្រូវធ្វើឡើងលើបញ្ហាចោទអំពីយុត្តាធិការបុគ្គលពុំមែនខុសគ្នាទាំងស្រុងនឹងការពិចារណាសម្រាប់គោលបំណងដាក់ទោស។

៣៩. ករណីនេះពុំគួរងាកចេញពីផលវិបាកជាក់ស្តែងដំបូង ដែលតួនាទីផ្លូវការដែលបុគ្គលម្នាក់មាននៅក្នុងឋានានុក្រមនោះទេ។ ចំណុចពិចារណាមួយសំខាន់ ប៉ុន្តែពុំមែនសំខាន់ខ្លាំងដាច់ខាតនោះទេ ក្នុងការសម្រេចថាតើបុគ្គលណាស្ថិតនៅក្នុងចំណោមអ្នកទាំងឡាយ "ដែលទទួលខុសត្រូវខ្ពស់បំផុត" គឺកម្រិតដែលជនល្មើសអាចចូលរួមចំណែកក្នុងការសម្រេចលើគោលនយោបាយ និង/ឬការអនុវត្តគោលនយោបាយ។

៤០. ដូចការវិភាគរបស់យើងលើភ័ស្តុតាងខាងក្រោម នឹងបង្ហាញអង្គហេតុទូទៅមួយទៀតដែលត្រូវចងចាំក្នុងចិត្ត។ ទោះបីជាមានការប្រជុំទៀងទាត់ក៏ដោយ ក៏ការធ្វើសេចក្តីសម្រេចនៅក្នុងឋានានុក្រមខ្មែរក្រហម ពុំមែនធ្វើឡើងក្នុងដំណើរប្រជាធិបតេយ្យផ្លូវការមួយ ដែលអាចឲ្យមានការលើកយោបល់ដោយសមភាពនៅចំពោះអ្នកមុខអ្នកការនៅគ្រប់ថ្នាក់ ហើយនាំឲ្យមានការពិភាក្សាគ្នារកច្រកចេញនោះទេ។ សេចក្តីសម្រេចត្រូវបានធ្វើឡើងនៅថ្នាក់កំពូល និងបន្ទាប់មកត្រូវបានអនុវត្តដោយថ្នាក់ក្រោមៗ ដោយមិនខ្វល់ពីផលវិបាកក្នុងលក្ខណៈបុគ្គលទោះនៅថ្នាក់ណាក៏ដោយ ប៉ុន្តែផលវិបាកកើតមានកាន់តែច្រើននៅថ្នាក់ក្រោម តាមរយៈខ្សែសង្វាក់នៃការបញ្ជាដែលគេអាចមើលឃើញ ប្រសិនបើបញ្ជាទាំងនោះពុំត្រូវបានគោរពតាម។ ករណីនេះមិនផ្ទុយពីការពិតដែលថា ជារឿយៗ គោលនយោបាយត្រូវបានសរសេរក្នុងន័យទូទៅដោយថ្នាក់លើ ហើយកម្មាភិបាលថ្នាក់ក្រោមៗត្រូវបានផ្តល់លទ្ធភាពស្វែងយល់លម្អិតនៅក្នុងពេលអនុវត្តគោលនយោបាយទាំងនោះ។ ការលំបាកកាន់តែខ្លាំងនៃការរក្សារចនាសម្ព័ន្ធអង្គការលេខ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យពុំទាមទារឲ្យមានការយល់ឃើញផ្សេងពីនេះឡើយ។ ករណីបុគ្គលម្នាក់បានបង្កើត

01508298



ឬត្រូវបង្កើតគំនិតផ្ដួចផ្ដើមរបស់ខ្លួននៅក្នុងកាលៈទេសៈទាំងនេះ ឬក៏យ៉ាងណានោះ គឺពុំមែនជាលក្ខណៈវិនិច្ឆ័យមួយ ដែលអាចនឹងឱ្យបុគ្គលនោះស្ថិតក្នុងប្រភេទអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ អង្គហេតុនៅតែបង្ហាញថា ទោះក្នុងពេលណាៗក៏ដោយ ការកំណត់ន័យលើខ្លឹមសារនៃគោលនយោបាយ និងមធ្យោបាយអនុវត្តគោលនយោបាយស្ថិតនៅលើថ្នាក់កំពូលដែលអាចជ្រៀតជ្រែកតាមចិត្តចង់របស់ពួកគេ។

៤១. ករណីនេះរួមផ្សំជាមួយនឹងការប្រើប្រាស់ទូលំទូលាយនូវប្រព័ន្ធទំនាក់ទំនងខ្សែបណ្ដោយនៅក្នុងខ្សែសង្វាក់នៃការបញ្ជា និងគោលការណ៍រក្សាការសម្ងាត់ជាប់មកជាមួយដែលជាទូទៅពុំអនុញ្ញាត ឬយ៉ាងហោចណាស់ ពុំលើកទឹកចិត្ត ឬជួយសម្រួលដល់ការផ្លាស់ប្ដូរព័ត៌មានយុទ្ធសាស្ត្រ និងប្រតិបត្តិ តាមលក្ខណៈសមភាពនៃខ្សែទទឹងនៅតាមថ្នាក់ក្រោមៗនៃការដឹកនាំថ្នាក់លើ។ តាមពិត ការណែនាំដែលបានពិភាក្សាគ្នាជាចំហលើសេចក្ដីណែនាំពី*អង្គការ* ឧទាហរណ៍ រវាងមេបញ្ជាការវរសេនាធំ ឬវរសេនាតូចអាចត្រូវបានពិចារណាដោយថ្នាក់លើថាជាវិធីដំបូង ក្នុងការយកអំណាចដោយថ្នាក់ក្រោម ហើយគ្មាននរណាម្នាក់អាចមានសុវត្ថិភាពនៅក្នុងការសន្មតថាការសន្ទនាបែបនោះនឹងពុំត្រូវបានរាយការណ៍នៅក្នុងក្រុមពាក់ព័ន្ធដែលទទួលរងនូវផលប៉ះពាល់អវិជ្ជមានមកលើខ្លួន។

## ខ. **ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក**

៤២. ឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក មានរៀបរាប់នៅក្នុងមាត្រា ៣ ដល់ មាត្រា ៧ នៃច្បាប់ អ.វ.ត.ក។ ផ្នែកនេះនឹងសង្ខេបច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើ **អ៊ឹម ចែម**។

### i. <u>ឧក្រិដ្ឋកម្មជាតិ (ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦)</u>

៤៣. មាត្រា ៣ ថ្មីនៃច្បាប់ អ.វ.ត.ក ផ្ដល់យុត្តាធិការឱ្យ ស.ច.ស លើឧក្រិដ្ឋកម្មមនុស្សឃាត[34] ទារុណកម្ម[35] និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា[36] ថាជាការរំលោភលើក្រមព្រហ្មទណ្ឌ

---

[34] មាត្រា ៥០១ មាត្រា ៥០៣ មាត្រា ៥០៤ មាត្រា ៥០៥ មាត្រា ៥០៦ មាត្រា ៥០៧ និងមាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

01508299



ឆ្នាំ ១៩៥៦ ដែលក្រមព្រហ្មទណ្ឌអាចយកមកអនុវត្តបាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[37]។

*មនុស្សឃាត*

៤៤. ឧក្រិដ្ឋកម្មមនុស្សឃាតក្នុងច្បាប់ជាតិមានពីរទម្រង់ យោងតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ពោលគឺ (១) មនុស្សឃាតដោយគ្មានចេតនាសម្លាប់[38] និង (២) មនុស្សឃាតគិតទុកជាមុន[39]។

៤៥. ឧក្រិដ្ឋកម្មមនុស្សឃាតក្នុងច្បាប់ជាតិទាមទារនូវធាតុផ្សំដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ចំពោះបទមនុស្សឃាតទាំងពីរទម្រង់ ចារីត្រូវជាអ្នកដែលបណ្តាលឱ្យបុគ្គលម្នាក់ទៀតស្លាប់[40]។

ខ. *ធាតុផ្សំអត្តនោម័ត៖*

i. ចំពោះមនុស្សឃាតដែលគ្មានចេតនាសម្លាប់ ចារីបានធ្វើសកម្មភាព "*ក្នុងគោលបំណងបង្កគ្រោះថ្នាក់ដល់បុគ្គលម្នាក់*" ប៉ុន្តែពុំមាន "*ចេតនាបណ្តាលឱ្យស្លាប់នោះទេ*"[41]។

---

[35] មាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[36] មាត្រា ២០៩ និងមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[37] សំណុំរឿងលេខ ០០១-ឯកសារ F28 *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៩២។

[38] មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៤ ដល់ កថាខណ្ឌ ៧៥។

[39] មាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។ **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៤ កថាខណ្ឌ ៧៦។

[40] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៤។

[41] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៥។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

01508300



ii. ចំពោះមនុស្សឃាតគិតទុកជាមុន ចារីបានធ្វើសកម្មភាព "*ដោយគិតទុកជាមុន*" និង "*មានចេតនាបណ្តាលឱ្យស្លាប់*"[42]។ ការគិតទុកជាមុនត្រូវបានកំណត់និយមន័យថា "*ការតាំងចិត្តជាស្រេចថា នឹងប្រព្រឹត្តនូវអំពើណាមួយ មុនពេលដែលប្រព្រឹត្តនូវអំពើនោះគឺថា ពេលសម្រេចចិត្តនឹងពេលដែលប្រព្រឹត្តមានចន្លោះឃ្លាតពីគ្នាល្មមឱ្យចារីរៀបចំដំណើរការនោះបាន*"[43]។

៤៦. អ.ប.ជ បានសម្រេចថា មនុស្សឃាតដោយគ្មានចេតនាសម្លាប់គឺត្រូវបានស្រូបបញ្ចូលនៅក្នុងបទមនុស្សឃាតក្រោមច្បាប់អន្តរជាតិ[44] ចំណែកមនុស្សឃាតគិតទុកជាមុនដែលទាមទារធាតុផ្សំនៃការគិតទុកជាមុន និង*ធាតុផ្សំអត្តនោម័ត*ខ្ពស់ជាងនោះ ពោលគឺ ចេតនាសម្លាប់ជាជាងចេតនាត្រឹមតែបង្កការខូចខាតធ្ងន់ធ្ងរលើរូបរាងកាយពុំត្រូវបានស្រូបបញ្ចូលនោះទេ[45]។

*<u>ទារុណកម្ម</u>*

៤៧. បទទារុណកម្មក្នុងច្បាប់ជាតិយោងតាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ទាមទារនូវធាតុផ្សំដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ចារីត្រូវតែបានប្រព្រឹត្ត "*អំពើទារុណកម្មលើបុគ្គលម្នាក់ទៀត*"[46]។

---

[42] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៦។

[43] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧៨។

[44] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៨៣។

[45] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៨៤។

[46] មាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៦២។



ECCC * CETC CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ខ. *ធាតុផ្សំអត្ថនោម័ត៖ ចារី* បានប្រព្រឹត្តអំពើបែបនេះ (១) ក្នុងគោលបំណងទទួលបានព័ត៌មាន "*មានប្រយោជន៍សម្រាប់ការប្រព្រឹត្តិបទឧក្រិដ្ឋ ឬបទមជ្ឈិម*" (២) "*ដើម្បីសងសឹក*" ឬ (៣) "*ដោយសារអំពើព្រៃផ្សៃ*"[47]។

៤៨. ទោះបីជាក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ពុំបានបញ្ជាក់ថាអ្វីទៅអាចចាត់ទុកជា "អំពើទារុណកម្មក៏ដោយ" ក៏យើងពុំឃើញមានការចង្អុលបញ្ជាក់ថា *ធាតុផ្សំសត្យានុម័ត* មានលក្ខណៈខុសពីធាតុផ្សំនៃឧក្រិដ្ឋកម្មទារុណកម្មក្រោមច្បាប់អន្តរជាតិ (ពោលគឺ "*អំពើ ទោះជាអំពើសកម្ម ឬ អំពើអកម្មក៏ដោយ ដែលធ្វើឲ្យមានការឈឺចុកចាប់ជាខ្លាំងខាងផ្លូវកាយ និងផ្លូវចិត្ត*")[48]។

៤៩. អ.ប.ជ បានសម្រេចឃើញថា ក្នុងចំណោមធាតុផ្សំ*អត្ថនោម័ត*ទាំងបី ចំណុចទីពីរ (ការសងសឹក) ត្រូវបានស្រូបបញ្ចូលនៅក្នុងឧក្រិដ្ឋកម្មទារុណកម្មក្រោមច្បាប់អន្តរជាតិ ចំណែក ចំណុចទីមួយ (ការទទួលបានព័ត៌មានដែលមានប្រយោជន៍សម្រាប់ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ) និងចំណុចទីបី (អំពើព្រៃផ្សៃ) ពុំត្រូវបានស្រូបបញ្ចូលនោះទេ[49]។ ហេតុដូច្នេះ អ.ប.ជ ពុំចាត់ទុកឧក្រិដ្ឋកម្មទារុណកម្មដែលមានចែងនៅក្នុងមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ថាត្រូវបានស្រូបបញ្ចូលក្រោមបទទារុណកម្មថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[50]។

៥០. អ.ប.ជ ពុំបានសម្រេចលើអត្ថន័យនៃ "អំពើព្រៃផ្សៃ" ហើយក៏ពុំមានគោលការណ៍ណែនាំនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ នោះដែរ។ ទោះបីជាយ៉ាងនេះក្តី អ.ប.ជ បានសម្រេច

---

[47] មាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៦២។

[48] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៦៨។

[49] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៦៩ ដល់ កថាខណ្ឌ ៧១។

[50] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៧២។

ថា អ.ប.ជ ពុំបានរកឃើញភ័ស្តុតាងគ្រប់គ្រាន់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០១ ថា ទារុណកម្មនៅ ស-២១ ត្រូវបានប្រព្រឹត្តឡើងដោយសារអំពើព្រៃផ្សៃនោះទេ[51]។

*ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា*

៥១. មាត្រា ២០៩ និងមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងអំពី ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។ មាត្រា ២០៩ ចែងជាភាសាបារាំងថា៖

> *"L'attentat contre la vie d'un religieux pratiquant un culte reconnu par le Gouvernement cambodgien, dans l'exercice ou à l'occasion de l'exercise de sa profession, est puni de la peine criminelle du troisième degré."*

៥២. ដោយមានការជួយជ្រោមជ្រែងលើការបកប្រែភាសាបារាំង សំណៅបកប្រែជាភាសាអង់គ្លេសពីសំណៅដើមជាភាសាខ្មែរនៃមាត្រា ២០៩ ត្រូវបានកំណត់ដូចខាងក្រោម៖

> *"ការព្យាបាទដល់ជីវិតរបស់បព្វជិតក្នុងសាសនារបស់រដ្ឋ នៅវេលាដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬ នៅឱកាសដែលលោកធ្វើវត្តប្រតិបត្តិតាមច្បាប់សាសនា ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី។"*

៥៣. មាត្រា ២១០ ចែងជាភាសាបារាំងថា៖

> *"L'attentat contre la personne d'un religieux pratiquant un culte reconnu par le Gouvernement cambodgien, dans l'exercice ou à l'occasion de l'exercise de sa profession, est puni de la peine criminelle du deuxième degré."*

៥៤. ដោយមានការជួយជ្រោមជ្រែងលើការបកប្រែភាសាបារាំង សំណៅបកប្រែជាភាសាអង់គ្លេសពីសំណៅដើមជាភាសាខ្មែរនៃមាត្រា ២១០ ត្រូវបានកំណត់ដូចខាងក្រោម៖

> *"ការព្យាបាទដល់រូបកាយរបស់បព្វជិតក្នុងសាសនារបស់រដ្ឋ នៅវេលាដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬនៅឱកាសដែលលោកធ្វើវត្តប្រតិបត្តិតាមច្បាប់សាសនា ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីពីរ។"*

---

[51] **សំណុំរឿងលេខ ០០១-ឯកសារ D99/3/42** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ១០១។

៥៥. ផ្អែកតាមចំណុចខាងលើ បទធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាមានធាតុផ្សំដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ចារីត្រូវប្រព្រឹត្តការវាយប្រហារប្រឆាំងនឹងជីវិត ឬ បុគ្គលនៃ "*គ្រូប្រតិបត្តិសាសនាដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជាក្នុងពេលប្រតិបត្តិ ឬ ក្នុងបរិបទជុំវិញការបំពេញមុខងារសាសនារបស់គាត់*"[52]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ទោះបីជាក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ពុំចែងជាក់លាក់នូវ*ធាតុផ្សំអត្តនោម័ត*ចាំបាច់ក៏ដោយ ក៏គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាកំណត់ថា ចារីត្រូវមានចេតនាប្រព្រឹត្ត*ធាតុផ្សំសត្យានុម័ត*នោះ។

៥៦. ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងថា "*ពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ*"[53]។ កំណត់សំគាល់នៅក្រោមមាត្រា ២០៩ និងមាត្រា ២១០ ចែងថា ចំពោះការវាយប្រហារលើជីវិត ឬបុគ្គលដែលពុំមែនជាអ្នកប្រតិបត្តិពុទ្ធសាសនាទេនោះ សូមមើលមាត្រា ៤៩៥ (ការវាយប្រហារលើបុគ្គល) និងមាត្រា ៥០១ (អំពើមនុស្សឃាត) ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[54]។ ហេតុដូច្នេះ ភាពអាចអនុវត្តបាននៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញក្រោមច្បាប់ជាតិគឺរឹតត្បិតត្រឹមការវាយប្រហារលើព្រះសង្ឃពុទ្ធសាសនាតែប៉ុណ្ណោះ។

ii. <u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ</u>

៥៧. អនុសញ្ញាអន្តរជាតិ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍ប្រជាជាតិ គឺជាប្រភពនៃច្បាប់អន្តរជាតិដែលអនុវត្តនៅក្នុង

---

[52] មាត្រា ២០៩ និងមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

[53] ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គន្ថី V ជំពូក II។

[54] កំណត់សម្គាល់នៅបន្ទាប់ពីមាត្រា ២០៩ សរសេរជាភាសាបារាំងថា៖ "*Attentat contre la vie d'un religieux non bouddhiste: voir Code Pénal : articles 501 et suivants*"។ កំណត់សម្គាល់នៅបន្ទាប់ពីមាត្រា ២១០ សរសេរជាភាសាបារាំងថា៖ "*Attentat contre la personne d'un religieux non bouddhiste, voir Code Pénal : articles 495 et suivants*"។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

អំឡុងពេលពាក់ព័ន្ធ[55]។ ទោះបីជាយុត្តិសាស្ត្រនៃសាលាក្តី *មិនអចិន្ត្រៃយ៍*ដែលត្រូវបានបង្កើតឡើងចាប់តាំងពីទសវត្សឆ្នាំ ១៩៩០ ពុំចងកាតព្វកិច្ចនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក៏ដោយ[56] ក៏អង្គជំនុំជម្រះតុលាការកំពូល ("អ.វ.ត.ក") បានទទួលស្គាល់ការសំអាងលើសេចក្តីសម្រេចរបស់សាលាក្តីទាំងនោះ ដរាបណាការសម្រេចរបស់សាលាក្តីទាំងនោះលើធាតុផ្សំនៃបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវបានឆ្លុះបញ្ចាំងច្បាប់ថាវាមានអត្ថិភាពនៅក្នុងអំឡុងយុត្តាធិការពេលវេលានៃ អ.វ.ត.ក ហើយអាចឱ្យជនត្រូវចោទប្រមើលមើលឃើញ និងដឹងថាមានច្បាប់ចែងនៅក្នុងអំឡុងពេលពាក់ព័ន្ធបទចោទ[57]។

៥៨. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការឱ្យ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមាត្រានេះកំណត់និយមន័យថាជា "*អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយ*" ដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ផ្សេងទៀត។

៥៩. លើកលែងតែអំពើរំលោភសេពសន្ថវៈ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[58]។ ចំពោះការរំលោភសេព

---

[55] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៧ ដល់ កថាខណ្ឌ ១៨។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៩២។

[56] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៩៧ *ដកស្រង់* មាត្រា ៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។

[57] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៩៧។

[58] <u>មនុស្សឃាត</u>៖ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤១១។ <u>ការសម្លាប់រង្គាល</u>៖ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤១៥។ <u>ការដាក់ឱ្យទៅជាទាសករ</u>៖ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤២។ <u>ការដាក់ពន្ធនាគារ</u>៖ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ

សន្តរ: អ.ជ.ត.ក បានសម្រេចថា វាពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែកនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ពោលគឺ អំឡុងពេលដែលថែងនៅក្នុងក្របខ័ណ្ឌយុត្តាធិការនៃ អ.វ.ត.ក[59]។ ទោះបីជាយ៉ាងនេះក្តី អ.វ.ត.ក មានយុត្តាធិការលើការរំលោភសេពសន្តរ:ថាជាអំពើទារុណកម្ម នៅពេលដែលធាតុផ្សំទាំងអស់ផ្សេងទៀតនៃអំពើទារុណកម្មបានបំពេញ[60] ហើយថាជាអំពើដែលបង្កើតបានជាអំពើអមនុស្សធម៌ផ្សេងទៀត[61]។

<u>*ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*</u>

៦០. ***អត្ថិភាពនៃការវាយប្រហារ៖*** ការវាយប្រហារគឺជាការប្រព្រឹត្តនូវអំពើហិង្សាច្រើន ដែលមិនមែនគិតត្រឹមតែការប្រើកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះទេ និងអាចរួមបញ្ចូលទាំងការធ្វើ

---

២០១០ កថាខណ្ឌ ៣៤៧។ <u>ទារុណកម្ម៖</u> **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៥៣។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៩៥ ដល់ កថាខណ្ឌ ២០៥។ <u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖</u> **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៦។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២២៥។ <u>អំពើអមនុស្សធម៌ផ្សេងទៀត៖</u> **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៥។

[59] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៨០ ដល់ កថាខណ្ឌ ១៨៣។

[60] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០៧ ដល់ កថាខណ្ឌ ២០៨ កថាខណ្ឌ ២១៣។

[61] **សំណុំរឿងលេខ ០០២-ឯកសារ D427/2/12** *សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ* កថាខណ្ឌ ១១(០២)។ **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៤៣៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Jean-Paul Akayesu,* ICTR-96-4-T សាលក្រម ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៦៨៨។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

បាបប្រជាជនស៊ីវិលផងដែរ[62]។ ការវាយប្រហារទៅលើប្រជាជនស៊ីវិល មានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធ[63]។

៦១. *លក្ខណៈជាទូទៅ ឬជាប្រព័ន្ធនៃការវាយប្រហារ៖* លក្ខខណ្ឌនៃ "លក្ខណៈជាទូទៅ" គឺសំដៅទៅលើការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានចំនួនជនរងគ្រោះច្រើន ហើយធាតុផ្សំនៃលក្ខណៈ "ជាប្រព័ន្ធ" គឺសំដៅទៅលើអំពើហិង្សាដែលមានការរៀបចំ[64]។ ភស្តុតាងដែលបង្ហាញអំពីការវាយប្រហារដែលមាន "លក្ខណៈជាទូទៅ" ឬ "ជាប្រព័ន្ធ" គឺជាភស្តុតាងមួយដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញនូវ*ធាតុផ្សំទូទៅ*នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះ[65]។

៦២. ***សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល៖*** ការវាយប្រហារត្រូវតែ "សំដៅប្រឆាំង" ទៅលើប្រជាជនស៊ីវិល[66]។ វាមិនចាំបាច់មានការបង្ហាញថា ទាល់តែមានប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រពាក់ព័ន្ធណាមួយដែលមានការវាយប្រហារ ទើបចាត់ទុកថាជាគោលដៅនៃការវាយប្រហារនោះឡើយ។ វាមានលក្ខណៈគ្រប់គ្រាន់ ដោយគ្រាន់តែបង្ហាញថាបុគ្គលមួយចំនួននៅក្នុងក្រុមនោះ ត្រូវបានគេកំណត់ថាជាគោលដៅនៃការវាយប្រហារ

---

[62] **សំណុំរឿងលេខ 002-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៧៨។ សំណុំរឿងលេខ 001-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ២៩៨។

[63] សំណុំរឿងលេខ 002-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៧៨។ សំណុំរឿងលេខ 001-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ២៩៨។

[64] សំណុំរឿងលេខ 002-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៧៩។ សំណុំរឿងលេខ 001-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣០០។

[65] សំណុំរឿងលេខ 002-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៧៩។ សំណុំរឿងលេខ 001-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣០០។

[66] សំណុំរឿងលេខ 002-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨២។ *រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* (ICTRY-IT-96-23 & IT-96-23/1-A) សាលដីកា ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ៩១-៩២។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

[67]។ ប្រជាជនដែលជាកម្មវត្ថុនៃការវាយប្រហារ ត្រូវតែជាជនស៊ីវិលច្រើនលើសលុប[68]។ វត្តមានរបស់បុគ្គលមួយចំនួនក្នុងចំណោមប្រជាជនស៊ីវិល ហើយដែលបុគ្គលទាំងនោះមិនមានលក្ខណៈគ្រប់គ្រាន់ជាជនស៊ីវិល មិនអាចដកហូតចរិតលក្ខណៈជាជនស៊ីវិលរបស់ប្រជាជនទាំងនេះបានទេ[69]។

៦៣. *ដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា៖* មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ចែងថា ការវាយប្រហារដូចបានកំណត់ខាងលើ ត្រូវតែធ្វើឡើងដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ប៉ុន្តែមិនមែនដោយមូលហេតុនៃការរើសអើងឡើយ[70]។ នេះគឺជាលក្ខខណ្ឌយុត្តាធិការដែលអនុវត្តចំពោះការវាយប្រហារជាទូទៅ និងមិនមែនចំពោះបទល្មើសទេ[71]។ ដូច្នេះ វាមិនចាំបាច់បង្ហាញភស្តុតាងអំពីចេតនា

---

[67] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨២-១៨៣។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣០២-៣០៣, ៣០៥, ៣០៨។

[68] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៣៨, ៧៤០។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨៣។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Dragomir Milošević,* (ICTY-IT-98-29/1-A) សាលដីកា ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៥០-៥១។

[69] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៤០។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨៣។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Stanislav Galić,* (ICTY-IT-98-29-A) សាលដីកា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៣៦-១៣៨។

[70] **សំណុំរឿងលេខ ០០២-ឯកសារ F36** សាលដីកា ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៤២, ៧៤៤-៧៤៥។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨៨។

[71] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៤៤។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨៨។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

រើសអើងសម្រាប់គ្រប់ឧក្រិដ្ឋកម្មទាំងអស់ប្រឆាំងនឹងមនុស្សជាតិឡើយ។ ចេតនារើសអើង គឺគ្រាន់តែជាលក្ខខណ្ឌមួយទាក់ទិននឹងឧក្រិដ្ឋកម្មការធ្វើទុក្ខបុកម្នេញប៉ុណ្ណោះ[72]។

៦៤. *ទំនាក់ទំនងរវាងអំពើរបស់ជនត្រូវចោទ និងការវាយប្រហារ៖* អំពើរបស់ចារី ទោះជាអំពើនោះជាអំពើប្រភេទណា ឬមានផលវិបាកយ៉ាងណាក៏ដោយ ជាសត្យានុម័តត្រូវតែជាផ្នែកមួយនៃការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល[73]។

៦៥. *ការដឹងជាចាំបាច់៖* ចារីត្រូវតែបានដឹងអំពីការវាយប្រហារលើប្រជាជនស៊ីវិល ព្រមទាំងបានដឹងថា អំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនោះ។ ចារីមិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារ ឬរួមចំណែកដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារដែលមានលក្ខណៈធំទូលាយនោះទេ[74]។

៦៦. *ពុំមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ៖* អត្ថិភាពនៃទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ លែងជាធាតុផ្សំសំខាន់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទៀតហើយ។[75]

---

[72] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៤៤។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨៨-១៨៩។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៣៨។ *សូមមើលផងដែរ* រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង *Jean-Paul Akayesu,* ICTR-96-4-A, សាលដីកា ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៤៦៥-៤៦៦។

[73] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* កថាខណ្ឌ ៧៥៣-៧៥៤។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៩០។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣១៨។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kunarac* សាលដីកា កថាខណ្ឌ ៩៩។

[74] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៩១។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣១៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kunarac,* សាលដីកា ,កថាខណ្ឌ ១០២-១០៣។

[75] *សូមមើល* **សំណុំរឿងលេខ ០០៣-ឯកសារ D87/2/1.7/1, សេចក្ដីសម្រេចលើសំណើ មាស មុត ស្នើបញ្ជាក់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ចំណងទាក់ទងនឹងជម្លោះប្រដាប់អាវុធ, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៦។ សំណុំរឿងលេខ ០០២-ឯកសារ E313** សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៧៧ និង**សំណុំរឿងលេខ ០០២-ឯកសារ F36** សាលដីកា ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧២១, ៧៣២។ នៅឆ្នាំ ២០០១

*<u>ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក</u>*

៦៧. ធាតុផ្សំនៃការធ្វើមនុស្សឃាត គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្មដែលបណ្តាលឲ្យជនរងគ្រោះស្លាប់[76]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចេតនារបស់ចារីក្នុងការសម្លាប់ ឬបង្កឲ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរ ដោយមានហេតុផលដឹងថា អំពើសកម្ម ឬអកម្មនោះមុខជាបង្កឲ្យមានការបាត់បង់ជីវិតមនុស្ស[77]។

៦៨. ធាតុផ្សំនៃការសម្លាប់រង្គាល គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម អំពើអកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះ ដែលនាំឲ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ[78]។ ការ

---

អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ចំណងទាក់ទងគឺជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ *សូមមើល* **សំណុំរឿងលេខ ០០២-D427/3/15** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ និង **សំណុំរឿងលេខ ០០២-D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១។ ទោះជាយ៉ាងណាក្តី បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៦ (**សំណុំរឿងលេខ ០០៣-D87/2/1.7/1**) អង្គបុរេជំនុំជម្រះបានពិចារណាសារជាថ្មីទៅលើជំហរពីមុនរបស់ខ្លួន និងបានសន្និដ្ឋានថា ពុំតម្រូវឲ្យមានចំណងទាក់ទងទេ ហេតុនេះបានប្រកាន់យកជំហរទៅតាមអង្គជំនុំជម្រះផ្សេងទៀតនៅ អ.វ.ត.ក ដែរ *សូមមើល* **សំណុំរឿងលេខ ០០៣-D87/2/1.7/1/1/7** *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ* ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៧។

[76] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤១២។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៣១។

[77] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៣៩១, ៤០៩, ៤១០។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤១២។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៣៣។

កំណត់ទៅលើការសម្លាប់រង្គាលមិនចាំបាច់ត្រូវបង្ហាញនូវចំនួននៃជនរងគ្រោះក្នុងកំរិតអប្បបរមាណាមួយនោះទេ[79]។ លក្ខខណ្ឌតម្រូវនៃទ្រង់ទ្រាយធំត្រូវវាយតម្លៃទៅតាមករណីនីមួយៗ ដោយផ្អែកលើកត្តានៃពេលវេលា និងទីកន្លែងនៃការសម្លាប់ ការសម្រិតសម្រាំងជនរងគ្រោះ និងវិធីកំណត់គោលដៅជនរងគ្រោះ និងអំពីការសម្លាប់ដែលមានចេតនាសំដៅលើក្រុមរួមណាមួយ ជាជាងសំដៅតែទៅលើជនរងគ្រោះម្នាក់ៗ[80]។

ខ. *ធាតុផ្សំអត្តនោម័ត*៖ ចេតនាសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬបង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឱ្យមានការបំផ្លាញផ្នែកសំខាន់ណាមួយនៃក្រុមនោះ[81]។ អ.ជ.ត.ក បានសន្និដ្ឋានថា គោលបំណងនៃការសម្លាប់រង្គាលគឺដើម្បីលុបបំបាត់បុគ្គលដែលជាផ្នែកនៃក្រុមមួយ ដូច្នេះហើយវាពុំស្របជាមួយនឹងសញ្ញាណនៃចេតនាប្រយោល (*dolul eventualis*) ទេ។ បន្ទាប់មក អង្គជំនុំជម្រះបានបញ្ជាក់ថា ទោះបីជាយ៉ាងណាក្តី ការដឹងថា *អំពើពិរុទ្ធ* នឹងបង្កឱ្យមានការស្លាប់មនុស្សជាក់ជាមិនខាននោះ មិនចាំបាច់ឡើយ ប៉ុន្តែអ្វីដែលចាំបាច់នោះគឺ "*ការបង្ហាញថា ការ*

[78] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥២០។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤១៦។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៣៤។

[79] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤១៦។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៣៦។

[80] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥២៥, ៥២៧។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤១៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milan Lukić និង Sredoje Lukić,* (ICTY-IT-98-32/1-A), សាលដីកា ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៥៣៨។

[81] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥២០, ៥២២ ដែលយោងទៅលើ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Krstić,* (ICTY-IT-98-33-T) សាលក្រម ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥០៣។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៣៨។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*សម្លាប់សមាជិកនៃក្រុមមួយគឺជាចេតនារបស់ចារី ដោយពុំគិតពីបញ្ហាថាតើចារីបានដឹងច្បាស់ថា ការសម្លាប់នេះនឹងកើតមានឡើងជាក់ស្តែង ដែរឬយ៉ាងណានោះឡើយ។ ការគ្រាន់តែដឹងថា មានការស្លាប់កើតឡើង ពុំគ្រប់គ្រាន់ឡើយ"*[82]។

៦៩.ធាតុផ្សំនៃការធ្វើឱ្យទៅជាទាសករ គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការប្រើអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើមនុស្ស[83]។ ការធ្វើការងារដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្ត អាចជាការធ្វើឱ្យទៅជាទាសករ[84]។ ការបង្ហាញភ័ស្តុតាងអំពីការធ្វើបាប គឺមិនចាំបាច់ឡើយ ក្នុងការសន្និដ្ឋានអំពីអត្ថិភាពនៃបទល្មើសនៃការធ្វើឱ្យទៅជាទាសករ[85]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីបានប្រើប្រាស់ដោយចេតនានូវអំណាចមួយ ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើបុគ្គលម្នាក់ទៀត[86]។

---

[82] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥២០។

[83] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤២, ៣៤៦។

[84] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Milorad Krnojelac,* (ICTY-IT-97-25-T), សាលក្រម ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ៣៥៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* (ICTY-IT-96-23-T & IT-96-23/1-T) សាលក្រម ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៥៤២-៥៤៣។

[85] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* IT-96-23 & IT-96-23/1-A, សាលដីកា ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១២៣ ដែលដកស្រង់រឿងក្តីសហរដ្ឋអាមេរិក តទល់នឹង *Oswald Pohl និងអ្នកផ្សេងទៀត* សាលក្រម ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៤៧ បានបោះពុម្ពឡើងវិញនៅក្នុង *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមចំពោះមុខតុលាការយោធា Nuremberg ក្រោមច្បាប់លេខ១០របស់ក្រុមប្រឹក្សាគ្រប់គ្រង* វ៉ុល ៥ (ឆ្នាំ ១៩៩៧) ត្រង់ទំព័រ ៩៧០។

[86] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត* IT-96-23 & IT-96-23/1-A, សាលដីកា ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ កថាខណ្ឌ ១២២។



CO-INVESTIGATING JUDGES *E.C.C.C*C.E.T.C* CO-JUGES D'INSTRUCTION

៧០. **ធាតុផ្សំនៃការដាក់ក្នុងមន្ទីរឃុំឃាំង គឺ៖**

ក. *ធាតុផ្សំសត្យានុម័ត៖* ការរដកហូតសេរីភាពរបស់បុគ្គលតាមទំនើងចិត្តដោយគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់ ឬផ្អែកលើបទប្បញ្ញត្តិច្បាប់ជាតិដែលរំលោភលើច្បាប់អន្តរជាតិ[87]។ មិនមែនរាល់ការរំលោភបំពានបន្តិចបន្តួចនៃសិទ្ធិសេរីភាព បង្កើតបានជាការដាក់ក្នុងមន្ទីរឃុំឃាំងនោះទេ ហើយការដកហូតសិទ្ធិសេរីភាពត្រូវតែមានភាពធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មនានាដែលចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក[88]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីមានចេតនាដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល ឬចារីបានប្រព្រឹត្តដោយការដឹងយ៉ាងសមហេតុផលថា សកម្មភាពរបស់ខ្លួនមុខជាបង្កឱ្យមានការដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល[89]។

៧១. **ធាតុផ្សំនៃការធ្វើទារុណកម្ម គឺ៖**

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើណាមួយដែលបណ្តាលឱ្យមានការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរ ផ្នែករាងកាយ ឬស្មារតី ដែលប្រព្រឹត្តឡើង ឬដោយញុះញង់ពី

---

[87] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤៧-៣៤៨។

[88] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤៩ ដែលដកស្រង់រឿងក្តី *Ntagerura* (ICTY-99-46-T) សាលក្រម ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ៧០២។ *សូមមើល ផ្ទុយពីនេះ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac*, IT-97-25-T សាលក្រម ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ១១២។

[89] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៥០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milorad Krnojelac*, IT-97-25-T, សាលក្រម ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ១១៥។

មន្ត្រីសាធារណៈក្នុងគោលបំណងដើម្បីទទួលបានព័ត៌មាន ឬចម្លើយសារភាព ការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ[90]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវមានចេតនាបង្កឲ្យមានការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរទៅលើជនរងគ្រោះ[91]។

៧២. អ.ជ.ត.ក បានសម្រេចថា **ការរំលោភសេពសន្ថវៈ** អាចជាការធ្វើទារុណកម្ម នៅពេលណាដែលធាតុផ្សំផ្សេងៗទៀតនៃអំពើធ្វើទារុណកម្ម ត្រូវបានបំពេញផងដែរនោះ[92]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ស្រដៀងគ្នានឹង អ.ជ.ត.ក ផងដែរនោះ[93] បានកំណត់ចរិតលក្ខណៈការរំលោភសេពសន្ថវៈ ដូចខាងក្រោម៖

ក. *ធាតុផ្សំសត្យានុម័ត៖* ការបញ្ចូលអង្គជាតិ ទោះបីជាមិនបានចូលជ្រៅក៏ដោយ ទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតិរបស់ចារី ឬវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ដោយចារី ឬការបញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតិរបស់ចារីនៅពេលដែលការបញ្ចូលអង្គជាតិនោះកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ ឬនៅក្នុងកាលៈទេសៈដែលផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ[94]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីបានប្រព្រឹត្តដោយមានចេតនាក្នុងការបញ្ចូលអង្គជាតិ និងដឹងថាការបញ្ចូលអង្គជាតិ កើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ ឬដោយបង្ខំដែលផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ[95]។

៧៣. **ធាតុផ្សំនៃបទធ្វើទុក្ខបុកម្នេញ គឺ៖**

---

[90] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៩៥។

[91] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៩៥។

[92] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០៧-២០៨, ២១៣។

[93] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០៨។

[94] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦២។

[95] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦៥។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

ក. *ធាតុផ្សំសត្យានុម័តៈ* អំពើសកម្ម ឬអកម្ម ដែលរើសអើងជាក់ស្តែង និងដកហូត ឬរំលោភសិទ្ធិសារវន្តដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬសន្ធិសញ្ញា[96]។ ធាតុផ្សំនៃការរើសអើងនៅក្នុង*អំពើ*ត្រូវបានបង្កើតឡើង នៅពេលដែលជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះជាសមាជិកនៅក្នុងក្រុមណាមួយដែលចារីបានកំណត់ជាអត្តនោម័ត និងបានធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[97]។ ជនរងគ្រោះត្រូវតែស្តែងឱ្យឃើញច្បាស់លាស់គ្រប់គ្រាន់ថាគាត់ស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយ ដែលផលវិបាកនៃការធ្វើទុក្ខបុកម្នេញតម្រូវ កើតមានទៅលើក្រុមនោះ[98]។ ទាក់ទិននឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ពុំមានការរើសអើងទេ នៅពេលដែលនៅក្នុងអង្គហេតុ ចារីមានការភាន់ច្រឡំលើជនរងគ្រោះដោយមិនដឹងថាតើ ជនរងគ្រោះពិតជាស្ថិតនៅក្នុងក្រុមគោលដៅ ដែលត្រូវកំណត់ដោយអត្តនោម័ត ដែរឬយ៉ាងណា ឬនៅពេលដែលចារីកំណត់ គោលដៅជនរងគ្រោះដោយមិនគិតថាតើ ជនរងគ្រោះស្ថិតនៅក្នុងលក្ខណៈវិនិច្ឆ័យនៃការរើសអើង ដែរឬយ៉ាងណា ឬក៏អាចនិយាយបានថា នៅពេលដែលចារី

[96] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦៧-៦៦៨។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៥៧, ២៦១-២៦២, ២៦៧, ២៧១-២៧៨។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៧-៤២៨។

[97] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦៧, ៦៧៨-៦៧៩, ៦៨៧, ៦៩៥។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៧២-២៧៣, ២៧៤, ២៧៦, ២៧៧។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៨។

[98] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦៨។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៧៤-២៧៧។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៨។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

កំណត់គោលដៅ "ដោយមិនរើសមុខ"[99]។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពិចារណាទៅលើការយល់ឃើញរបស់ចារី នៅពេលធ្វើការកំណត់ក្រុមដែលជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ ដូច្នេះមិនមានលក្ខខណ្ឌតម្រូវថា សមាជិកនៃក្រុមដែលគេកំណត់គោលដៅនោះ ត្រូវតែប្រកាន់ទស្សនៈនយោបាយរួមនោះឡើយ[100]។ ការធ្វើទុក្ខបុកម្នេញអាចប្រព្រឹត្តឡើងតាមរយៈបទល្មើសមួយ ឬច្រើនក្នុងចំណោមបទល្មើសជាមូលដ្ឋានដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ព្រមទាំងតាមរយៈអំពើដទៃទៀត ដែលមានស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងរស្មើគ្នា រួមបញ្ចូលទាំងអំពើទាំងឡាយដែលមិនត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[101]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ការប្រព្រឹត្តិអំពើសកម្ម ឬអកម្មដោយមានចេតនារើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[102]។ យោងតាមយុត្តិសាស្ត្រអន្តរជាតិទូទៅ ទោះបីជានៅពេលដែលអំពើជាមូលដ្ឋានគឺជាបទល្មើសនៅក្រោមច្បាប់អន្តរជាតិក៏ដោយ ក៏មិនចាំបាច់ត្រូវបង្ហាញនូវ *ចេតនាឧក្រិដ្ឋ*ដែលជាលក្ខខណ្ឌតម្រូវសម្រាប់បទល្មើសទាំងនេះឡើយ៖ វាគ្រប់គ្រាន់

---

[99] **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៧៧។ *សូមមើល ផងដែរ* កថាខណ្ឌ ២៧២-២៧៦។

[100] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៦៨, ៦៧៧-៦៨០។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៧២-២៧៣។

[101] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Radoslav Brđanin,* (ICTY-IT-99-36-A) សាលដីកា ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២៩៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tihomir Blaškić,* (ICTY-IT-95-14-A) សាលដីកា ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ១៣៥។

[102] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤២៧។ **សំណុំរឿងលេខ ០០១-ឯកសារ F28** *សាលដីកា* ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៥៧។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

ហើយក្នុងការបង្ហាញថា អំពើជាមូលដ្ឋានត្រូវបានអនុវត្តឡើងដោយមានចេតនារើសអើងចាំបាច់[103]។

៧៤. ធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀត គឺ៖

ក. *ធាតុផ្សំសត្យានុម័ត៖* អំពើសកម្ម ឬអកម្មរបស់ចារី ដែលបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[104]។ អំពើសកម្ម ឬអកម្មរបស់ចារីត្រូវតែមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាក់លាក់ផ្សេងទៀត ដូចមានរៀបរាប់នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដែលត្រូវធ្វើការវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗ ដោយពិចារណាលើកាលៈទេសៈដោយឡែកនីមួយៗនៅក្នុងរឿងក្តីនោះ[105]។ មិនមានលក្ខខណ្ឌតម្រូវថា ការឈឺចាប់នោះត្រូវមានផលប៉ះពាល់រយៈពេលយូរអង្វែងនោះឡើយ ទោះបីវាអាចត្រូវបានយកមកពិចារណាវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ[106]។

ខ. *ធាតុផ្សំអត្តនោម័ត៖* ចារីត្រូវតែបានប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយ ឬផ្លូវចិត្ត ឬប្រព្រឹត្ត

---

103 *រឿងក្តីវិវាទអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* (ICTY-IT-05-88-A) សាលដីកា ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ៧៣៨។ *រឿងក្តីវិវាទអាជ្ញា តទល់នឹង Radoslav Brđanin,* IT-99-36-A សាលដីកា ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២៩៦។

104 **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៨០។

105 **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៦៧, ៥៨៦។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៨។

106 **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៩។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦៩។

អំពើហិង្សាយ៉ាងធ្ងន់ធ្ងរ មកលើជនរងគ្រោះដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬអកម្មនោះ[107]។

៧៥. ការបាត់ខ្លួនដោយបង្ខំ[108] និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ[109] អាចមានលក្ខណៈគ្រប់គ្រាន់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត។

៧៦. *ការបាត់ខ្លួនដោយបង្ខំ៖* ធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំ គឺ៖ (i) បុគ្គលណាម្នាក់អាចត្រូវបានដកហូតសេរីភាពរបស់ខ្លួន (ii) ការដកហូតសេរីភាពនេះត្រូវបានធ្វើឡើង តាមរយៈការបដិសេធមិនបង្ហាញព័ត៌មានទាក់ទងនឹងជោគវាសនា ឬទីកន្លែងដែលបុគ្គលពាក់ព័ន្ធនោះស្ថិតនៅ ឬមិនទទួលស្គាល់ការដកហូតសេរីភាពនេះ (iii) បុគ្គលនោះត្រូវបានបដិសេធចំពោះដំណោះស្រាយតាមផ្លូវច្បាប់ និងការធានាផ្នែកនីតិវិធី និង (iv) ធាតុផ្សំទីមួយ និងទីពីរ ត្រូវបានអនុវត្តដោយភ្នាក់ងាររដ្ឋ ឬដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីរដ្ឋ ឬ អង្គការនយោបាយណាមួយ[110]។

៧៧. *ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ៖* ការមិនផ្តល់ចំណីអាហារ ទឹក ជម្រកស្នាក់នៅ និងជំនួយថ្នាំសង្កូវឲ្យបានគ្រប់គ្រាន់ ព្រមទាំងការដាក់បុគ្គលណាម្នាក់ឲ្យស្ថិតនៅក្រោមស្ថានភាពអនាម័យដែលមិនអាចទទួលយកបាន នៅក្នុងបរិបទនៃការ

---

[107] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៨០។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៧។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦៨, ៣៧១។

[108] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៤៤-៤៤៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Zoran Kupreškić និងអ្នកផ្សេងទៀត* (ICTY-IT-95-16-T) សាលក្រម ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៦៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Alex Tamba Brima និងអ្នកផ្សេងទៀត* SCSL-04-16-A សាលដីកា ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ កថាខណ្ឌ ១៨៤។

[109] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៥៨។

[110] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៤៨។

ឃុំឃាំង អាចបង្កើតបានជាការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់អ្នកជាប់ឃុំឃាំង[111] និងអាចស្ថិតនៅក្នុងវិសាលភាពនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅពេលដែលអំពើទាំងនេះមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាក់លាក់ផ្សេងទៀត ដូចមានរៀបរាប់នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[112]។

## គ. ទម្រង់នៃការទទួលខុសត្រូវ

### i. ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)

៧៨. អនុលោមតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក បុគ្គលម្នាក់អាចទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈទម្រង់នៃការទទួលខុសត្រូវនៃការប្រព្រឹត្ត (រួមទាំងការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម) ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយនិងការជំរុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើ។ ទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះ គឺសុទ្ធតែជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលដែលស្ថិតក្រោម យុត្តាធិការពេលវេលារបស់ អ.វ.ត.ក[113]។

---

[111] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៥៧។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Jadranko Prlić និងអ្នកផ្សេងទៀត* (ICTY-IT-04-74-T) សាលក្រម វ៉ុល III ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១១៥៩, ១១៦២។

[112] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៥៨។

[113] ការប្រព្រឹត្ត៖ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧៩។ ការរៀបចំផែនការ៖ សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៧។ ការញុះញង់៖ សំណុំរឿង ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៩។ ការបញ្ជា៖ សំណុំរឿង ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០១។ ការជួយនិងការជំរុញ៖ សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០៣។ ការទទួលខុសត្រូវរបស់ថ្នាក់លើ៖ សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៤។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៧៩. *ការប្រព្រឹត្ត៖* ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ គ្របដណ្តប់លើការប្រព្រឹត្តិដោយផ្ទាល់ ឬអំពើអកម្មដែលមានពិរុទ្ធនៃអំពើសកម្មមួយ[114]។ ចារីដែលរងការចោទប្រកាន់ ចាំបាច់ត្រូវតែបានប្រព្រឹត្តអំពើសកម្ម ដោយមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងអំពីភាពដែលអាចកើតមានថា ឧក្រិដ្ឋកម្មទំនងនឹងកើតមានឡើង ដោយសារតែផលវិបាកនៃអំពើដែលត្រូវបានចោទប្រកាន់[115]។ ការប្រព្រឹត្តិក៏គ្របដណ្តប់លើការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម[116] ដែលនឹងត្រូវពិភាក្សាបន្ថែមនៅផ្នែកខាងក្រោម។

៨០. *ការរៀបចំផែនការ៖* ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ កើតឡើង នៅពេលដែលមនុស្សម្នាក់ ឬច្រើននាក់រៀបចំអំពើព្រហ្មទណ្ឌ ដែលបង្កើតបានជាឧក្រិដ្ឋកម្មមួយ ឬច្រើន ដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងនៅពេលបន្ទាប់[117]។ ការរៀបចំផែនការចាំបាច់ត្រូវតែកើតឡើងមុន និងរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[118]។ ចារីដែលរងការចោទប្រកាន់ ចាំបាច់ត្រូវតែមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីភាពដែលអាចកើតមានដែលថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តឡើង នៅពេលបំពេញ ឬអនុវត្តផែនការ[119]។

---

[114] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧៩។

[115] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៨១។

[116] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧៩។

[117] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៨។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥១៨។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Kordić និង Čerkez* , (ICTY-IT-95-14/2-A) សាលដីកា ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ២៦។

[118] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥១៨។

[119] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៨។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥១៩។

៨១. *ការញុះញង់៖* ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះកើតឡើង នៅពេលដែលបុគ្គលម្នាក់ តាមរយៈអំពើសកម្ម ឬអកម្ម បណ្តាលឱ្យមនុស្សម្នាក់ទៀតប្រព្រឹត្តឧក្រិដ្ឋកម្ម[120]។ ការញុះញង់អាចកំណត់បាន តាមរយៈការនាំជាលាយលក្ខណ៍អក្សរដោយប្រយោល ឬការជម្រុញមិនផ្ទាល់មាត់ ហើយមិនចាំបាច់កំណត់ពីអំណាចណាមួយ រវាងអ្នកញុះញង់ ដែលរងការចោទប្រកាន់ និងជារីឡើយ[121]។ ការញុះញង់ចាំបាច់ត្រូវតែកើតឡើងមុន និងរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[122]។ អ្នកញុះញង់ចាំបាច់ត្រូវតែមានចេតនាបង្ករឿង ឬនាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីភាពដែលអាចកើតមានដែលថា ឧក្រិដ្ឋកម្មមួយនឹងត្រូវបានប្រព្រឹត្តឡើង នៅពេលអនុវត្តការញុះញង់[123]។

៨២. *ការបញ្ជា៖* ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះកើតឡើង នៅពេលដែលបុគ្គលម្នាក់ នៅក្នុងតួនាទីនៃ*សិទ្ធិអំណាចជាក់ស្តែង* ឬ*តាមផ្លូវច្បាប់* បង្គាប់ដល់មនុស្សផ្សេងទៀតឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[124]។ មិនតម្រូវឱ្យមានទំនាក់ទំនងថ្នាក់លើ ថ្នាក់ក្រោមផ្លូវការណាមួយឡើយរវាងអ្នកចេញបង្គាប់ និងអ្នកទទួលបង្គាប់[125]។ ការបញ្ជាដែលកំពុងចោទ ដែលមិនតម្រូវថាមានទម្រង់ជាក់លាក់ណាមួយនោះ[126] ចាំបាច់ត្រូវតែរួមចំណែកយ៉ាងសំខាន់ដល់

---

[120] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០០។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២២។

[121] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០០។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២២។

[122] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០០។ *សាលដីកា Kordić និង Čerkez* កថាខណ្ឌ ២៧។

[123] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០០។ សំណុំរឿងលេខ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៤។

[124] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

[125] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

[126] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[127]។ ការទទួលខុសត្រូវលើការបញ្ជា អាចកើតឡើងភ្លាមៗផងដែរ នៅពេលដែលបុគ្គលម្នាក់បានចេញបញ្ជា ឬបញ្ជូនបញ្ជា រួមទាំងការចេញ ឬបញ្ជូន តាមរយៈអន្តរការី[128]។ អ្នកចេញបញ្ជាចាំបាច់ត្រូវតែមានចេតនា ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬបានដឹងឮអំពីភាពដែលអាចកើតមានដែលថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្ត ជាផលវិបាកនៃការអនុវត្ត ឬការបំពេញតាមបញ្ជា[129]។

៨៣. *ការជួយ និងការជំរុញ៖* ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះកើតឡើង នៅពេលដែលបុគ្គលម្នាក់ផ្តល់នូវជំនួយជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រផ្លូវចិត្ត ដែលមានផលប៉ះពាល់សំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[130]។ ទាំងអំពើសកម្ម និងអកម្ម សុទ្ធតែអាចបង្កើតបានជាការជួយ និងការជំរុញ[131]។ ផែនការ ឬការព្រមព្រៀងគ្នាជាមុន រវាងចារី និងអ្នកជួយ ឬអ្នកជំរុញឡើយ មិនមែនជាលក្ខខណ្ឌតម្រូវឡើយ[132]។ បន្ថែមលើនេះ មិនមានលក្ខខណ្ឌតម្រូវឱ្យកំណត់ថាអំពើសកម្មរបស់អ្នកជួយ ឬអ្នកជំរុញ គឺសំដៅជាពិសេសទៅលើការជួយ ការលើកទឹកចិត្ត ឬការផ្តល់នូវការគាំទ្រផ្លូវចិត្ត ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មឡើយ។ ការពិចារណាពាក់ព័ន្ធគឺថាតើការជួយជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រផ្លូវចិត្តមានផលប៉ះពាល់សំខាន់ដែរឬយ៉ាងណាចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម[133]។

---

[127] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

[128] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៧។

[129] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០២។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៨។

[130] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០៤, ៧១២ ដល់ ៧១៣។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥២៨, ៥៣៣។

[131] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០៦។

[132] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០៤។ សំណុំរឿងលេខ ០០១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៣៤។

[133] សំណុំរឿងលេខ ០០២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០៨ ដល់ ៧១០។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Taylor* (SCSL-03-01-A) សាលដីកា *Taylor* ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

៨៤. ចំពោះ*ធាតុផ្សំអត្តនោម័ត* អ្នកជួយ ឬអ្នកជំរុញដែលត្រូវបានចោទប្រកាន់ ចាំបាច់ត្រូវតែដឹងថា ឧក្រិដ្ឋកម្មមួយប្រហែលជាត្រូវបានប្រព្រឹត្តឡើង ហើយអំពើរបស់គេបានជួយ ឬសម្របសម្រួលដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[134]។ គេគួរតែបានដឹងផងដែរពីធាតុផ្សំសំខាន់នៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយចារី[135]។

៨៥. *ការទទួលខុសត្រូវរបស់ថ្នាក់លើ៖* ការទទួលខុសត្រូវរបស់ថ្នាក់លើ (បញ្ជា) គឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយអំពើអកម្មដែលមានពិរុទ្ធភាព ដែលតាមរយៈអំពើនេះ ថ្នាក់លើស៊ីវិល ឬយោធា អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការមិនបានរារាំង និង/ឬ ដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់។

៨៦. លក្ខខណ្ឌតម្រូវទីមួយគឺអត្ថិភាពនៃទំនាក់ទំនងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់[136] ដែលអាចជាលក្ខណៈជាក់ស្តែង ឬផ្លូវច្បាប់[137]។ បន្ថែមលើនេះ ការទទួលខុសត្រូវរបស់ថ្នាក់លើអនុវត្តទាំងចំពោះថ្នាក់លើជាស៊ីវិល និងទាំងយោធា[138]។ ថ្នាក់លើទោះបីជាស៊ីវិល ឬយោធា ចាំបាច់ត្រូវតែមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ដែលជាសមត្ថភាពយ៉ាងសំខាន់ដើម្បីរារាំង និង/ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្ម របស់ចារីដែលជាអ្នកនៅក្រោម

---

២០១៣ កថាខណ្ឌ ៦៣៨។ សាលដីកា *Sainović* កថាខណ្ឌ ១៦៤៩។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Stanisić និង *Simatović,* (ICTY-IT-03-69-A), សាលដីកា ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ១០៤, ១០៦, ១០៨។

[134] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០៤។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៣៤ ដល់ ៥៣៥។

[135] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧០៤។ **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៣៥។ ការនេះក៏អនុវត្តផងដែរចំពោះ "ចេតនាជាក់លាក់" ក្នុងករណីនៃ "ការធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូលដ្ឋាននយោបាយ"។

[136] **សំណុំរឿង ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៣៨។ **សំណុំរឿង ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៥។

[137] **សំណុំរឿងលេខ ០០១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤០។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Delalic at al.,* (ICTY-IT-96-21-A) សាលដីកា ចុះថ្ងៃទី ២០ខែ កុម្ភៈ ឆ្នាំ ២០០១ , កថាខណ្ឌ ១៩១ ដល់ ១៩២។ សាលក្រម *Popovic* កថាខណ្ឌ ១០៣៨។

[138] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៤។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

01508323



បង្គាប់[139]។ ជាចុងក្រោយ ថ្នាក់លើមិនបានចាត់វិធានការដែលចាំបាច់ និងសមហេតុផល ដើម្បីរារាំងការប្រព្រឹត្តិឧក្រិដ្ឋកម្មបែបនេះ ឬដាក់ទណ្ឌកម្មចំពោះចារី[140]។ យោងតាមយុត្តិសាស្ត្ររបស់តុលាការ *ចំពោះកិច្ច* គឺមិនចាំបាច់ត្រូវបង្ហាញភ័ស្តុតាងនូវទំនាក់ទំនងហេតុ និងផល រវាងការដែលថ្នាក់លើមិនបានរារាំងឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់ និងការកើតឡើងនូវឧក្រិដ្ឋកម្មទាំងអស់នេះទេ[141]។

៨៧. បន្ថែមលើនេះ ដើម្បីទទួលខុសត្រូវព្រហ្មទណ្ឌ ថ្នាក់លើចាំបាច់ត្រូវតែបានដឹង ឬមានហេតុផលថាបានដឹង តាមរយៈការមានព័ត៌មាន ដែលសមល្មមនឹងធ្វើឱ្យជ្រួតជ្រាបសម្រាប់ជាយុត្តិកម្មលើការស៊ើបអង្កេតបន្ថែមថា ឧក្រិដ្ឋកម្មមួយនឹងត្រូវបានប្រព្រឹត្ត ឬបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់គាត់ម្នាក់ ឬក៏ច្រើននាក់[142]។

៨៨. ការមិនបានរារាំង និងការមិនបានដាក់ទណ្ឌកម្ម គឺជាទម្រង់នៃការទទួលខុសត្រូវដាច់ពីគ្នា ទាំងផ្នែកផ្លូវច្បាប់ និងផ្នែកអង្គហេតុ ដែលតំណាងឱ្យកាតព្វកិច្ចផ្លូវច្បាប់ពីរខុសដាច់ពីគ្នា។ ថ្នាក់លើអាចត្រូវទទួលខុសត្រូវចំពោះការមិនបានអនុវត្តកាតព្វកិច្ចទាំងពីរនេះ[143]។

៨៩. ការទទួលខុសត្រូវរបស់ថ្នាក់លើ អាចមានអត្ថិភាព ផ្អែកលើមូលដ្ឋាននៃទំនាក់ទំនងផ្ទាល់ និងប្រយោលរបស់ថ្នាក់ក្រោម គឺថាបុគ្គលនោះស្ថិតក្នុងខ្សែសង្វាក់នៃការបញ្ជា ហើយប្រើប្រាស់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់ ត្រូវទទួលខុស

---

[139] **សំណុំរឿងលេខ 00២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៥។ **សំណុំរឿងលេខ 00១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤០ ដល់ ៥៤២។

[140] **សំណុំរឿងលេខ 00២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៦។ **សំណុំរឿងលេខ 00១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤៥ ដល់ ៥៤៧។

[141] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Hadžihanasanović និង Kubura* (ICTY-IT-01-47-A) សាលដីកា ចុះថ្ងៃទី ២២ខែ មេសា ឆ្នាំ ២០០៨ កថាខណ្ឌ ៤០។

[142] **សំណុំរឿងលេខ 00២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៥។ **សំណុំរឿងលេខ 00១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤៣ ដល់ ៥៤៤។

[143] **សំណុំរឿងលេខ 00១-ឯកសារ E188** *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤៥ ដល់ ៥៤៧។ *សូមមើលផងដែរ*, សាលដីកា *Hadžihasanović* កថាខណ្ឌ ២៥៩ ដល់ ២៦០។



* CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ត្រូវចំពោះឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់ទាំងនោះ ប្រសិនបើលក្ខខណ្ឌតម្រូវនៃការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានបំពេញ[144]។

៩0. *សហឧក្រិដ្ឋកម្មរួម៖* ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមបង្កើតបានជាការប្រព្រឹត្តិអនុលោមតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[145]។ សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃសហចារីកម្មដែលមនុស្សជាច្រើននាក់មានគោលបំណង ឬគោលដៅរួមគ្នា ដែលបង្កើតបានជាឬពាក់ព័ន្ធជាមួយការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន[146]។

៩១. តុលាការព្រហ្មទណ្ឌអន្តរជាតិ និងអង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណទម្រង់ចំនួនបីនៃសហឧក្រិដ្ឋកម្មរួម[147]។ ទម្រង់ទីមួយ និងទីពីរនៃសហឧក្រិដ្ឋកម្មរួមមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយអាចអនុវត្តបាននៅ អ.វ.ត.ក[148]។ ទម្រង់ទីពីរនៃសហឧក្រិដ្ឋកម្មរួមដែលមានធាតុផ្សំដូចគ្នាជាមួយទម្រង់ទីមួយ មិនត្រូវបានចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ឡើយ។ ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលវេលានោះឡើយ

[144] សំណុំរឿងលេខ 00២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧១៦។ សំណុំរឿងលេខ 00១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៧២១។ សំណុំរឿងលេខ 00១-ឯកសារ E188 *សាលក្រម* ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៥៤២, ដកស្រង់ សាលដីកា *Blaskić* កថាខណ្ឌ ៦៧ និង សាលដីកា *Čelebići* កថាខណ្ឌ ២៥២។

[145] សំណុំរឿងលេខ 00២-ឯកសារ E100/6 *សេចក្តីសម្រេចលើភាពអាចអនុវត្តបាន នូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២២។ សំណុំរឿងលេខ 00២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩០។

[146] សំណុំរឿងលេខ 00២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩២។

[147] សំណុំរឿងលេខ 00២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩០។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Tadić* (ICTY-IT-94-1-A) សាលដីកា ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩៦ ដល់ ២០៤។

[148] សំណុំរឿងលេខ 00២-ឯកសារ E100/6 *សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ២២។ សំណុំរឿងលេខ 00២-ឯកសារ E313 *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩១។ សំណុំរឿងលេខ 00២-ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៩៧។



E.C.C.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដូច្នេះទម្រង់នេះមិនអាចអនុវត្តបាននៅ អ.វ.ត.ក ឡើយ[149]។ ហេតុដូច្នេះ មានតែធាតុផ្សំនៃទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួមប៉ុណ្ណោះដែលនឹងត្រូវសង្ខេបនៅក្នុងផ្នែកនេះ។

៩២. *គោលបំណងរួម៖* គោលបំណង ឬគោលដៅរួម អាចជាអំពើឧក្រិដ្ឋតែម្តង (ដូចជាគោលបំណងរួមដែលបង្កើតបានជាការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន)[150] ឬមានគោលដៅមិនមែនឧក្រិដ្ឋកម្មដែលមនុស្សជាច្រើនមានចេតនាសម្រេច តាមរយៈមធ្យោបាយឧក្រិដ្ឋកម្ម (ដូចជាគោលបំណងរួមដែលពាក់ព័ន្ធ ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន)[151]។

៩៣. ជាឧទាហរណ៍នៅក្នុងសំណុំរឿង 00២/0១ អង្គជំនុំជម្រះសាលាដំបូង និង អ.ជ.ត.ក បានសម្រេចថា សមាជិកនៃសហឧក្រិដ្ឋកម្មរួម មានគោលបំណងរួមមួយ ដើម្បីអនុវត្តបដិវត្តសង្គមនិយម នៅក្នុងប្រទេសកម្ពុជា ដែលគោលបំណងរួមនេះមិនមែនជាគោលបំណងឧក្រិដ្ឋឡើយ ប៉ុន្តែពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដើម្បីធ្វើឱ្យគោលបំណងរួមនោះ សម្រេចបានជាផ្លែផ្កា[152]។

---

[149] **សំណុំរឿងលេខ 00២-ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាន នូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ៣៥, ៣៨។ **សំណុំរឿងលេខ 00២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧៩១។ **សំណុំរឿងលេខ 00២-ឯកសារ D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៧៧, ៨៧ ដល់ ៨៨។

[150] **សំណុំរឿងលេខ 00២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨១៤។

[151] **សំណុំរឿងលេខ 00២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨១៤។ **សំណុំរឿងលេខ 00២-ឯកសារ E100/6** *សេចក្តីសម្រេចលើភាពអាចអនុវត្តបាន នូវសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ កថាខណ្ឌ ១៧។ **សំណុំរឿងលេខ 00២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៦។ សាលដីកា *Brđanin* កថាខណ្ឌ ៤១៨ ។ សាលដីកា *AFRC (Brima និងអ្នកផ្សេងទៀត)* កថាខណ្ឌ ៨០។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Kvočka* (ICTY-IT-98-30/1-A) សាលដីកា ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០០៥ កថាខណ្ឌ ៩៦។

[152] **សំណុំរឿងលេខ 00២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៧៧៨, ៨០៤ និង ៨៣៤។ **សំណុំរឿងលេខ 00២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨១៦។ ប្រហែលគ្នានៅក្នុង សាលក្រម *Prlic និងអ្នកផ្សេងទៀត* កថាខណ្ឌ ២៤, ៤១ ដល់ ៤៣, ៦៥ ដល់៦៨, អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សមាជិកនៃសហឧក្រិដ្ឋកម្មរួម មានគោលបំណងរួមដើម្បីបង្កើតរដ្ឋឯករាជ្យ ដែលដាច់ចេញពី Bosnia និង



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៩៤. មិនមានលក្ខខណ្ឌតម្រូវសម្រាប់ផែនការដែលបានរៀបចំ ឬបង្កើតឡើងកន្លងមក ដោយអ្នកចូលរួមឡើយ។ គោលបំណង ឬគោលដៅរួម អាចលេចចេញជារូបរាងដោយឥតព្រៀងទុក ហើយអាចទាញចេញពីអង្គហេតុដែលថា មនុស្សជាច្រើននាក់បានធ្វើសកម្មភាពរួមគ្នា ដើម្បីអនុវត្តសហឧក្រិដ្ឋកម្មរួម[153]។

៩៥. *មនុស្សច្រើន៖* សហឧក្រិដ្ឋកម្មរួមតម្រូវឲ្យមានការចូលរួមពីមនុស្សច្រើន នៅក្នុងគោលបំណងឧក្រិដ្ឋកម្មរួម[154]។ វាមិនមានភាពចាំបាច់ក្នុងការកំណត់ឈ្មោះរបស់អ្នកចូលរួមទាំងអស់នៅក្នុងសហឧក្រិដ្ឋកម្មរួមឡើយ គឺគ្រាន់តែយោងដោយត្រឹមត្រូវទៅរកប្រភេទ ឬក្រុមមនុស្ស គឺគ្រប់គ្រាន់ហើយ[155]។ មនុស្សច្រើនមិនចាំបាច់ត្រូវរៀបចំជារចនាសម្ព័ន្ធ

---

Herzegovina។ ទោះបីជាគោលដៅនេះមិនមានលក្ខណៈឧក្រិដ្ឋក៏ដោយ តែសមាជិករបស់សហឧក្រិដ្ឋកម្មរួម មានបំណងសម្រេចគោលដៅនេះ តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មមួយចំនួន ប្រឆាំងប្រជាជនមូស្លីម។

153 សាលដីកា *Tadić* កថាខណ្ឌ ២២៧ (ii)។ សាលដីកា *Brđanin* កថាខណ្ឌ ៤១៨។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Mpambara* (ICTR-01-65-T) សាលក្រមចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ១៣ "ខុសពីការសមគំនិតប្រព្រឹត្តបទឧក្រិដ្ឋ គឺមិនចាំបាច់បង្ហាញពីការព្រមព្រៀងជាក់លាក់ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ៖ គោលបំណងរួមអាចកើតឡើងក្នុងពេលជាមួយគ្នា និងដោយមិនផ្លូវការ ហើយអ្នកដែលចូលរួមពាក់ព័ន្ធ មិនចាំបាច់ពាក់ព័ន្ធជាមួយការរៀបចំផ្លូវការឡើយ"។

154 **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩២។ សាលដីកា *Kvočka* កថាខណ្ឌ ៨១។

155 **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩២។ សាលដីកា *Brđanin* កថាខណ្ឌ ៤៣០។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Đorđević* (ICTY-IT-05-87/1-T) សាលក្រមចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១, កថាខណ្ឌ ១៨៦១ *"មិនមានភាពចាំបាច់ក្នុងការកំណត់ឈ្មោះរបស់អ្នកចូលរួមទាំងអស់ឡើយ។ អាស្រ័យលើកាលៈទេសៈនៃរឿងក្តី គឺគ្រាន់តែយោងដោយត្រឹមត្រូវ ទៅរកប្រភេទឬក្រុមមនុស្សគឺគ្រប់គ្រាន់ហើយ។ ទោះជាយ៉ាងនេះក្តីប្រភេទ ឬក្រុមបែបនេះ ចាំបាច់ត្រូវតែកំណត់អត្តសញ្ញាណឲ្យបានគ្រប់គ្រាន់ ដើម្បីជៀសវាងភាពមិនច្បាស់លាស់ ឬមិនប្រាកដប្រជា"*។ សម្រាប់ឧទាហរណ៍នៃការកំណត់លក្ខណៈ ដែលមិនច្បាស់លាស់សម្រាប់សមាជិកនៃសហឧក្រិដ្ឋកម្មរួម សូមមើល រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Krajisnik* (ICTY-IT-00-39-A) សាលដីកា ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៥៦ ដល់ ១៥៧។

01508327



ឃោធា នយោបាយ ឬរដ្ឋបាលឡើយ[156]។ សមាជិករបស់សហឧក្រិដ្ឋកម្មរួម អាចប្រែប្រួល ឬផ្លាស់ប្តូរទៅតាមពេលវេលា[157]។

៩៦. *ការចូលរួមនៅក្នុងគោលបំណងរួម៖* ការចូលរួមនៅក្នុងគោលបំណងរួមមិនចាំបាច់ពាក់ព័ន្ធការអនុវត្តផ្នែកណាមួយនៃធាតុផ្សំសត្យានុម័តរបស់ឧក្រិដ្ឋកម្ម ដែលបង្កើតបានជាផ្នែកនៃគោលបំណងរួម[158]។ វាជាការគ្រប់គ្រាន់ដែលអំពើរបស់អ្នកចូលរួម គឺបែរឆ្ពោះទៅរកការជំរុញដល់ឧក្រិដ្ឋកម្ម ដែលបង្កើតបានជាផ្នែកនៃគោលបំណងរួម[159]។ ការប្រព្រឹត្តិរបស់សមាជិកសហឧក្រិដ្ឋកម្មរួមអាចជាអំពើសកម្ម ឬអំពើអកម្មដែលមានពិរុទ្ធភាព។[160]

---

[156] សាលដីកា *Tadić* កថាខណ្ឌ ២២៧(i)។

[157] **សំណុំរឿងលេខ ០០២ ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩២។ សាលដីកា *Brđanin* កថាខណ្ឌ ៤៣០។

[158] សាលដីកា *Brđanin* កថាខណ្ឌ ៤២៧។ សាលដីកា *Tadić* កថាខណ្ឌ ២២៧(iii)។ សាលដីកា *Krajišnik* កថាខណ្ឌ ២១៥។

[159] សាលដីកា *Tadić* កថាខណ្ឌ ១៩១, ២២៧ (iii) និង ២២៨ (iii)។ សាលដីកា *Kvočka* កថាខណ្ឌ ១៨៧។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Krajišnik* (ICTY-IT-00-39-T) សាលក្រមចុះថ្ងៃទី ២៧ខែ កញ្ញា ឆ្នាំ ២០០៦ បានផ្តល់នូវឧទាហរណ៍ល្អមួយ អំពីការប្រព្រឹត្តដែលមិនមានលក្ខណៈឧក្រិដ្ឋទេ ប៉ុន្តែនៅក្នុងកាលៈទេសៈនៃរឿងក្តី បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម។ អង្គជំនុំជម្រះសម្រេចថា ការរួមចំណែកទាំងអស់របស់ Krajišnik ជាមួយសហឧក្រិដ្ឋកម្មរួម គឺដើម្បីជួយបង្កើត និងរក្សា និរន្តរភាពនៃបក្ស SDS និងរចនាសម្ព័ន្ធរដ្ឋ "ដែលជាឧបករណ៍សម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្ម" កថាខណ្ឌ ១១២០ និង ១១២១ ។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបញ្ជាក់ថា "ការចូលរួមរបស់ជនជាប់ចោទ នៅក្នុងសហឧក្រិដ្ឋកម្មរួម មិនចាំបាច់ពាក់ព័ន្ធដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ អ្វីដែលសំខាន់គឺថាការចូលរួមនេះគឺដើម្បីជម្រុញ ការអនុវត្តគោលដៅឬគោលបំណង ដែលពាក់ព័ន្ធជាមួយការប្រព្រឹត្តឧក្រិដ្ឋកម្ម" សាលដីកា *Krajišnik,* កថាខណ្ឌ ២១៥, ២១៨។ *សូមមើលផងដែរ* សាលដីកា *Brđanin* កថាខណ្ឌ ៤៣០។

[160] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៣។ សាលដីកា *Kvočka* កថាខណ្ឌ ១៨៧, ៤២១, ៥៥៦។ សម្រាប់គោលការណ៍ទូទៅ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និង ICTR បានសម្រេចស្របគ្នាថា ឧក្រិដ្ឋកម្មអាចប្រព្រឹត្តឡើងដោយអំពើអកម្មដែលមានពិរុទ្ធភាព ក្នុងករណីដែលមានភារកិច្ចត្រូវអនុវត្តសកម្មភាព ហើយដែលជនជាប់ចោទអាចត្រូវទទួលខុសត្រូវផ្ទាល់ សម្រាប់ការចូលរួមចំណែកដល់ឧក្រិដ្ឋកម្មមួយ តាមរយៈអំពើអកម្ម ក្នុងករណីដែលជនជាប់ចោទមានភារកិច្ចអនុវត្តសកម្មភាព, *សូមមើល* សាលដីកា *Blaškić* កថាខណ្ឌ ៦៦៣។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Galić* (ICTY-IT-98-29-A) សាលដីកា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៧៥។

ការរួមចំណែក មិនចាំបាច់ត្រូវតែជាការរួមចំណែកដែលចាំបាច់ បើមិនមានការរួមចំណែកនោះ ឧក្រិដ្ឋកម្មដែលជាផ្នែកនៃគោលបំណងរួម មិនអាច ឬមិនត្រូវបានប្រព្រឹត្តឡើយ[161] ប៉ុន្តែ ការរួមចំណែកនោះគឺជាការរួមចំណែកយ៉ាងសំខាន់ចំពោះឧក្រិដ្ឋកម្ម[162]។

៩៧. សូម្បីតែចំពោះសកម្មភាពដែលតាមការមើលឃើញ គឺមិនមានភាពពាក់ព័ន្ធចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មក៏ដោយ ក៏អំពើនោះអាចត្រូវបានពិចារណា នៅពេលសម្រេចថាតើសមាជិករបស់សហឧក្រិដ្ឋកម្មរួមនោះ បានរួមចំណែកជាសំខាន់ដែរ ឬទេ[163]។ ទោះជាយ៉ាងនេះក្តី សកម្មភាពបែបនេះអាចជំរុញ និងគាំទ្រដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម បើទោះបីជាដោយប្រយោលក្តី[164]។ នៅក្នុងការវាយតម្លៃ សកម្មភាពទាំងអស់នឹងត្រូវយកមកពិចារណា ហើយការចូលរួមជាក់លាក់មិនគួរត្រូវបានវាយតម្លៃដាច់ដោយឡែកនោះឡើយ[165]។ ភាពសំខាន់នៃការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម គួរត្រូវបានសម្រេចតាមករណីជាក់ស្តែង ដោយគិតអំពីកត្តាផ្សេងៗគ្នា រួមទាំងតួនាទីរបស់ជនត្រូវចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម ព្រមទាំងការខិតខំណាមួយដើម្បីរារាំងឧក្រិដ្ឋកម្ម[166]។

៩៨. ធាតុ *ផ្សំអត្តនោម័ត៖* សមាជិករបស់សហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗ ដែលជាផ្នែកនៃគោលបំណងរួម គឺថាចេតនានោះចាំបាច់ត្រូវតែរួមមានទាំងគោលបំណងរួម និងឧក្រិដ្ឋកម្ម ដែលគ្របដណ្តប់ដោយចេតនានោះ[167]។ ចេតនានេះចាំបាច់ត្រូវតែចូលរួម និងជាចេតនារួមរបស់សមាជិកសហឧក្រិដ្ឋកម្មរួមទាំងអស់[168]។

---

161 សាលដីកា *Kvočka* កថាខណ្ឌ ៩៨, ១៩៣។

162 **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨០។ សាលដីកា *Brđanin* កថាខណ្ឌ ៤៣០។ *Krajišnik* សាលដីកា កថាខណ្ឌ ២១៥, ៦៩៦។ សាលដីកា *Tadić* កថាខណ្ឌ ១៩១។

163 **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨៥។

164 **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨៥។

165 **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨០។

166 **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៩៨០។

167 **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ១០៥៣។

168 សាលដីកា *Brđanin* កថាខណ្ឌ ៤៣០។ សាលដីកា *Krajišnik* កថាខណ្ឌ ២០០។ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Stakić* (ICTY-IT-97-24-A) សាលដីកា ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៥។ *សូមមើលផងដែរ* សាលដីកា *Tadić*

នៅក្នុងករណីដែលឧក្រិដ្ឋកម្មនោះពាក់ព័ន្ធជាមួយការធ្វើទុក្ខបុកម្នេញ ឬអំពើប្រល័យពូជសាសន៍ សមាជិករបស់សហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវតែមានគោលបំណងពិសេស ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មទាំងអស់នោះ[169]។

៩៩. អ.ជ.ត.ក បានបញ្ជាក់បំភ្លឺនាពេលថ្មីៗនេះថា នៅក្នុងករណីដែលគោលបំណងរួមពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើននោះ មិនចាំបាច់ថាអ្នកដែលឯកភាពលើគោលបំណងរួម ពិតជាមានបំណងចង់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលដៅចុងក្រោយ[170]។ អ.ជ.ត.ក បានបន្ថែមថា ករណីនេះអាចរួមបញ្ចូលនូវឧក្រិដ្ឋកម្ម ដែលត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយ ដើម្បីសម្រេចនូវគោលបំណងរួមណាមួយនោះ បើទោះបីជាការប្រព្រឹត្តិពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ[171]។ ប្រសិនបើគោលដៅនៃគោលបំណងរួមអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងមានការព្រមព្រៀងគ្នាបន្ត

---

កថាខណ្ឌ ១៩៦៖ "ប្រភេទបែបនេះលើកដំបូង ត្រូវបានតំណាងដោយរឿងក្តី ដែលសហជនជាប់ចោទទាំងអស់ ធ្វើសកម្មភាពផ្អែកតាមការរៀបចំរួម ដោយមានចេតនាឧក្រិដ្ឋកម្មតែមួយ។ ជាឧទាហរណ៍ ការបង្កើតផែនការក្នុងចំណោមសហចារី ដើម្បីសម្លាប់ ក្នុងករណីដែលជះឥទ្ធិពលដល់ការរៀបចំរួម *(និង បើទោះបីជាសហចារីនីមួយៗ អនុវត្តតួនាទីផ្សេងៗគ្នានៅក្នុងផែនការនោះក៏ដោយ), ប៉ុន្តែពួកគេទាំងអស់សុទ្ធតែមានចេតនាសម្លាប់។ លក្ខខណ្ឌតម្រូវសត្យានុម័ត និងអត្តនោម័តសម្រាប់ដាក់បន្ទុក ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអ្នកចូលរួមនីមួយៗ ដែលមិនបាន ឬមិនអាចបង្ហាញភស្តុតាងថាមានឥទ្ធិពល ទៅលើការសម្លាប់គឺមានដូចតទៅ៖ (១) ជនជាប់ចោទត្រូវតែចូលរួមដោយស្ម័គ្រចិត្ត នៅក្នុងផ្នែកមួយនៃការរៀបចំរួម (ឧទាហរណ៍ដោយការជម្រុញអំពើហិង្សា ដែលមិនបង្កឱ្យមានមរណភាព ដល់ជនរងគ្រោះ ឬតាមរយៈការផ្តល់សម្ភារៈ ដែលជំនួយដល់ ឬដែលសម្របសម្រួលដល់សកម្មភាព របស់សហចារីរបស់គាត់) និង (២) ជនជាប់ចោទបើទោះបីជាមិនមានឥទ្ធិពលផ្ទាល់ ទៅលើការសម្លាប់ ប៉ុន្តែមានចេតនាចង់បានលទ្ធផលបែបនេះ"* និង កថាខណ្ឌ ២២៨។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Ntakirutimana* (ICTR-96-10-A & ICTR-96-17-A) សាលដីកា ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤, កថាខណ្ឌ ៤៦៣៖ "ប្រភេទទីមួយគឺជាទម្រង់ "មូលដ្ឋាន" នៃសហឧក្រិដ្ឋកម្មរួម។ ទម្រង់នេះត្រូវបានតំណាងដោយរឿងក្តីដែល សហចារីទាំងអស់ អនុវត្តស្របតាមគោលបំណងរួម ហើយមានចេតនាឧក្រិដ្ឋតែមួយ"។ **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៤។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Vasiljević* (ICTR-IT-98-32-A) សាលដីកា ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ១០១។

[169] សាលដីកា *Kvočka* កថាខណ្ឌ ១១០។ សាលដីកា *Krnojelac* កថាខណ្ឌ ១១១ ដល់ ១១២។

[170] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨០៨។

[171] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨០៨។

សម្រេចគោលដៅនេះ ដោយពុំគិតពីបញ្ហាពាក់ព័ន្ធនោះ ទើបកំណត់ថា ឧក្រិដ្ឋកម្មទាំងនេះ មានរួមបញ្ចូលនៅក្នុងគោលបំណងរួម ព្រោះបើទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏ឧក្រិដ្ឋកម្មនេះត្រូវបានគ្រោងទុកក្នុងគោលបំណងរួម[172]។ យើងបកស្រាយការសម្រេចនាពេលថ្មីៗ របស់អង្គជំនុំជម្រះតុលាការកំពូលនេះ ដោយផ្អែកលើមូលដ្ឋាននៃការប្រើប្រាស់ពាក្យ *"បំណង"* ដែលជាការបញ្ជាក់បំភ្លឺថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនចាំបាច់ត្រូវតែជាគោលដៅចម្បងរបស់សមាជិកសហឧក្រិដ្ឋកម្មរួមឡើយ។ ទោះជាយ៉ាងនេះក្តី វាចាំបាច់ត្រូវតែបង្ហាញពីចេតនាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួមដែលជាលក្ខខណ្ឌតម្រូវមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមប្រភេទទីមួយ។

១០០. *ចារីផ្ទាល់៖* សមាជិកសហឧក្រិដ្ឋកម្មរួមអាចត្រូវទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយចារីផ្ទាល់ ដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម ប្រសិនបើឧក្រិដ្ឋកម្មនោះគឺជាផ្នែកនៃគោលបំណងរួម ហើយត្រូវបានប្រព្រឹត្តឡើងក្នុងការជំរុញដល់គោលបំណងរួមនោះ[173]។ ដើម្បីឱ្យសមាជិកនៃសហឧក្រិដ្ឋកម្មរួមទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ អ្នកមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនោះ ចាំបាច់ត្រូវតែបង្ហាញថា ឧក្រិដ្ឋកម្មនោះជាបន្ទុកទទួលខុសត្រូវរបស់សមាជិកនៃសហឧក្រិដ្ឋកម្មរួម យ៉ាងហោចណាស់ក៏ម្នាក់ដែរ ហើយសមាជិកនោះនៅពេលប្រើប្រាស់ចារីផ្ទាល់ ដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម បានអនុវត្តឡើងដើម្បីជំរុញដល់គោលបំណងរួម[174]។ អត្ថិភាពនៃទំនាក់ទំនងនេះ គឺជាបញ្ហាដែលត្រូវវាយតម្លៃផ្អែកលើមូលដ្ឋានជាក់ស្តែង[175]។

---

[172] **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៨០៨។

[173] សាលដីកា *Brđanin* កថាខណ្ឌ ៤១០ ដល់ ៤១៣។ សាលដីកា *Krajišnik* កថាខណ្ឌ ២២៥។

[174] **សំណុំរឿងលេខ ០០២-ឯកសារ E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៦៩៣។

[175] សាលដីកា *Brđanin* កថាខណ្ឌ ៤១៣, ៤១៨។ សាលដីកា *Krajišnik* កថាខណ្ឌ ២២៥ ដល់ ២២៦។ យោងតាម សាលដីកា *Krajišnik* កថាខណ្ឌ ២២៦៖ "កត្តាដែលបង្ហាញពីចំណងទាក់ទងបែបនេះ រួមមានភស្តុតាងបង្ហាញថា សមាជិករបស់សហឧក្រិដ្ឋកម្មរួម បានស្នើសុំដោយត្រង់ ឬដោយប្រយោល ទៅអ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ ឬញុះញង់ បញ្ជា ជំរុញ ឬលើកទឹកចិត្ត ឬជួយដល់អ្នកមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម"។ យោងតាម សាលដីកា *Brđanin* កថាខណ្ឌ ៤១០៖ "ក្នុងករណីដែលអាទិចារីនៃឧក្រិដ្ឋក[illegible]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ii. ទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តបានសម្រាប់ឧក្រិដ្ឋកម្មជាតិ (ការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦)

១០១. សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០២ បានសម្រេចថា ការប្រព្រឹត្តិតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់ អាចអនុវត្តបានតែចំពោះឧក្រិដ្ឋកម្មអន្តរជាតិ[176]។ អង្គបុរេជំនុំជម្រះមិនបានដោះស្រាយជាក់លាក់ ចំពោះភាពអាចអនុវត្តបាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ និងការញុះញង់ចំពោះឧក្រិដ្ឋកម្មជាតិឡើយ ប៉ុន្តែអង្គបុរេជំនុំជម្រះបានច្រានចោលទឡ្ហីករណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថា សហឧក្រិដ្ឋកម្មរួមអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មជាតិ។ តាមទស្សនៈរបស់អង្គបុរេជំនុំជម្រះ ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមគ្របដណ្តប់លើស្ថានភាពដែលជនត្រូវចោទអាច *"មានលក្ខណៈពីចំងាយពីការរួមប្រព្រឹត្តជាក់ស្តែងនៃអំពើពិរុទ្ធនៃបទឧក្រិដ្ឋ ផ្សេងពីស្ថានភាពដែលអាចមើលឃើញ តាមរយៈការចូលរួមផ្ទាល់ ដែលត្រូវបានកំណត់លក្ខខណ្ឌ យោងតាមច្បាប់នៅថ្នាក់ជាតិ"*[177]។ អង្គបុរេជំនុំជម្រះក៏បានបង្ហាញទស្សនៈផងដែរថា ទម្រង់ថ្នាក់ជាតិនៃសហចារី ដែលមានចែងនៅក្នុងមាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ គឺដូចសហឧក្រិដ្ឋកម្មរួមដែរ ជាទម្រង់មួយនៃការប្រព្រឹត្តិដែលស្ថិតក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក[178]។

---

លាក់មួយ មិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម លក្ខខណ្ឌតម្រូវសំខាន់អាចទាញចេញពី កាលៈទេសៈផ្សេងៗគ្នាជាច្រើន រួមមានអង្គហេតុដែលថាជនជាប់ចោទ ឬសមាជិកដទៃនៃសហឧក្រិដ្ឋកម្មរួមបានសហការណ៍យ៉ាងជិតស្និទ្ធជាមួយអាទិចារីដើម្បីជម្រុញដល់គោលបំណងឧក្រិដ្ឋកម្មរួម"។

176 **សំណុំរឿងលេខ ០០២-ឯកសារ D427** *ដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៣០៧។ **សំណុំរឿងលេខ ០០២-ឯកសារ D427/1/30** *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ២៨៦។

177 **សំណុំរឿងលេខ ០០២-ឯកសារ D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ១០១។

178 មាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងជាភាសាបារាំងថា៖ *"Toute personne participant volontairement, soit directement, soit indirectement, à la perpétration d'un crime ou d'un délit, est passible des peines applicables à l'auteur principal. La participation directe constitue la coaction, la participation indirecte constitue la complicité."*។ **សំណុំរឿងលេខ ០០២-ឯកសារ D97/15/9** *សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំង*...



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

១០២. ហេតុដូច្នេះ ការអនុវត្តនូវរូបមន្តរបស់អង្គបុរេជំនុំជម្រះសម្រាប់ទម្រង់នៃការទទួលខុសត្រូវនៅថ្នាក់ជាតិ និងដោយពិចារណាទៅលើវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ ទម្រង់នៃការទទួលខុសត្រូវសម្រាប់ការប្រព្រឹត្តិ (ទោះបីជាចារីតែម្នាក់ ឬសហចារី) ការរៀបចំផែនការ ការបញ្ជា និងការជួយនិងការជំរុញ នឹងត្រូវបានពិចារណា ដោយគិតដល់ការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

## III. ការពិចារណាទៅលើភស្តុតាង

### ក. ការធ្វើសម្ភាសន៍ដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយ ដែលបង្កើតឡើងដោយ ក.ស.ច.ស

១០៣. ភាគច្រើនលើសលប់នៃភស្តុតាងដែលត្រូវបានពឹងផ្អែកក្នុងសំណុំរឿង ០០៤/០១ គឺរួមមានកំណត់ហេតុស្តាប់ចម្លើយដែលបង្កើតឡើងដោយ ក.ស.ច.ស ក្នុងពេលស៊ើបអង្កេត ដែលត្រូវបានរៀបចំក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងជាកម្មវត្ថុនៃការការពារជាក់លាក់ផ្នែកច្បាប់ និងនីតិវិធី ដូច្នេះហើយត្រូវទទួលបាននូវសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន[179]។ យើងពិចារណាថា ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការមកពីសំណុំរឿងផ្សេងទៀតរបស់ អ.វ.ត.ក ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ០០៤/០១ ដោយសារតែភាពពាក់ព័ន្ធរបស់ប្រតិចារឹកទាំងនោះ ជាមួយការចោទប្រកាន់នានា ត្រូវទទួលបាននូវសច្ចធារណ៍ដូចគ្នា។

---

*សម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, កថាខណ្ឌ ១០១។

[179] **សំណុំរឿងលេខ ០០២-ឯកសារ E96/7** *សេចក្តីសម្រេចលើសំណើសុំ របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយក កំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង,* ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៦ ដល់ ២៧, ២៩, កំណត់សម្គាល់ ៤៨។ **សំណុំរឿងលេខ ០០២-ឯកសារ E162,** *ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះផ្នែកនៃឯកសារ E114, E114/1, E131/1/9. E131/6, E136 និង E158* ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៣។ **សំណុំរឿងលេខ ០០២-ឯកសារ E185** *សេចក្តីសម្រេចលើការជំទាស់ ទៅនឹងឯកសារដែលបានស្នើសុំដាក់ នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ ក១ ដល់ ក៥ របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់ នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃសំណុំរឿង០០២/០១* ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២០។

១០៤. សេចក្តីថ្លែងការណ៍ ឬភស្តុតាងដទៃទៀតដែលត្រូវបានប្រមូលដោយមិនមានការត្រួតពិនិត្យមើលតាមផ្លូវតុលាការ ដោយស្ថាប័នណាមួយដែលមិនស្ថិតក្នុង អ.វ.ត.ក នោះ មិនត្រូវទទួលបាននូវសច្ចធារណ៍បែបនេះឡើយ[180]។ ករណីលើកលែងសម្រាប់វិធាននេះ គឺត្រូវបានតំណាងដោយការស្តាប់ចម្លើយដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ត្រូវទទួលបាននូវសច្ចធារណ៍អាចបដិសេធបាននៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន *បឋម*[181]។ ទោះជាយ៉ាងនេះក្តី ការស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងដោយមិនមានការធានាតាមផ្លូវតុលាការ និងទម្រង់ ដែលកំណត់លក្ខណៈនៃកំណត់ហេតុស្តាប់ចម្លើយនោះឡើយ។

១០៥. ការស្តាប់ចម្លើយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលស៊ើបអង្កេតបឋមរបស់ពួកគេ បើទោះបីជាត្រូវបានរៀបចំជាពិសេស សម្រាប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏ការស្តាប់ចម្លើយនេះមិនត្រូវបានធ្វើឡើង ដោយមានការស្បថនោះឡើយ ហើយត្រូវបានរៀបចំឡើងដោយភាគីដែលមានផលប្រយោជន៍នៅក្នុងសំណុំរឿង។

១០៦. ទោះជាយ៉ាងនេះក្តី ការស្តាប់ចម្លើយបែបនេះត្រូវបានប្រមូលឡើងសម្រាប់គោលបំណងនៃសវនាការព្រហ្មទណ្ឌ ដូច្នេះហើយជាគោលការណ៍ ត្រូវទទួលបាននូវតម្លៃជាភស្តុតាងខ្ពស់

[180] **សំណុំរឿងលេខ ០០២-ឯកសារ E96/7** *សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៩។

[181] **សំណុំរឿងលេខ ០០២-ឯកសារ E185** *សេចក្តីសម្រេចលើការជំទាស់ ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ ក ១ ដល់ ក ៥ របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់ នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូង នៃសំណុំរឿង០០២/០១* ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៨។ **សំណុំរឿងលេខ ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៣៧៣។

01508334



ជាងភ័ស្តុតាងដែលមិនត្រូវបានប្រមូល សម្រាប់គោលបំណងនោះ (រួមទាំងភ័ស្តុតាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា)[182]។

១០៧. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចទទួលបាននូវសច្ចធារណ៍ នៃភាពអាចជឿជាក់បាន ហើយត្រូវទទួលបាននូវតម្លៃជាភ័ស្តុតាងទាបប៉ុណ្ណោះ ប្រសិនបើកាលៈទេសៈនៃការកត់ត្រាពាក្យសុំតាំងខ្លួននោះ មិនមានភាពច្បាស់លាស់[183]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះ បានផ្តល់នូវការសន្និដ្ឋានទូទៅប៉ុណ្ណោះ ដូច្នេះវាជា *"ការរៀបរាប់ទូទៅ"* ដែលខុសពីបទពិសោធន៍ផ្ទាល់ខ្លួន ហើយជាលទ្ធផលត្រូវចាត់ទុកថាមិនគ្រប់គ្រាន់ សម្រាប់កំណត់ពីអង្គហេតុពាក់ព័ន្ធ[184]។ ការស្តាប់ចម្លើយក្រៅតុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវទទួលបាននូវតម្លៃជាភ័ស្តុតាងទាប[185]។

១០៨. ជាការសន្និដ្ឋាន និងថ្លឹងថ្លែងលើការពិចារណាទាំងអស់នេះ កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរដែលបង្កើតឡើងដោយ ក.ស.ច.ស និងប្រតិចារិកសវនាការ ត្រូវទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បានខ្ពស់ជាង ហើយត្រូវទទួលបាននូវតម្លៃជាភ័ស្តុតាងខ្ពស់ជាងការស្តាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នដទៃផ្សេងទៀត។ ចំពោះការស្តាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នផ្សេងទៀតនោះ គួរត្រូវអនុម័តយកវិធីសាស្ត្រប្រុងប្រយ័ត្នខ្លាំងជាង ក្នុងការវាយតម្លៃទៅលើឯកសារទាំងនោះ ហើយព័ត៌មានដែលមាននៅក្នុងនោះ គួរត្រូវបានពឹងផ្អែកតែក្នុងករណីដែលទទួលបានការគាំទ្រដោយប្រភពផ្សេងទៀតប៉ុណ្ណោះ។

---

[182] សំណុំរឿងលេខ ០០២-ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ២៨៦។

[183] សំណុំរឿងលេខ ០០២-ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ២៨៦។

[184] សំណុំរឿងលេខ ០០២-ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៤៥៧។

[185] សំណុំរឿងលេខ ០០២-ឯកសារ F36 *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៥៥០។

## ខ. ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម

១០៩. អនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម គឺមានការហាមឃាត់ដាច់ខាត មិនឱ្យពឹងផ្អែកទៅលើព័ត៌មានដែលមាននៅក្នុងឯកសារ ដែលទទួលបានដោយការធ្វើទារុណកម្ម[186] និងមិនឱ្យប្រើប្រាស់ចម្លើយបែបនេះនៅក្នុងការសួរដេញដោលសាក្សី[187]។

១១០. ចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានសន្មតថាធ្វើឡើងដោយទារុណកម្ម។ នេះគឺជាសច្ចធារណ៍អាចបដិសេធបាន[188]។

១១១. ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ដែលផ្តល់ឱ្យដោយបុគ្គលដែលមិនមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម ឧទាហរណ៍ចំណារដោយអ្នកធ្វើទារុណកម្ម មិនស្ថិតក្រោមការហាមឃាត់នេះឡើយ[189]។ មាត្រា ១៥ ក៏មិនបានហាមឃាត់ការប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងចម្លើយដែលធ្វើឡើងដោយទារុណកម្ម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកសាក្សី និងអាចឈានទៅស្តាប់ចម្លើយពួក

---

[186] **សំណុំរឿងលេខ ០០២-ឯកសារ D130/9/21** *សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើការប្រើប្រាស់ចម្លើយដែលទទួលបាន ឬអាចទទួលបានតាមរយៈការធ្វើទារុណកម្ម* ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ កថាខណ្ឌ ៣០។ **សំណុំរឿងលេខ ០០១-ឯកសារ E1/27.1** *ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ កាំង ហ្គេកអ៊ាវ ហៅឌុច* ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៨ ដល់ ៩។ **សំណុំរឿងលេខ ០០១-ឯកសារ E176** *សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៨។ **សំណុំរឿងលេខ ០០២-ឯកសារ E1/129.1** *ប្រតិចារឹកសវនាការថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០១២ ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១២* កថាខណ្ឌ ៧៤។

[187] **សំណុំរឿងលេខ ០០២-ឯកសារ F26/12** *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជីឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៤៧។ **សំណុំរឿងលេខ ០០២-ឯកសារ E1/129.1** *ប្រតិចារឹកសវនាការ* ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១២, ថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០១២ កថាខណ្ឌ ៧៤។

[188] **សំណុំរឿងលេខ ០០២-ឯកសារ F26/12** *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជីឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៥៧ ដល់ ៥៨។

[189] **សំណុំរឿងលេខ ០០២-ឯកសារ F26/12** *សេចក្តីសម្រេចលើការជំទាស់ចំពោះបញ្ជីឯកសារ-សំអាងហេតុពេញលេញ* ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ៦៦ ដល់ ៦៨។

គាត់ដែរ[190]។ ហេតុដូច្នេះ មិនមានការហាមឃាត់មិនឱ្យប្រើប្រាស់ភ័ស្តុតាងរបស់សាក្សី ដែលត្រូវបានកំណត់នៅក្នុងចម្លើយ ដែលទទួលបានដោយការធ្វើទារុណកម្ម ដូចជាចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ និងការស្តាប់ចម្លើយនាពេលបន្ទាប់ដោយ ក.ស.ច.ស[191]។

១១២. ក្នុងអំឡុងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ ក.ស.ច.ស បានបង្កើតនូវអង្គការលេខរបស់រដ្ឋបាលតំបន់៥នៃភូមិភាគពាយ័ព្យ រួមទាំងស្រុកព្រះនេត្រព្រះ ដែលការបង្កើតនេះមានគោលបំណងដើម្បីប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ។ ឈ្មោះមនុស្សមួយចំនួននៅក្នុងអង្គការលេខ ត្រូវបានយកចេញពីចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១។ នៅក្នុងករណីមួយចំនួនតូច អង្គការលេខនេះត្រូវបានប្រើប្រាស់ហួសពីគោលបំណងដែលបានគ្រោងរបស់វា ហើយត្រូវបានដាក់បង្ហាញសាក្សី ដែលត្រូវបានសាកសួរឱ្យផ្តល់យោបល់លើអង្គ

---

[190] ហេតុផលមួយក្នុងចំណោមហេតុផលនានានៃគោលនយោបាយ ដែលមានចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មគឺ ដកចេញនូវការលើកទឹកចិត្តណាមួយ មិនឱ្យរដ្ឋចូលរួមក្នុងការធ្វើទារុណកម្ម។ ដើម្បីជៀសវាងបង្កបញ្ហាដល់ហេតុផលគោលនយោបាយនេះ ដើម្បីបញ្ជាក់ពីភាពស្របច្បាប់ក្នុងការប្រើប្រាស់ភ័ស្តុតាង ដើម្បីស្វែងរកព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ជាការចាំបាច់ត្រូវញែកចេញពីគ្នា នូវសេណារីយ៉ូពីរដូចតទៅ។ទីមួយស្ថានភាពដែលព័ត៌មានទទួលបានតាមរយៈការធ្វើទារុណកម្ម ត្រូវបានប្រើប្រាស់ដោយអាជ្ញាធរដែលធ្វើទារុណកម្ម ដើម្បីស្វែងរកសាក្សី ជនសង្ស័យ អ្នករត់គេចខ្លួន ឬដើម្បីជម្រុញបន្ថែមដល់ការស៊ើបអង្កេតដែលកំពុងបន្ត។ ទីពីរគឺស្ថានភាពដែលស្ថាប័នតុលាការ ស៊ើបអង្កេតទៅលើការធ្វើទារុណកម្ម បានព្យាយាមប្រើប្រាស់ព័ត៌មាន ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ដើម្បីកំណត់អត្តសញ្ញាណពីប្រភពនៃភ័ស្តុតាង ដែលអាចមានប្រឆាំងពួកគេ។ ការអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានទទួលបានតាមរយៈការធ្វើទារុណកម្ម ធ្វើជាតម្រុយនៃការស៊ើបអង្កេត នៅក្នុងសេណារីយ៉ូទីមួយ អាចជាការលើកទឹកចិត្តដល់ការប្រើប្រាស់ទារុណកម្ម។ ជាឧទាហរណ៍ប្រសិនបើអង្គភាពស៊ើបអង្កេតមួយ ទទួលបានចម្លើយតាមរយៈការធ្វើទារុណកម្ម ហើយបន្ទាប់មកប្រើប្រាស់ ឈ្មោះដែលមាននៅក្នុងចម្លើយនោះ ដើម្បីស្វែងរកបណ្តុំឯកសារ ឬមនុស្សដែលមានព័ត៌មានពាក់ព័ន្ធជាមួយការស៊ើបអង្កេតនោះ ឯកសារឬសក្ខីកម្មទាំងអស់របស់បុគ្គលនោះ នឹងមិនត្រូវទទួលយកធ្វើជាភ័ស្តុតាង នៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ។ ប៉ុន្តែនៅក្នុងសេណារីយ៉ូទីពីរ ស្ថាប័នតុលាការមិនពាក់ព័ន្ធផ្ទាល់ ឬប្រយោល ជាមួយអាជ្ញាធរដែលធ្វើទារុណកម្ម ហើយប្រើប្រាស់តម្រុយដែលមាន ដើម្បីស្វែងរកភ័ស្តុតាងប្រឆាំងនឹងអ្នកធ្វើទារុណកម្ម។ តាមទស្សនៈរបស់យើង ភ័ស្តុតាងពីសាក្សីដែលត្រូវស្វែងរក ផ្អែកលើមូលដ្ឋាននៃចម្លើយដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម អាចត្រូវបានប្រើប្រាស់តែក្នុងសេណារីយ៉ូទីពីរប៉ុណ្ណោះ។

[191] **សំណុំរឿងលេខ ០០២-ឯកសារ E350/8** *សេចក្តីសម្រេចលើភ័ស្តុតាងដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម* ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ កថាខណ្ឌ ៦៣, ៧០។

ការលេខនេះ[192]។ ដោយពិចារណាទៅលើសច្ចធារណ៍នៃការធ្វើទារុណកម្ម ដែលត្រូវជាប់ជាមួយចម្លើយសារភាពមន្ទីរសន្តិសុខ ស-២១ និងការហាមឃាត់មិនឱ្យប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាព សម្រាប់ការសួរដេញដោលសាក្សី រាល់ចម្លើយរបស់សាក្សីដែលផ្អែកទៅលើ ឬជាប់ទាក់ទងនិងអង្គការលេខនេះ នឹងមិនត្រូវបានពិចារណាឡើយ។ សម្រាប់សំអាងហេតុដូចគ្នា *កំណត់ត្រារបស់អ្នកស៊ើបអង្កេត* បន្ទាប់ពីសំណួរចម្លើយ ៣២ ព្រមទាំងសំណួរចម្លើយ ៣៣ នៃឯកសារ D219/477 (ERN ភាសាអង់គ្លេស 01141203-01141204, ERN ភាសាខ្មែរ 01134149-01134150) មិនត្រូវបានពិចារណាឡើយ។

### គ. របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៨

១១៣. របាយការណ៍ចំនួនពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួមមានព័ត៌មានដែលអាចពាក់ព័ន្ធនឹងការស៊ើបអង្កេតលើការចោទប្រកាន់ អ៊ឹម ចែម។ របាយការណ៍ទីមួយកត់ត្រាពីបេសកកម្មចុះតាមទីតាំងនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ (“របាយការណ៍ឆ្នាំ

---

[192] កំណត់ហេតុស្តាប់ចម្លើយ និងចម្លើយជាក់លាក់ដែលទទួលរងផលប៉ះពាល់ ដោយសារការអនុវត្តបែបនេះរួមមាន៖ **ឯកសារ D119/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ សំណួរ និងចម្លើយ ១៧ ( KH ERN 00895161-00895162)។ **ឯកសារ D119/33** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ សំណួរ និងចម្លើយ ១៣ រហូតទៅ និងរួមទាំងសំណួរ និងចម្លើយ ៣២ (KH ERN 00907525-00907530)។ **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ខែ មីនា ឆ្នាំ ២០០៤ សំណួរ និងចម្លើយ ៩៥ (KH ERN 00980397-00980398)។ **ឯកសារ D119/112** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល សេងលី ចុះថ្ងៃទី១ ខែ មេសា ឆ្នាំ ២០១៤– សំណួរ និងចម្លើយ ៤០ (KH ERN 00982235-00982235)។ **ឯកសារ D119/135** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម រៀម ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៤– កំណត់ត្រារបស់អ្នកស៊ើបអង្កេតបន្ទាប់ពី សំណួរ និងចម្លើយ ៥៧ (KH ERN 01003836-01003837)។ **ឯកសារ D119/137** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិត អៀត ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤– កំណត់ត្រារបស់អ្នកស៊ើបអង្កេតបន្ទាប់ពី សំណួរ និងចម្លើយ ២៦ (KH ERN 01003857-01003858)។ **ឯកសារ D219/477** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ សាមុត ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥– កំណត់ត្រារបស់អ្នកស៊ើបអង្កេតបន្ទាប់ពី សំណួរ និងចម្លើយ ៤១ (KH ERN 01134151-01134152)។

1987")[193] ហើយរបាយការណ៍ទីពីរគឺបេសកកម្មចុះតាមទីតាំងដែលបានធ្វើឡើងកាលពីថ្ងៃទី 19 ខែ សីហា ឆ្នាំ 1998 ("របាយការណ៍ឆ្នាំ 1987")[194]។ របាយការណ៍ទាំងពីរនេះរួមគ្នាផ្តល់ព័ត៌មានអំពីចំនួនរណ្តៅសាកសព និងការប៉ាន់ស្មានលើចំនួនជនរងគ្រោះនៅតាមទីតាំងចំនួន 13 ដែលទីតាំងចំនួនប្រាំបួនគឺជាផ្នែកមួយនៃការស៊ើបអង្កេតនៅក្នុងសំណុំរឿង 004/01។

i. <u>វិធីសាស្ត្រ</u>

114. ក.ស.ច.ស បានស្តាប់ចម្លើយ ស៊ិន ឃិន ធ្លាប់ជាអ្នកស៊ើបអង្កេតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានចូលរួមនៅក្នុងការបង្កើតរបាយការណ៍ទាំងពីរនេះ[195]។ គាត់លើកឡើងថា ក្រុមបេសកកម្មចុះតាមទីតាំងរួមមានរូបគាត់ដែលជាអ្នកប្រមូលព័ត៌មាន ធ្វើសម្ភាសន៍ និងព្រាងរបាយការណ៍ រួមជាមួយនឹងអ្នកជំនាញ GPS ម្នាក់ដែលកំណត់អត្តសញ្ញាណទីតាំង[196]។ បន្ទាប់មក របាយការណ៍ទាំងនេះត្រូវបានធ្វើប្រតិចារឹកដោយបុគ្គលទីបីនៅមជ្ឈមណ្ឌលឯកសារកម្ពុជា[197]។

---

193 **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ1987៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ1987 KH ERN 00750665-00750682។

194 **ឯកសារ D1.3.27.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ1998៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ1998 KH ERN 00184619-00184629។

195 **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី 3 ខែ មីនា ឆ្នាំ 2015 KH ERN 01074015 ឆ.13 (របាយការណ៍ឆ្នាំ1987)។ **ឯកសារ D219/206** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី 5 ខែ មីនា ឆ្នាំ 2015 KH ERN 01072260 ឆ.30 (របាយការណ៍ឆ្នាំ1998)។

196 **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី 3 ខែ មីនា ឆ្នាំ 2015 KH ERN 01074015 ឆ.13-ឆ.15។

197 **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី 3 ខែ មីនា ឆ្នាំ 2015 KH ERN 01074016 ឆ.19។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១១៥. ក្រុមការងារនេះបានចុះពិនិត្យទីតាំងចំនួនប្រាំបីដែលបានរៀបរាប់នៅក្នុងតារាងរបាយការណ៍ឆ្នាំ ១៩៩៧[198] រួមមាន ចម្ការខ្មុំ និងវត្តសុភមង្គលក្នុងស្រុកស៊ីសុផុន (ឬសេរីសោភ័ណ) ចម្ការយាយហ៊ឹម ល្អាងគួយយំ និងវត្តបន្ទាយនាងក្នុងស្រុកមង្គលបូរី និងទីតាំងចម្ការតាលឹង/វត្តព្រះនេត្រព្រះ ព្រៃតារុត និងភូមិចក្រីក្នុងស្រុកព្រះនេត្រព្រះ។

១១៦. ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានចុះពិនិត្យទីតាំងចំនួន ៦ ផងដែរនៅក្នុងរបាយការណ៍ឆ្នាំ ១៩៩៨[199] រួមមាន ចម្ការខ្មុំ និងវត្តសុភមង្គលក្នុងស្រុកស៊ីសុផុន (ឬសេរីសោភ័ណ ដែលបានចុះម្តងរួចមកហើយនៅក្នុងឆ្នាំ ១៩៩៧ ហើយនិងមន្ទីរសន្តិសុខស្រុក អាងស្តុកទឹកល្អាងត្រពាំងថ្ម ព្រៃគុកត្រាច និងវត្តកណ្តាលក្នុងស្រុកភ្នំស្រុក។

១១៧. របាយការណ៍ឆ្នាំ ១៩៩៧ ស្តីពីទីតាំងសម្លាប់មនុស្សនៅខេត្តបន្ទាយមានជ័យគឺជារបាយការណ៍សង្ខេបព័ត៌មានដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបាន[200]។ សម្រាប់ទីតាំងនីមួយៗ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសបុគ្គលពីរ ឬបីនាក់[201]ដែលត្រូវបានជ្រើសរើសគោលដៅសម្ភាសន៍ដោយផ្អែកលើព័ត៌មានដែលផ្តល់ជូនដោយមន្ត្រីវប្បធម៌ស្រុកអំពីអតីតអ្នកជាប់ឃុំនៅទីតាំងទាំងនោះ[202]។ ស៊ិន ឃិន បានផ្តល់ជូន ក.ស.ច.ស នូវ

---

[198] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074015 ឆ.១៣។

[199] **ឯកសារ D1.3.27.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ១៩៩៨៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៩៨ KH ERN 00184619-00184629។

[200] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074016 ឆ.១៩។

[201] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074015 ឆ.១១។

[202] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074017 ឆ.២៤។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

កិច្ចសម្ភាសន៍ទាំងអស់ដែលបានធ្វើឡើងនៅតាមទីតាំងនីមួយៗក្នុងចំណោមទីតាំងចំនួនប្រាំបីនេះ[203]។

១១៨. សំណៅជាភាសាអង់គ្លេស និងភាសាខ្មែរនៃរបាយការណ៍ឆ្នាំ ១៩៩៨ នៅក្នុងសំណុំរឿង 00៤/១ មានចំណុចខុសគ្នា។ ជាពិសេស តារាងដែលបានដាក់បញ្ចូលនៅក្នុងសំណៅបកប្រែជាភាសាអង់គ្លេស[204] ពុំឃើញមាននៅក្នុងសំណៅជាភាសាខ្មែរ។ តារាងនេះរួមមានចំនួនផ្នូរសាកសពរួម និងចំនួនជនរងគ្រោះដែលបានផ្តល់ជូនពីប្រភពមួយសម្រាប់ទីតាំងនីមួយៗ។ ទោះបីជាគ្មានព័ត៌មានបែបនេះនៅក្នុងសំណុំរឿងក៏ដោយ ក៏តារាងទាំងនេះអាចត្រូវបានដាក់បញ្ចូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលបកប្រែឯកសារទាំងនេះ។

១១៩. មានការលើកឡើងថា ការពិនិត្យមើលឡើងវិញនូវតារាងដូចគ្នាក្នុង របាយការណ៍ឆ្នាំ ១៩៩៧ បង្ហាញថា តារាងនេះពុំឆ្លុះបញ្ចាំងទាំងស្រុងនូវព័ត៌មានដែលបានផ្តល់ជូនដោយគោលដៅសម្ភាសន៍ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា និងពុំត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍នោះទេ។ នៅក្នុងកាលៈទេសៈខ្លះ ព័ត៌មានចន្លោះប្រហោងនេះមានចំណុចពាក់ព័ន្ធគ្នានឹងការស៊ើបអង្កេតលើ អ៊ឹម ចែម។ ចំណុចទីមួយ តារាងនេះរៀបរាប់គោលដៅសម្ភាសន៍ដែលបានផ្តល់ព័ត៌មានអំពីចំនួនជនរងគ្រោះ ហើយមានឈ្មោះតែបុគ្គលម្នាក់ចំពោះទីតាំងមួយកន្លែង។ ឧទាហរណ៍ តារាងនេះបង្ហាញថា ជនរងគ្រោះមានចំនួន ២០.000 នាក់នៅចម្ការខ្នុរ ដែលចំនួននេះបានផ្តល់ជូនពី ឃួន សាយ។ ទោះបីជាយ៉ាងនេះក្តី ប្រភពទីពីរបានលើកឡើងអំពីឡានចំនួន ១០ ទៅ ២០ ឡានដែលបានបើកចូលបន្តកន្ទុយគ្នា ហើយប្រភពទីបីពុំបានផ្តល់ចំនួនណាមួយនោះទេ[205]។ ចំណុចទីពីរ តារាងនេះពុំឆ្លុះបញ្ចាំងការប៉ាន់ស្មានរបស់អ្នកស៊ើបអង្កេតនៅក្នុងរបាយការណ៍អំពីចម្ការខ្នុរនោះទេ

---

[203] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074017 ត.២២-ត.២៣។

[204] ឯកសារ **D1.3.27.10** របាយការណ៍មជ្ឈមណ្ឌលកម្ពុជា ចុះកំណត់ទីតាំងរាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៨៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៩៨ KH ERN 00184619។

[205] **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងរាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៩៧ KH ERN 00750668-00750670។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C. ៦៦

ពោលគឺ *"ជនរងគ្រោះជាង ២.000 នាក់ (ប្រហែល ២៥.000 នាក់)"*[206]។ ចំណុចទីបី ករណីដែលថា គោលដៅសម្ភាសន៍បានផ្តល់តួលេខផ្សេងគ្នា តារាងនេះគ្រាន់តែរួមមានចំនួនច្រើនជាងគេបំផុត ឬចំនួនច្រើនជាងគេតែប៉ុណ្ណោះ។ ករណីនេះពាក់ព័ន្ធនឹងទីតាំងចំនួនបួន រួមទាំង ចម្ការតាលីងដែលពាក់ព័ន្ធសម្រាប់ការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤/០១។ ចំណុចទីបួន តារាងពុំឆ្លុះបញ្ចាំងព័ត៌មានចន្លោះប្រហោងនៅក្នុងរបាយការណ៍ឆ្នាំ ១៩៩៧។ ឧទាហរណ៍ ពាក់ព័ន្ធនឹងចម្ការតាលីង តារាងរួមមានជនរងគ្រោះចំនួន ៧២០ នាក់ ក្រោមឈ្មោះ ទុំ សឿន (ដែលជាសាក្សីរបស់ ក.ស.ច.ស ផងដែរ) ចំណែករបាយការណ៍នោះបានលើកឡើងថា ទុំ សឿន បានលើកឡើងអំពីមនុស្សស្លាប់ចំនួន ៦៦០ នាក់ ទៅ ៧២០ នាក់ និងឯកសារគ្មានអត្តសញ្ញាណមួយដែលបានរៀបរាប់ថាមានសាកសពចំនួន ៤៦៧[207]។ លើសពីនេះ របាយការណ៍នេះក៏រៀបរាប់អំពីសាកសពចំនួន ២៥៣ ផងដែរដែលជាចំនួនជនរងគ្រោះដកចេញពីរដ្ឋាភិបាលកម្ពុជាចុះឆ្នាំ ១៩៨៤ ("របាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤")[208]។

ii. <u>របាយការណ៍រដ្ឋាភិបាល ចុះឆ្នាំ ១៩៨៤ និងការប្រើប្រាស់របាយការណ៍នេះដោយមជ្ឈមណ្ឌលឯកសារកម្ពុជា</u>

១២០. ពាក់ព័ន្ធនឹងវត្តព្រះនេត្រព្រះ ភូមិចក្រី និងព្រៃតារុត[209] មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់ទិន្និន័យពីរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤ សម្រាប់របាយការណ៍របស់ខ្លួនចុះឆ្នាំ ១៩៩៧។ របាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤ ពាក់ព័ន្ធនឹងស្រុកព្រះនេត្រព្រះមាន

---

[206] **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៩៧ KH ERN 00750671។

[207] **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750678។

[208] **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750677។

[209] **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750677។



*C.C* INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C *C.E.T.C*

នៅក្នុងសំណុំរឿង ០០៤/០១[210]។ យោងតាម ស៊ិន ឃិន មជ្ឈមណ្ឌលឯកសារកម្ពុជាបាន ទទួលរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤ ពី ហាប់ សឿន ប្រធានមន្ទីរវប្បធម៌ស្រុក ព្រះនេត្រព្រះ និង ថ្លាង ចុង មន្ត្រីមកពីមន្ទីរវប្បធម៌ស្រុក[211] ក្រោយពេលមជ្ឈមណ្ឌល ឯកសារកម្ពុជាបានដាក់សំណើសុំ[212]ទៅមន្ទីរវប្បធម៌ស្រុក និងខេត្ត[213]។

១២១. ស៊ិន ឃិន ផ្តល់ភ័ស្តុតាងអំពីវិធីសាស្ត្រធ្វើរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤[214]។ ជាពិសេស អ្នកភូមិបានផ្តល់ព័ត៌មានអំពីទីតាំងផ្នូរសាកសពរួម និងទីតាំងផ្សេងទៀត និងចំនួនជនរងគ្រោះ[215] ជូនដល់ប្រធានភូមិ និងមេឃុំ[216] ដែលបានបញ្ជូនទិន្នន័យនោះបន្តមកឱ្យអាជ្ញាធរស្រុកពាក់ព័ន្ធ[217]។ ផ្អែកតាមព័ត៌មាននេះ មន្ទីរវប្បធម៌ស្រុកបានរៀបចំ

---

[210] **ឯកសារ D119/50.2** ស្រុកព្រះនេត្រព្រះ ស្ថិតិប្រាសាទបូរាណ-ស្តូបអធិដ្ឋាន និងសិល្បៈមហាជនរបស់គណៈកម្មការរបស់មន្ទីរឃោសនាការ វប្បធម៌-ព័ត៌មានខេត្តបាត់ដំបង លេខ ៧១១ ឃវពខ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH ERN 00933216-00933222។

[211] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074017 ឆ.២៨ KH ERN 01074018 ឆ.២៩។

[212] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074017 ឆ.២៥។

[213] **ឯកសារ D219/206** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072263 ឆ.៥១។

[214] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074018 ឆ.២៧។ *សូមមើល* ទិន្នន័យដែលបានប្រើប្រាស់សម្រាប់ព្រៃតារុត និង ភូមិចក្រី ក្នុង **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750679។

[215] *សូមមើល* **ឯកសារ D119/50.2** ស្រុកព្រះនេត្រព្រះ ស្ថិតិប្រាសាទបូរាណ-ស្តូបអធិដ្ឋាន និងសិល្បៈមហាជនរបស់គណៈកម្មការរបស់មន្ទីរឃោសនាការវប្បធម៌-ព័ត៌មានខេត្តបាត់ដំបង លេខ ៧១១ ឃវពខ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH ERN 00933219-00933220។

[216] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074018 ឆ.៣១។

[217] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074018 ឆ.៣០។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

របាយការណ៍ទាំងនេះដែលបានដាក់បញ្ចូលព័ត៌មានអំពីទីកន្លែង និងចំនួនទីតាំង[218] និងចំនួនជនរងគ្រោះ[219]។ បន្ទាប់មក ស្រុកបានបញ្ជូនរបាយការណ៍ទាំងនេះទៅខេត្ត[220]។

១២២. ស៊ិន ឃិន លើកឡើងថា នៅពេលពុំអាចចុះពិនិត្យទីតាំងនៅក្នុងរបាយការណ៍ឆ្នាំ ១៩៨៧ បាន មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់ចំនួនជនរងគ្រោះនៅក្នុងរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤[221]។ ទោះបីជាយ៉ាងនេះក្តី ក្នុងសភាពមិនស៊ីង្វាក់គ្នា សាក្សីក៏លើកឡើងផងដែរថា ចំពោះរបាយការណ៍ឆ្នាំ ១៩៨៧ គាត់បានចុះពិនិត្យទីតាំងនីមួយៗក្នុងចំណោមទីតាំងចំនួនប្រាំបី[222]។ ការលើកឡើងចំណុចនេះគឺដោយសារវាហាក់បង្ហាញឱ្យឃើញថា នៅក្នុងរបាយការណ៍ឆ្នាំ ១៩៨៧ របស់ខ្លួន មជ្ឈមណ្ឌលឯកសារកម្ពុជាបានសំអាងលើទិន្នន័យពីរបាយការណ៍រដ្ឋាភិបាលឆ្នាំ១៩៨៤ នៅពេលគោលដៅសម្ភាសន៍របស់ពួកគេពុំបានផ្តល់ចំនួនជនរងគ្រោះដូចក្នុងករណីពាក់ព័ន្ធនឹងព្រៃតារុត និងភូមិចក្រីទេ[223]។

---

[218] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074017 ទ.២៦។

[219] **ឯកសារ D119/50.2** ស្រុកព្រះនេត្រព្រះ ស្ថិតិប្រាសាទបូរាណ-ស្តូបអធិដ្ឋាន និងសិល្បៈមហាជនរបស់គណៈកម្មការរបស់មន្ទីរឃោសនាការវប្បធម៌-ព័ត៌មានខេត្តបាត់ដំបង លេខ ៧១១ ឃវពខ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH ERN 00933219-00933220។ *សូមមើលផងដែរ* **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074018 ទ.៣១។

[220] **ឯកសារ D219/206** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072262 ទ.៤៥។

[221] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074018 ទ.២៧។ *សូមមើល* ទិន្នន័យដែលបានប្រើប្រាស់សម្រាប់ព្រៃតារុត និង ភូមិចក្រី ក្នុង **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៨៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៨៧ KH ERN 00750679។

[222] **ឯកសារ D219/204** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074015 ទ.១៣-ទ.១៤។

[223] **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៨៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៨៧ KH ERN 00750679។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១២៣. និត ស៊ិត់ ដែលធ្លាប់ធ្វើជាលេខាស្រុកព្រះនេត្រព្រះភ្លាមៗ ក្រោយពេលចេញរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤ បានផ្ដល់ព័ត៌មានបន្ថែមអំពីវិធីសាស្ត្រធ្វើរបាយការណ៍នេះ។ គាត់ជឿថា ចំនួនជនរងគ្រោះដែលបានលើកឡើងនៅក្នុងរបាយការណ៍នោះទំនងជាបានប្រមូលបានតាមរយៈកិច្ចសម្ភាសន៍នីមួយៗ ជាជាងការរាប់សាកសពជាក់ស្ដែង[224]។ គាត់សន្និដ្ឋានថា ចំនួនជនរងគ្រោះលើសពី ៧៨.០០០ នាក់នៅក្នុងស្រុកព្រះនេត្រព្រះទាំងមូល[225] *"អាចទំនងពុំត្រឹមត្រូវនោះទេ"*[226]។ ផ្អែកតាមការសង្កេតរបស់ និត ស៊ិត់ យើងអាចសន្និដ្ឋានថា ចំនួនជនរងគ្រោះនៅវត្តព្រះនេត្រព្រះ ភ្នំចក្រី និងព្រៃតារុត ដែលបានយកចេញពីរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤ អាចផ្អែកលើកិច្ចសម្ភាសន៍ជាជាងការរាប់សាកសពជាក់ស្ដែង។

១២៤. គួរលើកឡើងផងដែរថា នៅក្នុងរបាយការណ៍ឆ្នាំ ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ចេញមកពីព័ត៌មានដែលប្រមូលបានដោយរដ្ឋាភិបាលជាតិក្នុងឆ្នាំ ១៩៧៩ ក្នុងបរិបទនៃតុលាការដែលបានបង្កើតឡើងប្រឆាំងនឹងសមាជិករដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ[227] ទោះជាយ៉ាងណាក្ដី ពុំមានភស្តុតាងពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់រដ្ឋាភិបាលកម្ពុជាទេ។

iii. <u>ចំនួនមនុស្សស្លាប់</u>

១២៥. របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងពីរមានបញ្ជាក់ពីចំនួនមនុស្សស្លាប់។ របាយការណ៍ឆ្នាំ ១៩៩៧ រួមមានចំនួនជនរងគ្រោះដែលបានស្លាប់នៅក្នុងអំឡុងរបប

[224] **ឯកសារ D119/133** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និត ស៊ិត់ ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 00998154 ឆ.១៣៣-ឆ.១៣៤។

[225] **ឯកសារ D119/133** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និត ស៊ិត់ ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 00998154 ឆ.១៣៣។

[226] **ឯកសារ D119/133** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និត ស៊ិត់ ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 00998154 ឆ.១៣៣ ។

[227] **ឯកសារ D219/204** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074018 ឆ.៣១។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

01508345



កម្ពុជាប្រជាធិបតេយ្យនៅក្នុងខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបងនាពេលបច្ចុប្បន្ន។ របាយការណ៍នេះរៀបរាប់ចំនួនជនរងគ្រោះសរុប ៤៧១.៧៦១ នាក់ដែលត្រូវបានបែងចែកចេញជាបីប្រភេទដូចតទៅ៖ កសិករ (២៧១.៥៤១ នាក់) មន្ត្រីរដ្ឋការ និងកម្មករ (៥៤.២៣០ នាក់) ព្រះសង្ឃ (១.៥២៥ អង្គ) ជនពិការ (១៤.២១៩ នាក់) ក្រុមជនជាតិភាគតិច (៩៥.៥៧៣ នាក់)[228]។ យោងតាម ស៊ិន ឃិន មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលព័ត៌មានក្នុងអំឡុងពេលនៃកិច្ចសម្ភាសន៍ជាមួយអ្នករស់នៅក្នុងភូមិដែលពាក់ព័ន្ធ[229]។ វាពុំបង្ហាញច្បាស់ថាតើចំនួននៃជនរងគ្រោះក្នុងប្រភេទទាំងនេះអាចជាន់គ្នា លេចចេញពីកិច្ចសម្ភាសន៍ដែលបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឬរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤[230]។ ពាក់ព័ន្ធនឹងចំនួនសរុប (៤៧១.៧៦១ នាក់) ស៊ិន ឃិន លើកឡើងថា តួលេខនេះបានផ្តល់ជូនដោយមន្ទីរវប្បធម៌ខេត្ត[231]។

១២៦. លើសពីនេះ ដូចបានលើកឡើងខាងលើ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសន៍ជាមួយនឹងប្រភពនានាដែលបានផ្តល់ចំនួនមនុស្សស្លាប់ និងរបួសនៅតាមទីតាំងចំនួនប្រាំបីក្នុងចំណោមទីតាំងចំនួន ១៣ ដែលបានលើកឡើងនៅក្នុងរបាយការណ៍ទាំងពីរនោះ រួមមាន ចម្ការខ្នុរ និងវត្តសុភមង្គល - ក្នុងស្រុកស៊ីសុផុន (ឬសេរីសោភ័ណ) ចម្ការយាយហ៊ឹម ល្អាងគួយឃំ និងវត្តបន្ទាយនាង - ក្នុងស្រុកមង្គលបូរី និងទីតាំងចម្ការតាលឹង/វត្តព្រះនេត្រព្រះ និងភ្នំទ្រយោង - ក្នុងស្រុកព្រះនេត្រព្រះ មន្ទីរសន្តិសុខស្រុក និងត្រពាំងថ្ម - ស្រុកភ្នំស្រុក។

---

[228] **ឯកសារ D1.3.10.10** របាយការណ៍មជ្ឈមណ្ឌលកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750666-00750667។

[229] **ឯកសារ D219/206** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072262 ឆ.៤៣-ឆ.៤៤។

[230] *សូមមើល*ឯកសារ **D219/206** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072262 ឆ.៤៣-ឆ.៤៤។

[231] **ឯកសារ D219/206** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072262 ឆ.៤៥។ ចូរកត់សម្គាល់ថា ចំនួនសរុបនៃប្រភេទជនរងគ្រោះខុសៗគ្នាបង្កើតបានចំនួនជនរងគ្រោះសរុប ៤៣៤.០៨៨ នាក់ដែលប្រភេទទាំងនេះអាចជាន់គ្នា។

១២៧. ចំពោះចំនួនជនរងគ្រោះនៅតាមទីតាំងនានា ពាក់ព័ន្ធនឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤/០១ របាយការណ៍ឆ្នាំ ១៩៩៧ លើកឡើងជនរងគ្រោះចំនួន ៤០.០០០ នាក់នៅភ្នំទ្រយោងដែលត្រូវបានពិពណ៌នាថារួមមានមន្ទីរសន្តិសុខ គុក និងទីតាំងសម្លាប់មនុស្សធំមួយ[232]។ ទោះបីជាគាត់បានចូលរួមធ្វើរបាយការណ៍ក៏ដោយ ក៏ ស៊ិន ឃិន ពុំបានដឹងថាតើនរណាគេបានព្រាងរបាយការណ៍ត្រង់ផ្នែកនេះ[233]។ គាត់ក៏ពុំបានចុះពិនិត្យទីតាំងនេះផងដែរ ហើយក៏ពុំបានសម្ភាសន៍ប្រជាជនដែលធ្លាប់បាននៅទីនោះ[234]។ គាត់សន្មតថាតួនាទីនេះបានទទួលមកពីគោលដៅសម្ភាសន៍ដែលគ្មានអត្តសញ្ញាណដោយផ្អែកលើរបាយការណ៍ស្រុក[235]។ ហេតុដូច្នេះ ប្រភពនៃទិន្និន័យនេះពុំមានភាពច្បាស់លាស់។

១២៨. របាយការណ៍ឆ្នាំ ១៩៩៧ លើកឡើងអំពីជនរងគ្រោះចំនួន ៣.៨៩០ នៅព្រៃតារុត[236] ចំណែក របាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤ លើកឡើងថា មានសាកសពចំនួន ៣.៨៩០ សាកសព[237]។ ព័ត៌មានចន្លោះប្រហោងនេះអាចផ្អែកលើភាពមិនអាចអានបាននូវចំនួនជាក់លាក់នេះនៅក្នុងរបាយការណ៍ឆ្នាំ ១៩៨៤។ សំណៅថតចម្លងដែល ក.ស.ច.ស មាន

---

[232] ឯកសារ D1.3.10.10 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750680។

[233] ឯកសារ D219/206 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072262 ឆ.៤២។

[234] ឯកសារ D219/206 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072261 ឆ.៣៧។ ឯកសារ D1.3.10.10 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៩៧ KH ERN 00750680។

[235] ឯកសារ D219/206 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072261 ឆ.៣៩។

[236] ឯកសារ D1.3.10.10 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750677។

[237] ឯកសារ D119/50.2 ស្រុកព្រះនេត្រព្រះ ស្ថិតិប្រាសាទបូរាណ-ស្តូបអធិដ្ឋាន និងសិល្បៈមហាជនរបស់គណៈកម្មការរបស់មន្ទីរឃោសនាការវប្បធម៌-ព័ត៌មានខេត្តបាត់ដំបង លេខ ៧១១ ឃវព៥ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH ERN 00933219។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01508347



អាចត្រឹមអាចអានបានតែប៉ុណ្ណោះ[238] ប៉ុន្តែយើងពុំបានដឹងអំពីគុណភាពនៃព័ត៌មានជាលាយលក្ខណ៍អក្សរដែលបានទទួលដោយមជ្ឈមណ្ឌលឯកសារកម្ពុជានោះឡើយ។ ហេតុដូច្នេះ ចំនួននេះគឺជាចំនួនប៉ាន់ស្មានតែប៉ុណ្ណោះ។

១២៩. នៅក្នុងរបាយការណ៍ឆ្នាំ ១៩៩៧ និងឆ្នាំ១៩៩៨ ក៏ឃើញមានព័ត៌មានចន្លោះប្រហោងពាក់ព័ន្ធនឹងចម្ការខ្នុរផងដែរ។ របាយការណ៍ឆ្នាំ ១៩៩៧ លើកឡើងជនរងគ្រោះចំនួន ២.000 នាក់[239] ២0.000 នាក់[240] ឬ ២៥.000 នាក់[241] ហើយរបាយការណ៍ឆ្នាំ ១៩៩៨ លើកឡើងសាកសពចំនួន ៤.000 ទៅ ៥.000 សាកសព[242]។ ទោះបីជាជាគាត់មានតួនាទីនៅក្នុងការធ្វើរបាយការណ៍ឆ្នាំ១៩៩៨ ក៏ដោយ[243] នៅពេលសួរអំពីព័ត៌មានចន្លោះ

---

[238] ឯកសារ D119/50.2 ស្រុកព្រះនេត្រព្រះ ស្ថិតិប្រាសាទបុរាណ-ស្តូបអធិដ្ឋាន និងសិល្បៈមហាជនរបស់គណៈកម្មការរបស់មន្ទីរឃោសនាការវប្បធម៌-ព័ត៌មានខេត្តបាត់ដំបង លេខ ៧១១ ឃវពខ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH ERN 00933219។ *សូមមើល*សម្រាប់សំណៅជាភាសាខ្មែរឯកសារ ឯកសារ D119/50.2 ស្រុកព្រះនេត្រព្រះ ស្ថិតិប្រាសាទបុរាណ-ស្តូបអធិដ្ឋាន និងសិល្បៈមហាជនរបស់គណៈកម្មការរបស់មន្ទីរឃោសនាការវប្បធម៌-ព័ត៌មានខេត្តបាត់ដំបង លេខ ៧១១ ឃវពខ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH ERN 00933216-00933222។

[239] ឯកសារ D1.3.10.10 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750671។

[240] ឯកសារ D1.3.10.10 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750665។

[241] ឯកសារ D1.3.10.10 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៧ KH ERN 00750671។

[242] ឯកសារ D1.3.27.10 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៨៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៨ KH ERN 00184620។

[243] ឯកសារ D219/206 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072260 ឆ.៣០។ *សូមមើលផងដែរ*ឯកសារ D1.3.27.10 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៨៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៨ KH ERN 00184626។

ប្រហោងនេះ ស៊ិន ឃិន ហាក់ដូចជាពុំបានទៅដល់ចម្ការខ្នុរនៅក្នុងឆ្នាំ ១៩៩៨ នោះឡើយ[244]។

១៣០. ពាក់ព័ន្ធនឹងអាងត្រពាំងថ្មក្នុងស្រុកភ្នំស្រុក គោលដៅសម្ភាសន៍ម្នាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងរបាយការណ៍ឆ្នាំ១៩៩៨ បានផ្តល់តួលេខប៉ាន់ស្មាននៃជនរងគ្រោះចំនួន ២.000 នាក់[245]។ ស៊ិន ឃិន ចងចាំថាបានចុះទៅពិនិត្យអាងត្រពាំងថ្មក្នុងស្រុកភ្នំស្រុកក្នុងឆ្នាំ ១៩៩៨[246]។

iv. <u>សេចក្តីសន្និដ្ឋាន</u>

១៣១. របាយការណ៍ឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៨ បានផ្អែកជាចម្បងលើការចុះតាមទីតាំង និងកិច្ចសម្ភាសន៍ជាមួយនឹងប្រភពនានា ហើយនឹងរួមបញ្ចូលព័ត៌មានពីរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤។ របាយការណ៍ទាំងនេះផ្តល់ព័ត៌មានអំពីទីតាំង និងចំនួនជនរងគ្រោះ។

១៣២. ចំពោះចំនួនជនរងគ្រោះ មានតែប្រភពមួយ ឬពីរនៃមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទីតាំងមួយៗបានផ្តល់ចំនួនបែបនេះ។ របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាដែលជារបាយការណ៍សង្ខេបពុំរួមមានកំណត់ហេតុទាំងស្រុងនៃកិច្ចសន្ទនាដែលបានធ្វើឡើងជាមួយនឹងប្រភពផ្សេងៗគ្នា ហេតុដូច្នេះ វាខ្វះព័ត៌មានដូចជាមូលដ្ឋានសំអាងលើការដឹងឮអំពីប្រភពអំពីចំនួនជនរងគ្រោះ។ ម្យ៉ាងវិញទៀត ចំនួននេះពុំស៊ីសង្វាក់គ្នា ហើយដើមហេតុនាំឱ្យមានការស្លាប់នោះពុំមានភាពច្បាស់លាស់។

១៣៣. ផ្អែកតាមវិធីសាស្ត្រនេះ វាហាក់ដូចជាបង្ហាញថា ចំនួនជនរងគ្រោះនៅក្នុងរបាយការណ៍ឆ្នាំ ១៩៨៤ បានផ្អែកលើព័ត៌មានដែលប្រមូលបានក្នុងលក្ខណៈប្រព័ន្ធ និងតាមរយៈប្រភព

---

[244] **ឯកសារ D219/206** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072261 ឆ.៣២។

[245] **ឯកសារ D1.3.27.10** របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជាលើផែនទី ឆ្នាំ ១៩៩៨៖ ខេត្តបន្ទាយមានជ័យ ឆ្នាំ ១៩៩៨ KH ERN 00184626។

[246] **ឯកសារ D219/206** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01072261 ឆ.៣៤។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * C.C.C * C.E.T.C *

ច្រើនជាងទិន្នន័យយកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ របាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤ ក៏បង្ហាញអំពីដើមហេតុនាំឱ្យមានការស្លាប់ ក៏ប៉ុន្តែពុំបានបញ្ជាក់ថាតើព័ត៌មាននេះបានបង្កើតឡើងដោយរបៀបណានោះទេ។ របាយការណ៍នេះពុំរួមមានកំណត់ហេតុនៃកិច្ចសន្ទនាដែលបានធ្វើឡើងជាមួយនឹងប្រភពនានានោះឡើយ។

១៣៤. របាយការណ៍ទាំងនេះគ្មានបានលើកឡើងអំពីកាលបរិច្ឆេទដែលជនរងគ្រោះបានស្លាប់ ឬរចនាសម្ព័ន្ធរដ្ឋបាល និងខ្សែសង្វាក់នៃការបញ្ជាដែលនាំឱ្យមានការស្លាប់នោះទេ។ ហេតុដូច្នេះ យើងពុំអាចកំណត់ថាតើមរណភាពស្ថិតនៅក្រោមរង្វង់ក្របខ័ណ្ឌយុត្តាធិការពេលវេលាពាក់ព័ន្ធ ឬក៏អត់នោះឡើយ។

១៣៥. ផ្អែកលើចំណុចខាងលើ យើងយល់ឃើញថា ចំនួនជនរងគ្រោះដែលបានផ្តល់ជូននៅក្នុងរបាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ ១៩៩៧ និងឆ្នាំ ១៩៩៨ និងរបាយការណ៍រដ្ឋាភិបាលឆ្នាំ ១៩៨៤ ពុំអាចទុកចិត្តបាន និងមានតម្លៃជាភ័ស្តុតាងតិចតួច។ អាស្រ័យហេតុនេះ យើងពុំបានសំអាងលើចំនួនទាំងនេះឡើយ។ ចំនួន និងដើមហេតុនាំឱ្យមានការស្លាប់ដែលសាក្សីបានផ្តល់ជូន ក.ស.ច.ស ត្រូវបានយកមកសំអាងជំនួសវិញ។

## ឃ. កិច្ចសម្ភាសន៍ អ៊ឹម ចែម ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គភាពផ្សេងទៀត

១៣៦. ទោះបីជាវិធានផ្ទៃក្នុងចែងអំពីប្រព័ន្ធធ្វើកិច្ចស្តាប់ចម្លើយជនសង្ស័យ និងជនត្រូវចោទ (ដែលជាបុរេលក្ខខណ្ឌស្តីពីភាពអាចទទួលយកបាន) ក៏ដោយ[247] ក៏វិធានទាំងនេះពុំចែងឱ្យបានច្បាស់លាស់លើការប្រើប្រាស់ចម្លើយដែលជនសង្ស័យ និងជនត្រូវចោទបានផ្តល់ជូនអង្គភាព ឬអង្គការផ្សេង ទោះបីនៅមុន ឬក្រោយបានដឹងថាក្លាយជាជនសង្ស័យ ឬកំពុងត្រូវបានចោទប្រកាន់ទៅតាមការការស៊ើបអង្កេតរបស់ អ.វ.ត.ក ក៏ដោយ។

១៣៧. ស.ច.ស នៅក្នុងសំណុំរឿង ០០២ បានទទួលយកសំណើសុំរបស់សហព្រះរាជអាជ្ញាសុំដាក់ចូលក្នុងសំណុំរឿងនូវខ្សែភាពយន្តដែល នួន ជា នៅមុនពេលត្រូវបានចោទប្រកាន់ត្រូវបានសម្ភាសន៍ និងបានធ្វើសេចក្តីប្រកាសទាក់ទងនឹងបទចោទក្នុងសំណុំរឿង ០០២។

[247] វិធាន ២១ និងវិធាន ៥៨ នៃវិធានផ្ទៃក្នុង។

01508350



នៅក្នុងករណីនោះ ស.ច.ស ពុំចាត់ទុកថា វាមានរបាំងចំពោះការប្រើប្រាស់សេចក្តីថ្លែងការណ៍ទាំងអស់នោះជាភស្តុតាងនោះទេ។ ស្របជាមួយនឹងវិធានទូទៅស្តីពីការវាយតម្លៃលើភស្តុតាងដែលបានលើកឡើងខាងលើនៅក្នុងផ្នែកនេះ ស.ច.ស គ្រាន់តែបានកត់សម្គាល់ថា ខ្លឹមសារនៃខ្សែភាពយន្ត និងសេចក្តីប្រកាសដែលបានធ្វើឡើងដោយជនត្រូវចោទ *"ត្រូវបានគិតថាវាកម្រិតស្រាលជាង បើប្រៀបជាមួយនឹងភស្តុតាងដែលប្រមូលបានដោយផ្ទាល់ដោយ ស.ច.ស នៅក្នុងអំឡុងពេលនៃការស៊ើបសួរ"*[248]។

១៣៨. នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើកិច្ចសម្ភាសន៍របស់ នួន ជា ត្រង់ផ្នែកខ្លះដែលបានទទួលស្គាល់សេចក្តីថ្លែងការណ៍ដាក់បន្ទុកថាអាចជឿជាក់បាន ហើយច្រានចោលសេចក្តីថ្លែងការណ៍ដែលអាចទំនងមានលក្ខណៈដោះបន្ទុក។ នៅពេលសំអាងដូច្នោះ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃលើសេចក្តីថ្លែងការណ៍របស់ នួន ជា រួមជាមួយនឹងភស្តុតាងនៅក្នុងសំណុំរឿង ហើយអ្វីដែលសំខាន់នោះបានអនុវត្តឆន្ទានុសិទ្ធិ ស្របទៅតាមបទដ្ឋានទូទៅនៃការវាយតម្លៃភស្តុតាង[249]។ នៅដំណាក់កាលបណ្តឹងសាទុក្ខ អ.ជ.ត.ក បានទទួលស្គាល់វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងការសំអាងលើផ្នែកស្តីពីភស្តុតាងដាក់បន្ទុកដែលបានរកឃើញនៅក្នុងវីដេអូ ព្រមទាំងការច្រានចោលរបស់អង្គជំនុំជម្រះសាលាដំបូងលើផ្នែកនៃភស្តុតាងដោះបន្ទុកដែលមានកិច្ចសម្ភាសន៍ដដែលនោះ[250]។

១៣៩. សេចក្តីថ្លែងការណ៍ចំនួនពីរដែល **អ៊ឹម ចែម** បានផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា[251] សេចក្តីថ្លែងការណ៍មួយផ្តល់ជូនអង្គការយុវសន្តិភាព[252] និងមួយទៀតផលិតកម្មស្នាយលីង

---

[248] **សំណុំរឿង ០០២-ឯកសារ D344/1** *ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងខ្សែភាពយន្ត "សត្រូវរបស់ប្រជាជន"* ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១០ កថាខណ្ឌ ៣។

[249] **សំណុំរឿង ០០២/០១-E313** *សាលក្រម* ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៥០១-កថាខណ្ឌ ៥០៣ កំណត់សម្គាល់ ១៥១០ កថាខណ្ឌ ៨៣៨ ដល់ ៨៣៩។

[250] **សំណុំរឿង ០០២-ឯកសារ F36** *សាលដីកា* ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៣៥៨-៣៥៩។

[251] **ឯកសារ D123/1/5.1a** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ KH ERN 00929726-00929761។ **ឯកសារ D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ KH ERN 00929846-00929916។



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C

ថូត[253] ត្រូវបានយកមកពិចារណានៅក្នុងដីកាដំណោះស្រាយនេះ (សំអាងហេតុ)។ ស្រប ជាមួយនឹងវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងសំណុំរឿង ០០២ និងវិធានទូទៅនៃការវាយ តម្លៃលើភ័ស្តុតាងដែលបានពន្យល់នៅក្នុងផ្នែកនេះ សេចក្តីថ្លែងការណ៍ទាំងនេះត្រូវបាន ផ្តល់ទម្ងន់តិចតួចជាងការស្តាប់ចម្លើយដែលបានធ្វើឡើងដោយ ក.ស.ច.ស។ ភាពអាច ជឿជាក់បាន និងតម្លៃជាភ័ស្តុតាងរបស់សេចក្តីថ្លែងការណ៍ទាំងនេះត្រូវបានវាយតម្លៃ ដោយពិនិត្យពិចារណាលើភ័ស្តុតាងទាំងអស់ផ្សេងទៀតដែលមាននៅក្នុងសំណុំរឿង។

## IV. ការវិភាគអង្គហេតុ និងសេចក្តីសន្និដ្ឋាន

### ក. អ៊ឹម ចែម មុនខែ មេសា ឆ្នាំ ១៩៧៥ និងក្រោយថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩

១៤០. **អ៊ឹម ចែម** កើតនៅឆ្នាំ ១៩៤៦ នៅភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ[254] និងបានចូលរួមក្នុងចលនាខ្មែរក្រហមនៅឆ្នាំ ១៩៧០[255]។ ក្រោយពេលចូលរួមជាមួយខ្មែរ

---

[252] **ឯកសារ D219/264.1** ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់អង្គការយុវសន្តិភាពជាមួយនឹង អ៊ឹម ចែម ក្នុងឆ្នាំ ២០១១ KH ERN 01106993-01107054។

[253] **ឯកសារ D1.3.12.1** កិច្ចសម្ភាសន៍របស់ផលិតកម្មស្នាយលីងថូតជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH ERN 00234184-00234227។

[254] **ឯកសារ D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ KH ERN 00929848។ **ឯកសារ D1.3.12.1** កិច្ចសម្ភាសន៍របស់ផលិតកម្មស្នាយលីងថូតជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH ERN 00234184-00234185។ **ឯកសារ D118/208** *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិល ហឿន* ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៤ KH ERN00980088 ឆ.៥៧។

[255] **ឯកសារ D1.3.12.1** កិច្ចសម្ភាសន៍របស់ផលិតកម្មស្នាយលីងថូតជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH ERN 00234190.



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ក្រហម គាត់ធ្វើជាមេឃុំជាងទងរយៈពេលពីរឆ្នាំ[256]។ សាក្សីនានាបានលើកឡើងថា គាត់ស្ថិតនៅស្រុកត្រាំកក់ប្រហែលជារហូតដល់ខែ មេសា ឆ្នាំ ១៩៧៥[257]។

១៤១. សាក្សីម្នាក់បានរាយការណ៍ថា នៅពេលកងទ័ពវៀតណាមចូលមកដល់នៅឆ្នាំ ១៩៧៩ អ៊ឹម ចែម បានភៀសខ្លួនចូលព្រៃ ប្រហែលនៅជិតព្រំដែនថៃ[258]។ គាត់ប្រហែលជារស់នៅជិតព្រំដែនថៃក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដោយសារសាក្សីម្នាក់ទៀតបានជួបគាត់នៅក្នុងការប្រជុំមួយដែលដឹកនាំដោយ តាម៉ុក នៅខេត្តសុរិន្ទ ប្រទេសថៃ[259]។

១៤២. **អ៊ឹម ចែម** សព្វថ្ងៃ រស់នៅភូមិអូរអង្រែ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ[260]។

## ខ. តួនាទី និង សិទ្ធិអំណាចរបស់ អ៊ឹម ចែម នៅភូមិភាគនិរតី

១៤៣. អនុលោមទៅតាមសំអាងហេតុដែលបានពន្យល់នៅក្នុងផ្នែកនេះ យើងសន្និដ្ឋានថា នៅក្នុងភូមិភាគនិរតី **អ៊ឹម ចែម** មានតួនាទីជាលេខាសមាគមនារីនៃតំបន់ ១៣ ហើយនៅក្នុងតួនាទីនេះគាត់ទទួលខុសត្រូវលើការអប់រំនយោបាយដល់ស្ត្រីនៅតាមស្រុកក្នុងតំបន់ ១៣។

---

256 **ឯកសារ D1.3.12.1** កិច្ចសម្ភាសន៍របស់ផលិតកម្មស្នាយលីងចូតជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH ERN 00234190-00234191.

257 **ឯកសារ D118/208** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៤ KH ERN00980088 ឆ.៥៧។ **ឯកសារ D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01008700 ឆ.២៤។

258 **ឯកសារ D119/139** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN01003887-01003888 ឆ.៦២។

259 **ឯកសារ D119/68** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969021 ឆ.១។

260 **ឯកសារ D118/150** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00968006 ឆ.៨២។ **ឯកសារ D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ KH ERN 00929850។ សូមមើល ផងដែរ **ឯកសារ A150** ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

១៤៤. ស.ព.អ អះអាងថា ចាប់ពីឆ្នាំ ១៩៧៦ **អ៊ឹម ចែម** ជាលេខាស្រុកកោះអណ្តែតក្នុងតំបន់ ១៣ នៃភូមិភាគនិរតីផង[261] និងជាសមាជិកគណៈតំបន់ ១៣ ផង។ ហេតុនេះ គាត់ត្រូវបានចោទប្រកាន់ថាជាប់ពាក់ព័ន្ធទៅនឹងរាល់ការសម្រេចទាំងអស់ដែលប៉ះពាល់ដល់ស្រុកកោះអណ្តែត និងតំបន់ ១៣[262]។ យើងសន្និដ្ឋានថា ពុំមានភស្តុតាងគាំទ្រដល់ការអះអាងទាំងនេះទេ។

១៤៥. ស.ព.អ លើកឡើងថា **អ៊ឹម ចែម** ជាលេខាស្រុកកោះអណ្តែត ដោយសំអាងទៅលើចម្លើយមួយរបស់ **អ៊ឹម ចែម** និង ទៅលើភស្តុតាងរបស់សាក្សីម្នាក់។ ទោះជាយ៉ាងណាក្តី នៅក្នុងចម្លើយនោះ **អ៊ឹម ចែម** គ្រាន់តែនិយាយថា នៅស្រុកកោះអណ្តែត គាត់ "*ធ្វើតែជាមួយប្រជាជន ប៉ុនធ្វើបានតែស្លួង*" ថា គាត់ពុំមានកាន់ "*មុខងារអីធំដុំទេ*" ហើយថា គាត់ទទួលខុសត្រូវខាងជម្លៀសស្ត្រី[263]។ សាក្សីដែល ស.ព.អ យកមកសំអាងគ្រាន់តែលើកឡើងថា **អ៊ឹម ចែម** បានទៅកោះអណ្តែតពី "*សមាគមនារីតំបន់ ១៣*" សាក្សីមិនដឹងថាគាត់ជាលេខាស្រុកកោះអណ្តែត ឬយ៉ាងណាទេ ហើយសាក្សីក៏មិនដឹងច្បាស់ពីការទទួលខុសត្រូវរបស់គាត់ដែរ សាក្សីបានឃើញគាត់ទៅមន្ទីរស្រុក "*ហៅនារីទៅប្រជុំ*"។ សាក្សីក៏លើកឡើងបន្ថែមដែរថា **អ៊ឹម ចែម** មិនបានទៅមន្ទីរស្រុកញឹកញាប់ទេ តែ "*យូរៗមកម្តង*" ប៉ុណ្ណោះ[264]។

---

[261] សូមមើលផងដែរ ទាក់ទិងនឹងទីតាំងស្រុកកោះអណ្តែត។ **ឯកសារ D119/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាង អ៊ូច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ KH ERN00971368 ឆ.១៦។

[262] **ឯកសារ D304/2** ដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ កថាខណ្ឌ ១០៥-១០៧។

[263] **ឯកសារ D123/1/5.1a** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ KH ERN00089783, KH ERN00929750។

[264] **ឯកសារ D119/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាង អ៊ូច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ KH ERN 00971372-00971374 ឆ.៤០-ឆ.៥១។



* CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

១៤៦. ពេជ្រ ជឹម ដែលធ្លាប់ជាអនុលេខាស្រុកត្រាំកក់ នៅតំបន់ ១៣ ពីឆ្នាំ ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៦[265] លើកឡើងថា **អ៊ឹម ចែម** ពុំមានតួនាទីផ្លូវការនៅក្នុងគណៈស្រុកកោះអណ្តែតទេ តែថា គាត់បានទៅធ្វើការនៅគ្រប់ស្រុកទាំងអស់ក្នុងតំបន់ ១៣ ដែលជាផ្នែកមួយនៃតួនាទីរបស់គាត់ជាប្រធានសមាគមនារីតំបន់ ១៣[266]។ **អ៊ឹម ចែម** ពិតជាបានលើកឡើងនៅក្នុងបទសម្ភាសន៍នាពេលក្រោយមកថា បន្ទាប់ពីគាត់ផ្ទេរទៅកោះអណ្តែត គាត់គឺជាសមាជិកក្នុងគណៈកម្មាធិការមួយដែលមានសមាសភាពបីរូប ហើយគាត់ផ្តោតលើការងារបង្កបង្កើនផលស្រូវ[267]។ ទោះជាយ៉ាងណាក្តី ទាក់ទិននឹងភ័ស្តុតាងដែលបានយកមកពិនិត្យនៅក្នុងកថាខណ្ឌនេះ និងអនុលោមតាមសំអាងហេតុនានាដែលបានពន្យល់នៅក្នុងចំណុចផ្សេងទៀតនៃផ្នែកនេះ យើងយល់ឃើញថា **អ៊ឹម ចែម** ពុំមែនជាលេខាស្រុកកោះអណ្តែតទេ តែគាត់បានធ្វើការនៅទីនោះដោយសារគាត់មានតួនាទីជាប្រធានសមាគមនារីតំបន់ ១៣។

១៤៧. ទាក់ទិននឹងតួនាទីរបស់ **អ៊ឹម ចែម** ជាសមាជិកគណៈតំបន់ ១៣ ស.ព.អ សំអាងទៅលើចម្លើយមួយរបស់ **អ៊ឹម ចែម** ដែលគាត់លើកឡើងថា គាត់ជំនួស តាសោម (ដែលជាលេខាស្រុកក្នុងតំបន់ ១៣) មួយរយៈពេលខ្លី នៅពេលគាត់ធ្លាក់ខ្លួនឈឺ[268]។ ស.ព.អ ក៏បានសំអាងផងដែរទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលយើងចាត់ទុកថាមានតម្លៃជាភ័ស្តុតាងតិចតួច ឬពុំមានតម្លៃជាភ័ស្តុតាងទេនោះ[269]។

---

[265] **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00997026-00997027 ឆ.២៨-ឆ.៣១។

[266] **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00997028 ឆ.៤១-ឆ.៤៣។

[267] **ឯកសារ D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ KH ERN 00951846, KH ERN 00929874។

[268] **ឯកសារ D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ KH ERN 00951848, KH ERN 00929877។

[269] សូមមើលផ្នែក III(ក)។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D' INSTRUCTION

១៤៨. ជាការពិត មានសាក្សីបីនាក់ដែលបានលើកឡើងដោយមានភាពច្បាស់លាស់ និងជាក់លាក់ដែលមានកម្រិត ខុសៗគ្នាត្រង់ថា អ៊ឹម ចែម ជាសមាជិកគណៈតំបន់ ១៣ នៅភូមិភាគនិរតី[270]។ ទោះជាយ៉ាងណាក្តី សាក្សីជាច្រើននាក់បានផ្តល់ភ័ស្តុតាងជាក់លាក់ជាងលើបញ្ហានេះ ដោយលើកឡើងថា តួនាទីរបស់ **អ៊ឹម ចែម** នៅតំបន់ ១៣ គឺជាប្រធានសមាគមនារី[271]។ ក្នុងចំណោមសាក្សីទាំងនោះ មានសាក្សីឈ្មោះ ពេជ្រ ជឹម ដែលថា ចំពោះតួនាទីនេះ **អ៊ឹម ចែម** បានធ្វើដំណើរទៅតាមស្រុកនានាក្នុងតំបន់ ១៣ ដែលគាត់បានបើកវគ្គរៀនសូត្រដល់ស្ត្រី វាយតម្លៃអំពីប្រវត្តិរូបរបស់ពួកគេ និងចាត់តាំងឱ្យពួកគេទៅកាន់ការងារ និងទីកន្លែងខុសៗគ្នា[272]។ ឧទាហរណ៍ **អ៊ឹម ចែម** បានចូលរួម និងបាន

---

[270] **ឯកសារ D118/78** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អន សុភាព ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00934396 ទ.៨។ **ឯកសារ D119/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀម ជ្រៀវ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ KH ERN 00893264 ទ.៦។ **ឯកសារ D219/37** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01032102 ទ.១៧។

[271] **ឯកសារ D119/83** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00975684 ទ.១៨-ទ១៩។ **ឯកសារ D119/84** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត KH ERN 00975692,00975694-00975695 ទ.១៩-ទ.២០, ទ.២៩-ទ.៣១។ **ឯកសារ D118/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00934400 ទ.៦។ **ឯកសារ D6.1.688** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ KH ERN 00368607 ទំព័រ ១២។ **ឯកសារ D119/15** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ វ៉ន ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ KH ERN 00893277 ទ.១២។ **ឯកសារ D118/274** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 00999991 ទ.២៨។ **ឯកសារ D219/521** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គីប គី ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ KH ERN 01149836 ទ.៦៣។ **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00997028 ទ.៤០-ទ.៤៥។ **ឯកសារ D119/149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01022478 ទ.៣២-ទ.៣៤។ **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN00997028 ទ.៤០-ទ.៤១។

[272] **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN00997028 ទ.៤១-ទ.៤៣។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ថ្លែងនៅក្នុងការប្រជុំនៅស្រុកអង្គរជ័យ តំបន់ ១៣[273] ដែលនៅទីនោះ គាត់ទទួលបន្ទុកផ្នែកនារីស្រុក[274] រួមទាំងស្រុកផ្សេងទៀតដែលនៅក្នុងតំបន់នោះ ចំណែកឯការទទួលខុសត្រូវរបស់គាត់រួមមាន ការចាត់តាំងមនុស្សឱ្យធ្វើការងារ និងទៅកន្លែងផ្សេងៗ[275]។ **អ៊ឹម ចែម** ខ្លួនឯងបានបញ្ជាក់ថា គាត់ពិតជាមានតួនាទីនេះមែន[276]។ គាត់ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ តាសោម ជាលេខាតំបន់ ១៣[277]។

១៤៩. សាក្សីម្នាក់បានពន្យល់ពីវត្តមានរបស់ **អ៊ឹម ចែម** នៅអង្គរជ័យ ដោយលើកឡើងថា គាត់ជាលេខាស្រុក[278]។ ទោះជាយ៉ាងណាក្តី ភស្តុតាងនេះដាច់តែឯង ពុំមានមូលដ្ឋានច្បាស់លាស់

---

[273] **ឯកសារ D119/156** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អឹង ជឿន ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN01024772 ឆ.១៣-ឆ.១៤។ **ឯកសារ D119/84** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត KH ERN 00975692, 00975695, 00975697 ឆ.១៩-ឆ.២០, ឆ.៣២, ឆ.៣៧។

[274] **ឯកសារ D6.1.648** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ភន ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៩ KH ERN 00368661 ទំព័រ ៦។

[275] **ឯកសារ D119/149**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01022478, ឆ.៣២-ឆ.៣៤។ **ឯកសារ D119/156** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អឹង ជឿន ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN01024772 ឆ.១៥-ឆ.១៧។ **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN00997028 ឆ.៤០។ **ឯកសារ D118/208** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980088 ឆ.៥៦។ **ឯកសារ D1.3.11.19** កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយសាក្សី កោ ចេង ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៨ KH ERN00848195។ នៅក្នុង **ឯកសារ D119/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ឆេង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣KH ERN00893284- ឆ.២៤ កៅ ឆេង លើកឡើងថា **អ៊ឹម ចែម** ទទួលបន្ទុកផ្នែកយោធានៅស្រុកកោះអណ្តែត (ស្រុក ១០៨)។ ភស្តុតាងនេះពុំមានសាក្សីណាផ្សេងលើកឡើងទេ។ ជាងនេះទៀត កៅ ឆេង មិនដែលបានជួប **អ៊ឹម ចែម** ទេ ហើយត្រឹមតែឮថាគាត់ទទួលបន្ទុកផ្នែកយោធាស្រុកពីអ្នកផ្សេងប៉ុណ្ណោះ សូមមើល KH ERN00893284-00893285 ឆ.៣១-ឆ.៣២។

[276] **ឯកសារ D123/1/5.1a** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ KH ERN00929750។

[277] **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN00997024 ឆ.១៧, KH ERN 00997039 ឆ.១២៤។

[278] **ឯកសារ D118/208** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន KH ERN00980089 ឆ.៦២-ឆ.៦៤។ **ឯកសារ D118/209** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980115 ឆ.១២៨-ឆ.១២៩។

និងផ្អែយពីសាក្សីម្នាក់ដែលលើកឡើងថា ទោះបី អ៊ឹម ចែម ពិតជាបានចូលរួមក្នុងការប្រជុំនៅអង្គរជ័យក៏ដោយ តែគាត់ចូលរួមពុំមែនក្នុងនាមជាលេខាស្រុកទេ[279] ដោយសារមនុស្សម្នាក់ឈ្មោះ តាញ៉ែន ជាអ្នកកាន់កាប់តំណែងនេះ នេះបើតាមការលើកឡើងរបស់សាក្សីនេះ និងសាក្សីម្នាក់ទៀត[280]។

១៥០. អ៊ឹម ចែម ដឹកនាំសមាគមនារីនៅតំបន់ ១៣ ពីឆ្នាំ ១៩៧០ ឬ ១៩៧២ រហូតដល់ប្រហែលជាខែ កុម្ភៈ ឬ មីនា ឆ្នាំ ១៩៧៧ នៅពេលដែលគាត់ផ្លាស់ទៅភូមិភាគពាយ័ព្យ[281]។

## គ. ការចូលគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតីទៅលើភូមិភាគពាយ័ព្យ

១៥១. នៅដើមឆ្នាំ ១៩៧៦ និងបន្តរហូតដល់ឆ្នាំ ១៩៧៨ តាម៉ុក ដែលជាលេខាភូមិភាគនិរតី[282] បានបញ្ជូនកម្មាភិបាលជាច្រើនក្រុមពីភូមិភាគនិរតីឱ្យទៅជំនួសកម្មាភិបាលមូលដ្ឋាននៅក្នុងរចនា សម្ព័ន្ធរដ្ឋបាលនៃភូមិភាគពាយ័ព្យ[283]។ សាក្សីជាច្រើនដែលត្រូវបានបញ្ជូន

---

[279] **ឯកសារ D119/149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01022478 ឆ.៣២-ឆ.៣៤។

[280] **ឯកសារ D119/149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01022478 ឆ.៣៤។

[281] **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00997028 ឆ.៤០-ឆ.៤៥។ **ឯកសារ D119/15** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ វ៉ន ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ KH ERN 00893277 ឆ.១២។ **ឯកសារ D119/83** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 0097568400982073 ឆ.១៨, ឆ.១៩។ **ឯកសារ D118/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00934400 ឆ.៦។ **ឯកសារ D118/209** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980115 ឆ.១២៨, ឆ.១២៩។ *សូមមើលផងដែរ* **ឯកសារ D119/149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01022478 ឆ.៣៥-ឆ.៤០។

[282] **ឯកសារ D118/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00968032 ឆ.១៥។

[283] **ឯកសារ D118/60** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង សុខឃី ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 00920148-00920149, ឆ.១៥, ឆ.២៧។ **ឯកសារ D118/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សឿន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ KH ERN00945428 ឆ.៧។ **ឯកសារ D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយ...



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ទៅភូមិភាគពាយ័ព្យបានចូលរួមប្រជុំនៅតាកែវ មុនពេលចេញដំណើរ ដែលនៅទីនោះ តាម៉ុក បានប្រកាសថា បាត់ដំបងជា "*តំបន់រំដោះថ្មី*" សភាពការណ៍នៅទីនោះ "*មិនល្អ*" ហើយភូមិភាគត្រូវការជំនួយ[284]។ តាម៉ុក បានស្តីបន្ទោសដល់កម្មាភិបាលពាយ័ព្យចំពោះបញ្ហាទាំងនេះ[285]។ ការប្រជុំបានធ្វើឡើងនៅឆ្នាំ ១៩៧៦[286] ឆ្នាំ ១៩៧៧[287] និង ឆ្នាំ ១៩៧៨[288]។ តាម៉ុក និងកម្មាភិបាលជាន់ខ្ពស់ផ្សេងទៀតបានចាត់តាំងកម្មាភិបាលពីភូមិភាគនិរតីឲ្យទៅកាន់តំណែង និងទីកន្លែងផ្សេងៗ នៅពេលពួកគេទៅដល់ភូមិភាគពាយ័ព្យ[289]។

---

សាក្សី មូល អេង ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01095237-01095239 ឆ.៩-ឆ.១០, ឆ.១៥, ឆ.២០, KH ERN 01095240-01095241 ឆ.៣២, ឆ.៣៦, KH ERN 01095242 ឆ.៤៣-ឆ.៤៤។ **ឯកសារ D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01008700 ឆ.២៧-ឆ.២៩, ERN 01008703 ឆ.៣៨-ឆ.៤១។ **ឯកសារ D219/62** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ KH ERN 01037140 ឆ.២២, KH ERN 01037142 ឆ.៣២, ឆ.៣៣, ឆ.៣៦, KH ERN 01037143 ឆ.៣៩។ **ឯកសារ D119/124** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00987269 ឆ.២៥-ឆ.២៧។

[284] **ឯកសារ D118/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00968033 ឆ.២២។ **ឯកសារ D118/107** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែត ឌុន ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00951916 ឆ.៦-ឆ.៨។ **ឯកសារ D118/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ជឿន ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៣ KH ERN 00945404-00945405 ឆ.១០, , ឆ.១៣។

[285] **ឯកសារ D219/228** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នុត នូវ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01075762 ឆ.៤៦, ឆ.៤៨-ឆ.៥០។ **ឯកសារ D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01008702-01008703 ឆ.៣៧-ឆ.៤០។

[286] **ឯកសារ D118/85** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ជឿន ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៣ KH ERN 00945404-00945405 ឆ.៩-ឆ.១២។

[287] **ឯកសារ D118/107** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែត ឌុន ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00951915-00951916, ឆ២, ឆ៥-ឆ៦។

[288] **ឯកសារ D118/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00968032 ឆ.16, KH ERN 00968033-00968034 ឆ.២២, ឆ.២៥។

[289] **ឯកសារ D118/84** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូច ភឿន ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៣ KH ERN 00945366 ឆ.១៤។ **ឯកសារ D118/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សៀន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ



INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C

01508359





១៩២. តាម៉ុក បានបញ្ជូនកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យបីដង[290]។ លើកទីមួយធ្វើឡើងនៅឆ្នាំ ១៩៧៦ នៅពេលដែលកម្មាភិបាលភូមិភាគនិរតីមួយក្រុមតូចត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ ដើម្បីធ្វើការជាមួយកម្មាភិបាលភូមិភាគពាយ័ព្យ តែមិនបានទៅជំនួសឬគ្រប់គ្រងពួកគេទេ[291]។ លើកទីពីរធ្វើឡើងនៅឆ្នាំ ១៩៧៧ និងដើមឆ្នាំ ១៩៧៨ នៅពេលតាម៉ុក បញ្ជូនកម្មាភិបាលភូមិភាគនិរតី រួមជាមួយក្រុមគ្រួសារពួកគេ ដើម្បីទៅចាប់ខ្លួននិងជំនួសកម្មាភិបាលភូមិភាគពាយ័ព្យនៅថ្នាក់ឃុំ សហករណ៍ និងស្រុក[292] ដែលដឹកនាំដោយ **អ៊ឹម ចែម** ដែលក្រោយមក គាត់បានផ្លាស់ទៅស្រុកព្រះនេត្រព្រះក្នុងតំបន់ ៥[293]។ ការបញ្ជូនកម្មាភិបាលលើកទីបីធ្វើឡើងនៅពាក់កណ្ដាលឆ្នាំ ១៩៧៨។ នៅពេលនោះកម្មាភិបាលភូមិភាគនិរតីបានទៅជំនួសកម្មាភិបាលភូមិភាគពាយ័ព្យថ្នាក់លើ ដោយបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យនៅថ្នាក់តំបន់ និងភូមិភាគ តែក៏បានទៅជំនួស

---

២០១៣ KH ERN00945430 ទ.២៨, KH ERN00945431 ទ.៣៧-ទ.៤១។ **ឯកសារ D118/285** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01008703 ទ.៣៨-ទ.៤១។

[290] **ឯកសារ D118/153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00968038 ទ.៥៤។

[291] **ឯកសារ D118/86** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ក លី ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៣ KH ERN 00945419 ទ.១៣។ **ឯកសារ D118/107** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សែត ឌុន ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00951918-00951919 ទ.២៩។ **ឯកសារ D118/250** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុត វើក ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00992419 ទ.៧០, KH ERN00992421 ទ.៨៧។

[292] **ឯកសារ D118/107** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សែត ឌុន ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00951915-00951916- ទ.២, ទ.៦, ទ.១១, KH ERN00951918-00951919 ទ.២៩។ **ឯកសារ D118/153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00968030-00968031 ទ.៣-ទ.៤។ **ឯកសារ D118/137** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈន វន ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00960677 ទ.៨-ទ.៩។ **ឯកសារ D118/4** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ KH ERN 00882709-00882710 ទ.១៥-ទ.១៧។ **ឯកសារ D118/285** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ណុប ង៉ឹម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01008700-01008701 ទ.២៥, ទ.២៨, ទ.៣១។ **ឯកសារ D118/250** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុត វើក ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00992419 ទ.៧០។

[293] ភស្តុតាងស្ដីពីប្រធានបទនេះត្រូវបានយកមកពិនិត្យនៅផ្នែកដែលពាក់ព័ន្ធនឹងតួនាទីរបស់ **អ៊ឹម ចែម** នៅភូមិភាគពាយ័ព្យ។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

កម្មាភិបាលថ្នាក់ក្រោមនៅថ្នាក់ស្រុក និងឃុំ ដែលធ្វើការក្រោមកម្មាភិបាលភូមិភាគ និងតំបន់ មុនពេលមានការបោសសម្អាតដែរ[294]។

១៥៣. តាម៉ុក បានចាត់តាំងកងទ័ពភូមិភាគនិរតីឱ្យធ្វើការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ។ សាក្សី ហែម មឿន ដែលជាទាហាន និងជាសាច់ញាតិរបស់ តាម៉ុក ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយ តាម៉ុក នៅភូមិភាគពាយ័ព្យ លើកឡើងថា មុនពេលកងពលនៃកងទ័ពរបស់គាត់ត្រូវបានបញ្ជូនទៅបាត់ដំបងនៅដើមឆ្នាំ ១៩៧៨ តាម៉ុក បានបញ្ជាឱ្យពួកគេ "*បោសសម្អាតពួកពាយ័ព្យ*"[295]។ ក្រោយពេលកម្មាភិបាលភូមិភាគនិរតីទៅដល់ កងទ័ព និងកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅតាមមន្ទីរសន្តិសុខនានាក្នុងភូមិភាគពាយ័ព្យ និងនៅមន្ទីរ ស-២១ នៅភ្នំពេញ ដោយចាត់តាំងឱ្យធ្វើការងារនៅតាមការដ្ឋាននានាក្នុងភូមិភាគពាយ័ព្យដើម្បី "កសាងខ្លួន" ឬយកទៅសម្លាប់[296]។ នៅ

---

[294] **ឯកសារ D118/107**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែត ឌុន ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00951918-00951919 ទ.២៩។ **ឯកសារ D118/86** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ឹក លី ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៣ KH ERN 00945419 ទ.១៣, KH ERN00945423 ទ.៤១-ទ.៤៣។ **ឯកសារ D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01095244-01095245 ទ.៦១។ **ឯកសារ D118/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទាត់ ធឿន ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN00947578-KH ERN00947582 ទ.១៥-ទ.៣២។

[295] **ឯកសារ D118/150** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00967996 ទ.៥, KH ERN 00967998 ទ.២៣-ទ.២៥, KH ERN 00968003 ទ.៦០។ សូមមើលផងដែរ **ឯកសារ D118/137** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈន វន ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00960682 ទ.៥៨។ **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969014-00969016ទ.៧-ទ.១៤។ **ឯកសារ D118/106** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ជឿម ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00951902 ទ.២។

[296] **ឯកសារ D118/136** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00960662-00960663 ទ.២។ **ឯកសារ D118/77** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00934389 ទ.៣០។ **ឯកសារ D118/285** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01008702-01008703 ទ.៣៧, ទ.៤០, ទ.៤២។ **ឯកសារ D118/290** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ វ៉ាច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01022367 ទ.៣០-ទ.៣[illegible]។ **ឯកសារ D219/20** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈុំ វ៉ាន់ ចុះថ្ងៃទី [illegible]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ពាក់កណ្តាលឆ្នាំ ១៩៧៨ ក្រោយពេលចាប់ខ្លួន និងដកកម្មាភិបាលជាន់ខ្ពស់ចេញពីតំណែង ហើយ តាម៉ុក ក៏ក្លាយជាលេខាភូមិភាគពាយ័ព្យជាផ្លូវការ[297]។

១៥៤. តាម៉ុក បានបោសសម្អាតតំបន់ ៥ នៃភូមិភាគពាយ័ព្យ ដែលនៅទីនោះ មេដឹកនាំមូលដ្ឋាន និងកម្មាភិបាលថ្នាក់ក្រោម ត្រូវបានចាប់ខ្លួន និងសម្លាប់ដោយកម្មាភិបាលភូមិភាគនិរតី ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧ មក[298]។ ដូចដែលនឹងឃើញនៅផ្នែកបន្ទាប់ អ៊ឹម ចែម

---

២ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01029496 ឆ.៥០, KH ឆ.៥២។ **ឯកសារ D118/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កន ចឹក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ KH ERN 00882709-00882710 ឆ.១៥-ឆ.១៧។ សម្រាប់ការចាប់ខ្លួន និងការសម្លាប់មន្ត្រីយោធា *សូមមើល* **ឯកសារ D219/263** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំ លុយ ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៥ KH ERN 01086091-01086093 ឆ.១-ឆ.២៤។ **ឯកសារ D219/172** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូច ប៊ុនធី ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH ERN 01065960 ឆ.៣, KH ERN 01065967 ឆ.២៥-ឆ.២៦។ **ឯកសារ D219/20** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈុំ វ៉ាន់នី ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01029504 ឆ.១១៥-ឆ.១២២។ **ឯកសារ D119/73** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ជួង ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00971121 ឆ.១៦-ឆ.១៧។ **ឯកសារ D119/124** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN00987270 ឆ.២៩-ឆ.៣២។

[297] **ឯកសារ D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01095238 ឆ.១២-ឆ.១៤។ **ឯកសារ D118/86** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ឹក លី ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៣ KH ERN 00945417-00945418 ឆ.៤, KH ERN00945419 ឆ.១៣, KH ERN00945420-00945421 ឆ.១៨-ឆ.២១។ **ឯកសារ D118/150** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN00967997 ឆ.១៦-ឆ.១៩, KH ERN 00968000 ឆ.៣៥, ឆ.៣៧។ **ឯកសារ D118/136** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ KH ERN00960663-00960664 ឆ.៧។ **ឯកសារ D123/1/5.1a** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ KH ERN 00929739។

[298] **ឯកសារ D118/250** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត វើក ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00992412 ឆ.១៦, KH ERN 00992419 ឆ.៦៨-ឆ.៧០, KH ERN 00992421 ឆ.៨៨។ **ឯកសារ D118/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទាត់ ធឿន ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00947578 ឆ.១៥, KH ERN 00947580 ឆ.២៨។ **ឯកសារ D119/124** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00987269 ឆ.២២, KH ERN 00987271 ឆ.៣៦។ **ឯកសារ D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01115774



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

បានផ្លាស់ទៅតំបន់ ៥ នៃភូមិភាគពាយ័ព្យនៅពាក់កណ្ដាលឆ្នាំ ១៩៧៧ និងជំនួសអតីតកម្មាភិបាលពាយ័ព្យ ទាំងនៅថ្នាក់ស្រុក និងតំបន់។

១៥៥. សាក្សីលើកឡើងថា តាម៉ុក បានជ្រើសរើសមនុស្សស្និទ្ធរបស់គាត់ឱ្យដឹកនាំកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ[299]។ មានភ័ស្តុតាងដែលស្របទៅនឹងចម្លើយរបស់ **អ៊ឹម ចែម** ដែលថា **អ៊ឹម ចែម** គឺជាជំនួយការដែល តាម៉ុក មានភាពជិតស្និទ្ធ និងទុកចិត្ត[300] ហើយថា អ្នកទាំងពីរបានប្រាស្រ័យទាក់ទងការងារគ្នាដោយផ្ទាល់[301]។ មេធាវីការពារក្ដីជំទាស់ថា **អ៊ឹម ចែម** ពុំមានទំនាក់ទំនងពិសេសជាមួយ តាម៉ុក ទេ[302]។ ពួកគេសំអាងទៅលើចម្លើយរបស់សាក្សី ហែម មាន ដែលថា ការទាក់ទងរវាងថ្នាក់ស្រុក និងភូមិភាគ ពុំអាចធ្វើទៅបានទេ ហើយថា ការទាក់ទងរបស់ **អ៊ឹម ចែម** ត្រូវឆ្លងកាត់ តាចាយ ជាកម្មាភិបាលថ្នាក់

---

ឆ.១៨, KH ERN 01115776-01115777 ឆ.៣៩, ឆ.៤៤-ឆ.៤៥។ **ឯកសារ D219/475** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អិត ហល់ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ KH ERN01134129 ឆ.៩-ឆ.១០។ **ឯកសារ D119/42** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គ្រិត រិត ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 00915872-00915873 ឆ.១០-ឆ.១៤។

[299] **ឯកសារ D119/68** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភី ភួន ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969023 ឆ.១០។ **ឯកសារ D119/124** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម អេន ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00987269 ឆ.២៣។

[300] **ឯកសារ D119/124** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម អេន ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00987269 ឆ.២២, KH ERN 00987271 ឆ.៣៥, KH ERN00987272 ឆ.៣៨។ **ឯកសារ D219/294** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មួល អេង ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01095245 ឆ.៦៣-ឆ.៦៥។ **ឯកសារ D123/1/5.1b** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH ERN 00929834។

[301] **ឯកសារ D119/123** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហែម មាន ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00987260 ឆ.២០។ **ឯកសារ D123/1/5.1a** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ KH ERN 00929739-00929740។

[302] **ឯកសារ D304/6** *ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៦៨-៧៤។



* សហចៅក្រមស៊ើបអង្កេត * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

តំបន់ មុនពេលទៅដល់ តាម៉ុក[303]។ ទោះជាយ៉ាងណាក្តី ហែម មាន ដែលជានិរសាររបស់តាចាយ នៅពេលនោះ បានបន្ថែមថា ទោះបីពីដំបូង ការផ្ញើសំបុត្ររវាង តាម៉ុក និង **អ៊ឹម ចែម** មិនត្រូវបានធ្វើឡើងដោយផ្ទាល់ក៏ដោយ តែ "*ក្រោយមក*" គាត់បានផ្ញើសំបុត្រពី តាម៉ុក ទៅឱ្យ **អ៊ឹម ចែម** ដោយផ្ទាល់[304]។ មេធាវីការពារក្តីក៏ជំទាស់ផងដែរថា ចម្លើយរបស់ **អ៊ឹម ចែម** ស្តីពីលក្ខណៈនៃទំនាក់ទំនងរបស់គាត់ជាមួយ តាម៉ុក មានតម្លៃជាភ័ស្តុតាងតិចតួច ដោយសារគាត់បានផ្តល់ចម្លើយដោយពុំបានធ្វើសម្បថទេ[305]។ យើងបានលើកឡើងជាក់លាក់ខាងលើរួចហើយក្នុងផ្នែកភ័ស្តុតាងនៃដីកាដំណោះស្រាយ (សំអាងហេតុ) នេះ អំពីការយល់ឃើញរបស់យើងទៅលើតម្លៃជាភ័ស្តុតាងនៃកិច្ចសម្ភាសន៍របស់ **អ៊ឹម ចែម**។ ក្នុងករណីនេះ យើងយល់ឃើញថា ចម្លើយទាំងនោះត្រូវបានគាំទ្រដោយភ័ស្តុតាងដែលថា **អ៊ឹម ចែម** ត្រូវបានជ្រើសរើសឱ្យដឹកនាំ កម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យលើកទីពីរ នៅក្នុងប្រតិបត្តិការមួយដែល តាម៉ុក បានបង្កើតឡើង និងគ្រប់គ្រង ហើយគាំទ្រដោយចម្លើយរបស់សាក្សីនានាដែលត្រូវបានយកមកពិចារណានៅក្នុងកថាខណ្ឌនេះ។ ហេតុនេះ យើងសន្និដ្ឋានថា ភ័ស្តុតាងដែលថា **អ៊ឹម ចែម** មានទំនាក់ទំនងជិតស្និទ្ធជាមួយ តាម៉ុក ហើយ តាម៉ុក ទុកចិត្តគាត់ អាចឱ្យជឿជាក់បាន។ ទោះជាយ៉ាងណាក្តី យើងយល់ថា ទំនាក់ទំនងជិតស្និទ្ធនេះពុំមានសារៈសំខាន់ជាពិសេសក្នុងការវាយតម្លៃអំពីសិទ្ធិអំណាច និងកម្រិតនៃការទទួលខុសត្រូវរបស់ **អ៊ឹម ចែម** ទាក់ទិននឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទៅលើគាត់ទេ។ កម្រិតនៃសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** និងការប្រព្រឹត្តិដែលពាក់ព័ន្ធរបស់គាត់ នឹងយកមកពិចារណានៅក្នុងផ្នែកបន្ទាប់។

---

303 **ឯកសារ D304/6** *ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧០។

304 **ឯកសារ D119/123** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មាន ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00987260 ឆ.១៨-ឆ.២០។

305 **ឯកសារ D304/6** *ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ៧២។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

## ឃ. តួនាទី និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម នៅភូមិភាគពាយ័ព្យ

### i. ការបញ្ជូន អ៊ឹម ចែម ទៅភូមិភាគពាយ័ព្យ

១៥៦. នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ ទំនងជាក្នុងខែ មីនា ដូចដែលនឹងពិភាក្សានៅផ្នែកបន្ទាប់ តាម៉ុក បានបញ្ជូន ៥០០ ទៅ ៦០០ គ្រួសារ តាមរថភ្លើងពីតាកែវ ក្នុងភូមិភាគនិរតី ទៅកាន់ភូមិភាគពាយ័ព្យ។ **អ៊ឹម ចែម** ជាអ្នកដឹកនាំក្រុមក្នុងការបញ្ជូននាពេលនោះ[306]។ ក្រុមនេះមានទាហានចំនួនពី ៣០០ ទៅ ៥០០ នាក់ដែរ[307] បានឈប់សម្រាកមួយ ឬពីរយប់នៅភ្នំពេញ មុននឹងទៅដល់ភូមិភាគពាយ័ព្យ។ នៅភ្នំពេញ ប៉ុល ពត បានដឹកនាំអង្គប្រជុំដល់ពួកគេ ចំណែក **អ៊ឹម ចែម** អង្គុយនៅកៅអីជួរមុខ[308]។ **អ៊ឹម ចែម** អាចដឹងពីផែនការបញ្ជូនអ្នកភូមិភាគនិរតីទៅភូមិភាគពាយ័ព្យតាំងពីដើមឆ្នាំ ១៩៧៦ ដូចដែលសាក្សីម្នាក់លើកឡើងថា នៅឆ្នាំនោះ **អ៊ឹម ចែម** បានចូលរួមការប្រជុំធំមួយដែលបានធ្វើនៅស្រុកកោះអណ្ដែត

---

[306] **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953023 ឆ.៣០-៣១, KH ERN00953024-00953025 ឆ.៤០-ឆ.៤៤។ **ឯកសារ D106/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ KH ERN00801022-00821023 ឆ.៦-ឆ.១៣។ **ឯកសារ D219/37** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01032104-01032105 ឆ.៣១-ឆ.៣៥។ **ឯកសារ D118/153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង វុន ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00968038 ឆ.៥៣។ **ឯកសារ D119/30** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895167 ឆ.5។ **ឯកសារ D123/1/5.1b** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH ERN00929775។ **ឯកសារ D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០១២ KH ERN 00929879-00929880។

[307] **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953023 ឆ.៣០-២១, KH ERN00953024-00953025 ឆ.៤០-ឆ.៤៤។ **ឯកសារ D1.3.12.1** កិច្ចសម្ភាសន៍របស់ផលិតកម្មស្នាយលីងថូតជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH ERN00234194។

[308] **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953025 ឆ.៤៧-ឆ.៥០។ **ឯកសារ D219/37** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01032105 ឆ.៣៣។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

តំបន់ ១៣ នៃភូមិភាគនិរតី ដែលមានការពិភាក្សាពីផែនការនោះ ទោះបីជាលក្ខណៈទូទៅក៏ដោយ[309]។

១៥៧. សាក្សី ពេជ្រ ជឹម ដែលជាអនុលេខាស្រុកត្រាំកក់ ក្នុងភូមិភាគនិរតី បានទទួលដំណឹងថា មានពួកក្បត់នៅភូមិភាគពាយ័ព្យ[310] ហើយថា តាម៉ុក បានបញ្ជូន **អ៊ឹម ចែម** ទៅដោះស្រាយ "*ការបះបោរ*"[311]។

ii. <u>លេខាស្រុកព្រះនេត្រព្រះ</u>

១៥៨. នៅពេលគាត់ផ្លាស់ទៅដល់ **អ៊ឹម ចែម** ត្រូវបានតែងតាំងជាលេខាស្រុកព្រះនេត្រព្រះ ក្នុងតំបន់ ៥ នៃភូមិភាគពាយ័ព្យ។ សាក្សីលើកឡើងថា គាត់បានផ្លាស់ទៅនៅឆ្នាំ ១៩៧៧ ចំណែកសាក្សីខ្លះបានលើកឡើងថា ពេលនេះគឺក្នុងរដូវក្តៅ មុនចូលឆ្នាំខ្មែរ ឬកាន់តែច្បាស់ទៅទៀតគឺនៅខែ មីនា ឆ្នាំ ១៩៧៧[312]។ សាក្សី ទុំ សឿន ដែលបានធ្វើដំណើរជាមួយ **អ៊ឹម**

---

[309] **ឯកសារ D119/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00979404-00979405 ឆ.៤៦-ឆ.៥០។

[310] **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN00997027 ឆ.៣២, KH ERN00997030 ឆ.៥៤។

[311] **ឯកសារ D118/259** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00997041 ឆ.១៣៨-ឆ.១៣៩។

[312] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953023 ឆ.៣១, KH ERN00953024-00953025 ឆ.៤០-ឆ.៤៤, KH ERN 00953027 ឆ.៦២។ **ឯកសារ D219/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្ណែត ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH ERN 01066318 ឆ.១៦។ **ឯកសារ D119/21** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ឡេង ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894508 ឆ.១១។ **ឯកសារ D119/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស្វ៊ីយ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ KH ERN00894518 ឆ.១៩។ **ឯកសារ D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895167 ឆ.៤-ឆ.៦។ **ឯកសារ D119/32** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ KH ERN 00907516 ឆ.៣៣-ឆ.៣៤។ **ឯកសារ D101/1.1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្ណែត ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ KH ERN 00743545។ **ឯកសារ D43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នៀម ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ KH ERN 00722205។ **ឯកសារ D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933103 ឆ.១៦។ **ឯកសារ**



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ចែម ចេញពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ បានអះអាងថា គាត់ទៅដល់ទីនោះ ប្រហែលក្នុងខែ មីនា ឆ្នាំ ១៩៧៧។[313] កាលបរិច្ឆេទនេះក៏ស្របទៅនឹងភស្តុតាងស្តីពីការចាប់ខ្លួន និងការជំនួស តាម៉ោង ដែលកាន់តំណែងមុន អ៊ឹម ចែម ជាកម្មាភិបាលភូមិភាគពាយ័ព្យ ដែលជាលេខាស្រុកព្រះនេត្រព្រះ រហូតដល់ដើម ឬពាក់កណ្តាលឆ្នាំ ១៩៧៧[314] និងបានធ្វើការជាមួយ អ៊ឹម ចែម មួយរយៈមុនពេលចាប់ខ្លួន[315]។ នៅពេល អ៊ឹម ចែម និង កម្មាភិបាលភូមិភាគនិរតីផ្សេងទៀតទៅដល់ តាម៉ោង ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១។ សាក្សីបានកំណត់ពីពេលវេលានៃការចាប់ខ្លួនប្រហែលពាក់

---

**D119/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈួក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933133 ទ.២៨-ទ.២៩។ **ឯកសារ D119/139** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN01003887 ទ.៦១។ **ឯកសារ D219/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន សេរិន ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01025644 ទ.៣៤។

[313] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953023 ទ.៣១, KH ERN00953024-00953025 ទ.៤០-ទ.៤៤, KH ERN 00953027 ទ.៦២។

[314] **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឹម សឹត ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ KH ERN 00800997 ទ.៣៤។ **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978920 ទ.១៦។ **ឯកសារ D119/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស៊្វយ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894518 ទ.១៤។ **ឯកសារ D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895167 ទ.៤-ទ.៥។ **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976081 ទ.៤២។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡឹន ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978909 ទ.១១។ **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978920 ទ.១៦។ **ឯកសារ D119/139** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 01003882, 01003887, ទ.៣៨, ទ.៥៨។ **ឯកសារ D119/154** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ាភ៌ ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024747 ទ.៣១។ **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ើយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969014 ទ.៤។

[315] **ឯកសារ D119/145** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធិប គឹមលន់ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01022034 ទ.៧៥។



* ECCC * CETC * CO-INVESTIGATING JUDGES *CO-JUGES D' INSTRUCTION*

កណ្តាលឆ្នាំ ១៩៧៧ ហើយចម្លើយសារភាពរបស់ តាម៉ោង នៅមន្ទីរ ស-២១ បញ្ជាក់ថា ការចាប់ខ្លួនត្រូវបានធ្វើឡើងមុនថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៧៧[316]។

១៥៩. នៅភូមិភាគពាយ័ព្យ អ៊ឹម ចែម បានទៅរស់នៅ និងធ្វើការនៅភូមិភ្នំលៀប ក្នុងស្រុកព្រះនេត្រព្រះ[317]។

១៦០. គាត់បានកាន់តំណែងជាលេខាស្រុកព្រះនេត្រព្រះរហូតដល់ពេលកងទ័ពវៀតណាមចូលទៅដល់នៅខែ មករា ឆ្នាំ ១៩៧៩[318]។

iii. <u>តួនាទីជាសមាជិកគណៈតំបន់ ៥</u>

១៦១. ភស្តុតាងពីសាក្សីមួយចំនួនក៏លើកឡើងផងដែរថា អ៊ឹម ចែម មានតួនាទីមួយនៅក្នុងគណៈតំបន់ ៥ បន្ថែមទៅលើតួនាទីជាលេខាស្រុកព្រះនេត្រព្រះ។

---

[316] **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978909 ឆ.៩, ឆ.១១។ **ឯកសារ D219/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01029674 ឆ.៦៩។ **ឯកសារ D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933103 ឆ.១៥-ឆ.១៦។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឺត ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ KH ERN 00800997 ឆ.៣៩។ **ឯកសារ D1.3.4.1** ចម្លើយសារភាពរបស់ អន ម៉ោង នៅមន្ទីរ ស-២១ KH ERN 00204263។ *សូមមើលផងដែរ* **ឯកសារ D101/1.1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ KH ERN 00743545។

[317] **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហឿយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969016 ឆ.១២។ **ឯកសារ D119/73** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ដួង ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00971122 ឆ.២៥។ **ឯកសារ D219/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01043243 ឆ.៥៩។ **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049233 ឆ.៦៥។ **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980388 ឆ.៤៤។

[318] **ឯកសារ D119/74** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាថ់ គិត ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤ KH ERN 00971129 ឆ.២។ **ឯកសារ D119/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈួក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933133 ឆ.២៨-ឆ.២៩។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

១៦២. មុនពេល អ៊ឹម ចែម និងកម្មាភិបាលភូមិភាគនិរតីទៅដល់ភូមិភាគពាយ័ព្យនៅខែ មីនា ឆ្នាំ ១៩៧៧ តាហ៊ឹង (ឬ តាហ៊ីង) តាជាល (ឬ តាជៀល) តាវ៉ាល់ និងអាចថា តាវុធ គឺជាសមាជិកគណៈតំបន់ ៥[319]។ តាហ៊ឹង ត្រូវបានចាប់ខ្លួនមុនគេ ហើយបើតាមការលើកឡើងរបស់សាក្សីម្នាក់ ការចាប់ខ្លួននេះត្រូវបានធ្វើឡើងក្រោយ អ៊ឹម ចែម និង តាម៉ុក ទៅដល់ភូមិភាគពាយ័ព្យ[320]។ ក្រោយពេលចាប់ខ្លួន តាហ៊ឹង តាជាល ត្រូវបានតែងតាំងជា *"មនុស្សទទួលបន្ទុកបណ្ដោះអាសន្ន"* មុនពេលកម្មាភិបាលម្នាក់ទៀតឈ្មោះ តារិន កាន់តំណែងជំនួស តាហ៊ឹង[321]។ តាជាល ហៅ ឆ្នាំង[322] គឺជាកម្មាភិបាលភូមិភាគពាយ័ព្យ និងជាកូនប្រុសរបស់ មូល សម្បត្តិ ហៅ រស់ ញឹម[323] ដែលជាលេខាគណៈភូមិភាគ

---

[319] **ឯកសារ D119/66** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន ហឿយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969014 ឆ.៤។ **ឯកសារ D6.1.364** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿន សែម ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២00៩ KH ERN00316510-00316511។ **ឯកសារ D6.1.425** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គន់ ថាន ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២00៨ KH ERN 00267781។ **ឯកសារ D119/30** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី KH ERN 00895173 ឆ.៣៧។

[320] **ឯកសារ D119/136** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាន ឈួង ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 01003847 ឆ.៤៨។ **ឯកសារ D119/66** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន ហឿយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969015 ឆ.៩។

[321] **ឯកសារ D219/494.1.8** ប្រតិចារឹកនៃការជំនុំជម្រះលើអង្គសេចក្ដីក្នុងសំណុំរឿង 00២/0២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ KH ERN 01132168-011321169។ សូមមើលផងដែរ **ឯកសារ D6.1.450** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សោម ជាន់ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២00៩ KH ERN 00279105។ **ឯកសារ D6.1.431** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជៀប ឈាន ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២00៨ KH ERN 00267746។

[322] **ឯកសារ D118/102** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទាត់ ជឿន ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00947589 ឆ.៦៣, KH ERN 00947590 ឆ.៧៤។

[323] **ឯកសារ D118/102** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទាត់ ជឿន ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00947589 ឆ.៦៣, KH ERN 00947590 ឆ.៧៤។ **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953027 ឆ.៦៣។ **ឯកសារ D119/139** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុន មុត ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 01003882 ឆ.៣៧។ **ឯកសារ D219/35** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សោម សីលា ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01032082ឆ.២៨។ **ឯកសារ D123/1/5.1c** បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ KH ERN 00929892។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

ពាយ័ព្យ[324] និងជាកូនប្រសាររបស់ សោ ភឹម ជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ទៀតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា[325]។ បើតាមសាក្សី ទុំ សឿន តាជាល ជាអ្នកចាត់តាំង អ៊ឹម ចែម ធ្វើជាលេខាស្រុកព្រះនេត្រព្រះនៅពេលគាត់ទៅដល់ភូមិភាគពាយ័ព្យ[326]។

១៦៣. ទោះជាយ៉ាងណាក្តី តាជាល ត្រូវបានចាប់ខ្លួនដោយគេចោទថាជាជនក្បត់ និងត្រូវបានបញ្ជូនទៅសម្លាប់នៅភ្នំពេញ ទំនងជានៅដើម ឬពាក់កណ្តាលឆ្នាំ ១៩៧៨ ដោយមានការរាយការណ៍ថា គាត់ត្រូវបានចាប់ខ្លួនជាមួយឪពុករបស់គាត់គឺ តាញឹម[327]។ បន្ទាប់ពី

---

[324] **ឯកសារ D6.1.364** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន សែម ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩ KH ERN 00316510-00316511។ **ឯកសារ D6.1.358** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ា សាអែម ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩ KH ERN 00295956។ **ឯកសារ D118/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទាត់ ធឿន ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00947610 ឆ.១៨១។ **ឯកសារ D118/150** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00967997 ឆ.១៥។

[325] **ឯកសារ D119/68** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969023 ឆ.១១។ **ឯកសារ D118/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទាត់ ធឿន ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00947589 ឆ.៦៣។ **ឯកសារ D1.3.29.1** កិច្ចសម្ភាសន៍ជាមួយជនសង្ស័យ អៀង សារី ហៅ វ៉ាន់ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ KH ERN 00062454។ **ឯកសារ D6.1.529** ប្រតិចារឹកនៃកិច្ចសម្ភាសន៍រវាង Steve Heder ជាមួយលោក អ៊ុក ប៊ុនឈឿន KH ERN00379489។

[326] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953027 ឆ.៦៣។

[327] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953032 ឆ.៩៣-៩៥។ **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976178 ឆ.២៦។ **ឯកសារ D119/156** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធឹង ជឿន ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024775 ឆ.២៩។ **ឯកសារ D6.1.450** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ KH ERN 00279105(ចុងឆ្នាំ ១៩៧៧)។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978909 ឆ.៩ (ពាក់កណ្តាលឆ្នាំ ១៩៧៨)។ **ឯកសារ D119/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00979413-00979414 ឆ.៩០-ឆ.៩៤ (ឆ្នាំ ១៩៧៨)។ **ឯកសារ D118/150** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00967997-00967998 ឆ.១៧-ឆ.២១ (ខែ កក្កដា ឬ ខែ សីហា ឆ្នាំ ១៩៧៨)។ **ឯកសារ D219/494.1.8** ប្រតិចារឹកនៃការជំនុំជម្រះលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ KH ERN 01132169។

ចាប់ខ្លួន តាជាល តារិន ដែលជាកម្មាភិបាលភូមិភាគនិរតីត្រូវបានចាត់តាំងជាលេខាតំបន់ ៥[328]។ តារិន ក៏ត្រូវបានផ្លាស់ចេញដែរ ក្រោយពេល តាចាយ ក្លាយជាប្រធានគណៈតំបន់ ៥ ចំណែក **អ៊ឹម ចែម** បានក្លាយជាអនុលេខា[329]។ ក្នុងឋានៈជាអនុលេខាតំបន់ ៥ **អ៊ឹម ចែម** បន្តគ្រប់គ្រងស្រុកព្រះនេត្រព្រះ[330]។

១៦៤. សាក្សីជាច្រើនផ្តល់ភ័ស្តុតាងពីតួនាទីរបស់ **អ៊ឹម ចែម** នៅក្នុងគណៈតំបន់ ៥[331] ថាបានបន្តរហូតដល់ពេលកងទ័ពវៀតណាមចូលមកដល់នៅដើមឆ្នាំ ១៩៧៩[332]។ សាក្សីម្នាក់លើក

---

[328] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953050 ឆ.២២៤។ **ឯកសារ D119/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895161ឆ.១៣។ **ឯកសារ D119/156** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024775 ឆ.២៩។ **ឯកសារ D85/5.1.4.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តូត ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ KH ERN 00808780ឆ.១២។

[329] **ឯកសារ D219/37** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01032101 ឆ.៨, KH ERN 01032106-01032107 ឆ.៤៩-ឆ.៥០។ **ឯកសារ D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01095241 ឆ.៤១, KH ERN 01095242 ឆ.៤៤-ឆ.៤៥។ **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969016 ឆ.១១។ **ឯកសារ D118/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ីម ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN00947260ឆ.៧-ឆ.៨, KH ERN 00947262ឆ.១៩។

[330] **ឯកសារ D118/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ីម ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00947260 ឆ.៧-ឆ.៨, KH ERN 00947262 ឆ.១៩។

[331] **ឯកសារ D219/575** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក សួង ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៥ KH ERN 01166357-01166358 ឆ.១៦-ឆ.១៩។ **ឯកសារ D119/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894503ឆ.១៦។ **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969015-00969016 ឆ.៩, ឆ.១១។ **ឯកសារ D118/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជឹម ចាន់ធឿន ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 00920186ឆ.២៩។ **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978921 ឆ.២២។ **ឯកសារ D119/69** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រូច ទឹម ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ KH ERN 00969037 ឆ.៨៧, KH ERN 00969038 ឆ.៩០។ **ឯកសារ D119/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00969028 ឆ.១៦។ **ឯកសារ D67.9** ឧបសម្ព័ន្ធ ៩៖ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ "កិច្ចសម្ភាសន៍ជាមួយ ឈិត យឿក" ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១១ 00728826។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឡើងថា អ៊ឹម ចែម ខ្លួនឯងជាអ្នកប្រាប់គាត់ថា គាត់ជា "*គណៈ*" តំបន់ ៥ ថ្មី ហើយថា គាត់ជំនួស តាហ៊ីង ដែលជាជនក្បត់[333]។ សាក្សីផ្សេងទៀតជឿថា គាត់ជាកម្មាភិបាលថ្នាក់តំបន់ទទួលខុសត្រូវផ្នែកឃោសា[334]។

១៦៥. សាក្សីម្នាក់លើកឡើងថា ទោះបីមានភាពមិនច្បាស់លាស់ក្នុងចំណោមប្រជាជនអំពីចំណុចថា តើ អ៊ឹម ចែម ជាកម្មាភិបាលថ្នាក់ស្រុក ឬថ្នាក់តំបន់ក៏ដោយ តែគាត់បានដឹងថា អ៊ឹម ចែម មានតួនាទីនៅថ្នាក់ស្រុកដែរ ទោះបីគាត់បន្ថែមដោយមានភាពពុំស៊ីសង្វាក់ថា អ៊ឹម ចែម បានគ្រប់គ្រង "តំបន់ ៥"[335] ក៏ដោយ។ ទោះយ៉ាងណាក៏ដោយ ភ័ស្តុតាងដែលថា អ៊ឹម ចែម មានតួនាទីជាសមាជិកគណៈតំបន់ ៥ មានចំនួនច្រើនជាង និងមានគុណភាពអាចឲ្យជឿជាក់បានច្រើនជាង។ ភ័ស្តុតាងនេះក៏ត្រូវបានគាំទ្រដោយប្រយោលដោយកាលៈទេសៈជាច្រើនដែលបង្ហាញពីកម្រិតនៃសិទ្ធិអំណាចរបស់គាត់ដែលខ្ពស់ជាងលេខាស្រុក និងគ្របដណ្តប់ហួសពីស្រុកព្រះនេត្រព្រះទៅទៀត៖

---

[332] **ឯកសារ D119/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈួក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933133 ឆ.២៩។ **ឯកសារ D119/74** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាច់ គិត ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤ KH ERN 00971129 ឆ.២។ **ឯកសារ D119/154** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024747 ឆ.៣១។

[333] **ឯកសារ D119/91** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976148-00976149 ឆ.១៥។ សូមមើលផងដែរ **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ឹយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969015 ឆ.៩។

[334] **ឯកសារ D119/67** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណេត ឈួង ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969009 ឆ.៩-ឆ.១១។ **ឯកសារ D119/131** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00996495 ឆ.៣៤, KH ERN 00996499 ឆ.៥៤, ឆ.៥៦, ឆ.៦០, KH ERN 00996506-00996507 ឆ.១២១-១២៤។ **ឯកសារ D119/90** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន ភាព ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976141ឆ.១៣។

[335] **ឯកសារ D61** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ KH ERN 00727222។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ក. គេឃើញ **អ៊ឹម ចែម** ចូលរួមប្រជុំជាមួយកម្មាភិបាលថ្នាក់តំបន់ និងថ្នាក់ភូមិភាគ[336]។

ខ. **អ៊ឹម ចែម** បានទទួលការណែនាំពីគម្រោងសាងសង់ប្រព័ន្ធចែកចាយទឹកដោយផ្ទាល់ពី តាម៉ុក ក្រោយពេលគាត់គ្រប់គ្រងភូមិភាគពាយ័ព្យ។ ហេតុនេះ យ៉ាងហោចណាស់ក្នុងករណីមួយចំនួន ពុំមានអន្តរការីរវាង តាម៉ុក (លេខាភូមិភាគ) និង **អ៊ឹម ចែម** ទេ[337]។

គ. ការធ្វើដំណើររបស់ **អ៊ឹម ចែម** មិនមែនមានតែនៅស្រុកព្រះនេត្រព្រះទេ តែគាត់បានធ្វើដំណើរទៅភ្នំស្រុក និងស្រុកផ្សេងទៀតក្នុងតំបន់ ៥ ដែលនៅទីនោះ គាត់បានទៅពិនិត្យការដ្ឋានក្នុងតួនាទីជាអ្នកគ្រប់គ្រង[338]។

ឃ. សាក្សីម្នាក់លើកឡើងថា ស្រុកព្រះនេត្រព្រះពុំមានយន្តជំនិះផ្ទាល់ខ្លួនទេ មានតែថ្នាក់តំបន់ទេដែលមាន ហើយគាត់បានឃើញ **អ៊ឹម ចែម** ធ្វើដំណើរតាមរថយន្តជាមួយកម្មាភិបាលថ្នាក់តំបន់ និងថ្នាក់ភូមិភាគ[339]។

ង. ក្រៅពីស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** បានធ្វើការ និងមានមន្ទីរនៅស្រុកស្វាយស៊ីសុផុន និងស្រុកភ្នំស្រុក[340]។

---

[336] **ឯកសារ D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ KH ERN 01166969-01166970, ឆ.៩៥, ឆ.៩៧-ឆ.៩៩, KH ERN 01166972, ឆ.១១១, ឆ.១១២។ **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980391 ឆ.៦១។

[337] សូមមើលខាងលើ ផ្នែកស្តីអំពីការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតីទៅលើភូមិភាគពាយ័ព្យ។

[338] **ឯកសារ D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01114726 ឆ.២។ **ឯកសារ D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976156ឆ.២១។ **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន KH ERN 00976166 ឆ.១៨។

[339] **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980395 ឆ.៨៥-ឆ.៨៦។

ច. **អ៊ឹម ចែម** មានសិទ្ធិអំណាចទៅលើ ទុំ សឿន នៅពេលសាក្សីជាមេកងចល័តតំបន់ ៥[341]។

ឆ. ទាក់ទិននឹងស្រុកភ្នំស្រុក សាក្សីម្នាក់លើកឡើងថា ទោះបី ញ៉ៀន ដែលជាប្តី **អ៊ឹម ចែម** ជាអ្នកគ្រប់គ្រងស្រុកនេះក៏ដោយ តែ **អ៊ឹម ចែម** បានអនុវត្តសិទ្ធិអំណាចនៅទីនោះ។ សាក្សីបានបន្ថែមថា គាត់ជាមនុស្សមានអំណាចណាស់ និងគ្រប់គ្រងផ្នែកយោធា ទោះបីសាក្សីពុំបានលើកឡើងច្បាស់ថាជាយោធាស្រុក ឬតំបន់ក៏ដោយ[342]។ អតីតលេខាស្រុកបវេល (ដែលពីដំបូងស្ថិតនៅក្នុងតំបន់ ៥ តែក្រោយមកស្ថិតក្នុងតំបន់ ៣ វិញ) ដែលបានចូលរួមការប្រជុំមួយជាមួយ តាម៉ុក **អ៊ឹម ចែម** និង កម្មាភិបាលផ្សេងទៀត លើកឡើងថា **អ៊ឹម ចែម** ទទួលខុសត្រូវស្រុកភ្នំស្រុក ហើយថា សាក្សីមិនអាចនៅចាំថា គាត់មានតំណែងអ្វីផ្សេងទៀតទេ[343]។

ជ. **អ៊ឹម ចែម** ធ្លាប់បានបើកការប្រជុំមួយនៅទំនប់អូរលៀប ដែលមានការចូលរួមពីតំណាងថ្នាក់ស្រុកទាំងអស់ក្នុងតំបន់ ៥[344]។

---

340 **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969016 ឆ.១៣។ **ឯកសារ D219/37** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01032107 ឆ.៥២។

341 **ឯកសារ D219/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043197 ឆ.២៦-ឆ.២៩។ សូមមើលផងដែរ ផ្នែកខាងក្រោមស្តីពីការដ្ឋានប្រឡាយស្ពានស្រែង។

342 **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN01049233-01049234 ឆ.៦៥, ឆ.៧៥-ឆ.៧៧។ *សូមមើលផងដែរ* **ឯកសារ D219/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01043244 ឆ.៦៦។

343 **ឯកសារ D219/294** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01095241ឆ.៤១, KH ERN01095234-01095244 ឆ.៥៤-៥៩។

344 **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976166 ឆ.១៩។

ឈ. អ្នកធ្វើការនៅទំនប់ត្រពាំងថ្ម ស្រុកភ្នំស្រុក ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**[345] មកពីស្រុកបីផ្សេងគ្នារួមមាន ព្រះនេត្រព្រះ ស្វាយស៊ីសុផុន និងភ្នំស្រុក[346]។

១៦៦. ទាក់ទិននឹងការលើកឡើងខាងលើ យើងយល់ថា ក្រោយពេលគាត់ទៅដល់ភូមិភាគពាយ័ព្យ នៅខែ មីនា ឆ្នាំ ១៩៧៧ **អ៊ឹម ចែម** ត្រូវបានចាត់តាំងជាលេខាស្រុកព្រះនេត្រព្រះ។ នៅដើម ឬពាក់កណ្តាលឆ្នាំ ១៩៧៨ គាត់ក៏បានក្លាយជាសមាជិកគណៈតំបន់ ៥ ជាតំណែងដែលគាត់កាន់រហូតដល់ពេលកងទ័ពវៀតណាមចូលទៅដល់នៅខែ មករា ឆ្នាំ ១៩៧៩។

iv. <u>ការទទួលខុសត្រូវ សិទ្ធិអំណាច និងប្រភពនៃការទទួលបានព័ត៌មានរបស់ អ៊ឹម ចែម នៅតំបន់ ៥ នៃភូមិភាគពាយ័ព្យ</u>

*អំណាចតាមផ្លូវច្បាប់របស់តំបន់ និងស្រុក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

១៦៧. ក្របខណ្ឌរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានកំណត់ក្នុងលក្ខន្តិកៈ ប.ក.ក ដែលបញ្ជាក់អំពីតួនាទី អំណាច និងបុព្វសិទ្ធិរបស់ស្ថាប័ននយោបាយ និងថ្នាក់រដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ[347]។ ដើម្បីបង្ហាញពីការទទួលខុសត្រូវដែល **អ៊ឹម ចែម** មាននៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនឹងការចោទប្រកាន់មកលើគាត់ និងកម្រិតនៃសិទ្ធិអំណាចដែលគាត់មាន ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវទាំងនេះ ជាដំបូង យើងបានពិនិត្យមើលអំណាច និងបុព្វសិទ្ធិរបស់ថ្នាក់តំបន់ និងថ្នាក់ស្រុកដែលមានចែងក្នុងលក្ខន្តិកៈ ប.ក.ក និងបន្ទាប់មកពិនិត្យមើលភស្តុតាងអំពីអំណាចដែល **អ៊ឹម ចែម** បានអនុវត្តជាក់ស្តែងនៅមូលដ្ឋាន។

---

[345] សូមមើលផ្នែក ស្តីពីការដ្ឋានទំនប់ត្រពាំងថ្ម។

[346] ឯកសារ **D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049237 ដ.១០៩។

[347] ឯកសារ **D1.3.20.1** ឯកសារច្បាប់របស់ ប.ក.ក មានចំណងជើងថា "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ខែ មករា ឆ្នាំ ១៩៧៦។



១០០ E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១៦៨. លក្ខន្តិកៈ ប.ក.ក ផ្ដល់ឱ្យគណៈតំបន់នូវការទទួលខុសត្រូវក្នុងការអនុវត្តផែនការនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ដែលថ្នាក់ភូមិភាគបានកំណត់ ស្របទៅនឹងគោលការណ៍ដែលគ្រប់គ្រងបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក។ គណៈតំបន់ក៏ទទួលខុសត្រូវផងដែរក្នុងការណែនាំ "*ឱ្យជាប់ និងឱ្យណែនជានិច្ច*" ខាងនយោបាយ សតិអារម្មណ៍របស់ថ្នាក់ក្រោម និងប្រជាជន ស្របទៅនឹងមនោគមវិជ្ជានយោបាយរបស់ ប.ក.ក។ ចុងក្រោយ ពួកគេទទួលខុសត្រូវក្នុងការរៀបចំទ្រព្យសម្បត្តិរបស់តំបន់ គ្រប់គ្រងវិន័យ និងរាយការណ៍ជូនថ្នាក់លើស្ដីពីសភាពការណ៍ក្នុងតំបន់[348]។ ថ្នាក់តំបន់សម្រេចលើផែនការការងារដែលបញ្ជូនមកស្រុក[349]។ ស្រដៀងគ្នាដែរ ថ្នាក់តំបន់ផ្ដល់បញ្ជីឈ្មោះអ្នកដែលត្រូវចាប់ខ្លួនទៅឱ្យថ្នាក់ស្រុក[350]។ សាក្សី មួល អេង ដែលជាអតីតលេខាស្រុកនៅតំបន់ ៣ នៃភូមិភាគពាយ័ព្យ[351] លើកឡើងថា ការចាប់ខ្លួន និងការដោះលែងអ្នកទោសក្នុងស្រុកត្រូវទទួលការអនុញ្ញាតពីថ្នាក់តំបន់។ ប្រសិនបើស្រុកដឹងពីសកម្មភាពខ្មាំងដែលអាចកើតមាន ស្រុកនឹងរាយការណ៍ទៅតំបន់ ហើយតំបន់ណែនាំវិធានការអនុវត្តមកស្រុកវិញ[352]។

១៦៩. ស្រុកគឺជាអង្គភាពរដ្ឋបាលនៅក្រោមថ្នាក់តំបន់។ ដូចតំបន់ដែរ ស្រុកស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការបក្សដែលមានសមាសភាពបីរូបគឺ លេខា អនុលេខា និង

---

[348] **ឯកសារ D1.3.20.1** ឯកសារច្បាប់របស់ ប.ក.ក មានចំណងជើងថា "លក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជា" ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00053030-00053031 មាត្រា ១៦ ។

[349] តួនាទីរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រមទាំងតួនាទីរបស់ថ្នាក់ភូមិភាគ មិនត្រូវបានពិភាក្សានៅផ្នែកនេះទេ ដោយសារវាផ្ដោតតែទៅលើថ្នាក់រដ្ឋបាលដែលពាក់ព័ន្ធ ដើម្បីវាយតម្លៃទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌដែលចោទប្រកាន់ចំពោះ អ៊ឹម ចែម។

[350] **ឯកសារ D219/34** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិល ហឿន ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01032070 ឆ.២៣-ឆ.២៣។

[351] **ឯកសារ D219/294** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មួល អេង ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN01095229 ឆ.៣៦។

[352] **ឯកសារ D219/294** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មួល អេង ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN01095263-01095264 ឆ.១៨៥-ឆ.១៩០។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

សមាជិក[353]។ ស្រុកត្រូវបានបែងចែកជាឃុំ ហើយឃុំបែងចែកជាភូមិ។ ជាធម្មតា ភូមិជាច្រើនរួមបញ្ចូលគ្នាជាអង្គភាពធំៗដែលហៅថា សហករណ៍[354]។

១៧០. លេខាទទួលខុសត្រូវក្នុងការតែងតាំង និងដកតំណែងសមាជិកផ្សេងទៀតក្នុងគណៈកម្មាធិការ ដោយមានការយល់ស្របពីលេខាតំបន់ លេខាភូមិភាគ និងគណៈកម្មាធិការអចិន្ត្រៃយ៍[355]។

១៧១. លក្ខន្តិកៈ ប.ក.ក ផ្ដល់សិទ្ធិអំណាចដល់គណៈស្រុកក្នុងការរៀបចំការងារថ្មីៗ ទៅតាមមាគ៌ារបស់ ប.ក.ក (និង ដូចដែលបង្ហាញខាងលើ ទទួលការណែនាំពីតំបន់)[356]។ ពួកគេក៏មានតួនាទីក្នុងការគ្រប់គ្រងវិន័យនៅថ្នាក់ស្រុក និងរាយការណ៍ពីការងារ និងបញ្ហាផ្សេងៗទៀតនៅថ្នាក់ស្រុកទៅថ្នាក់តំបន់ដែរ[357]។

១៧២. ប.ក.ក ទទួលស្គាល់លេខាស្រុកថាជាថ្នាក់ដឹកនាំសំខាន់ ដោយសារគណៈស្រុកគឺជាស្ពានយ៉ាងសំខាន់រវាងសហករណ៍ និង តំបន់[358]។ នៅក្នុងការចុះផ្សាយមួយរបស់ *ទង់បដិវត្ត*

---

[353] **ឯកសារ D1.3.20.1** ឯកសារច្បាប់របស់ ប.ក.ក មានចំណងជើងថា "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00053025 មាត្រា ៧ កថាខណ្ឌ ៤។ **ឯកសារ D6.1.533** របាយការណ៍អ្នកជំនាញការ Craig C. Etcheson ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ KH ERN00314780 កថាខណ្ឌ៩។

[354] **ឯកសារ D6.1.533** របាយការណ៍អ្នកជំនាញការ Craig C. Etcheson ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ KH ERN 00314780 កថាខណ្ឌ ១០។

[355] **ឯកសារ D1.3.20.1** ឯកសារច្បាប់របស់ ប.ក.ក មានចំណងជើងថា "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00053028 មាត្រា ១២។ **ឯកសារ D6.1.533** របាយការណ៍អ្នកជំនាញការ Craig C. Etcheson ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ KH ERN00314780 កថាខណ្ឌ ៩។

[356] **ឯកសារ D1.3.20.1** ឯកសារច្បាប់របស់ ប.ក.ក មានចំណងជើងថា "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00053028 មាត្រា ១២។

[357] **ឯកសារ D1.3.20.1** ឯកសារច្បាប់របស់ ប.ក.ក មានចំណងជើងថា "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00053028 មាត្រា ១២។

[358] **ឯកសារ D6.1.740** ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា "ទង់បដិវត្ត លេខពិសេស" ខែ តុលា - វិច្ឆិកា ឆ្នាំ ១៩៧៧ KH ERN 00064770។ **ឯកសារ D6.1.533** របាយការណ៍អ្នកជំនាញការ Craig C. Etcheson ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ KH ERN00314810 កថាខណ្ឌ ៧៧។

ដែលជាទស្សនាវដ្ដីដែលបោះពុម្ពផ្សាយដោយ ប.ក.ក សម្រាប់ ខែ ធ្នូ ឆ្នាំ ១៩៧៧ - ខែ មករា ឆ្នាំ ១៩៧៨ ប.ក.ក បានសង្កត់ធ្ងន់អំពីសារៈសំខាន់ក្នុងការតាមដានវត្តមានរបស់ប្រជាជនដែលមានទស្សនៈខុសពីមាគ៌ាបក្សជាផ្លូវការ ដែលត្រូវបានចាត់ទុកថាជា *"ដង្កូវនៅក្នុងសាច់ដែលត្រូវឆ្កឹះចោល"* ។ ប.ក.ក ដាស់តឿនឱ្យស៊ើបអង្កេតស្វែងរកវត្តមាននៃមនុស្សទាំងនោះ ជាពិសេសនៅថ្នាក់ស្រុក និងសហករណ៍ ដោយសារថ្នាក់រដ្ឋបាលទាំងនេះនៅជិតជាមួយអ្នកធ្វើការងារ[359]។

*ភ័ស្តុតាងស្តីពីការអនុវត្តការទទួលខុសត្រូវ និង សិទ្ធិអំណាចរបស់ អ៊ឹម ចែម*

១៧៣. ភ័ស្តុតាងបង្ហាញថា នៅស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** បានអនុវត្តអំណាចតាមផ្លូវច្បាប់ទាំងអស់របស់លេខាស្រុកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ភ័ស្តុតាងនេះបង្ហាញបន្ថែមថា គាត់បានចូលរួមការងារនៅក្រៅស្រុកព្រះនេត្រព្រះ ដែលស្របទៅនឹងការកាន់តំណែងនៅថ្នាក់តំបន់របស់គាត់ បន្ថែមទៅលើតួនាទីនៅថ្នាក់ស្រុកនោះ។ ទោះជាយ៉ាងណាក្តី វិសាលភាព និង ព្រំដែនច្បាស់លាស់នៃសិទ្ធិអំណាចទៅលើបញ្ហានានាពាក់ព័ន្ធនឹងថ្នាក់តំបន់នៅតែមិនមានភាពច្បាស់លាស់។

១៧៤. ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** គ្រប់គ្រងទាំងស្រុងទៅលើស្រុកនេះ រួមទាំងឃុំ និងភូមិទាំងអស់ផង[360]។ សិទ្ធិអំណាចរបស់ **អ៊ឹម ចែម** បានគ្របដណ្ដប់ទៅដល់

---

[359] **ឯកសារ D1.3.22.5** ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា "ទង់បដិវត្ត លេខពិសេស" ខែ ធ្នូ ឆ្នាំ ១៩៧៧ - ខែ មករា ឆ្នាំ ១៩៧៨ KH ERN00064545-00064546។

[360] **ឯកសារ D119/32** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ KH ERN 00907516 ឆ.៣៤។ **ឯកសារ D119/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894502ឆ.១៥។ **ឯកសារ D119/144** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ KH ERN 01009211 ឆ.៥០។ **ឯកសារ D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00985669 ឆ.១៩។ **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049234 ឆ.៧៧។ **ឯកសារ D219/173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស ស្តើង ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH ERN 01065977 ឆ.៣៣។ **ឯកសារ D219/383** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អើយ ញៀ ចុះថ្ងៃទី ២៤ ខែ មីនា



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

មន្ទីរសន្តិសុខ[361] និងការដ្ឋាន[362] នៅក្នុងស្រុក។ គាត់រៀបចំកម្លាំងការងារ[363] តែងតាំងមេឃុំ និងការដ្ឋាន[364] និងបានចេញលិខិតអនុញ្ញាតឲ្យធ្វើការក្នុងស្រុក[365]។ គាត់ក៏បានទៅពិនិត្យការសាងសង់ទំនប់ត្រពាំងថ្មដែលស្ថិតនៅស្រុកភ្នំស្រុក ទោះបីវិសាលភាពនៃការចូលរួមនិងសិទ្ធិអំណាចរបស់គាត់ទៅលើគម្រោងសាងសង់នោះមិនច្បាស់លាស់ក៏ដោយ។

---

ឆ្នាំ ២០១៥ KH ERN 01113227 ឆ.៣៤-ឆ.៣៦។ **ឯកសារ D119/21** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ជៀង ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894508 ឆ.១១-ឆ.១២។

[361] **ឯកសារ D119/22** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ គុយ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894512-00894513 ឆ.៧-ឆ.៩។ **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953042 ឆ.១៧១។ **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN00976184 ឆ.៥៦។ សូមមើលផងដែរ ផ្នែកស្តីពីមន្ទីរសន្តិសុខភ្នំទ្រយោង។

[362] **ឯកសារ D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976159 ឆ.៣១។ **ឯកសារ D119/42** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 00915873 ឆ.១៦។ **ឯកសារ D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01114726 ឆ.៤។ **ឯកសារ D119/90** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន ភាព ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976141ឆ.១២។ **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953035 ឆ.១១១-ឆ.១១២, KH ERN 00953047 ឆ.២០៧។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978912 ឆ.៣២។ ភ័ស្តុតាងស្តីពីការគ្រប់គ្រងរបស់ អ៊ឹម ចែម ទៅលើការដ្ឋានជាក់លាក់គឺនឹងយកមកពិភាក្សានៅខាងក្រោមដែរ ក្នុងផ្នែកស្តីអំពីទីតាំងឧក្រិដ្ឋកម្មជាក់លាក់។

[363] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953030-00953031- ឆ.៨០, , ឆ.៨២, , ឆ.៨៥។

[364] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953033 ឆ.៩៦, KH ERN00953050 ឆ.២២២។ **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980387 ឆ.៤១។ សូមមើលផងដែរ ផ្នែកស្តីអំពីការដ្ឋានប្រឡាយស្ពានស្រែង និងមន្ទីរសន្តិសុខភ្នំទ្រយោង។

[365] **ឯកសារ D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933105 ឆ.២៦-ឆ.៣០។

១៧៥. មានភស្តុតាងជាច្រើនបង្ហាញថា **អ៊ឹម ចែម** មានសិទ្ធិអំណាចបញ្ជាឱ្យចាប់ខ្លួននៅស្រុកព្រះនេត្រព្រះ[366] ហើយកងឈ្លបស្ថិតក្នុងការគ្រប់គ្រងរបស់គាត់ជាអ្នកអនុវត្ត[367]។ មានមន្ទីរសន្តិសុខបណ្តោះអាសន្នមួយនៅជិតផ្ទះគាត់នៅភ្នំលៀប ដែលឃុំឃាំងអ្នកទោសមុនពេលបញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោង[368]។ មានភស្តុតាងដែលអាចជឿជាក់បានផងដែរ រួមទាំងភស្តុតាងពីសាក្សី ទុំ សឿន[369] ជាអតីតប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង ថា **អ៊ឹម ចែម** មានសិទ្ធិអំណាចបញ្ជាឱ្យសម្លាប់មនុស្ស។ ភស្តុតាងបង្ហាញថា សិទ្ធិអំណាចនេះគ្រប់

---

[366] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953050-00953051 **ឆ.២២២-ឆ.២២៣, ឆ.២២៩**។ **ឯកសារ D219/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043199 **ឆ.៤៤**។ **ឯកសារ D119/154** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ម៉ារ៉ា ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024747 **ឆ.៣១**, KH ERN 01024748 **ឆ.៣៦**។ **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049233 **ឆ.៦៥-ឆ.៦៧**។ **ឯកសារ D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895168-00895169 **ឆ.៩-ឆ.១៥**។ **ឯកសារ D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933106-00933107 **ឆ.៣៦, ឆ.៣៩, ឆ.៤៣, ឆ.៤៤**។ **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969014-00969016**ឆ.៧-ឆ.១៤**។ **ឯកសារ D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800980-00800981 **ឆ.១១**។ **ឯកសារ D106/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ KH ERN00800990 **ឆ.២២-ឆ.២៣**។

[367] **ឯកសារ D119/73** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ជួង ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00971122-00971123 **ឆ.២៦-ឆ.៣៤**។ **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976182 **ឆ.៤៦**, KH ERN00976183 **ឆ.៥៤**។ **ឯកសារ D119/131** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00996506**ឆ.១២០-ឆ.១២១**។ សូមមើលផងដែរ ផ្នែកស្តីអំពីមន្ទីរសន្តិសុខភ្នំទ្រយោង។

[368] សូមមើលខាងក្រោម ផ្នែកស្តីអំពីមន្ទីរសន្តិសុខភ្នំទ្រយោង។

[369] **ឯកសារ D230** កំណត់ហេតុនៃការតទល់មុខគ្នា ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01045318។

ដណ្តប់ដល់ប្រជាជនក្នុងស្រុករបស់គាត់ និងអ្នកដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង[370]។

១៧៦. មេធាវីការពារក្តីជំទាស់ថា សិទ្ធិអំណាចរបស់ **អ៊ឹម ចែម** ទៅលើបញ្ហាសន្តិសុខ មានតិចតួច *"ដោយសារប្រព័ន្ធយោធន័រជាទូទៅ ដែលតាមរយៈកត្តានេះ វាមិនសមទំនងទាល់តែសោះដែលថា កម្មាភិបាលនារី អាចមានតួនាទីសំខាន់ណាមួយក្នុងកិច្ចការទាក់ទងនឹងបញ្ហាសន្តិសុខ"*[371]។ នៅក្នុងសេចក្តីសន្និដ្ឋាននេះ មេធាវីការពារក្តីសំអាងទៅលើអង្គហេតុដែលថា អ្នកទោសស្ត្រីនៅភូមិភាគពាយ័ព្យមិនដែលត្រូវបានកត់ត្រាថាមានតួនាទីផ្នែកសន្តិសុខទេ ហើយថា មន្ទីរសន្តិសុខ និងគុកចំនួន ២៤ នៅភូមិភាគពាយ័ព្យត្រូវបានគ្រប់គ្រងដោយបុរសទាំងអស់[372]។ ការអះអាងនេះមិនអាចឱ្យជឿបានទេ។ ទីមួយ ភ័ស្តុតាងស្តីពីសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** ទៅលើបញ្ហាសន្តិសុខ បានមកពីសាក្សីជាច្រើនដែលបានដឹងដោយផ្ទាល់ពីបញ្ហានេះ ហើយស្របទៅនឹងតួនាទី និងអំណាចតាមផ្លូវច្បាប់របស់លេខាស្រុកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទីពីរ ភ័ស្តុតាងនៅក្នុងសំណុំរឿងបង្ហាញភ័ស្តុតាងចំនួនពីរយ៉ាងតិចអំពីលេខាជាស្ត្រីពីរនាក់ ក្រៅពី **អ៊ឹម ចែម** ដែលអនុវត្តសិទ្ធិអំណាចធំធេងពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ។ ទីមួយ គឺ សេក សំអាត ហៅ យាយរីម ដែលជាអតីតលេខា

---

[370] **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976182 ឆ.៤៦។ **ឯកសារ D119/131** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចង ធឿយ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00996499ឆ.៥៤-ឆ.៥៦។ **ឯកសារ D219/151** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ឡៀង ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ KH ERN01058749 ឆ.១១-ឆ.១២។ សូមមើលខាងក្រោមផងដែរ ផ្នែកស្តីអំពីមន្ទីរសន្តិសុខភ្នំទ្រយោង។

[371] **ឯកសារ D304/6** *ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ KH ERN 01376194 កថាខណ្ឌ ៧៥។

[372] **ឯកសារ D304/6** *ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ KH ERN 01376338-01376340 ជើងទំព័រ ២២៩-២៣០។



ECCC * CEIC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION ១០៦

ស្រុកបាកាន[373]។ សាក្សីពីរនាក់ផ្តល់ភ័ស្តុតាងដោយផ្ទាល់អំពីសិទ្ធិអំណាច និងការចូលរួមរបស់គាត់ក្នុងការចាប់ខ្លួន និងការសម្លាប់មនុស្ស[374]។ ទីពីរគឺ ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម[375] ផ្អែកតាមសក្ខីកម្មរបស់គាត់ វាមិនត្រឹមតែអនុវត្តបញ្ជាដែលថ្នាក់ស្រុកចេញដើម្បីចាប់ខ្លួន និងសម្លាប់ប្រជាជនភាគតិចដោយសារមូលហេតុសាសនា និងត្រូវបានចាត់ទុកថាជាខ្មាំងរបស់បក្សកុម្មុយនីស្ត[376] ប៉ុណ្ណោះទេ តែថែមទាំងមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការអនុវត្តបញ្ជាទាំងនេះ រួមទាំងការសម្រេចថាអ្នកណាខ្លះត្រូវចាប់ខ្លួន និងសម្លាប់[377]។

១៧៧. ស.ព.អ លើកឡើងថា អំណាចរបស់ **អ៊ឹម ចែម** ទៅលើការចេញបញ្ជាចាប់ខ្លួនបានគ្របដណ្តប់ទៅលើស្រុកផ្សេងទៀតក្នុងតំបន់ ៥។ ក្នុងការលើកឡើងនេះ គាត់សំអាងទៅលើភ័ស្តុតាងរបស់សាក្សីម្នាក់ដែលត្រូវបានចាប់ខ្លួននៅស្រុកស្វាយស៊ីសុផុន ត្រូវបាននាំមកឱ្យ **អ៊ឹម ចែម** និងចុងក្រោយត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំទ្រយោង ក្នុងស្រុកព្រះ

---

[373] **ឯកសារ D219/222** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សេង ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01075734 ឆ.១១៩, KH ERN 01075736 ឆ.១៣១។ **ឯកសារ D219/187** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ឃន ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH ERN 01068112 ឆ.៣៣-ឆ.៣៤, ឆ.៣៧។

[374] **ឯកសារ D118/1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សឿម ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ KH ERN 00872599 ឆ.១៧-ឆ.២០។ **ឯកសារ D6.1.991** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សឿម ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១០ KH ERN 00485648-00485649 ឆ.១៣-ឆ.១៤។ **ឯកសារ D219/188** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ឃន ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH ERN 01067244-01068145 ឆ.១២០-ឆ.១២១, ឆ.១២៣-ឆ.១២៤, ឆ.១៣១, KH ERN 01068147-01068148 ឆ.១៣៧-ឆ.១៣៩, ឆ.១៤១។

[375] **ឯកសារ D6.1.730** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ KH ERN 00357510។ **ឯកសារ D117/70** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 01046795 ឆ.២៦។

[376] **ឯកសារ D117/71** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 01046808 ឆ.៤៧-ឆ.៥២។ **ឯកសារ D117/72** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 01046814 ឆ.៦-ឆ.៨។ **ឯកសារ D117/73** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៣ KH ERN 01048919-01046820 ឆ.១០-ឆ.១២។

[377] **ឯកសារ D219/120** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01046833-01046834 ឆ.២៥, ឆ.២៧, ឆ.២៩។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * ECCC * CETC

នេត្រព្រះ[378]។ យើងយល់ថា ភស្តុតាងនេះមិនគាំទ្រដល់ការអះអាងរបស់ ស.ព.អ ទេ ដោយសារភស្តុតាងនេះមិនបានបញ្ជាក់ថា ការចាប់ខ្លួនសាក្សីនោះត្រូវបានធ្វើតាមបញ្ជាអ្នកណានោះឡើយ។ ទោះជាយ៉ាងណាក្តី យើងយល់ថា ដោយសារគាត់ទទួលខុសត្រូវមន្ទីរសន្តិសុខភ្នំទ្រយោង សិទ្ធិអំណាចរបស់ អ៊ឹម ចែម បានគ្របដណ្តប់ទៅដល់អ្នកទោសដែលមកពីស្រុកផ្សេងៗក្នុងតំបន់ ៥[379]។

*ប្រភពនៃការទទួលបានព័ត៌មាន*

១៧៨. អ៊ឹម ចែម បានទទួលព័ត៌មានអំពីដំណើរការគម្រោងសាងសង់ ការផលិតស្បៀង និងបញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងការងារ តាមរយៈប្រភពព័ត៌មានមួយចំនួន។ គាត់ជាអ្នករៀបចំ និងចូលរួមប្រជុំនៅតាមឃុំនានាក្នុងស្រុកព្រះនេត្រព្រះ ដើម្បីពិភាក្សាអំពីការងារ និងគម្រោងសាងសង់ដែលកំពុងដំណើរការ[380] ពិនិត្យការដ្ឋានដោយផ្ទាល់ផង[381] ឬតាមរយៈ

---

[378] **ឯកសារ D101/1.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ KH ERN00743550។ **ឯកសារ D304/2** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ កថាខណ្ឌ ១៤៤។

[379] សូមមើលខាងក្រោម ផ្នែកស្តីអំពីមន្ទីរសន្តិសុខភ្នំទ្រយោង។

[380] **ឯកសារ D119/96** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម ម៉ន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976671 ឆ.៧៤។ **ឯកសារ D119/133** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ិត ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 00998139-00998140 ឆ.៣៦, ឆ.៣៩, ឆ.៤០។ **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980388ឆ.៤៥។ **ឯកសារ D119/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈូក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933131-00933132 ឆ.១៨។

[381] **ឯកសារ D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976156-00976157 ឆ.២០-ឆ.២១, KH ERN 00976159 ឆ.៣១។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978912 ឆ.៣២។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឹត ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ KH ERN 00800996 ឆ.២៣-ឆ.២៣។ **ឯកសារ D119/42** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 00915873 ឆ.១៥។ **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976166 ឆ.១៨។ **ឯកសារ D119/90** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

មនុស្សក្រោមបង្គាប់ផង[382] និងបានទទួលរបាយការណ៍ស្ដីពីដំណើរការការងារ[383]។ ភស្តុតាងដែលថា គាត់បានទៅពិនិត្យគម្រោងសាងសង់ទំនប់ត្រពាំងថ្មក៏បង្ហាញផងដែរថា ការដឹងឮរបស់គាត់អំពីព្រឹត្តិការណ៍នានានៅតាមមូលដ្ឋាន មានលើសពីស្រុកព្រះនេត្រព្រះទៅទៀត។

១៧៩. ទាក់ទិននឹងបញ្ហាសន្តិសុខ **អ៊ឹម ចែម** បានទទួលរបាយការណ៍ស្ដីពីប្រវត្តិរូបរបស់បុគ្គលនានា បន្ទាប់ពីមានការវាយតម្លៃនៅតាមភូមិ និងសហករណ៍។ បន្ទាប់មក គាត់សម្រេចថា តើមានវិធានការវិន័យបែបណាខ្លះដែលចាំបាច់ត្រូវយកមកប្រើ រួមទាំងការឃុំឃាំងផង[384]។ គាត់ក៏បានទៅពិនិត្យដោយផ្ទាល់នៅតាមមន្ទីរសន្តិសុខនានា ដូចជា ភ្នំទ្រយោង និងវត្តព្រះនេត្រ ព្រះ[385] និងបានទទួលរបាយការណ៍ពីមេគុកទៀតផង[386]។

---

ជួន ភាព ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976141ឆ.១២។ **ឯកសារ D119/69** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ក្រូច ទឹម ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ KH ERN 00969044 ឆ.១៣៩9។ **ឯកសារ D219/506** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សែន សុផុន ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ EN ERN 01167928 ឆ.៤៦-៤៧។ ការចុះពិនិត្យរបស់ **អ៊ឹម ចែម** ទៅកាន់ការដ្ឋានត្រូវបានពិភាក្សានៅផ្នែកទីតាំងឧក្រិដ្ឋកម្ម នៃដីកាដំណោះស្រាយនេះ (សំអាងហេតុ)។

[382] **ឯកសារ D219/130** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049237 ឆ.១០៩។ **ឯកសារ D219/361** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី លើយ តើស ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01105586 ឆ.៤៧។

[383] **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953035 ឆ.១១៧, KH ERN 00953049 ឆ.២១៥។

[384] **ឯកសារ D119/99** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ រស់ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978922-00978923 ឆ.៣២។ **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953045 ឆ.១៨៩។

[385] **ឯកសារ D219/153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹម សឿន ចុះថ្ងៃទី ២៣ មករា ឆ្នាំ ២០១៥ KH ERN 01058768 ឆ.៣៤។ **ឯកសារ D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ តួក ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ KH 01115778-01115779 ឆ.៦៤-៧០។ **ឯកសារ D119/34** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សែម ឡៃហៀង ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ KH ERN 00907537 ឆ.១៧។ **ឯកសារ D119/96** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម ម៉ន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ 00976675 ឆ.១០៤។ សូមមើលផងដែរ ផ្នែកស្ដីអំពីមន្ទីរសន្តិសុខភ្នំទ្រយោង។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

## ង. ភស្តុតាងអំពីការប្រព្រឹត្តិរបស់ អ៊ឹម ចែម នៅភូមិភាគពាយ័ព្យ

១៨០. នៅក្នុងផ្នែកនេះ យើងនឹងពិនិត្យមើលភស្តុតាងអំពីការប្រព្រឹត្តិជាទូទៅរបស់ **អ៊ឹម ចែម** នៅពេលដែលគាត់ផ្លាស់ទៅតំបន់ ៥ ភូមិភាគពាយ័ព្យ។ ភស្តុតាងអំពីការប្រព្រឹត្តិរបស់ **អ៊ឹម ចែម** ជាពិសេសទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្មដែលបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ក៏នឹងត្រូវពិនិត្យមើលផងដែរតាមករណីសមស្រប នៅក្នុងផ្នែកនានានៅខាងក្រោមនេះស្តីពីទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ។

១៨១. មានភស្តុតាងយ៉ាងច្រើនបញ្ជាក់ថា នៅពេលដែលគាត់មកដល់តំបន់ ៥ **អ៊ឹម ចែម** បានលើក ឡើងជាសាធារណៈប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ ជំរុញប្រជាជនមូលដ្ឋានឱ្យប្រយ័ត្នប្រយែងជាមួយនឹងជនដែលអាចជាខ្មាំងរបស់ ប.ក.ក ហើយ បង្គាប់ឱ្យកម្មករដើមតាមមនោគមន៍វិជ្ជារបស់ ប.ក.ក និងខិតខំធ្វើការ ដោយគំរាមកំហែងថានឹងមានលទ្ធផលមិនល្អប្រសិនបើពួកគេមិនធ្វើតាមដូច្នេះទេ។

១៨២. ឧទាហរណ៍ សាក្សីម្នាក់ នៅចាំថា នៅក្នុងអង្គប្រជុំមួយនៅភូមិឡោតេ ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** បានបញ្ជាក់ថា *"កង់ប្រវត្តិសាស្ត្រចាប់ផ្តើមដើរហើយ ប៉ះដៃយកដៃ ប៉ះជើងយកជើង។ ស៊ូទុកពូជស្រូវ មិនទុកពូជមនុស្ស។ ទុកមិនចំណេញ ដកចេញក៏មិនខាត។ អង្ករគេរែង យកតែអង្ករដើមទេ ឯកម្ទេចគេមិនយកទេ។ កុំយល់ថា បដិវត្តមានពីរ បដិវត្តអង្គការ គឺមានតែមួយទេ"*។ សាក្សីនេះក៏នៅចាំថា **អ៊ឹម ចែម** បានចោទកម្មាភិបាលភូមិភាគពាយ័ព្យថាមានផែនការធ្វើ*"បដិវត្តទីពីរ"*[387]។ សាក្សីម្នាក់ នៅចាំថា នៅក្នុងអង្គប្រជុំមួយនៅឃុំភ្នំលាប **អ៊ឹម ចែម** បានហៅអ្នកចូលរួមអង្គប្រជុំឱ្យចង្អុលប្រាប់ *"អ្នកដែលមានឋានន្តរស័ក្តិយកទៅសម្លាប់"* ដើម្បីធានាថាមានអាហារសម្រាប់អ្នកដែល

---

[386] **ឯកសារ D219/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043198 ឆ.៣៧-៤០។ **ឯកសារ D230** កំណត់ហេតុនៃការតទល់មុខគ្នា ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 010453325។ សូមមើលផងដែរ ផ្នែកស្តីអំពីមន្ទីរសន្តិសុខភ្នំទ្រយោង។

[387] **ឯកសារ D219/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01025644-01025645 ឆ.៣៦-ឆ.៣៨។

ស្មោះនឹងកម្ពុជាប្រជាធិបតេយ្យ[388]។ នៅក្នុងអង្គប្រជុំនានាដែលបានធ្វើឡើងនៅថ្នាក់ឃុំ **អ៊ឹម ចែម** បានប្រាប់អ្នកចូលរួមអង្គប្រជុំថា *"កុំឱ្យមានសតិអារម្មណ៍"* រម្លឹកអ្នកចូលរួមអំពីសារៈសំខាន់ដែលត្រូវខិតខំធ្វើការ ហើយព្រមានថា អ្នកដែលមិនខិតខំធ្វើការនឹងត្រូវចាប់ខ្លួន[389]។

១៨៣. អតីតអ្នកជាប់ឃុំម្នាក់បញ្ជាក់ថា នៅក្នុងអង្គប្រជុំមួយនៅមន្ទីរសន្តិសុខភ្នំទ្រយោងដែលមានអ្នកចូលរួមប្រហែល ១០០ នាក់ **អ៊ឹម ចែម** បាននិយាយទៅអ្នកទោសថា អ្នកដែលមិនកសាងខ្លួននឹងស្លាប់ ដែលពាក្យសម្តីនេះបើតាមសាក្សីអតីតអ្នកជាប់ឃុំនេះ គឺមានន័យថា គាត់នឹងបញ្ជាឱ្យអ្នកយាមសម្លាប់អ្នកទាំងនោះ[390]។

១៨៤. **អ៊ឹម ចែម** ក៏បាននិយាយនៅក្នុងអង្គប្រជុំនានាដែលមានកម្មករចូលរួមក្នុងចំនួនដ៏ច្រើននាក់ ដោយបង្គាប់ឱ្យអ្នកទាំងនោះ ត្រូវខិតខំធ្វើការ និង ប្រយ័ត្នប្រយែងជាមួយនឹងអ្នកដែលអាចជាខ្មាំង[391]។ មានភស្តុតាងបញ្ជាក់ថា **អ៊ឹម ចែម** បានព្រមានកម្មករ ថា អ្នកដែលមិនខិតខំធ្វើការ និងមិន *"កសាង"* ខ្លួននឹងស្លាប់[392]។ នៅក្នុងអង្គប្រជុំមួយចូលរួមដោយប្រធានឃុំទាំងអស់នៅស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** បានព្រមានអ្នកចូលរួមអង្គប្រជុំថា អ្នកដែល

---

[388] **ឯកសារ D119/155** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ឈានឡុង ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024759- KH ERN 01024760 ឆ.៤១, ឆ.៤៣-ឆ.៤៧។

[389] **ឯកសារ D106/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ERN 00800990 ឆ.២២-ឆ.២៣។

[390] **ឯកសារ D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01115778-01115779 ឆ.៦៤-ឆ.៦៩។

[391] **ឯកសារ D119/133** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 00998140-00998141 ឆ.៤៣-ឆ.៤៩។

[392] **ឯកសារ D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01115779 ឆ.៦៨-ឆ.៦៩។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ជាប់ខ្សែស៊ីអាយអេ អ្នកខ្ជិល ឬប្រឆាំងអង្គការ នឹងបញ្ជូនទៅ*"រៀនសូត្រ"*[393] ដែលពាក្យនេះជាញឹកញាប់ មានន័យថា ត្រូវបញ្ជូនទៅឃុំខ្លួន ឬសម្លាប់ចោល[394]។

១៨៥. ការលើកឡើងទាំងនោះមិនមែនជាការគំរាមកំហែងខ្យល់ទេ។ បន្ទាប់ពីកម្មាភិបាលនិរតី និង អ៊ឹម ចែម ចូលគ្រប់គ្រងតំបន់ ៥ នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ មក ពួកគេបានអនុវត្តយុទ្ធនាការធ្វើការចាប់ខ្លួនជាប្រព័ន្ធដែលដាក់មុខសញ្ញាលើកម្មាភិបាលពាយ័ព្យ[395] នៅថ្នាក់សហករណ៍ ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់តំបន់[396]។

---

[393] **ឯកសារ D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895168 ឆ.៧-ឆ.៨។

[394] **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆោ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049234 ឆ.៧១។ **ឯកសារ D119/30**កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895169 ឆ.១២-ឆ.១៨។ **ឯកសារ D219/380** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុក សុផាត ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01113193-01113194 ឆ.២២-ឆ.២៤ និង**ឯកសារ D219/360.1** ឧបសម្ព័ន្ធ៖ អតីតគណៈកងពលទី ២ ភូមិភាគពាយ័ព្យ ខែ មេសា ឆ្នាំ ២០១៥ KH ERN01105578 ។ **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976178 ឆ.២៨។ **ឯកសារ D6.1.452** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ៃ កៀត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH ERN 00279099 ។ **ឯកសារ D219/173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស ស្តើង ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH ERN 01065976 ឆ.២៧។ **ឯកសារ D119/133** *ក*ំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ ERN 00998141 ឆ.៤៨។

[395] **ឯកសារ D119/73** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ជួង ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ KH ERN 00971122-00971123 ឆ.២៤-ឆ.៣៤។ **ឯកសារ D219/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01025646 ឆ.៤០។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978910-00978911 ឆ.១៩-ឆ.២៥។ **ឯកសារ D219/381** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ រត្តនា ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01113200-01113201 ឆ.៤-ឆ.៧។ **ឯកសារ D119/154** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ ម៉ារ៉ា ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024747 ឆ. ៣១ និង KH ERN 01024748- 01024749 ឆ.៣៦-ឆ.៣៨។

[396] **ឯកសារ D119/32** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ERN 00907513 ឆ.៨, ERN 00907515 ឆ.២០, ERN 00907515 ឆ.២៥ , ERN 00907516 ឆ.៣៤។ **ឯកសារ D119/13**



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

១៨៦. កម្មាភិបាលភូមិភាគនិរតីមិនមែនដាក់មុខសញ្ញាតែលើកម្មាភិបាលភូមិភាគពាយ័ព្យប៉ុណ្ណោះទេ។ សាក្សីនានាបញ្ជាក់ថា បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីមកដល់ និងនៅក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** ជាលេខាស្រុកព្រះនេត្រព្រះ កម្មករដែលមានកំហុស មនុស្សដែលជាប់ទាក់ទងជាមួយនឹងវៀតណាម និងអតីតមន្ត្រី លន់ នល់ ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល[397]។ ការចាប់ខ្លួនត្រូវបានពិភាក្សាជាមួយប្រធានសហករណ៍ នៅក្នុងអង្គប្រជុំនៅផ្ទះ **អ៊ឹម ចែម** ។ ទោះជា **អ៊ឹម ចែម** គឺជាអ្នកសម្រេចលើការចាប់ខ្លួនមនុស្សជា

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 00915883-00915884 ឆ.១៣-ឆ.១៧។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978909 ឆ.៧-ឆ.១១។ **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN00978920 ឆ.១៥-ឆ.១៦។ **ឯកសារ D119/100** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាម គិន ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00978931 ឆ.៨, KH ERN 00978933 ឆ.២១-ឆ.២៣។ **ឯកសារ D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933103 ឆ.១២-ឆ.១៦។ **ឯកសារ D119/89** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976129-00976130 ឆ.២២-ឆ.២៣។ **ឯកសារ D118/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទាត់ ធឿន ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៣ KH ERN 00947578 ឆ.១៥, KH ERN 00947580 ឆ.២៨។ **ឯកសារ D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ KH ERN 00985871-ERN00985873 ឆ.៣៥-ឆ.៤៤។ សូមមើលផងដែរផ្នែកដែលនិយាយអំពីតួនាទី និងការមកដល់ភូមិភាគពាយ័ព្យរបស់ **អ៊ឹម ចែម**។ **ឯកសារ D219/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH ERN 01066318 ឆ.១៦។

[397] **ឯកសារ D219/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ERN 01066319 ឆ.១៨-ឆ.១៩។ **ឯកសារ D119/125** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីម៉ក់ វន្នី ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00987279-00987280 ឆ.១៤-ឆ.១៨។ **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976180 ឆ.៣៧។ **ឯកសារ D119/22** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីភោគ គុយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894512 ឆ.៦។ **ឯកសារ D61** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈ្លង ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ KH ERN 00727221-00727223។ **ឯកសារ D219/212** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខុប សុក ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01074065 ឆ.២៩-ឆ.៣០។ **ឯកសារ D119/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 00915884 ឆ.២២។ **ឯកសារ D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01115779 ឆ.៦៨។

ច្រើននាក់ក៏ដោយ ក៏នៅពេលខ្លះ ប្រធានសហករណ៍ អាចបានចាប់ខ្លួនតាមគំនិតខ្លួនឯងដែរ[398]។ ឈ្លបស្រុកព្រះនេត្រព្រះ ដែល ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ឃុំ បានចាប់ខ្លួនមនុស្សនៅតាមសហករណ៍នានា[399]។

១៨៧. សាក្សីម្នាក់បញ្ជាក់ថា នៅក្នុងអង្គប្រជុំមួយដែលធ្វើឡើងនៅឆ្នាំ ១៩៧៨ នៅបាត់ដំបង មានអ្នកចូលរួមរាប់ពាន់នាក់ ហើយតា ម៉ុក និង អ៊ឹម ចែម ធ្វើជាគណៈអធិបតីនោះ អ្នកដែលរិះគន់ផែនការការងារត្រូវបានចាប់ខ្លួន និងអាចត្រូវសម្លាប់ចោល[400]។ សាក្សីប៉ុន្មាននាក់បានបញ្ជាក់ថា អ្នកទាំងនោះត្រូវបានចាប់ខ្លួនតាមបញ្ជារបស់ អ៊ឹម ចែម[401]។

១៨៨. ដូចបានបង្ហាញតាមរយៈភស្តុតាងដែលបានពិភាក្សាខាងលើទាក់ទិននឹងតួនាទី និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម ដែរ អ៊ឹម ចែម គ្រប់គ្រងមន្ទីរសន្តិសុខ និងការដ្ឋានទាំងនៅក្នុងស្រុកព្រះនេត្រព្រះ ទាំងនៅក្រៅស្រុកព្រះនេត្រព្រះផង។ នៅផ្នែកបន្ទាប់នេះ យើងនឹង

---

[398] **ឯកសារ D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីប៊ិន សុខ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01114731 **ទ.៤២**។

[399] **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978911 **ទ.២៤-ទ.២៥**។ **ឯកសារ D106/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីប្រាច់ គិត ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ KH ERN 00780968 **ទ.១៤-ទ.១៥**។

[400] **ឯកសារ D119/66** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីប៊ិន ហ៊ឹយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH ERN 00969016 **ទ.១៥**។

[401] **ឯកសារ D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800980-00800981 ទ.១១។ **ឯកសារ D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933107 **ទ.៤៤**។ **ឯកសារ D219/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043163 **ទ.១៩**។ **ឯកសារ D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01040786 **ទ.១៤-ទ.១៦**។ **ឯកសារ D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801014-00801015 **ទ.៧-ទ.១៣**។ **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ERN 00976182 **ទ.៤៦**។ **ឯកសារ D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895169 **ទ.១២**។ សូមមើលផងដែរ ឯកសារ **D106/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800990 **ទ.២២-ទ.២៣**។



ECCC CETC CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION

វិភាគយ៉ាងលម្អិតអំពីភស្តុតាងពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មពីរកន្លែង ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ (គឺ មន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង)។ នៅផ្នែក បន្ទាប់នេះ ក្រៅពីភស្តុតាងដែលបានពិនិត្យរួចហើយពាក់ព័ន្ធនឹងទំហំនៃសិទ្ធិអំណាចរបស់គាត់ និងការប្រព្រឹត្តិជាទូទៅរបស់គាត់នៅតំបន់ ៥ និងនៅស្រុកព្រះនេត្រព្រះ យើងនឹងពិនិត្យមើល ភស្តុតាងបន្ថែមទៀតអំពីការចូលរួមជាក់លាក់របស់គាត់នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទថា បានប្រព្រឹត្តឡើងនៅទីតាំងទាំងនេះ។

## ច. ឧក្រិដ្ឋកម្មដែលបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

### i. <u>មន្ទីរសន្តិសុខភ្នំទ្រយោង</u>

*សេចក្តីផ្តើម*

១៨៩. ភ្នំទ្រយោង គឺជាមន្ទីរសន្តិសុខមួយកន្លែងនៅតំបន់ ៥។ មន្ទីរនេះគ្រប់គ្រងដោយ ទុំ សឿន ជាកម្មាភិបាលភូមិភាគនិរតី ដែលរាយការណ៍ផ្ទាល់ទៅ **អ៊ឹម ចែម**។ នៅក្នុងអំឡុងពេលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី យ៉ាងហោចណាស់ អ្នកទោសរាប់រយនាក់បានទទួលរងការធ្វើបាប កង្វះអាហារ និងត្រូវការងារធ្ងន់ធ្ងរ នៅពេលដែលជាប់ឃុំខ្លួននៅទីនោះ។ មនុស្សរាប់រយនាក់បានស្លាប់ ដោយសារកង្វះអាហារដែលមានជីវជាតិ និងជំងឺ។ ផ្អែកតាមភស្តុតាងដែលមាន យើងបានប៉ាន់ស្មានថា អ្នកទោសជាង ២០០០ នាក់ ត្រូវអ្នកយាមគុក សម្លាប់នៅចន្លោះពេលពីពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់ខែ មករា ឆ្នាំ ១៩៧៩។

*ទីតាំង និងការបង្កើតមន្ទីរសន្តិសុខ*

១៩០. មន្ទីរសន្តិសុខភ្នំទ្រយោងមានទីតាំងនៅឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ តំបន់ ៥ ភូមិភាគពាយ័ព្យ នៅជិតភ្នំទ្រយោង និងនៅតាមបណ្តោយផ្លូវលំទៅត្បូងពីផ្លូវជាតិលេខ ៦[402]។ សាក្សីមួយចំនួនបញ្ជាក់ថា មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើង

[402] **ឯកសារ D106/18** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខភ្នំទ្រយោង KH ERN 00919481-00919483។ **ឯកសារ D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 0080[...]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដោយកម្មាភិបាលភូមិភាគនិរតី នៅពេលដែលពួកគេមកដល់នៅឆ្នាំ ១៩៧៧[403] ចំណែក សាក្សី ផ្សេងទៀតបញ្ជាក់ថា មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៥ នៅពេល ចាប់ផ្តើមរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានពង្រីកបន្ទាប់ពីកម្មាភិបាលភូមិភាគ និរតីមកដល់ ទីនោះ[404]។

១៩១. មន្ទីរពេទ្យមួយកន្លែង[405] ផ្ទះប្រធានមន្ទីរសន្តិសុខឈ្មោះទុំ សឿន[406] ទីតាំងសម្លាប់មនុស្ស ជាច្រើនកន្លែង និងរណ្តៅសាកសពជាច្រើនកន្លែង[407] ព្រមទាំងកន្លែងស្នាក់នៅជាច្រើន

---

00801018 ទ.៣៦។ **ឯកសារ D106/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ERN 00801024 ទ.២១។

[403] **ឯកសារ D119/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894503 ទ.១៥។ **ឯកសារ D119/21** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ងៀង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ KH ERN00894507 ទ.៧។ **ឯកសារ D219/152** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែត ដួង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ KH ERN01058755 ទ.៥។ **ឯកសារ D119/22** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីភោគ គុយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894512 ទ.៥។ **ឯកសារ D106/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ KH ERN00801003 ទ.៣៣។ **ឯកសារ D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801018 ទ.៣៩។ **ឯកសារ D119/137** កំណត់ហេតុនៃ ការស្តាប់ចម្លើយសាក្សី អ៊ិត អៀត ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN01003855 ទ.១២។ **ឯកសារ D219/141** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នាម ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥ KH ERN01056100 ទ.៥។ **ឯកសារ D219/318** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជន តំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN01097895 ទ.៥៨។

[404] **ឯកសារ D119/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីម្លួង វ័ន្តធី ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933097 ទ.២។ **ឯកសារ D119/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ វិន ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024738 ទ.២៩។ **ឯកសារ D219/13** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01025647 ទ.៤៤។ **ឯកសារ D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាក ស ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN01104647 ទ.៧៦-ទ.៧៨។

[405] **ឯកសារ D106/18** របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខភ្នំទ្រយោង KH ERN 00919483។ **ឯកសារ D219/151** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ងៀង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ KH ERN01058746 ទ.១។ **ឯកសារ D106/5** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ KH ERN 00801024 ទ.២១។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

កន្លែងសម្រាប់អ្នកទោសធ្ងន់ មានទីតាំងនៅតាមបណ្ដោយផ្លូវរទេះគោនៅចន្លោះពីផ្លូវជាតិលេខ ៦ និងមន្ទីរសន្តិសុខនេះ[408]។ អ្នកយាម និងអ្នកទោស "ស្រាល" មានកន្លែងស្នាក់នៅដាច់ដោយឡែកនៅខាងកើតភ្នំទ្រយោង[409] ហើយមានកន្លែងវាយថ្មធំមួយកន្លែងនៅខាងត្បូងឈៀងខាងលិច[410]។ សាក្សីម្នាក់ដែលធ្លាប់ធ្វើការនៅជិតគុកនេះ បានបញ្ជាក់ថាទីតាំងនេះមានផ្ទះ និងរោងធ្វើពីឈើប្រហែល ១០០ កន្លែង[411]។

---

[406] **ឯកសារ D106/18** របាយការណ៍ស្ដីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខភ្នំទ្រយោង KH ERN 00919483។ **ឯកសារ D106/8** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801017-00801018 ឆ.៣៦។

[407] **ឯកសារ D106/8** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801018 ឆ.៣៦។ **ឯកសារ D119/30** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895170 ឆ.២០, ឆ.២១។ **ឯកសារ D119/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ KH ERN00894496 ឆ.៣៤-ឆ.៣៥។ **ឯកសារ D219/151** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុក ង៉ៀង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ KH ERN01058747 ឆ.៧។ **ឯកសារ D219/152** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ែត ដួង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ KH ERN01058757 ឆ.១៣។ **ឯកសារ D219/92** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01040789 ឆ.៣១, ERN 01040789 ឆ.៣៤។

[408] **ឯកសារ D119/30** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895169-00895170 ឆ.១៩, ERN 00895175។ **ឯកសារ D119/159** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីឡេង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN01025131 ឆ.៤៧។ **ឯកសារ D119/159.1** KH ERN 01025123 គំនូសទីកន្លែង។

[409] **ឯកសារ D106/8** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801016 ឆ.២១, ERN 00801017- 00801018 ឆ.៣៦។ **ឯកសារ D106/7** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ KH ERN00801002 ឆ.២៣-ឆ.២៥។ **ឯកសារ D119/159** កំណត់ហេតុនៃការស្ដាប់ចម្លើយ សាក្សីឡេង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN01025131 ឆ.៤៧។ **ឯកសារ D119/159.1** KH ERN 01025123 គំនូសទីកន្លែង។

[410] **ឯកសារ D106/8** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801017- 00801018 ឆ.៣៦។ **ឯកសារ D106/5** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី ២៩ ខែ មីនា

*របនាសម្ព័ន្ធ និងបុគ្គលិក*

១៩២. ទុំ សឿន ដែលបានធ្វើដំណើរជាមួយ **អ៊ឹម ចែម** ទៅស្រុកព្រះនេត្រព្រះនៅខែ មីនា ឆ្នាំ ១៩៧៧[412] ត្រូវបានស្គាល់ជាទូទៅថាជាកម្មាភិបាលភូមិភាគនិរតីដែលទទួលបន្ទុកនៅមន្ទីរសន្តិសុខ នេះ[413]។ ទុំ សឿន ខ្លួនឯង បានបញ្ជាក់ថា គាត់គឺជាប្រធានគុកនេះ ចាប់តាំងពីខែ ឧសភា ឆ្នាំ ១៩៧៨ ហើយ **អ៊ឹម ចែម** គឺជា អ្នកតែងតាំងគាត់ឲ្យកាន់តួនាទីនេះ[414]។

---

២០១២ KH ERN 00801024 ទ.២១។ **ឯកសារ D119/98** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡឹន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978910 ទ.១៥។

[411] **ឯកសារ D106/4** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800988 ទ.៩។

[412] **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៣ ERN 00953023, ទ.៣១។

[413] **ឯកសារ D61** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ KH ERN 00727222-00727223។ **ឯកសារ D119/29** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ KH ERN00895162 ទ.១៨។ **ឯកសារ D101/1.1** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ KH ERN007435546។ **ឯកសារ D101/1.2** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គោ ពិនថង ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ KH ERN007435550។ **ឯកសារ D119/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ KH ERN00894495 ទ.៣២។ **ឯកសារ D106/6** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800982 ទ.១៨។ **ឯកសារ D106/7** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ KH ERN00801000 ទ.៩។ **ឯកសារ D106/8** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801015 ទ.១៦។ **ឯកសារ D119/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933107 ទ.៤២។ **ឯកសារ D119/30** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895170 ទ.២៤។ **ឯកសារ D119/51** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៣ KH ERN00933124 ទ.៣៤។ **ឯកសារ D119/98** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡឹន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978910 ទ.១៦។ **ឯកសារ D119/136** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN01003849 ទ.៥៤។ **ឯកសារ D219/153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ KH ERN01058764 ទ.១៣។ **ឯកសារ D219/149** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជុំ ធិម ថ្ងៃទី ២០ ខែ



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១៩៣. សាក្សីមួយចំនួនបានបង្ហាញថា ភ្នំទ្រយោង គឺជាមន្ទីរសន្តិសុខថ្នាក់តំបន់ ពីព្រោះថា មន្ទីរនេះដាក់អ្នកទោសមកពីស្រុកផ្សេងៗនៃតំបន់ ៥[415]។ ឧទាហរណ៍ កម្មករដែលគេចាប់ខ្លួននៅស្រុកស្វាយស៊ីសុផុន ត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខនេះ[416]។ អ្នកទោសមកពីសៀមរាប ដែលសាក្សីម្នាក់បានបញ្ជាក់នៅតំបន់ ៤ ក៏ជាប់ឃុំនៅមន្ទីរសន្តិសុខភ្នំទ្រយោងនេះដែរ[417]។ ប៉ុន្តែ សាក្សីនេះអាចច្រឡំថា សៀម រាប ស្ថិតនៅតំបន់ ៤ ពីព្រោះថា

---

មករា ឆ្នាំ ២០១៥ KH ERN01058731 ឆ.៣៦។ **ឯកសារ D219/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN01040811 ឆ.៧។ **ឯកសារ D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01040789 ឆ.៣៦។ **ឯកសារ D219/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043161 ឆ.៤។ **ឯកសារ D219/174** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH ERN 01065992 ឆ.៦៦។ **ឯកសារ D219/256** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី គាល់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ KH ERN 01085166 ឆ.២៨។ **ឯកសារ D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីផែង លៀប ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01085125 ឆ.២៩។ **ឯកសារ D219/318** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដន តំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN01097895 ឆ.៦០។

[414] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953039 ឆ.១៤១-១៤៤, KH ERN 00953041 ឆ.១៥៨, KH ERN 00953043 ឆ.១៧៥-ឆ.១៧៧។ **ឯកសារ D219/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN01043194 ឆ.៦-ឆ.៧។

[415] **ឯកសារ D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្លុក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01115778 ឆ.៥៦-ឆ.៥៧។ **ឯកសារ D119/20** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH ERN00894502 ឆ.១១។ **ឯកសារ D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01040790 ឆ.៤២។ **ឯកសារ D219/255** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ រឿប ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ KH ERN 01085158 ឆ.១៩។ **ឯកសារ D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933108 ឆ.៤៩។

[416] **ឯកសារ D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាក ស ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN01104647 ឆ.៧៦-ឆ.៨១។ **ឯកសារ D101/1.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ KH ERN00743550។ **ឯកសារ D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895171 ឆ.៣០។

[417] **ឯកសារ D219/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043166 ឆ.៥២។ **ឯកសារ D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ KH ERN



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

មានភស្តុតាងបញ្ជាក់ថា សៀមរាបស្ថិតនៅតំបន់ ១០៦ ឬអាចជាតំបន់ ១០៣ នៅតំបន់ស្វយ័តពិសេស[418]។ អាចថា ភ្នំទ្រយោង កាលពីដើមដំបូង គឺជាគុកថ្នាក់ស្រុក ហើយបានក្លាយជាគុកថ្នាក់តំបន់ ប្រហែល ជានៅដើមឆ្នាំ ១៩៧៨[419]។

១៩៤. ភស្តុតាងរបស់ប្រធានគុកឈ្មោះ ទុំ សឿន ខុសពីនេះត្រង់ចំណុចនេះ ពីព្រោះគាត់បញ្ជាក់ថា អ្នកទោសមកតែពីសហករណ៍ផ្សេងៗនៅក្នុងស្រុកព្រះនេត្រព្រះទេ[420]។ យើងយល់ថា សាក្សីមួយចំនួនបានបញ្ជាក់ថា គុកនេះដាក់មនុស្សមកពីស្រុកផ្សេងៗគ្នា ហើយអតីតអ្នកទោស ដែលទំនងជាបាននិយាយគ្នាជាមួយអ្នកទោសផ្សេងទៀតនៅពេលកំពុងជាប់ឃុំខ្លួននោះ គឺជាប្រភពភស្តុតាងអាចទុកចិត្តបានត្រង់ចំណុចនេះ ហើយមិនទំនងជាមានមូលហេតុដែលនិយាយមិនពិតទេ។ ម្យ៉ាងទៀត ទុំ សឿន ជាមនុស្សដែលយើងចាត់ទុកថាជាទូទៅអាចទុកចិត្តបានចំពោះបញ្ហានានាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងខ្សែសង្វាក់នៃការបញ្ជានៅភ្នំទ្រយោងនោះ ជួនកាល បែរជាមិនសូវអាចឲ្យទុកចិត្តបានទៅវិញអំពីបញ្ហានានាពាក់ព័ន្ធនឹងចំនួនអ្នកទោស ការប្រព្រឹត្តិមកលើអ្នកទោស និងទំហំប្រតិបត្តិការរបស់មន្ទីរសន្តិសុខនេះ។ ហេតុនេះ យើងយល់ឃើញថា ភស្តុតាងពីអតីតអ្នកទោសដែលបញ្ជាក់ថា គុកនេះដាក់អ្នកទោសមកពីស្រុកផ្សេងៗនៅតំបន់ ៥ អាចទុកចិត្តបាន។

---

00800983 ទ.២៨។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895171 ទ.៣០។

[418] សូមមើល ឯកសារ D6.1.456 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស៊ុំ រិទ្ធី ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៩ និងឯកសារ D179/1.2.43 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ KH ERN00853051។

[419] ឯកសារ D219/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ KH ERN 01058742 ទ.៤។

[420] ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953047 ទ.២០០។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

១៩៥. **អ៊ឹម ចែម** មានសិទ្ធិអំណាចជាទូទៅលើគុកនេះ ហើយជាមេផ្ទាល់របស់ ទុំ សឿន[421]។ **អ៊ឹម ចែម** បានចេញបទបញ្ជាសម្រាប់មន្ទីរសន្តិសុខនេះ ហើយគ្រប់គ្រងប្រតិបត្តិការមន្ទីរនេះ[422]។ ទុំ សឿន ទទួលបញ្ជាពី **អ៊ឹម ចែម** បើមិនដោយផ្ទាល់ ក៏តាមរយៈនិរសាររបស់គាត់ដែរ។ ទុំ សឿន រាយការណ៍ផ្ទាល់ទៅគាត់ ឧទាហរណ៍ អំពីចំនួនអ្នកទោស ហើយធ្វើការស្នើសុំអាហារ និងការផ្គត់ផ្គង់ផ្សេងៗ[423]។

១៩៦. ទោះបីជាប្រធានមន្ទីរសន្តិសុខនេះផ្តល់ភស្តុតាងដែលហាក់មិនស៊ីសង្វាក់គ្នាពីវត្តមានអ្នកយាម[424] ក៏ដោយ ក៏មានភស្តុតាងយ៉ាងច្រើន និងអាចទុកចិត្តបានបញ្ជាក់ថា មានអ្នកយាមប្រដាប់អាវុធចំនួនប្រហែល ១៥ នាក់ ទៅ៣០ នាក់នៅគុកនេះ[425]។

---

[421] **ឯកសារ D219/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043195 ឆ.១៣។ **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953046-00953047 ឆ.១៩៨-ឆ.១៩៩, KH ERN 00953050 ឆ.២១៥។ **ឯកសារ D230** កំណត់ហេតុនៃការតទល់មុខគ្នា ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN01045303-01045304, 010453317។ **ឯកសារ D219/256** កំណត់ហេតុនៃការស្តាប់ ចម្លើយសាក្សី មី គាល់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ KH ERN 01085166 ឆ.២៤។ **ឯកសារ D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801017 ឆ.៣៥។ **ឯកសារ D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 0033111 ឆ.៧៥។ **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00980395 ឆ.៨៩។

[422] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទុំ សឿន ថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953042 ឆ.១៧១។

[517] ការគណនាចំនួនអប្បបរមាផ្អែកលើ **ឯកសារ D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800980 ឆ.៥, KH ERN 00800980 ឆ.៨, KH ERN 00800984 ឆ.៣១-ឆ.៣២។ **ឯកសារ D219/94** កំណត់ហេតុនៃ ការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043161 ឆ.២, KH ERN 01043167 ឆ.៥៤-ឆ.៥៥, KH ERN 01043168 ឆ.៦៨, KH ERN 01043169 ឆ.៧០។ សូមមើល សាក្សី ដែលប៉ាន់ស្មានចំនួនអប្បបរមាខ្ពស់បំផុតគឺ មានអ្នកទោសចំនួន ២៤00 នាក់ ត្រូវបានសម្លាប់។ **ឯកសារ D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01115778 ឆ.៥៨, KH ERN 01115783 ឆ.១០៨។



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

ប្រហែល ១០០០ នាក់ ត្រូវបាន សម្លាប់នៅឆ្នាំ ១៩៧៨[518]។ ការប៉ាន់ស្មាននេះមិនរាប់បញ្ចូលហេតុការណ៍ដែលអ្នកទោសចំនួន ៧០០ នាក់ ឬ ១០០០ នាក់ ត្រូវបានរាយការណ៍ថាត្រូវបានសម្លាប់នោះទេ ដោយ ហេតុការណ៍នេះយើងយល់ថាមិនអាចទុកចិត្តបានទេ ទាក់ទិននឹងចំនួនមនុស្សស្លាប់នេះ។

២១៩. ក្រៅពីត្រូវគេសម្លាប់ អ្នកទោសបានស្លាប់ដោយសារអត់អាហារ ជំងឺ ការងារហួសកម្លាំង[519] និងការធ្វើបាបរាងកាយ[520]។ សាក្សីម្នាក់បានឃើញសាកសពអ្នកទោសពីរនាក់នៅជាប់ខ្នោះ ជើងនៅក្នុងរោងនៅក្នុងគុក នៅរយៈពេលកន្លះខែក្រោយពីកងទ័ពវៀតណាមចូលមកដល់[521]។

---

[518] ការគណនាចំនួនអប្បបរមាផ្អែកលើ **ឯកសារ D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800980 **ឆ.៥,** KH ERN 00800980 **ឆ.៨,** KH ERN 00800984 **ឆ.៣១-ឆ.៣២**។ **ឯកសារ D219/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043161 **ឆ.២,** KH ERN 01043167 **ឆ.៥៤-ឆ.៥៥,** KH ERN 01043168 **ឆ.៦៨,** KH ERN 01043169 **ឆ.៧០**។ សូមមើល សាក្សី ដែលប៉ាន់ស្មានចំនួនអប្បបរមាខ្ពស់បំផុតគឺមានអ្នកទោសចំនួន ១០ ៨០០ នាក់ ត្រូវបានសម្លាប់។ **ឯកសារ D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895172 ឆ.៣១, ឆ.៣៦។ **ឯកសារ D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01040791 **ឆ.៥២**។

[519] **ឯកសារ D106/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ សាល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ KH ERN 00801003 ឆ.៣១។ **ឯកសារ D106/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800989 ឆ.១៣។ **ឯកសារ** D219/318 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដន តំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01097896 ឆ.៦៣-ឆ.៦៤។ **ឯកសារ D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៣ KH ERN 01049191 ឆ.១០, KH ERN 01049200 ឆ.៥៤។

[520] **ឯកសារ D219/230** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង វ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01076374 ឆ.៧។

[521] **ឯកសារ D219/141** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នាម ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥ KH ERN 01056101-01056102 ឆ.១១-ឆ.១៧។ **ឯកសារ D43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នាម ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ KH ERN 00722205 ។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

២២០. អតីតអ្នកទោសប្រាប់ថា អ្នកជាប់ឃុំជាច្រើននាក់បានស្លាប់ដោយសារអត់អាហារ[522]។ ការប៉ាន់ស្មានអំពីចំនួននេះដោយអតីតអ្នកទោសមានភាពខុសគ្នា។ សាក្សីម្នាក់ប៉ាន់ស្មានថាមាន ចំនួនរាប់ពាន់នាក់[523] សាក្សីម្នាក់ទៀតថាមានចំនួនប្រហែល ១០០ នាក់ក្នុងរយៈពេលបីខែ[524] ហើយសាក្សីពីរនាក់ទៀតបញ្ជាក់ថាស្លាប់ពីរបីនាក់ក្នុងមួយថ្ងៃ[525]។ យើងមិនអាចរកឃើញ ឱ្យបានច្បាស់អំពីចំនួនមនុស្សស្លាប់ដោយសារអត់អាហារនៅគុកនេះទេ ប៉ុន្តែ យើងជឿថា នៅចន្លោះពេលដែលកម្មាភិបាលនិរតីមកដល់នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ រហូតដល់ពេល កងទ័ពវៀតណាមចូលមកដល់នៅខែ មករា ឆ្នាំ ១៩៧៩ មានមនុស្សរាប់រយនាក់បានស្លាប់ ដោយសារអត់អាហារនៅមន្ទីរសន្តិសុខភ្នំទ្រយោង។

២២១. ជនរងគ្រោះដោយសារការសម្លាប់ និងមនុស្សស្លាប់ដោយសារអត់អាហារ ត្រូវបានកប់នៅក្នុងរណ្ដៅខាងជើងភ្នំទ្រយោង[526]។ មនុស្សដែលស្លាប់នៅក្នុងមន្ទីរពេទ្យនៅជិតនោះ ក៏

---

[522] **ឯកសារ D119/130** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00989343 ឆ.៤៧។ **ឯកសារ D219/318** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដន តំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01097895 ឆ.៥៨, ឆ.៦៤។ **ឯកសារ D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ ត្លុក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ERN 01115776 ឆ.៣៧។

[523] **ឯកសារ D219/153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ KH ERN01058765-01058766 ឆ.២១។

[524] **ឯកសារ D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ ត្លុក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01115776-01115777 ឆ.៤៣-ឆ.៤៧, KH ERN 01115780 ឆ.៨០-ឆ.៨១។

[525] **ឯកសារ D219/230** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីឡេង វ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01076376 ឆ.២១-ឆ.២២។ **ឯកសារ D119/159** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡេង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01025129 ឆ.២៨, KH ERN 01025131 ឆ.៤៦, KH ERN 01025132 ឆ.៥០។ **ឯកសារ D119/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ERN 00933109 ឆ.៥៧។

[526] **ឯកសារ D119/99** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978925 ឆ.៤២។ **ឯកសារ D119/137** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិត អៀត ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 01003861 ឆ.៤៤-ឆ.៤៦។ **ឯកសារ D119/130** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 00989345 ឆ.៦៦។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

01508419



ត្រូវកប់នៅក្បែរភ្នំទ្រយោងដែរ។ ប៉ុន្តែ អ្នកធ្វើការម្នាក់នៅមន្ទីរពេទ្យដែលត្រូវបានបញ្ជាឲ្យកប់សព នោះ បានបញ្ជាក់ថា អ្នកជំងឺដែលស្លាប់ ត្រូវបានកប់នៅរណ្តៅសពម្នាក់មួយៗទេ ចំណែកឯ ជនរងគ្រោះស្លាប់ដោយសារការសម្លាប់វិញ ត្រូវបានកប់នៅក្នុងរណ្តៅផ្សេងរួមគ្នា[527]។

*ទស្សនកិច្ចរបស់ អ៊ឹម ចែម*

២២២. អតីតអ្នកជាប់ឃុំមិនដែលឃើញ **អ៊ឹម ចែម** ចុះទៅមើលគុកទេនៅក្នុងអំឡុងពេលដែលពួកគាត់ជាប់ឃុំទេ[528] ប៉ុន្តែ សាក្សីបីនាក់ចាំថាបានឃើញ **អ៊ឹម ចែម** នៅមន្ទីរសន្តិសុខនេះ[529] ក្នុងនោះបានឃើញម្តងនៅពេលដែលគាត់ព្រមានអ្នកទោសថា ប្រសិនបើមិន "កសាង"ខ្លួន ខិតខំធ្វើការទេ ពួកគេនឹងត្រូវសម្លាប់ចោល[530]។ ក្រៅពីនេះ តាមទម្លាប់

---

ឆ.៦២។ **ឯកសារ D219/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ សល់ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043242 ឆ.៤៤-ឆ.៤៥, KH ERN 01043242 ឆ.៤៧-ឆ.៥០។ **ឯកសារ D219/151** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក វៀង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ KH ERN 01058748 ឆ.៨-៩។

[527] **ឯកសារ D219/152** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែត ដួង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ KH ERN 01058755- 01058756 -01066816 ឆ.៧-ឆ.១០។

[528] **ឯកសារ D101/1.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គោ ពិនថង ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ ERN00743550-00743551។ **ឯកសារ D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00894497 ឆ.៤០។ **ឯកសារ D106/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ KH ERN 00800990 ឆ.១៩។ **ឯកសារ D106/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ សាល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ KH ERN 00801003 ឆ.៣៥។ **ឯកសារ D119/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២១៣ ERN00933125 ឆ.៤២។ **ឯកសារ D119/88** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976122 ឆ.២៨។ **ឯកសារ D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ERN ឆ.៣៩។ **ឯកសារ D219/94** កំណត់ហេតុនៃ ការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043171 ឆ.៩១។ **ឯកសារ D219/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01043180 ឆ.២២។

[529] **ឯកសារ D219/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ KH ERN 01058768 ឆ.៣៤។

[530] **ឯកសារ D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្លុក ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ ERN ឆ.៦៥-ឆ.៦៩, ERN 01115786-01115788 ឆ.១៤៤-ឆ.១៦០។

ជាទៀងទាត់ គេឃើញគាត់ធ្វើដំណើរដោយជិះម៉ូតូ ក្នុងទិសដៅទៅភ្នំទ្រយោង[531]។ ទុំ សឿន ជាប្រធានគុកបានបញ្ជាក់ថា គាត់មិនដែលឃើញ **អ៊ឹម ចែម** នៅគុកទេ ប៉ុន្តែសារភាពថា **អ៊ឹម ចែម** អាចទៅទីនោះនៅពេលដែលគាត់ចុះទៅឃុំផ្សេងធ្វើការ។ យ៉ាងណាក៏ដោយ ទុំ សឿន និយាយអំពីការពិភាក្សាគ្នាជាមួយនឹង **អ៊ឹម ចែម** អំពីការដោះលែងអ្នកទោស ហើយក៏បាននិយាយថា និរសាររបស់ **អ៊ឹម ចែម** មកមន្ទីរសន្តិសុខនេះរៀងរាល់ពីរបីថ្ងៃម្តង[532]។

២២៣. នៅក្នុងចម្លើយរបស់គាត់នៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា **អ៊ឹម ចែម** បដិសេធថាមិនបានជាប់ពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខភ្នំទ្រយោងទេ ប៉ុន្តែ បញ្ជាក់ថា មន្ទីរសន្តិសុខនេះនៅជិតផ្ទះគាត់ ប្រមាណពី ២០០ ម៉ែត្រ ទៅ ១ គីឡូម៉ែត្រ[533]។ ដោយពិចារណាលើចម្ងាយជិតគ្នារវាងមន្ទីរសន្តិសុខនេះជាមួយនឹងផ្ទះគាត់ ព្រមទាំងភ័ស្តុតាងពីសាក្សីនានាដែលបានឃើញគាត់នៅទីនោះ ទើបយើងយល់ឃើញថា ការបដិសេធរបស់ **អ៊ឹម ចែម** មិនគួរឲ្យជឿទេ។

ii. <u>ការដ្ឋានប្រឡាយស្ពានស្រែង</u>

*សេចក្តីផ្តើម*

២២៤. នៅការដ្ឋានស្ពានស្រែង នៅចុងឆ្នាំ ១៩៧៧ និងនៅដើមឆ្នាំ ១៩៧៨ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៨ **អ៊ឹម ចែម** បានផ្តួចផ្តើម និងណែនាំឲ្យពង្រីកប្រឡាយ និងអាងទឹកដែលមានស្រាប់។ កម្មកររាប់ពាន់នាក់ រួមទាំងអតីតកម្មាភិបាលភូមិភាគពាយ័ព្យផង ត្រូវបានបង្ខំ

---

[531] **ឯកសារ D219/383** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ើយ ពឿ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01113227 ឆ.៣៣។

[532] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953044 ឆ.១៨៣។ **ឯកសារ D230** កំណត់ហេតុនៃការតទល់មុខគ្នា ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៣ KH ERN 010 45318 ។

[533] **ឯកសារ D123/1/5.1c** ប្រតិចារឹកនៃការស្តាប់ចម្លើយ **អ៊ឹម ចែម** KH ERN 00929887-00929888 ។



CO. INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ឲ្យធ្វើការនៅនោះ។ យើងមិនដឹងអំពីចំនួនមនុស្សដែលត្រូវបានចាប់ខ្លួន បាត់ខ្លួន និងស្លាប់នៅទីនោះទេ។

*ទីតាំង និងការបង្កើតការដ្ឋានប្រឡាយស្ពានស្រែង*

២២៥. ការដ្ឋានប្រឡាយស្ពានស្រែង លាតសន្ធឹងពីភូមិចារ ឃុំស្ពានស្រែង ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ តំបន់ ៥ ភូមិភាគពាយ័ព្យ[534] ទៅទិសខាងត្បូង កាត់ឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ[535] ដល់អាងទឹកព្រៃនាម នៅឃុំប្រសាទ និងឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ[536]។

២២៦. ប្រឡាយដែលកសាងដោយកម្មាភិបាលភូមិភាគនិរតី គឺជាការពង្រីកប្រឡាយដែលមានស្រាប់ ដែលមានទីតាំងនៅស្រុកភ្នំស្រុក ដោយត្រូវបានកសាងក្រោមការដឹកនាំរបស់ភូមិភាគពាយ័ព្យ មុនពេលដែលកម្មាភិបាលភូមិនិរតីមកដល់[537]។ ប្រឡាយពង្រីកថ្មីនេះមាន

---

[534] **ឯកសារ D106/19** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងស្ពានស្រែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH ERN 00919501 ។

[535] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953033 ឆ.៩៨។ **ឯកសារ D106/9** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តក់ ប៊ុយ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ KH ERN 00801010 ឆ.២៧។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឺត ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ KH ERN 00800996 ឆ.២៥។

[536] **ឯកសារ D106/19** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងស្ពានស្រែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH ERN 00919501 ។

[537] **ឯកសារ D119/139** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីមុន មុត ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 01003881 ឆ.៣៣, KH ERN 01003887 ឆ.៦០។ **ឯកសារ D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01114726 ឆ.៦។ **ឯកសារ D119/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អាយ ផន KH ERN 00915861 ឆ.១២-ឆ.១៥។ **ឯកសារ D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣ KH ERN 00895173 ឆ.៣៧។ **ឯកសារ D119/137** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិត អៀត ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ KH ERN 01003863 ឆ.៥៩។ **ឯកសារ D119/133** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០១៤ ERN ឆ.១២១-ឆ.១២៤។ **ឯកសារ D119/89** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976132 ឆ.៣៣, ឆ.៣៥។



CCC * CETC * CO-JUGES D'INSTRUCTION

ប្រវែងប្រហែល ៨ គីឡូម៉ែត្រ ទៅ ១០ ម៉ែត្រ និងទទឹង១៥ ម៉ែត្រ[538] ហើយភ្ជាប់ប្រឡាយដើមទៅអាងទឹក ព្រៃរនាម នៅទិសខាងត្បូង[539]។

២២៧. ការកសាងពង្រីកប្រឡាយនេះ ហៅថា ប្រឡាយអូរលោប ឬទំនប់អូរលោប[540] បានចាប់ផ្តើមនៅចុងឆ្នាំ ១៩៧៧ ឬនៅដើមឆ្នាំ ១៩៧៨ ហើយបានបញ្ចប់ប្រហែលជាក្នុងរយៈពេលពីរបីខែ បន្ទាប់មក[541]។ ទូរលេខចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨ ពី តា ញឹម លេខាភូមិភាគ ពាយ័ព្យ ផ្ញើទៅមន្ទីរ ៨៧០ គណៈមជ្ឈិមនៅភ្នំពេញ[542] បានបញ្ជាក់ថា អាងទឹកនេះជិតរួចហើយ[543]។

*វចនាសម្ព័ន្ធ និងបុគ្គលិក*

---

[538] **ឯកសារ D106/19** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងស្ពានស្រែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH ERN 00919501 ។

[539] **ឯកសារ D119/129** កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ KH ERN 01001321 ។

[540] **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976167 ; 00976168 ឆ.២៣-ឆ.២៤ ឆ.៣១។ **ឯកសារ D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976156 ឆ.២១។ **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978921 ឆ.២៤-ឆ.២៥។

[541] **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ERN 00980392 ឆ.៦៥។ **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953033-00953034 ឆ.១០៣-ឆ.១០៤។ **ឯកសារ D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00985871 ឆ.៣៨។

[542] **ឯកសារ D219/665** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង់ សុផង់ KH ERN01200302 , ឆ១២-ឆ១៣; **ឯកសារ D6.1.1051** កំណត់ហេតុនៃការស្តាប់ចម្លើយជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៧ KH ERN 00154926-00154927 ។

[543] **ឯកសារ D6.1.586** ឯកសារប្រាស្រ័យទាក់ទងគ្នារបស់ខ្មែរក្រហម ឆ្នាំ ១៩៧៥-ឆ្នាំ ១៩៧៨ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦ EN ERN 00143070។

01508423



២២៨. នៅពេលដែលគាត់បានផ្លាស់ទៅតំបន់ ៥ ភូមិភាគពាយ័ព្យ **អ៊ឹម ចែម** ជាអ្នកបញ្ជាឱ្យកសាងពង្រីកប្រឡាយ និងអាងទឹកនេះ[544]។ គាត់ទទួលបន្ទុកលើទីតាំងនេះ ដែលគាត់បានចុះពិនិត្យ និយាយទៅកាន់កម្មករនៅទីនោះ និងទទួលសេចក្តីរាយការណ៍អំពីការរីកចម្រើនការងារ[545]។ បើតាម ទុំ សឿន ក្នុងចន្លោះខែ មករា ដល់ ខែ ឧសភា ឆ្នាំ ១៩៧៨[546] ដែលជាអ្នកទទួលបន្ទុកកងចល័តតំបន់ ៥ ដែលធ្វើការងារប្រឡាយនេះ[547] បានឱ្យដឹងថា តំបន់ ៥ ឱ្យស្រុកព្រះនេត្រព្រះ ទទួលបន្ទុកផែនការនេះ ដោយ **អ៊ឹម ចែម** រាយការណ៍ត្រឡប់មកវិញជូនតំបន់អំពីការរីកចម្រើនការងារនេះ[548]។ កងចល័តតំបន់ រួមជាមួយនឹងកងផ្សេងទៀត ដែលហៅថា កងនារី និងកងយុវជន គឺជាកម្លាំងការងារនៅការដ្ឋានប្រឡាយ

---

[544] **ឯកសារ D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01114726 ឆ.៦។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឹត ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ KH ERN 00800993 ; ឆ.៣, KH ERN 00800994-00800995 ឆ.១២-១៥។ **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953035 ឆ.១១១, ឆ.១១៧។

[545] **ឯកសារ D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976159 ឆ.៣១។ **ឯកសារ D119/42** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH ERN 00915873; 00915874 ឆ.១៥-ឆ.១៦, ឆ.១៩។ **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976166-00976167 ឆ.១៨-ឆ.២៤។ **ឯកសារ D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១៥ KH ERN 01114726 ឆ.៤។ **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953035 ឆ.១១២។ **ឯកសារ D119/52** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈូក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ KH ERN 00933131 ឆ.១៨។ **ឯកសារ D119/69** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ KH ERN 00969044 ឆ.១៣៩។ **ឯកសារ D119/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ វិន ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024736 ឆ.១៩។

[546] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953033 ឆ.១០៣។

[547] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00966792 ឆ.៨៧, KH 00953033 ឆ.៩៩។

[548] **ឯកសារ** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953035-00953037 ឆ.១១៦-ឆ.១២៧។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

នេះ[549]។ កងចល័តតំបន់មានកងចល័តតូចៗមួយចំនួន ដោយកងនីមួយៗមានអ្នកធ្វើការ រហូតដល់រាប់រយ ១០០ នាក់[550]។

២២៩. សាក្សីពីរនាក់បានបញ្ជាក់ថា កម្មាភិបាលនិរតីម្នាក់ឈ្មោះ តាពាល់ អនុប្រធានកងចល័តតំបន់ ៥ ជាអ្នកទទួលបន្ទុកនៅការដ្ឋាននេះនៅក្នុងចន្លោះពេលដែលកម្មាភិបាលភូមិភាគនិរតី និងកងទ័ពវៀតណាមចូលមកដល់[551]។ ប៉ុន្តែ ទុំ សឿន បញ្ជាក់ថា **អ៊ុម ចែម** បានជ្រើសរើសគាត់ ឱ្យកាន់តួនាទីជាប្រធានកងចល័តតំបន់ ៥ នៅទីតាំងនោះ ហើយគាត់ និងប្រធានកងចល័ត ផ្សេងទៀត រាយការណ៍ផ្ទាល់ និងផ្ដាច់មុខទៅ **អ៊ុម ចែម**[552]។ ដោយមិនគិតថាតើមានមនុស្សម្នាក់ ឬច្រើននាក់ ជាអ្នកគ្រប់គ្រងផ្ទាល់លើការងារប្រចាំថ្ងៃរបស់កម្មករនៅប្រឡាយនេះទេនោះ ក៏មានភស្តុតាងបង្ហាញថា ចុងក្រោយបំផុត អ្នកទាំងនោះរាយការណ៍ទៅ **អ៊ុម ចែម** ដែលជាអ្នកទទួលបន្ទុកទូទៅលើផែនការប្រឡាយនេះ។

២៣០. ព័ត៌មានពីសាក្សីផ្សេងៗអំពីចំនួនកម្មករនៅការដ្ឋាននេះ មានភាពខុសគ្នា។ ទុំ សឿន និងសាក្សីផ្សេងទៀតដែលចូលរួមផ្ទាល់ក្នុងការកសាងប្រឡាយ (ម្នាក់ក្នុងចំណោមនោះ ជាអ្នកធ្វើការដែលត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅប្រឡាយនេះ) បានបញ្ជាក់ថា ផែនការ

---

[549] **ឯកសារ D219/23** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពុំ ខូ KHERN 01029678 ឆ.៩៧។ **ឯកសារ D219/13** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឃុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01025649 ឆ.៥១។ **ឯកសារ D219/253** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាន់ ហួរ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥ KH ERN 01085138 ឆ.២៧។ **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953033 ឆ.៩៩។

[550] **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953035-00953037 ឆ.១១៦-ឆ.១២៧។ **ឯកសារ D119/98** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ERN 00978911 ឆ.២៦។

[551] **ឯកសារ D119/94** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ERN 00976180 ឆ.៣៧, ឆ.៣៩។ **ឯកសារ D219/130** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049236 ឆ.១០៣, KH ERN 01049249 ឆ.២២៨-ឆ.២៣០។

[552] **ឯកសារ D119/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953033 ឆ.៩៦, KH ERN 00953035 ឆ.១១៧។

ប្រឡាយ នេះប្រើប្រាស់មនុស្សរាប់ពាន់នាក់ទៅរាប់ម៉ឺននាក់[553]។ សាក្សីម្នាក់ដែលបានធ្វើការលើប្រឡាយមួយផ្នែកប្រវែងប្រហែល ១០០ ម៉ែត្រ បានបញ្ជាក់ថា មានកម្មករប្រហែលជា ១៥០ នាក់នៅផ្នែកនោះ[554]។ អតីតកម្មករប្រឡាយនេះម្នាក់បានធ្វើការប៉ាន់ស្មានចំនួនទាបជាងនេះ ដោយបញ្ជាក់ថា មានកម្មករប្រហែលតែ ៥០០ នាក់ទេ ដែលជីកប្រឡាយទាំងមូល និងប្រហែល ១០០ នាក់ធ្វើស្ពាន នៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី[555]។ ដើម្បីដោះស្រាយបញ្ហាចំនួនខុសគ្នានេះ យើងបានពិចារណាលើទំហំនៃផែនការនេះ និងរយៈពេលដ៏ខ្លីក្នុងការកសាង (ប្រហែល ៣ ខែ)។ យើងក៏បានពិចារណាផងដែរថា ទុំ សឿន ដែលជាប្រធានកងចល័តតំបន់ ៥ និងសាក្សីបីនាក់ រួមទាំងអតីតសមាជិកគណៈឃុំម្នាក់ ដែលចាត់តាំងមនុស្សឱ្យធ្វើការលើផែនការប្រឡាយនេះ បាននិយាយថា មានកម្មកររាប់ពាន់នាក់នៅការដ្ឋាននេះ ហើយសាក្សីផ្សេងទៀតបាននិយាយថា កងចល័តតំបន់មានកងមួយ ចំនួន ដោយកងនីមួយៗមានអ្នកធ្វើការចំនួនរាប់រយនាក់។ ដោយផ្អែកលើការពិចារណា ទាំងនេះ យើងជឿថា មានអ្នកធ្វើការរាប់ពាន់នាក់នៅក្នុងផែនការប្រឡាយនេះ។

*លក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារ*

---

[553] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ KH ERN 00953036 ឆ.១២៣។ **ឯកសារ D219/1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យូ មុត ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024626 ឆ.៨៥។ សូមមើលផងដែរ **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ERN 00980389-00980399 ឆ.៤៨-ឆ.៤៩ (មនុស្សរាប់ម៉ឺននាក់)។ **ឯកសារ D219/291** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈូ សំរិត ថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១៥ KH ERN 01091470 ឆ.៧៨។

[554] **ឯកសារ D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាក ស ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01104646 ឆ.៦៨-ឆ.៧១។

[555] **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049250 ឆ.២៣៦-ឆ.២៣៧។



E.C.C.C * C.E.T.C
INVESTIGATING JUDGES * JUGES D'INSTRUCTION

២៣១. សាក្សីមួយចំនួន រួមទាំង អតីតឈ្លបនៅទីតាំងនេះ លើកឡើងថា អ្នកយាម ទាំងមាន និង គ្មានអាវុធ នៅថ្នាក់ក្រោមកម្មាភិបាលភូមិភាគនិរតី យាមកាមកម្មករកុំឱ្យរត់គេចខ្លួន ហើយ ចាប់ខ្លួនអ្នកទាំងឡាយណាដែលបានប្រព្រឹត្តខុស[556]។

២៣២. ផ្ទុយទៅវិញ ទុំ សឿន និងកម្មករពីរនាក់ផ្សេងទៀតនៅប្រឡាយនោះ លើកឡើងថា កម្មករទាំងឡាយពុំត្រូវបានគេឃ្លាំមើលនោះទេ[557]។ យើងយល់ថា ភ័ស្តុតាងនេះមិនអាចទុកចិត្តបានឡើយ (ពាក់ព័ន្ធនឹងសាក្សីទាំងពីរនាក់នេះ) ឬ មិនអាចជឿជាក់បាន (ពាក់ព័ន្ធនឹង ទុំ សឿន) ហើយយល់ថា ទុំ សឿន អាចមានចេតនាបិទបាំងភាពលំបាកលំបិនដែលអ្នកធ្វើការនៅក្រោមការគ្រប់គ្រងរបស់ខ្លួនបានទទួលរង។ យើងក៏កត់សម្គាល់ឃើញមានភ័ស្តុតាងបង្ហាញអំពីអតីតកម្មាភិបាលភូមិភាគពាយ័ព្យម្នាក់លើកឡើងថា មេដឹកនាំភូមិភាគពាយ័ព្យចាប់ពីថ្នាក់បញ្ជាការវរសេនាធំរហូតដល់ថ្នាក់បញ្ជាការកងអនុសេនាតូចត្រូវបានគេបញ្ជូនឱ្យទៅធ្វើ "ការអប់រំ" ក្រោយពីបានចាត់ទុកថាជាជនក្បត់។ ក្រោយពេលភ្លង់នឹងកាំភ្លើងបញ្ជូនទៅការដ្ឋានប្រឡាយស្ពានស្រែង ពួកគេត្រូវបានគេឱ្យធ្វើការងារ ហើយអ្នកទាំងឡាយដែលបានប្រព្រឹត្តខុសតូចតាចត្រូវបានគេចោទថាជាជនក្បត់ និងអាចត្រូវបានគេសម្លាប់ចោល[558]។ របបបែបនេះមិនអាចធ្វើទៅបានទេ ប្រសិនបើពុំមាន

---

[556] **ឯកសារ D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ KH ERN 01049192 ឆ.១៤ ឆ.១៦។ **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ KH ERN 01049248 ឆ.២១៩-ឆ.២២១ KH ERN 01049250-01049251 ឆ.២៤៧-ឆ.២៤៩។ **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976166 ឆ.១៦ KH ERN 00976168 ឆ.២៨-ឆ.៣០។

[557] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ KH ERN 00953036 ឆ.១២០។ **ឯកសារ D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជឹម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ KH ERN 01058727 ឆ.១៣។ **ឯកសារ D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាក ស ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥ KH ERN 01104640 ឆ.១២-ឆ.១៣ KH ERN 01104645 ឆ.៦២។

[558] **ឯកសារ D219/381** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ រត្តនា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ KH ERN 01058725- 01058727 -01128282 ឆ.៤-ឆ.១៣។



CO-INVESTIGATING JUDGES *E.C.C.C*C.E.T.C* CO-JUGES D'INSTRUCTION

អ្នកឃាមចាំតាមឃ្លាំមើលអ្នកធ្វើការងារ ហើយនឹងប្រសិនបើពុំអនុវត្តវិធានការចាប់បង្ខំទាំងនេះនោះ។

២៣៣. កម្មករលើកឡើងថា គេតម្រូវឱ្យពួកគេរែកដីតាមផែនការកំណត់ប្រហែលចន្លោះពីពីរទៅប្រាំម៉ែត្រគូបក្នុងមួយថ្ងៃ[559]។ តាមរបាយការណ៍ អ៊ឹម ចែម បានកំណត់ផែនការបីម៉ែត្រគូបក្នុងមួយថ្ងៃ[560]។ ការងារទាំងអស់ត្រូវធ្វើដោយដៃ[561]។ អ្នកទាំងឡាយដែលពុំអាចរែកដីបានត្រូវបានគេចាត់ឱ្យធ្វើជីពីលាមកមនុស្សដោយហាលឱ្យស្ងួត ឬ ដកស្មួងក្រោមការគំរាមកំហែងថានឹងសម្លាប់ចោលប្រសិនបើមិនធ្វើតាមការណែនាំ[562]។

២៣៤. អតីតកម្មករ និងប្រធានកងចល័ត លើកឡើងអំពីការធ្វើការងារយូរម៉ោង (លើកលែងតែសាក្សីម្នាក់ប៉ុណ្ណោះដែលនិយាយថា វេនធ្វើការងារប្រហែលម្តងបួនម៉ោងក្នុងមួយថ្ងៃ)[563] របបអាហារមិនគ្រប់គ្រាន់ និងបរិយាកាសភ័យខ្លាចដែលឃើញកើតមានទូទៅនៅការដ្ឋាន

---

[559] **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976167 ឆ.២៦ (ពីរម៉ែត្រគីបក្នុងមួយថ្ងៃ បន្ទាប់មក បី និងប្រាំម៉ែត្រគីប)។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឹម សឹត ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ KH ERN 00800994 ឆ.៧-ឆ.៨ (៣.៥ ម៉ែត្រគីបក្នុងមួយថ្ងៃ)។ **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ KH ERN 01049250 ឆ.២៣៨ (២០ ម៉ែត្រគីបក្នុងរយៈពេល ៥ ថ្ងៃ)។ **ឯកសារ D219/175** កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហង់ ហោន ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ KH ERN01066001 ឆ.២៧។

[560] **ឯកសារ D119/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ វិន ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤ KH ERN 01024736 ឆ.១៩។

[561] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ KH ERN 00953034 ឆ.១០៧។

[562] **ឯកសារ D219/381** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ រត្តនា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ KH ERN 01058727 ឆ.១៣។

[563] **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ KH ERN 00980389 ឆ.៤៩ (ពីរក្រុម ក្រុមទីមួយ ចាប់ពីម៉ោង ៧ ព្រឹក ដល់ ម៉ោង ១១ ព្រឹក ហើយនឹងក្រុមទីពីរចាប់ពីម៉ោង ២ ល្ងាច ដល់ ម៉ោង ៤ ល្ងាច)។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

01508428



នោះ[564]។ អ្នកធ្វើការដែលខកខានមិនបានបំពេញតាមផែនការប្រចាំថ្ងៃ បានទទួលអាហារតិច ឬ គ្មានតែម្តង[565]។ សាក្សីទាំងឡាយលើកឡើងថា ក្រោយពេលកម្មាភិបាលភូមិភាគនិរតីបានមកដល់ កម្មករទទួលបានរបបអាហារតិចជាងមុន ហើយប្រជាជនបានធ្លាក់ខ្លួនឈឺដោយសាររបបអាហារនេះ[566]។

---

[564] **ឯកសារ D119/41** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ភាន ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ KH ERN 00915867 ឆ.១០។ **ឯកសារ D119/42** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រិត រិត ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ KH ERN 00915875 ឆ.២៣។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឺត ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ KH ERN 00800994 ឆ.៧ KH ERN 00800995 ឆ.១៦។ **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976167 ឆ.២៦។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN 00978910 ឆ.១៣ KH ERN 00985192 ឆ.៤២។ **ឯកសារ D219/1** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យូ មុត ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤ KH ERN 01024626 ឆ.៨៤។ **ឯកសារ D119/69** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទីម ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣ KH ERN 00969035 ឆ.៧០។ **ឯកសារ D219/175** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ KH ERN 01066001 ឆ.២៧។ **ឯកសារ D219/291** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈូ សំរិត ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៥ KH ERN 01091470 , 01091471 ឆ.៧៩ ឆ.៩០។ **ឯកសារ D219/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ KH ERN 01029143 , ឆ.១៤។

[565] **ឯកសារ D119/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ វិន ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤ KH ERN 01024736-01024737 ឆ.១៩-២៥។ **ឯកសារ D119/152** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទារ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤ KH ERN 01024728 ឆ.៣០។ **ឯកសារ D119/120** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ KH ERN 00984311 ឆ.៥៥។

[566] **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN 00978910- 00978914 ឆ.១៣ KH ERN 00978914 ឆ.៤២។ **ឯកសារ D119/78** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត បណ្តែត ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ KH ERN 00971159 ឆ.១៩។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឺត ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ KH ERN 00800997 ឆ.៣១។



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

01508429



២៣៥. អតីតអ្នកធ្វើកាងារបានលើកឡើងថា ពួកគេពុំទទួលបានពេលសម្រាក ឬ ថ្ងៃឈប់នោះទេ[567]។ អតីតកម្មករម្នាក់លើកឡើងថា គេមិនអនុញ្ញាតច្បាប់ឈប់សម្រាកឱ្យគាត់ទៅលេងឪពុកម្ដាយនោះឡើយ[568]។ យើងឃើញមានភស្តុតាងបង្ហាញអំពីកម្មករម្នាក់ដែលបានទទួលច្បាប់ឈប់សម្រាកមួយថ្ងៃឱ្យទៅមើលកូនគាត់ដែលទើបនឹងកើត[569]។

២៣៦. ទុំ សឿន ខ្លួនឯងសារភាពថា ពេលខ្លះ មានការខ្វះអាហារនៅតាមកងចល័តមួយចំនួន[570]។ **អ៊ឹម ចែម** លើកឡើងថា គាត់បានឃើញកម្មករស្គមស្គាំង ដោយសារខ្វះអាហារនៅពេលកំពុងជីកប្រឡាយប៉ុន្តែអះអាងថា គាត់បានចាត់វិធានការជួយសម្រាលស្ថានភាពរបស់ពួកគេ[571]។ យើងឃើញមានភស្តុតាងបង្ហាញថា នៅការដ្ឋានមានរោងមួយដែលកម្មករសម្រាននៅលើដីក្រោមរោងនោះ[572]។

---

567 **ឯកសារ D219/494.1.1** ប្រតិចារឹកនៃសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ KH ERN 01122551 ។ **ឯកសារ D119/69** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣ KH ERN 00969035 **ឆ.**៧០។

568 **ឯកសារ D219/494.1.1** ប្រតិចារឹកនៃសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ KH ERN 01122551 ។ **ឯកសារ D119/69** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣ KH ERN 00969035 **ឆ.**៧០។

569 **ឯកសារ D119/138** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សរ ឡោម ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ KH ERN 01003870 **ឆ.**២០។

570 **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ KH ERN 00953034 **ឆ.**១០៧។

571 **ឯកសារ D123/1/5.1a** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង អ៊ឹម ចែម ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៧ KH ERN 00929737-00929738 ។

572 **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ KH ERN 00953034 **ឆ.**១០៧។ **ឯកសារ D219/291** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈូ សំរិត ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៥ KH ERN 01091470 **ឆ.**៧៩។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៣៧. អតីតកម្មករនៅការដ្ឋាននោះនាអំឡុងចុងឆ្នាំ១៩៧៧[573] លើកឡើងថា កម្មករដែលបានធ្លាក់ខ្លួនឈឺត្រូវបានគេជម្លៀសត្រឡប់មកភូមិដើមរបស់ពួកគេវិញ ឬទៅពេទ្យស្រុក[574] ទោះបី ជាភ័ស្តុតាងពី ទុំ សឿន ហាក់បង្ហាញថា អ្នកឈឺពុំមែនត្រូវបានឱ្យចាកចេញពីការដ្ឋានគ្រប់ ពេលនោះឡើយ[575]។ សាក្សីម្នាក់បានលើកឡើងថា អ្នកឈឺបានទទួលអាហារតិចហើយបាន ទទួល "*ថ្នាំអាចម៍ទន្សាយ*" ធ្វើពីឫសឈើដែល "*ខាងសង្គមកិច្ច*" ឱ្យដើម្បីយកមកហូបព្យាបាល[576]។ ពេលខ្លះទៀត អ្នកដែលចូលពេទ្យពុំដែលបានឃើញមកវិញនោះឡើយ[577]។

*ការចាប់ខ្លួន ការស្លាប់ និងការបាត់ខ្លួន*

---

[573] **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ KH ERN 01049248 **ឆ.២១៥-ឆ.២២១**។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឹត ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ KH ERN 00800994 **ឆ.៥ ឆ.៩**។ **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ KH ERN 00980392 **ឆ.៦៥**។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN 00978911 **ឆ.២៦**។

[574] **ឯកសារ D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ KH ERN 00980390 **ឆ.៥២**។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN 00978914 **ឆ.៤២**។ **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ KH ERN 01049250 **ឆ.២៤៣-ឆ.២៤៥**។ **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឹត ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ KH ERN 00800996 **ឆ.២៨**។

[575] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ KH ERN 00953038 **ឆ.១៣៩-ឆ.១៤០**។

[576] **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ KH ERN 01049250 **ឆ.២៤៣-ឆ.២៤៥**។

[577] **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN 00978914 **ឆ.៤២**។



E.C.C.C * C.E.T.C * CO INVESTIGATING JUDGES * JUGES D'INSTRUCTION

២៣៨. ក្រោយពេលមកដល់ កម្មាភិបាលភូមិភាគនិរតីបានចាប់ តាវ៉ាល់ ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យកាន់កាប់កងចល័តនៅការដ្ឋាន[578]។ ការចាប់ខ្លួន និងការបាត់ខ្លួនកម្មករឃើញកើតមានជាទូទៅនៅការដ្ឋានប្រឡាយស្ពានស្រែង[579]។ ការចាប់ខ្លួនមានហេតុផលខុសៗគ្នា។ ប្រជាជនត្រូវបានគេចាប់ខ្លួនដោយសារមិនបានធ្វើការងារតាមផែនការការងារដែលជាទណ្ឌកម្មមួយដែលត្រូវបានគំរាមកំហែងដោយ **អ៊ឹម ចែម** នៅក្នុងពេលប្រជុំ ដែលគាត់បានថ្លែងទៅកាន់កម្មករ[580]។ ហេតុផលផ្សេងទៀតរួមមាន ការជាប់ទាក់ទងជាមួយគ្រួសារ ឧទាហរណ៍ ជាមួយនឹងអ្នកដែលជាប់សាច់ឈាមវៀតណាម[581] ឬ ការប៉ុនប៉ងរត់គេចខ្លួន ឬ ចាកចេញពី ការដ្ឋានទៅលេងសមាជិកគ្រួសារ។ ចំពោះករណីនេះ អតីតកម្មករបានលើកឡើងថា ប្រជាជនត្រូវបានគេបញ្ជូនទៅ "អប់រំ" ក្រោយពេលបានព្យាយាម

---

[578] **ឯកសារ D119/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វា នង់ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ KH ERN00915882-00915884 ឆ.១២-ឆ.១៧។ **ឯកសារ D119/100** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាម គិន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00978931 ឆ.៨ KH ERN 00978933 ឆ.២១។ **ឯកសារ D219/506** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ EN ERN 01167929 ឆ.៤៨។

[579] **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឹម សឹត ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ KH ERN 00800995 ឆ.១៧ ឆ.១៨ ឆ.២១។ **ឯកសារ D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ KH ERN 00894491, 00894492, 00894493 ឆ.៥ ឆ.៧ ឆ.១៣ ឆ.១៥។ **ឯកសារ D219/175** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហង់ ហោន ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ KH ERN 01066001 ឆ.២៨។

[580] **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976165-00976166 ឆ.១២-ឆ.១៤ KH ERN 00976168 ឆ.២៨-ឆ.៣០។

[581] **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយ ប៊ូ ម៉ៅ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976180 ឆ.៣៧។



* ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

វត់ជាលើកទីមួយ។ ក្រោយពេលបានព្យាយាមម្តងទៀត ពួកគេនឹងត្រូវចាប់ខ្លួន[582]។ សាក្សីម្នាក់លើកឡើងថា ការចាប់ខ្លួនបាន ធ្វើឡើងដោយលួចលាក់នៅពេលយប់[583]។

២៣៩. ទុំ សឿន ច្រានចោលថា កម្មករត្រូវបានចាប់ខ្លួន ប៉ុន្តែលើកឡើងថា កម្មករ “*ដែលរឹងរូស*” ត្រូវបានគេបញ្ជូនទៅ “*អប់រំ*”[584] ដោយពុំបានបញ្ជាក់ការអប់រំនោះមានអ្វីខ្លះនោះឡើយ។ អតីតកម្មករម្នាក់នៅការដ្ឋាននេះក្នុងអំឡុងពេញមួយរដូវប្រាំងក្នុងឆ្នាំ១៩៧៧ លើកឡើងថា គាត់ពុំដែលបានឃើញគេដាក់ទោសកម្មករទេ ហើយពុំចាំកម្មករទាំងឡាយណាបានបាត់ខ្លួននោះទេ។ ទោះបីជាយ៉ាងនេះក្តី គាត់ក៏លើកឡើងថា គាត់បានរត់គេចពីការដ្ឋានដោយសារគាត់ខ្លាចគេសម្លាប់គាត់ ហើយបានឮពីអ្នកធ្វើការជាមួយគាត់អំពីការបាត់ខ្លួនមនុស្ស[585]។

២៤០. អតីតកម្មករដែលត្រូវបានគេចាប់ខ្លួនត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខភ្នំត្រយោង[586]។

២៤១. អតីតកម្មករនៅការដ្ឋាននេះលើកឡើងថា កម្មករបានស្លាប់ដោយសារធ្វើការងារហួសកម្លាំង ជំងឺ និងការហត់បាក់កម្លាំង[587]។

---

[582] **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ផៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ KH ERN01049250-01049251 ឆ.២៤៧-ឆ.២៤៩។ **ឯកសារ D119/120** កំណត់ហេតុនៃការស្តាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ KH ERN 00984315 ឆ.៩៤។

[583] **ឯកសារ D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឺត ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ KH ERN 00800995-00800996 ឆ.១៧ ឆ.១៨ ឆ.២០-ឆ.២២។

[584] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ KH ERN 00953038 ឆ.១៤០។

[585] **ឯកសារ D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជឹម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ KH ERN 01058726- 01058727 ឆ.១២-ឆ.១៦។

[586] **ឯកសារ D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាក ស ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៥ KH ERN 01104647-01104648 ឆ.៧៦-ឆ.៨១។

[587] **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976183 ឆ.៥១។ **ឯកសារ D119/120** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង

២៤២. ចំណុចចុងក្រោយ សាក្សីមួយចំនួនរាយការណ៍ថា អ្នកធ្វើការបានបាត់ខ្លួនពីការដ្ឋាន[588]។

*ទស្សនកិច្ចរបស់ អ៊ឹម ចែម*

២៤៣. សាក្សីមួយចំនួន រួមទាំងមេកងចល័ត និងកម្មករ លើកឡើងថា **អ៊ឹម ចែម** បានចុះពិនិត្យមើលការដ្ឋានយ៉ាងទៀងទាត់[589] ហើយបានកោះប្រជុំនៅទីនោះ[590]។ មានពេលមួយនោះ **អ៊ឹម ចែម** បានចុះពិនិត្យមើលការដ្ឋានសាងសង់ដោយមានកងទ័ពប្រដាប់ដោយអាវុធចំនួនពីប្រាំទៅដប់នាក់ទៅជាមួយ ហើយបានព្រមានកម្មករថា ប្រសិនបើពុំសម្រេចបានតាមផែនការការងារទេ ពួកគេនឹងទទួលទណ្ឌកម្ម[591]។ ប្រធានកងចល័តម្នាក់លើកឡើងថា

---

រដ្ឋប្បវេណី សម ស័ក្ត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ KH ERN00984315 ទ.៩១។ **ឯកសារ D119/40** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាយ ផាន KH ERN 00915862 ទ.១៩។

[588] **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ KH ERN 01049241 ទ.១៩៨ KH ERN 01049251 ទ.២៥២។ **ឯកសារ D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជឹម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ KH ERN 01058727 ទ.១៦។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN 00978910 ទ.១៤។ **ឯកសារ D119/69** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រូច ទឹម ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣ KH ERN 00969035 ទ.៧១-ទ.៧២។ **ឯកសារ D219/506** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ EN ERN 01167928 ទ.៤២-ទ.៤៣។ **ឯកសារ D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ KH ERN 00894493 ទ.១៥។

[589] **ឯកសារ D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ KH ERN 00953035 ទ.១១២។ **ឯកសារ D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976156 ទ.២១។ **ឯកសារ D219/506** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ EN ERN 01167928 ទ.៤៦-ទ.៤៧។

[590] **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976166 ទ.១៩។ **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN 00978913 ទ.៣៩។ **ឯកសារ D119/69** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រូច ទឹម ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣ KH ERN 00969044 ទ.១៣៩។ **ឯកសារ D119/139** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ KH ERN 01003888 ទ.៦៤។

[591] **ឯកសារ D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ KH ERN 00976166-00976167 ទ.២០ ទ.២២។

01508434



នៅក្នុងពេលទសន្សកិច្ច គាត់ពេលខ្លះជួយកម្មករលើកដី[592] ដែលចំណុចនេះ អ៊ឹម ចែម ខ្លួនឯងក៏បានទទួលស្គាល់ផងដែរដោយគាត់បានលើកឡើងថា គាត់បានធ្វើដូច្នោះមែនដើម្បីជាការកសាងទំនុកចិត្ត[593]។

## V. តំបន់ក្នុងបទឧក្រិដ្ឋដែលបានចោទប្រកាន់ដោយ ស.ព.អ ប៉ុន្តែពុំបានដាក់ស្ថិតក្រោមការពិនិត្យដោយ ស.ច.ស.អ

### ក. ការពិចារណាបឋម

២៤៤. អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋមួយចំនួនដែល ស.ព.អ ចោទប្រកាន់ថា គាត់ទទួលខុសត្រូវព្រហ្មទណ្ឌ ពោលគឺ ការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយ៉ូង និងការដ្ឋានទំនប់ស្ពានស្រែង[594]។

២៤៥. ទោះបីជាយ៉ាងនេះក្តី ស.ព.អ ស្នើសុំឱ្យ ស.ច.ស ចោទប្រកាន់បញ្ជូន អ៊ឹម ចែម ទៅជំនុំជម្រះលើបទឧក្រិដ្ឋដែលមានលក្ខណៈទូលាយជាងនេះដែលបានប្រព្រឹត្តតាមរយៈទម្រង់នៃការទទួល ខុសត្រូវច្រើនជាងនេះ លើសពីបទឧក្រិដ្ឋទាំងឡាយដែលចោទប្រកាន់លើរូបគាត់[595]។ មេធាវី ការពារក្តីបានជំទាស់ត្រឹមត្រូវថា ការចោទប្រកាន់បែបនេះមិនអាចអនុញ្ញាតនោះទេ។ គោលការណ៍មូលដ្ឋាននៃដំណើរការនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់គឺ

---

[592] ឯកសារ D119/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN 00978912 ឆ.៣២។

[593] ឯកសារ D219/264.1 ប្រតិចារឹកកិច្ចសម្ភាសន៍របស់យុវសន្តិភាពជាមួយនឹង អ៊ឹម ចែម ក្នុងឆ្នាំ២០១១ KH ERN 01107043 ។

[594] ឯកសារ D239/1 *ឧបសម្ព័ន្ធ៖ សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំងនឹង អ៊ឹម ចែម* ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥។

[595] ឯកសារ D304/2 *សេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុងប្រឆាំងនឹង អ៊ឹម ចែម* ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ KH ERN 01342163, KH ERN 01342202 កថាខណ្ឌ ៤៤៩-កថាខណ្ឌ ៥៤១។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01508435



ការជូនដំណឹងលម្អិតអំពីលក្ខណៈ និងមូលហេតុនៃបទចោទ[596] ហើយគោលការណ៍នេះគឺជាលក្ខខណ្ឌចាំបាច់ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិរបស់ជនត្រូវចោទក្នុងការរៀបចំការការពារក្ដីរបស់ខ្លួន[597]។ ជនត្រូវចោទអាចត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះតែចំពោះបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់ ហើយនឹងជូនដំណឹងត្រឹមត្រូវប៉ុណ្ណោះ[598]។

២៤៦. មេធាវីការពារក្ដីក៏ផ្ដល់ទឡ្ហីករណ៍ត៏វាថា នៅពេលវាយតម្លៃយុត្តាធិការបុគ្គល ស.ច.ស អាចត្រឹមតែសំអាងលើភ័ស្តុតាងជាប់ពាក់ព័ន្ធនឹងបទចោទប្រឆាំងនឹង **អ៊ឹម ចែម** ប៉ុណ្ណោះ[599]។ នេះគឺជាបញ្ហាមួយផ្សេងពីបញ្ហានៃការចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះពីបទឧក្រិដ្ឋដែលពុំត្រូវបានចោទប្រកាន់ ហើយសិទ្ធិមនុស្ស និងយុត្តិសាស្ត្រ អ.វ.ត.ក ផ្ដល់ការណែនាំតិចតួចប៉ុណ្ណោះសម្រាប់ដោះស្រាយលើករណីនេះ។ យុត្តិសាស្ត្រនៃអង្គជំនុំជម្រះលើសមត្ថកិច្ចនៃសាលាក្ដី ICTY ដែលសំអាងដោយមេធាវីការពារក្ដី មានតម្លៃតិចតួចប៉ុណ្ណោះ ដោយសារភាពខុសគ្នាផ្នែកនីតិវិធីជាសារវ័ន្តជាមួយនឹង អ.វ.ត.ក។ ទោះបីជាយ៉ាងនេះក្ដី យើងពុំចាំបាច់ពិនិត្យមើលលម្អិតថាតើវិសាលភាពនៃភ័ស្តុតាងអង្គហេតុណាមួយដែលពុំបានដាក់ស្ថិតក្រោមការពិនិត្យ **អ៊ឹម ចែម** អាចត្រូវប្រើប្រាស់សម្រាប់ការសម្រេចលើយុត្តាធិការបុគ្គលនោះទេ។ តាមពិត យើងជឿថា បើទោះជា **អ៊ឹម ចែម** ត្រូវបានចោទប្រកាន់ទៅបទចោទទាំងអស់លើគាត់ ដែលកំណត់ដោយ ស.ព.អ ក៏ដោយ ក៏គាត់នៅតែស្ថិតនៅក្រៅវង្វង់យុត្តាធិការនៃ អ.វ.ត.ក ដដែល។ យោង

---

[596] **សូមមើលវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង និងវិធាន ៥៧ នៃវិធានផ្ទៃក្នុង ព្រមទាំងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៦៦។**

[597] សូមមើល តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្ដី *Dallos តទល់នឹង ប្រទេសហុងគ្រី* ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០០១ កថាខណ្ឌ ៤៧។ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្ដី *Péllissier និង Sassi តទល់នឹង ប្រទេសបារាំង* ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ ៥០ - កថាខណ្ឌ ៥៤។

[598] **សំណុំរឿង ០០២-ឯកសារ D198/1** *ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបំភ្លឺអំពីបទចោទ* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០ KH ERN 00403608។

[599] **ឯកសារ D304/6** *ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រីតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ KH ERN 01376175 កថាខណ្ឌ ៥០ KH ERN 01376177- 01376181 កថាខណ្ឌ ៥៤-កថាខណ្ឌ ៥៨។

តាមហេតុនេះហើយទើបយើងនឹងបង្ហាញទិដ្ឋភាពរួមសង្ខេបមួយអំពីភស្តុតាងពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៥ ដែល អ៊ឹម ចែម ពុំត្រូវបានចោទប្រកាន់។

**ខ. ការពិនិត្យមើលដោយសង្ខេបលើភស្តុតាងអំពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ ដោយ ស.ព.អ ប៉ុន្តែពុំត្រូវបានចោទប្រកាន់ដោយ ស.ច.ស.អ លើ អ៊ឹម ចែម**

i. <u>ការពិចារណាបឋមលើលទ្ធភាពដែល អ៊ឹម ចែម អាចជាប់ពាក់ព័ន្ធជាមួយនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានពិនិត្យនៅក្នុងផ្នែកនេះ</u>

២៤៧. យោងតាមការសន្និដ្ឋានរបស់យើងនៅក្នុងផ្នែក IV(៤)(ii) ខាងលើ ទីតាំងឧក្រិដ្ឋកម្មនៅក្នុងស្រុកព្រះនេត្រព្រះស្ថិតនៅក្នុងរង្វង់សិទ្ធិអំណាចរបស់ អ៊ឹម ចែម។ វាលពិឃាតវត្តអង្គស្រីមុន្នី និងព្រៃសុខុន ស្ថិតនៅក្នុងស្រុកកោះអណ្តែត តំបន់ ១៣ ក្នុងភូមិភាគនិរតី។ ក្នុងផ្នែក IV(ខ) យើងបានរកឃើញថា **អ៊ឹម ចែម** ពុំមានសិទ្ធិអំណាចផ្នែកប្រតិបត្តិនៅក្នុងស្រុកនោះទេ។ ចំណុចចុងក្រោយ ទីតាំងពីរទៀតដែលនៅសេសសល់ គឺ វត្តចំការខ្នុរ និងទំនប់ត្រពាំងថ្ម គឺស្ថិតនៅក្នុងស្រុកស៊ីសុផុន និងស្រុកភ្នំស្រុក ក្នុងតំបន់ ៥។ យើងបានរកឃើញនៅក្នុងផ្នែក IV (៤) ខាងលើថា **អ៊ឹម ចែម** ស្ថិតនៅក្នុងគណៈតំបន់ ៥ ក្រោយពេលដកសមាជិកភូមិពាគពាយ័ព្យ ហើយយើងឃើញមានភស្តុតាងបញ្ជាក់ថា គាត់មានសិទ្ធិអំណាចលើសព្រំដែនសិទ្ធិអំណាចរដ្ឋបាលក្នុងស្រុកព្រះនេត្រព្រះទៅទៀត។ ទោះបីជាយ៉ាងនេះក្តី យើងក៏បានរកឃើញថា វិសាលភាព និងរូបភាពនៃសិទ្ធិអំណាចនេះពុំត្រូវបានរកឃើញយ៉ាងច្បាស់នៅក្នុងពេលស៊ើបអង្កេតនោះទេ។ យើងឃើញមានភស្តុតាងបង្ហាញពុំជាក់លាក់ខ្លះអំពីលទ្ធភាពនៃការពាក់ព័ន្ធរបស់គាត់នៅក្នុងការសាងសង់ទំនប់ត្រពាំងថ្ម។ ភស្តុតាងទាំងនេះនឹងយកមកពិភាក្សានៅក្នុងផ្នែក V(ខ)(៧) ខាងក្រោម។

## ii. វាលពិឃាតវត្តអង្គស្រីមុន្នី និងព្រៃសុខុន

២៤៨. វត្តអង្គសិរីមាលីស្ថិតនៅក្នុងឃុំព្រៃខ្លា ស្រុកកោះអណ្តែត តំបន់ ១៣ ក្នុងភូមិភាគនិរតី[600] រួមមាន វត្តមួយ ហើយនឹងយ៉ាងហោចណាស់អាគារពីរដែលបានប្រើប្រាស់សម្រាប់ឃុំមនុស្ស[601]។ ព្រៃសុខុនគឺជាទីតាំងវាលពិឃាតនៅក្នុងព្រៃជិតវត្តអង្គសិរីមាលី ដែលសាក្សីមួយចំនួន ពិពណ៌នាថាជាកន្លែងដែលគេបញ្ជូនមនុស្សយកទៅសម្លាប់ចោល[602]។

---

[600] **ឯកសារ D219/568** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ KH ERN 01165966 **ឆ.៥៤-ឆ.៥៧** ។ **ឯកសារ D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ KH ERN 00866861 **ឆ.៣៦**។ **ឯកសារ D119/82** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាង អ៊ូច ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ KH ERN 00971368 **ឆ.១៦** KH ERN 00971375 **ឆ.៦២**។ សូមមើលផងដែរ **ឯកសារ D119/9** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ KH ERN 01100827-01100828 ។ **ឯកសារ D1.3.10.14** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការវិភាគខេត្តតាកែវ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៨ KH ERN 00714205 -KH ERN 00714207 ។ **ឯកសារ D119/9.1** ឧបសម្ព័ន្ធ១៖ ផែនទីនៃបណ្តាញផ្លូវថ្នល់ក្នុងខេត្តតាកែវ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ EN ERN 00887256។

[601] **ឯកសារ D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ KH ERN 00866860 **ឆ.៣៣**។ **ឯកសារ D119/9** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ KH ERN 01100828 ។

[602] **ឯកសារ D119/5** កំណត់ហេតុស្តាប់ចម្លើយសាក្សី ហង់ សុង ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ KHKH ERN 00872457 **ឆ.៣៥-ឆ.៣៧**។ **ឯកសារ D119/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១២ KH ERN 00872468- 00872469 **ឆ.២១-ឆ.២៨**។ **ឯកសារ D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ KH ERN 00866859-00866860 **ឆ.២៨ ឆ.៣០** KH ERN 00866860 **ឆ.៣៤**។ **ឯកសារ D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ KH ERN01169866-01169867 **ឆ.៣៤ ឆ.៣៦** KH **ឆ.៣៧**។ **ឯកសារ D119/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ឆេង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ KH ERN 00893282 **ឆ.១២**។ **ឯកសារ D219/604** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ KH ERN 01173499 **ឆ.៦៩**។ សូមមើលផងដែរ **ឯកសារ D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ KH ERN 00872486 **ឆ.៣០**។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

២៤៩. ទីតាំងទាំងពីរនេះដំណើរការពីខែមេសា ឆ្នាំ១៩៧៥ ដល់យ៉ាងហោចណាស់ខែវិច្ឆិកា ឆ្នាំ១៩៧៨[603]។ ភ័ស្តុតាងបង្ហាញថា នៅក្នុងអំឡុងពេលនោះ អ្នកទោសដែលជាប់ឃុំឃាំងនៅវត្តអង្គសិរីមាលី គឺជាខ្មែរក្រោម និងប្រជាជន ១៧ មេសា[604] ហើយដែលត្រូវបានគេយកទៅសម្លាប់ចោលនៅព្រៃសុខុន។ សាក្សីម្នាក់លើកឡើងថា ប្រជាជន ១៧ មេសា ត្រូវ បាន គេឲ្យជីកផ្នូរដាក់ខ្លួនឯង ហើយបានឃើញគេវាយសម្លាប់មនុស្សពីរ ឬបីនាក់ដោយប្រើប្រាស់ដំបងឫស្សីជារៀងរាល់ថ្ងៃរយៈពេលមួយខែ[605]។ សាក្សីម្នាក់ផ្សេងទៀតយល់ឃើញថា ការកាប់សម្លាប់ទាំងនោះបានកើតឡើង *"ជារៀងរាល់ថ្ងៃជាហូរហែមក"* ក្នុងអំឡុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[606] ហើយសាក្សីម្នាក់ទៀតពន្យល់ថា នេះគឺជាផែនការខ្មែរ ក្រហមក្នុងការបណ្តុះចលនាបដិវត្តន៍[607]។

២៥០. ផ្នូរ ឬ រណ្តៅមួយចំនួនត្រូវបានគេរកឃើញក្រោយឆ្នាំ១៩៧៩ ប៉ុន្តែយើងពុំអាចបញ្ជាក់ឲ្យបានត្រឹមត្រូវថាតើមានមនុស្សប៉ុន្មាននាក់ស្លាប់នៅវត្តអង្គសិរីមាលី ឬ ព្រៃសុខុន។ សាក្សីម្នាក់ប៉ាន់ស្មានថា យើងឃើញទំនងមានមនុស្សរាប់រយនាក់ជាប់ឃុំឃាំងនៅ

---

[603] **ឯកសារ D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ KH ERN 00866860 ទ.៣៤។ **ឯកសារ D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ KH ERN 01169868 ទ.៤៧។ **ឯកសារ D119/10** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃ ក.ស.ច.ស ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២ KH ERN 00981802 ។

[604] **ឯកសារ D219/568** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ KH ERN 01165967 ទ.៦១។ សូមមើលផងដែរ **ឯកសារ D119/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ KH ERN 00872487 ទ.៣៦។ **ឯកសារ D219/591** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ KH ERN 01169871 ទ.៧១-ទ.៧៤។ **ឯកសារ D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ KH ERN 00866858 ទ.១៧-ទ.១៩។ **ឯកសារ D219/604** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ KH ERN 01173499 ទ.៧៤។

[605] **ឯកសារ D219/604** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ KH ERN 01173499 ទ.៧០-ទ.៧៤។

[606] **ឯកសារ D119/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង ណុប ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ KH ERN 00866860 ទ.៣៤។

[607] **ឯកសារ D119/16** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ឆេង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ KH ERN 00893282 ទ.១២។



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

01508439



វត្តអង្គសិរីមាលី[608] ហើយសាក្សីម្នាក់ទៀតប៉ាន់ស្មានថា មនុស្សប្រហែល ៤.០០០ នាក់ ត្រូវបានគេសម្លាប់នៅព្រៃសុខុន[609]។

២៥១. យើងពុំឃើញមានភស្តុតាងបង្ហាញអំពីការជាប់ពាក់ព័ន្ធរបស់ អ៊ឹម ចែម ជាមួយនឹងទីតាំងឧក្រិដ្ឋកម្មនេះ។ ផ្ទុយពីការចោទប្រកាន់របស់ ស.ព.អ[610] យើងពុំឃើញមានភស្តុតាងបង្ហាញថា អ៊ឹម ចែម បានកាន់កាប់មុខតំណែងពាក់ព័ន្ធនឹងប្រតិបត្តិការនៅវត្តអង្គមាលី ឬ ព្រៃសុខុន គាត់ចុះពិនិត្យទីតាំងទាំងនេះ ឬ គាត់បានចេញបញ្ជាដោយផ្ទាល់ពាក់ព័ន្ធនឹងទីតាំងទាំងនេះ។

iii. <u>វត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ</u>

២៥២. ភស្តុតាងបង្ហាញថា ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតីយ៉ាងហោចណាស់ពីឆ្នាំ១៩៧៧ រហូតដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ យើងពុំដឹងថាមានមនុស្សប៉ុន្មាននាក់ដែលជាប់ឃុំឃាំង និងត្រូវបានគេសម្លាប់ចោល ឬ សម្លាប់ដោយសារការអត់អាហារ ឬ ជំងឺនៅវត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធនានាទេ។

ទោសតាមរយៈការបន្ថយរបបអាហារ[705]។ ម្យ៉ាងវិញទៀត តាមរបាយការណ៍ អ្នករត់គេចពីការងារត្រូវបានដាក់ទោសឲ្យធ្វើការងារធ្ងន់ធ្ងរជាងមុន[706] បញ្ជូនទៅ "*រៀនសូត្រ*" និងពុំដែលឃើញត្រឡប់មកវិញទេ[707] ឬ តាមដានប្រវត្តិរូប និងទទួល "*ទោសស្រាល*"[708]។ អ្នកធ្វើការមានការភ័យខ្លាចមិនហ៊ានរត់គេចខ្លួនទេ ដោយសារខ្លាចគេឃើញ[709] ហើយដោយខ្លាច គេសម្លាប់ចោលពេលចាប់បាន[710]។ អ្នករត់គេចខ្លួនពីការដ្ឋានទំនប់មួយចំនួនត្រូវបានគេឃុំខ្លួននៅមន្ទីរ សន្តិសុខភ្នំលៀប[711]។

២៧៦. សាក្សីបានលើកឡើងអំពីរយៈកាលចុងឆ្នាំ១៩៧៦ ដល់ ចុងឆ្នាំ១៩៧៨ ថា កម្មករត្រូវបានគេបញ្ជូនទៅអប់រំ[712] ឬ រៀនសូត្រ[713] ចាប់ខ្លួន[714] ឬ ត្រូវបានគេយកទៅបាត់[715] ហើយជា

---

705 **ឯកសារ D119/78** កំណត់ហេតុនៃការស្តាប់ចម្លើយ ឡុត បណ្តែត ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ KH ERN 00971157 ឆ.១១។

706 **ឯកសារ D6.1.430** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ថុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH ERN 00267754 ។

707 **ឯកសារ D219/361** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01105587 ឆ.៥៧។សូមមើលផងដែរ **ឯកសារ D219/35** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម សីលា ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ KH ERN 01032082-01032083 ឆ.៣៣ ឆ.៣៥។

708 **ឯកសារ D6.1.357** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េង ប៊ុនថារ៉ា ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ KH ERN 00295962 ។

709 **ឯកសារ D119/120** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00984320 ឆ.១៣៧។

710 **ឯកសារ D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤ KH ERN 01049239 ឆ.១៣៣។ សូមមើលផងដែរ **ឯកសារ D6.1.426** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH ERN 00267765 ។

711 **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976178-00976179 ឆ.២៩ ឆ.៣២។

712 **ឯកសារ D6.1.425** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ ថាន KH ERN 00267780-00267784 ។ **ឯកសារ D6.1.345** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុត ផល ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH ERN 00279115 ។

713 **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976178 ឆ.២៨។ **ឯកសារ D6.1.425** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ ថាន ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH ERN

ញ៉ីកញាប់ពុំដែលឃើញវិលត្រឡប់មកវិញឡើយ[716]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានលើកឡើងយ៉ាងច្បាស់លាស់ថា មនុស្សកាន់តែច្រើនឡើងៗត្រូវបានគេបញ្ជូនទៅវគ្គរៀនសូត្រ ដោយសារពុំបានបំពេញតាមផែនការ ហើយពុំដែលឃើញវិលត្រឡប់មកវិញនោះទេក្រោយពេល **អ៊ឹម ចែម** បានមកដល់ បើធៀបនឹងរយៈកាលមុន[717]។ សាក្សីម្នាក់អះអាងថា **អ៊ឹម ចែម** បានបញ្ជាកងឈ្លបឱ្យវាយដំ និងចាប់ខ្លួនអ្នកដែលដួលសន្លប់ដោយសារហត់ហេវអស់កម្លាំង[718]។ អតីតកម្មករម្នាក់និយាយថា ក្នុងរយៈពេល ២៤ ម៉ោងក្នុងឆ្នាំ១៩៧៨ គ្រួសារ "វៀតណាម" ប្រហែល ១.០០០ នាក់ពី

---

00267783 ។ សូមមើលផងដែរ **ឯកសារ D219/361** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01105590 ទ.៨៥។

[714] **ឯកសារ D6.1.450** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ KH ERN 00279104 ។ **ឯកសារ D6.1.426** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH ERN 00267766 ។ **ឯកសារ D6.1.430** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ថុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH ERN 00267755 ។ **ឯកសារ D6.1.452** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ៃ កើត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH ERN 00279099 ។

[715] **ឯកសារ D119/90** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន ភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976140 ទ.១១។ **ឯកសារ D219/1** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យូ មុត ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ KH ERN 01024616 ទ.១៥ ទ.១៦។

[716] **ឯកសារ D6.1.450** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ KH ERN 00279104-00279105 ។ **ឯកសារ D6.1.452** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ៃ កើត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH ERN 00279099 ។ **ឯកសារ D6.1.425** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ ថាន ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH ERN 00267783 ។ **ឯកសារ D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976178 ទ.២៨។ **ឯកសារ D119/90** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន ភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH ERN 00976140 ទ.១១។ សូមមើល **ឯកសារ D6.1.430** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ថុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH ERN 00267755 ។

[717] **ឯកសារ D219/361** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ 2015 KH ERN 01105591 ទ.៩០។

[718] **ឯកសារ D119/131** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ KH ERN 00996506 ទ.១២១។

សហករណ៍នៅជុំវិញនោះបានបាត់ខ្លួនពីការដ្ឋាន[719]។ ចំនួននេះគឺជាចំនួនមួយផ្នែកធំនៃកម្លាំងការងារ។ ភ័ស្តុតាងក៏ពុំបានបង្ហាញច្បាស់លាស់ថាតើគ្រួសារវៀតណាមជាច្រើនគ្រួសារទាំងនេះពិតជាធ្លាប់បានធ្វើការនៅទំនប់ដែរឬទេ។ ដោយសារមានចំនួនមនុស្ស ១.000 គ្រួសារ គឺអាចឱ្យកម្មករផ្សេងទៀតមើលឃើញ ហើយការបាត់ខ្លួនពួកគេក្នុងរយៈពេលតែមួយយប់ ក៏អាចឱ្យពួកគេដឹងផងដែរ។ ការដែលគ្មានភ័ស្តុតាងផ្សេងទៀតគាំទ្រទៅសក្ខីកម្មរបស់សាក្សីរូបនេះ យើងមានការសង្ស័យលើភាពត្រឹមត្រូវនៃចម្លើយនេះ។

២៧៧. សាក្សីក៏ពិពណ៌នាអំពីកម្មករស្លាប់ដោយសារការដាច់អាហារ ឬជំងឺ ដោយសារការខ្វះអាហារ[720] ហើយនឹងការហត់ហេវបាក់កម្លាំងពេលកំពុងធ្វើការងារក្រោមការដឹកនាំនៃភូមិភាគពាយ័ព្យ និងភូមិភាគនិរតី[721]។ សាក្សីម្នាក់លើកឡើងថា ប្រជាជនស្លាប់ដោយសារការដាច់អាហារ និងជំងឺ[722] ហើយប្រជាជនទាំងនេះ "*ជាច្រើននាក់*" បានស្លាប់ដោយសារជំងឺគ្រុនចាញ់[723] ជាពិសេស "*ប្រជាជនថ្មី*"។ ទោះបីជាយ៉ាងនេះក្ដី យើងពុំឃើញមានការបញ្ជាក់អំពីពេលវេលានោះឡើយ។

---

[719] **ឯកសារ D119/23** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ុត ស្វឹយ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ 2013 KH ERN 00894519 ទ.២0។

[720] **ឯកសារ D119/120** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ដ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២0១៤ KH ERN 00984321 ទ.១៥៥-ទ.១៥៦។

[721] **ឯកសារ D6.1.345** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុត ផល ថ្ងៃទី 0៤ ខែ កុម្ភៈ ឆ្នាំ ២00៩ KH ERN 00279115 ។ **ឯកសារ D119/131** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថង ជឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២0១៤ KH ERN 00996505 ទ.១១៤។

[722] **ឯកសារ D219/130** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី 0៨ ខែ ធ្នូ ឆ្នាំ ២0១៤ KH ERN 01049238 ទ.១២៤។

[723] **ឯកសារ D219/130** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី 0៨ ខែ ធ្នូ ឆ្នាំ ២0១៤ KH ERN 01049238 ទ.១២៥។



CO-INVESTIGATING JUDGES * ECCC * C.E.T.C. * CO-JUGES D'INSTRUCTION

២៧៨. យើងឃើញមានភ័ស្តុតាងបន្ថែមទៀតពាក់ព័ន្ធនឹងការកាប់សម្លាប់ និងការបាត់ខ្លួន ដែលយើងពុំអាចបញ្ជាក់អំពីវិសាលភាពពេលវេលាបាន[724]។ យើងក៏ពុំអាចបង្ហាញឲ្យបានត្រឹមត្រូវពីភ័ស្តុតាងផ្សេងទៀតដែលមានស្រាប់អំពីចំនួនមនុស្សដែលធ្វើការនៅត្រពាំងថ្មក្នុងអំឡុងពេលណា ហើយនឹងចំនួនប្រជាជនសរុបដែលអាចស្លាប់នៅការដ្ឋាននោះដែរ។

viii. <u>ការរំលោភសេពសន្ថវៈ ការធ្វើមនុស្សឃាតស្ត្រីជាប់ខ្សែស្រឡាយវៀតណាមពីររូបនៅព្រះនេត្រព្រះ</u>

២៧៩. សាក្សីចំនួនពីរនាក់ពិពណ៌នាពីការកាប់សម្លាប់បងប្អូនស្រីជាប់ខ្សែស្រឡាយវៀតណាមចំនួនពីរនាក់[725] នៅកន្លែងមួយ ដែលពុំមានការបញ្ជាក់ទីតាំងច្បាស់លាស់ក្នុងស្រុកព្រះនេត្រព្រះ[726]។ សាក្សីម្នាក់បានលើកឡើងថា នៅមុនពេលសម្លាប់ សមាជិកកងចល័តបានរំលោភបងប្អូន ស្រីទាំងពីរនាក់នេះនៅពេលនោះ។ ក៏ប៉ុន្តែ សាក្សីរូបនេះបានឮហេតុការណ៍នេះពីសាក្សីផ្សេង[727]ដែលសាក្សីនេះបែរជាបដិសេធថាពុំមានហេតុការណ៍ដូច្នេះកើតឡើងទៅវិញ[728]។ សាក្សីទាំងពីរលើកឡើងខុសគ្នាពីពេលវេលានៃហេតុការណ៍នេះ[729]។

---

[724] **ឯកសារ D6.1.428** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត អ៊ិន ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH ERN 00267738-00267739 ។ **ឯកសារ D6.1.345** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុត ផល ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH ERN 00279115 ។ **ឯកសារ D6.1.343** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យី ឡៃសួរ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH ERN 00279134 ។

[725] **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978923 ឆ.៣៣។ **ឯកសារ D123/1/2.52** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ភាច រស់ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ 00927187 ។

[726] **ឯកសារ D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00985867 ឆ.៣ ឆ.៥ KH ERN 00985869 ឆ.១៨។ **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978922 ឆ.៣១។

[727] **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978923 ឆ.៣៣។

[728] **ឯកសារ D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00985867 ឆ.៤ KH ERN 00985868 ឆ.១១។ កោ ឡិន និយាយថា គាត់គ្រាន់តែបានឮគេនិយាយពីការសម្លាប់

២៨០. សរុបមក មានភស្តុតាងពុំគ្រប់គ្រាន់បង្ហាញអំពីការកាប់សម្លាប់ និងការរំលោភសេពសន្ថវៈ ដែលបានចោទប្រកាន់ ទីតាំង និងពេលវេលា អត្តសញ្ញាណរបស់ចារីផ្ទាល់ និងកងចល័ត ណាមួយដែលបានចូលរួមពាក់ព័ន្ធនឹងហេតុការណ៍នេះ។

## VI. សំអាងច្បាប់លើឧក្រិដ្ឋកម្ម

### ក. ធាតុផ្សំ "មូលដ្ឋាន" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

២៨១. យើងជឿថា ចន្លោះពីខែមេសា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែលជាពេលវេលាពាក់ព័ន្ធទៅនឹងបទចោទប្រឆាំងនឹង អ៊ឹម ចែម[730] នោះ កម្មាភិបាលភូមិភាគនិរតីបានធ្វើការវាយប្រហារទៅលើប្រជាជនស៊ីវិលនៅក្នុងភូមិភាគពាយ័ព្យនៃកម្ពុជាប្រជាធិបតេយ្យ រួមទាំងតំបន់ ៥ ផងដែរ។ ភស្តុតាងបង្ហាញថា ការវាយប្រហារនេះបានធ្វើឡើងក្នុងទម្រង់ជាពលកម្មដោយបង្ខំ និងការតម្រូវឱ្យរស់នៅក្នុងស្ថានភាពលំបាក។ កម្មករបានទទួលរងការឈឺចាប់យ៉ាងខ្លាំង ទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយជាទូទៅ ពួកគេបានស្លាប់ដោយសារតែការនឿយហត់ខ្លាំង ការអត់ឃ្លាន និងជំងឺ។ ទីពីរ ការវាយប្រហាររួមមាន "ការរៀនសូត្រ" ឬការបោសសម្អាត "សមាសធាតុមិនល្អ" ឬ "ខ្មាំង" ពិតប្រាកដ ឬតាមការគិតរបស់ ប.ក.ក ប្រជាជនដែលគេគិតថាមានទំនាក់ទំនងជាមួយវៀតណាម អតីតអ្នករដ្ឋការ និងយោធារបស់របបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ និងកម្មាភិបាលភូមិភាគពាយ័ព្យ។ ប្រជាជនដែលត្រូវបានកំណត់ថាស្ថិតក្នុងក្រុមទាំងអស់នេះ

---

ប៉ុណ្ណោះ (**ឯកសារ D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00985868 ឆ.១២ KH ERN 00985869 ឆ.២២) ហើយគាត់មិនដឹងថាអ្នកណាជាអ្នកបញ្ជាឱ្យសម្លាប់ ឬអ្នកណាជាអ្នកសម្លាប់នោះទេ (**ឯកសារ D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00985869 ឆ.២០ KH ERN 00985873 ឆ.៤៧)។

[729] **ឯកសារ D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978920 ឆ.១៥។ **ឯកសារ D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00985867 ឆ.៣។ ក្រោយខែ ឧសភា ឆ្នាំ ១៩៧៧ សូមមើល **ឯកសារ D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00978910 ឆ.១៩។

[730] ឯកសារ D239.1, *ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទ ប្រឆាំង អ៊ឹម ចែម, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥,* កថាខណ្ឌ ៣ KH ERN 01070890 ។

ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សផ្សេងៗ នៅក្នុងតំបន់ ៥ ដូចជាមន្ទីរសន្តិសុខភ្នំត្រយោង ដែលនៅទីនោះ ពួកគេរាប់រយនាក់ត្រូវបានសម្លាប់។

២៨២. ចំនួនជនរងគ្រោះនៅទីតាំងឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមការត្រួតពិនិត្យ តែងតែជាចំណុចដែល ពិបាកក្នុងការកំណត់ឱ្យបានច្បាស់លាស់។ ទោះជាយ៉ាងនេះក្ដី ភស្តុតាងបង្ហាញថា បើទោះបីជាពឹងផ្អែកទៅលើការប៉ាន់ស្មានក្នុងកម្រិតទាបក៏ដោយ ប្រជាជនរាប់ពាន់នាក់នៅទូទាំងតំបន់ ៥ ត្រូវបានកំណត់ជាគោលដៅសម្រាប់ការវាយប្រហារ ដែលអាចត្រូវបានកំណត់ថាជាការកើតមានទូទៅ។ ការវាយប្រហារនេះក៏មានលក្ខណៈជាប្រព័ន្ធផងដែរ ដោយអ្នកដែលគេចាត់ទុកថាជាខ្មាំងរបស់ ប.ក.ក ត្រូវបានចាប់ខ្លួន និងសម្លាប់ និងប្រជាជនធ្វើការក្នុងស្ថានភាពលំបាកនៅទូទាំងតំបន់៥។

២៨៣. ការវាយប្រហារត្រូវបានធ្វើឡើងសំដៅទៅលើប្រជាជនស៊ីវិល ដោយសារមូលហេតុនយោបាយ។ ការវាយប្រហារនេះមានគោលដៅទៅលើប្រជាជនដែលគេចាត់ទុកថា មិនអាចទុកចិត្តបានផ្នែកនយោបាយ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ក៏ត្រូវបានហៅម្យ៉ាងទៀតថាជា អ្នករដ្ឋការ លន់ នល់) កម្មាភិបាលភូមិភាគពាយ័ព្យ ដែលត្រូវបានចោទប្រកាន់ថាជា "ជនក្បត់" និងអ្នកទាំងឡាយណាដែលត្រូវបានចាត់ទុកថាធ្វើឱ្យប៉ះពាល់ដល់បដិវត្ត ដោយសារតែការខ្ជិលច្រអូល ឬប្រព្រឹត្ត "កំហុស"។ ការវាយប្រហារនេះតាមពិតទៅ គឺជាការអនុវត្តរបៀបវារៈនយោបាយរបស់ ប.ក.ក។

២៨៤. **អ៊ឹម ចែម** មានទំនាក់ទំនងផ្ទាល់ជាមួយ តាម៉ុក ដែលជាមេគំនិតនៃការជម្លៀសកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ និងការបោសសម្អាតដែលកើតឡើងនាពេលបន្ទាប់។ គាត់បានដឹកនាំកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ ហើយនៅពេលដែលទៅដល់ទីនោះ គាត់ក៏បានទទួលខុសត្រូវទៅលើការដ្ឋាន និងមន្ទីរសន្តិសុខមួយនៅថ្នាក់តំបន់។ ភស្តុតាងបានបង្ហាញថា គាត់បានទទួលដំណឹងអំពីអ្វីដែលបានកើតឡើងនៅមូលដ្ឋានតាមរយៈប្រភពជាច្រើន ដូចជា របាយការណ៍ ការចុះពិនិត្យផ្ទាល់ ការប្រជុំ និងនិរសា។ ហេតុដូច្នេះ យើងជឿថា គាត់បានដឹងអំពីអត្ថិភាពនៃការវាយប្រហារ ហើយសកម្មភាពរបស់គាត់គឺជាផ្នែកមួយនៃការវាយប្រហារនេះ។



ECCC * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D' INSTRUCTION"

### ខ. ការកំណត់ប្រភេទនៃបទល្មើសដែលត្រូវបានរកឃើញថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង

#### i. <u>មន្ទីរសន្តិសុខភ្នំត្រយោង</u>

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការធ្វើមនុស្សឃាត*

២៨៥. យើងជឿថា ការសម្លាប់មនុស្សរាប់រយនាក់ត្រូវបានធ្វើឡើងនៅចន្លោះពាក់កណ្តាលឆ្នាំ ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅមន្ទីរសន្តិសុខភ្នំត្រយោង គឺជាអំពើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

២៨៦. លើសពីនេះទៀត យើងសូមរម្លឹកថា អ្នកទោសតែងតែត្រូវបានផ្តល់អាហារមិនគ្រប់គ្រាន់ នៅខណៈដែលពួកគេត្រូវបានបង្ខំឱ្យធ្វើពលកម្មធ្ងន់។ ដោយមូលហេតុនេះហើយទើបមានមនុស្សរាប់រយនាក់បានស្លាប់ ដោយសារតែការអត់ឃ្លាន និងការធ្វើការហួសកម្លាំង។ យើងយល់ឃើញថា យ៉ាងហោចណាស់ ចារីប្រាកដជាអាចប្រមើលមើលដឹងថា អ្នកទោសដែលត្រូវបានផ្តល់អាហារមិនគ្រប់គ្រាន់ ហើយត្រូវបង្ខំឱ្យធ្វើពលកម្មធ្ងន់ ឬត្រឹមតែការបង្អត់អាហារនេះ ក៏អាចធ្វើឱ្យមានការអត់ឃ្លាន និងស្លាប់បានដែរ។ ហេតុដូច្នេះ យើងជឿថា ការស្លាប់ទាំងអស់នេះគឺជាអំពើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពនៃការសម្លាប់រង្គាល*

២៨៧. យើងសូមរម្លឹកពីភស្តុតាងរបស់សាក្សីម្នាក់អំពីការសម្លាប់មនុស្សជាច្រើននាក់នៅក្នុងពេលមួយយប់ និងមួយព្រឹក នៅមន្ទីរសន្តិសុខភ្នំត្រយោង។ យើងយល់ឃើញថា ចំនួនជនរងគ្រោះពី ៧០០ នាក់ ទៅ ១០០០ នាក់ ដែលសាក្សីផ្តល់ឱ្យនោះ មិនអាចឱ្យជឿបានឡើយ។ ការណ៍ដែលជនរងគ្រោះនៃហេតុការណ៍នោះ តាមការចោទប្រកាន់ថា មានចំនួនច្រើនត្រូវបានសម្លាប់ជាផ្នែកមួយនៃប្រតិបត្តិការតែមួយនៅក្នុងអំឡុងពេលដ៏ខ្លី មិនបានគាំទ្រដល់ការសន្និដ្ឋានថា ការសម្លាប់នេះត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំសម្រាប់គោលបំណងនៃការសម្លាប់រង្គាលឡើយ។ ភស្តុតាងរបស់សាក្សីនេះមិនអាចឱ្យជឿជាក់បានទាល់តែ

នោះ សម្រាប់គាំទ្រដល់ការសន្និដ្ឋានអំពីអត្តសញ្ញាណក្រុមមួយ ដែលអាចបំពេញតាមលក្ខខណ្ឌកម្រិតខ្ពស់ដែលកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូលឡើយហើយបញ្ហានេះក៏មានដូចគ្នាចំពោះលក្ខណៈវិនិច្ឆ័យនៃ "ទ្រង់ទ្រាយធំ"។ យើងមិនអាចដកការសន្និដ្ឋានថាហេតុការណ៍នេះជាហេតុការណ៍មួយ ទោះជាហេតុការណ៍ដ៏ធំមួយ ក្នុងចំណោមការសម្លាប់ជាប្រចាំជារួមនោះបានឡើយ។

២៨៨. ចំពោះការសម្លាប់ទាំងអស់ដែលត្រូវបានប្រព្រឹត្តឡើងជាប្រចាំនៅមន្ទីរសន្តិសុខភ្នំត្រយោងនោះ ចំនួននៃការសម្លាប់សរុបរួមបានឈានដល់លក្ខខណ្ឌនៃទ្រង់ទ្រាយធំ។ ពួកគេទាំងនោះត្រូវបានសម្លាប់ដោយសារមូលហេតុដូចគ្នា គឺអាកប្បកិរិយាដែលផ្ទុយទៅនឹងមនោគមន៍វិជ្ជា និងគោលនយោបាយរបស់ ប.ក.ក។ ទោះជាយ៉ាងនេះក្ដី ការសម្លាប់ទាំងអស់នេះត្រូវបានធ្វើឡើងក្នុងរយៈពេលយូរ ហើយប្រហែលជាធ្វើឡើងដោយចារីផ្ទាល់ផ្សេងៗគ្នាផង។ កាលៈទេសៈទាំងអស់នេះធ្វើឲ្យមានភាពមិនច្បាស់លាស់ថាតើ ការសម្លាប់ទាំងនេះត្រូវបានធ្វើឡើងដោយមានចេតនាសម្លាប់ជាទ្រង់ទ្រាយធំដែរឬយ៉ាងណា។ ហេតុដូច្នេះ យើងជឿថា មិនមានមូលដ្ឋានសមហេតុផលឲ្យជឿបានថា ការស្លាប់ទាំងអស់នេះ បន្ថែមលើការធ្វើមនុស្សឃាត គឺជាការសម្លាប់រង្គាលនោះឡើយ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការដាក់ឲ្យទៅជាទាសករ*

២៨៩. មានមូលដ្ឋានរឹងមាំឲ្យជឿថា ឧក្រិដ្ឋកម្មនៃការដាក់ឲ្យទៅជាទាសករ ត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំត្រយោង។ អ្នកទោស រួមទាំងកុមារផង ត្រូវបានការពារ និងឃាមកាមដោយអ្នកយាមប្រដាប់អាវុធ នៅពេលដែលពួកគេធ្វើការ។ អ្នកធ្វើការត្រូវបានគំរាមកំហែង ហើយអ្នកដែលព្យាយាមរត់គេច ត្រូវបានដាក់ទណ្ឌកម្ម ហើយប្រហែលជាអាចត្រូវបានសម្លាប់ផង។ យើងជឿថា អ្នកគ្រប់គ្រងគុកមានចេតនា និងពិតជាបានប្រើប្រាស់សិទ្ធិអំណាចដែលមានជាទូទៅជាម្ចាស់ទៅលើអ្នកដែលត្រូវបានឃុំឃាំង និងធ្វើការនៅមន្ទីរសន្តិសុខភ្នំត្រយោង។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការដាក់ក្នុងមន្ទីរឃុំឃាំង*

01508467



២៩០. ភស្តុតាងដែលបានលើកឡើងខាងលើក៏បានបង្ហាញផងដែរថា អ្នកដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំត្រយោង ត្រូវបានចាប់ខ្លួនតាមអំពើចិត្ត (ដូចជា ដោយសារ "ខ្ជិលច្រអូស" មានកំហុសក្នុងពេលធ្វើការងារ ឬគ្រាន់តែដោយសារជាប់ទំនាក់ទំនងជាមួយអ្នកដែលត្រូវបានចាប់ខ្លួន)។ ពេលខ្លះ អ្នកដែលត្រូវបានចាប់ខ្លួនមិនត្រូវបានប្រាប់ពីមូលហេតុនៃការចាប់ខ្លួនឡើយ ទោះប្រាប់ក្នុងភាពមិនច្បាស់លាស់ក៏ដោយ ហើយអ្នកយាមគុកក៏មិនបានទទួលឯកសារដែលពន្យល់ពីមូលហេតុនៃការឃុំឃាំងឡើយ នៅពេលដែលអ្នកទោសទៅដល់មន្ទីរសន្តិសុខភ្នំត្រយោងនោះ។ អ្នកទោសទាំងអស់ត្រូវបានដកហូតសិទ្ធិសេរីភាព ហើយត្រូវបានឃុំខ្លួនដោយមិនមានដំណើរការផ្លូវច្បាប់ត្រឹមត្រូវនោះឡើយ។ ចុងក្រោយ ការឃុំខ្លួននោះមានរយៈពេលគ្រប់គ្រាន់តាមលក្ខខណ្ឌនៃស្ថានទម្ងន់ ដូចទៅនឹងកម្រិតកំណត់នៃបទល្មើសដទៃទៀត ដែលមានចែងក្នុងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

២៩១. ភស្តុតាងពាក់ព័ន្ធនឹងមូលហេតុតាមអំពើចិត្ត ឬការមិនមានមូលហេតុនៃការចាប់ខ្លួន បានបង្ហាញពីចេតនារបស់អាជ្ញាធរក្នុងការចាប់ខ្លួនដោយមិនមានដំណើរការផ្នែកព្រហ្មទណ្ឌ។ ចារីប្រាកដជាបានដឹងថា ការចាប់ខ្លួនទាំងអស់នេះមិនអាចធ្វើឡើងបានឡើយ បើអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌនោះ។

២៩២. ហេតុដូច្នេះ យើងជឿថា ការឃុំខ្លួនមនុស្សជាង ១០០០ នាក់ នៅមន្ទីរសន្តិសុខភ្នំត្រយោង ចន្លោះពីពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់ចុងឆ្នាំ ១៩៧៨ គឺជាការដាក់ក្នុងមន្ទីរឃុំឃាំង ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាអំពើអមនុស្សធម៌ដទៃទៀត*

២៩៣. អ្នកទោសនៅមន្ទីរសន្តិសុខភ្នំត្រយោង ត្រូវបានផ្តល់អាហារ និងទឹកមិនគ្រប់គ្រាន់ជាប្រចាំ។ ចំណុចនេះត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈរបាយការណ៍ស្របៗគ្នាអំពីចំនួនមនុស្សដែលស្លាប់យ៉ាងច្រើន ដោយសារតែការអត់ឃ្លាន។ ពួកគេត្រូវបានរក្សាទុកក្នុងលក្ខខណ្ឌ អនាម័យមិនល្អ។ លើសពីនេះទៀត អ្នកទោសដែលគេចាត់ទុកថាជាអ្នកប្រព្រឹត្តល្មើសកម្រិតធ្ងន់ ត្រូវបានគេដាក់ខ្នោះជើងនៅពេលយប់។ យើងជឿថា ការដាក់ឲ្យស្ថិត



INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

01508468



ក្នុងស្ថានភាពទាំងអស់នេះ គឺការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូរបស់មនុស្ស ដែលមានស្ថានទម្ងន់គ្រប់គ្រាន់ឲ្យចាត់ទុកថាជាអំពើអមនុស្សធម៌ដទៃ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

២៩៤. មានរបាយការណ៍អំពីអ្នកទោស ដែលបាត់ខ្លួន ហើយមិនដែលឃើញត្រឡប់មកវិញ។ ទោះជាយ៉ាងនេះក្តី មិនមានភស្តុតាងបង្ហាញថា អាជ្ញាធរបានបដិសេធលើសំណើសុំបង្ហាញព័ត៌មានអំពីទីតាំង និងជោគវាសនារបស់ជនរងគ្រោះ ដែលនេះជាធាតុផ្សំគន្លឹះនៃឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំឡើយ។ ដោយពិចារណាទៅការសន្និដ្ឋានរបស់យើងអំពីអំពើមនុស្សឃាត និងការសម្លាប់រង្គាល ក៏អាចមានលទ្ធភាពដែលថា អ្នកដែលមិនឃើញត្រឡប់មកវិញទាំងនោះ តាមពិតទៅត្រូវបានគេសម្លាប់។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលហេតុនយោបាយ*

២៩៥. មនុស្សជាច្រើនដែលត្រូវបានឃុំខ្លួន ត្រូវបានដាក់ឲ្យទៅជាទាសករ និងត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោង គឺជាកម្មាភិបាលភូមិភាគពាយ័ព្យ ជាអតីតអ្នករដ្ឋការលន់ នល់ ជាមនុស្សដែលគេគិតថាមានទំនាក់ទំនងជាមួយវៀតណាម ឬ ជាមនុស្សដែលគេចាត់ទុកថាជា "ជនក្បត់" ប.ក.ក ឬ "សមាសធាតុមិនល្អ" ដែលបង្ហាញពីលក្ខណៈមួយនៃអ្នកទាំងឡាយណាដែលគេគិតថាមានអាកប្បកិរិយាប្រឆាំង ឬមិនស្របជាមួយគោលនយោបាយ ឬគំនិតរបស់ ប.ក.ក។ ពួកគេត្រូវបានកំណត់គោលដៅ និងត្រូវបានដកហូតនូវសិទ្ធិជាសារវ័ន្ត ដូចជា សេរីភាពបុគ្គល បូរណភាពនៃរាងកាយ និងសិទ្ធិក្នុងការរស់នៅរបស់ពួកគេ ដោយសារតែពួកគេស្ថិតក្នុងប្រភេទមនុស្សទាំងអស់នេះ។ ហេតុដូច្នេះ យើងជឿថាឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត ដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រភេទមនុស្សទាំងអស់នេះ គឺជាការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលហេតុនយោបាយ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

*អំពើមនុស្សឃាតដោយគិតទុកជាមុន*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ៧១ ទូរសព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Original EN: 01476906-01477009

២៩៦. ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខភ្នំត្រយោង គឺជាអំពើមនុស្សឃាតដោយគិតទុកជាមុន អនុលោមតាមមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

ii. <u>ការដ្ឋានប្រឡាយស្ពានស្រែង</u>

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការធ្វើមនុស្សឃាត*

២៩៧. មិនមានភស្តុតាងច្បាស់លាស់អំពីអ្នកធ្វើការដែលត្រូវបានសម្លាប់នៅការដ្ឋានប្រឡាយស្ពានស្រែងឡើយ។ ទោះជាយ៉ាងនេះក្តី អ្នកធ្វើការនៅការដ្ឋានទទួលបានអាហារមិនគ្រប់គ្រាន់ ហើយត្រូវធ្វើពលកម្មធ្ងន់ ក្រោមការគំរាមកំហែងនៃការចាប់ខ្លួន ឬកាន់តែអាក្រក់ថែមទៀត ប្រសិនបើពួកគេមិនអាចបំពេញបានតាមផែនការកំណត់លើការងាររបស់ពួកគេទេនោះ។ ជាលទ្ធផល អ្នកធ្វើការធ្លាក់ខ្លួនឈឺ ហើយពួកគេមួយចំនួនបានស្លាប់ ដោយសារតែការនឿយហត់ខ្លាំង ដែលបណ្តាលមកពីការធ្វើពលកម្មហួសកម្រិត និងការហូបចុកមិនគ្រប់គ្រាន់។ យ៉ាងហោចណាស់ គេអាចប្រមើលមើលដឹងថា ការដាក់ពលករឱ្យស្ថិតក្នុងស្ថានភាពបែបនេះ អាចបណ្តាលឱ្យពួកគេស្លាប់បាន។ ហេតុដូច្នេះ យើងជឿថា មានភស្តុតាងគ្រប់គ្រាន់ដែលថា អំពើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើងនៅការដ្ឋានប្រឡាយស្ពានស្រែង។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការដាក់ឱ្យទៅជាទាសករ*

២៩៨. កម្មាភិបាលភូមិភាគនិរតីបានប្រើប្រាសអំណាចជាម្ចាស់ទៅលើពលករ ជាពិសេស តាមរយៈការកំណត់ថា ពួកគេត្រូវសម្រាកនៅទីណា ក្រោកឡើងនៅពេលណា ត្រូវហូបអ្វី (ប្រសិនបើមានអ្វីហូប) និងបង្ខំពួកគេធ្វើពលកម្មធ្ងន់ ដែលពេលខ្លះ មានការឃោមកាម និងជាក់ស្តែងក្រោមការគំរាមកំហែងសម្លាប់ ប្រសិនបើពួកគេមិនអាចបំពេញបានតាមផែនការការងារ ឬមិនបានគោរពតាមការកំណត់ជាក់លាក់ទេនោះ។ ផ្អែកលើលក្ខណៈនៃការរៀបចំត្រឹមត្រូវ និងជាប្រព័ន្ធនេះ យើងជឿថា ស្ថានភាពទាំងអស់នេះត្រូវបានកំណត់ឡើងដោយមានចេតនាប្រើប្រាស់អំណាចនៃការត្រួតត្រាទៅលើអ្នកទោស។ ហេតុដូច្នេះយើង



* ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION *

យល់ថា ភស្តុតាងបានគាំទ្រថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការដាក់ឱ្យទៅជាទាសករ ត្រូវបានប្រព្រឹត្តឡើងនៅការដ្ឋានប្រឡាយស្ពានស្រែង។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការដាក់ក្នុងមន្ទីរឃុំឃាំង*

២៩៩. ពលករនៅការដ្ឋានប្រឡាយស្ពានស្រែង ដែលមានកំហុស ឬមានបំណងរត់គេច ត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំត្រយោង។ ពលករត្រូវបានចាប់ខ្លួនតាមអំពើចិត្ត ហើយធ្វើឡើងនៅពេលយប់។ មិនមានភស្តុតាងបង្ហាញថា អ្នកដែលត្រូវបានចាប់ខ្លួនទទួលបានសិទ្ធិណាមួយ ឬត្រូវបាននាំយកមកចំពោះមុខបុគ្គលណាម្នាក់ដែលមានអំណាចពិនិត្យទៅលើភាពស្របច្បាប់នៃការចាប់ខ្លួនពួកគេនោះឡើយ។ មិនមានការបង្ហាញផងដែរថា រយៈពេលនៃការឃុំឃាំងត្រូវបានកំណត់ទុកជាមុននោះឡើយ។ ចុងក្រោយ មានភស្តុតាងបង្ហាញថា អ្នកដែលបញ្ជា និងអនុវត្តការចាប់ខ្លួន បានដឹងថា ការចាប់ខ្លួននេះធ្វើឡើងតាមអំពើចិត្ត។ ហេតុដូច្នេះ យើងជឿថា ការដាក់ក្នុងមន្ទីរឃុំឃាំងដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើង នៅការដ្ឋានប្រឡាយស្ពានស្រែង។ យើងកត់សម្គាល់ថា ការដាក់ក្នុងមន្ទីរឃុំឃាំង គឺជាអ្វីដែលនៅក្នុងទ្រឹស្តីច្បាប់ព្រហ្មទណ្ឌ កំណត់ថាជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តបន្ត។ ហេតុដូច្នេះ ការឃុំឃាំងអ្នកដែលត្រូវបានចាប់ខ្លួននៅស្ពានស្រែង និងបញ្ជូនទៅភ្នំត្រយោង ដែលនៅទីនោះពួកគេត្រូវបានឃុំខ្លួនបន្ត ត្រូវចាត់ទុកថាជាឧក្រិដ្ឋកម្មតែមួយ។ ប្រសិនបើ **អ៊ឹម ចែម** ត្រូវបានបញ្ជូនទៅជំនុំជម្រះ ពីបទស្តីពីការដាក់ក្នុងមន្ទីរឃុំឃាំង នៅទីតាំងទាំងពីរនោះ ករណីនៃការឃុំឃាំងដែលរកឃើញនៅស្ពានស្រែង មិនអាចត្រូវរាប់ម្តងទៀតប្រឆាំងនឹងរូបគាត់ឡើយ ពាក់ព័ន្ធនឹងភ្នំត្រយោងនេះ។

៣00. យើងមិនជឿថា ការដាក់ឱ្យទៅជាទាសករចំពោះពលករនៅការដ្ឋានប្រឡាយស្ពានស្រែង មិនត្រូវបានចាត់ទុកថាជាការដាក់ក្នុងមន្ទីរឃុំឃាំងឡើយ។ ទោះបីជាមានភស្តុតាងដែលបង្ហាញថា មានការតម្រូវឱ្យមានលិខិតអនុញ្ញាតក្នុងការចាកចេញពីការដ្ឋានក៏ដោយ តែក៏មានភស្តុតាងដែលបង្ហាញថា កម្មករដែលឈឺត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅភូមិរបស់ពួកគេ ឬទៅកាន់មន្ទីរពេទ្យក្នុងស្រុក។ មានភាពមិនច្បាស់លាស់ដែលថា តើកម្លាំងពលកម្មទាំងអស់ត្រូវបានបង្ខំឱ្យនៅការដ្ឋានពេញមួយយប់ ឬក៏ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅភូមិ

របស់ពួកគេនោះឡើយ។ សរុបមក ទោះបីជាមានភស្តុតាងបង្ហាញថា សេរីភាពរបស់ពលករត្រូវបានរឹតត្បិតក៏ដោយ តែយើងមិនអាចសន្និដ្ឋានបានថា ក្រៅម៉ោងបំពេញការងារ សេរីភាពរបស់ពួកគេត្រូវបានរឹតត្បិតដល់កម្រិតមួយដែលស្មើទៅនឹងការរឹតត្បិតដែលអ្នកជាប់ឃុំឃាំងមានឡើយ។

*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាអំពើអមនុស្សធម៌ដទៃទៀត*

៣០១. មានមូលដ្ឋានសមស្របក្នុងការសន្និដ្ឋានថា របបអាហារនៅការដ្ឋានប្រឡាយស្ពានស្រែងត្រូវបានកាត់បន្ថយបន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីមកដល់ ហើយយ៉ាងណាក៏ដោយ របបអាហារទាំងនោះមិនគ្រប់គ្រាន់ទេ។ មានភស្តុតាងដែលអាចជឿបានថា ពលករដែលមិនអាចបំពេញបានតាមផែនការការងារប្រចាំថ្ងៃ ត្រូវបានគេផ្ដាច់របបអាហារទាំងស្រុងដែលជាទម្រង់មួយនៃការដាក់ទណ្ឌកម្ម ហើយពលករបានធ្លាក់ខ្លួនឈឺ ដោយសារតែមិនមានអាហារគ្រប់គ្រាន់។ យើងយល់ឃើញថា ការអនុវត្តបែបនេះបណ្ដាលឲ្យមានព្យសនកម្មលើរូបរាងកាយយ៉ាងធ្ងន់ធ្ងរ ហើយក៏ជាការវាយប្រហារដល់សេចក្ដីថ្លៃថ្នូរបស់មនុស្សផងដែរ។ ហេតុដូច្នេះ យើងជឿថា ការដកហូតម្ហូបអាហារ ត្រូវបានចាត់ទុកថាជាអំពើអមនុស្សធម៌ដទៃទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៣០២. មានភស្តុតាងជាច្រើនដែលបង្ហាញថា ពលករត្រូវបានចាប់ខ្លួន យកចេញទៅ ឬបាត់ខ្លួនពីការដ្ឋានប្រឡាយស្ពានស្រែង ព្រមទាំងមានភស្តុតាងថា អ្នកដែលបានបាត់ខ្លួនពីការដ្ឋានប្រហែលជាត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយោង។ ទោះបីជាមានការសង្ស័យតិចតួចប៉ុណ្ណោះដែលថា ក្រុមគ្រួសារពលករដែលបានបាត់ខ្លួនអាចដឹងពីជោគវាសនារបស់ពួកគេ ឬដឹងអំពីទីកន្លែងស្នាក់នៅរបស់ពួកគេក៏ដោយ តែមិនមានភស្តុតាងបង្ហាញថា មានការសួរលើចំណុចនេះទៅអាជ្ញាធរដែលទទួលខុសត្រូវលើការដ្ឋានឡើយ។ ដោយសារមូលហេតុនេះតែមួយ ភស្តុតាងមិនអាចអនុញ្ញាតឲ្យយើងសន្និដ្ឋានបានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការបាត់ខ្លួនដោយបង្ខំត្រូវបានប្រព្រឹត្តឡើងនៅការដ្ឋានប្រឡាយស្ពានស្រែងឡើយ។

*អំពើមនុស្សឃាតដោយគិតទុកមុន*



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៣០៣. មិនមានភស្តុតាងនៃអំពើមនុស្សឃាតដោយគិតទុកមុន នៅការដ្ឋានប្រឡាយស្ពានស្រែង ឡើយ។

### គ. ការកត់សម្គាល់ទៅលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ប៉ុន្តែមិនត្រូវបាន ដាក់ក្រោមការពិនិត្យប្រឆាំងនឹង អ៊ឹម ចែម

៣០៤. នៅក្នុងផ្នែក ៥(២) ខាងលើ យើងបានពិនិត្យមើលដោយសង្ខេបទៅលើភស្តុតាងនៃទីតាំង ឧក្រិដ្ឋកម្មមួយចំនួន ដែលបើទោះបីជាមិនមានការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម ក៏ដោយ ប៉ុន្តែបង្កើតបានជាផ្នែកមួយនៃការចោទប្រកាន់ដោយសហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំង រូបគាត់។

៣០៥. សម្រាប់គោលបំណងនៃការសន្និដ្ឋានរបស់យើងអំពីយុត្តាធិការបុគ្គល ដែលនឹងត្រូវ ពិភាក្សានៅផ្នែកបន្ទាប់នោះ យើងកត់សម្គាល់ថា ភស្តុតាងបានបង្ហាញថា ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត ការដាក់ឱ្យទៅជា ទាសករ អំពើអមនុស្សធម៌ដទៃទៀត ការធ្វើទុក្ខបុកម្នេញ ព្រមទាំងឧក្រិដ្ឋកម្មជាតិនៃអំពើ មនុស្សឃាត ត្រូវបានប្រព្រឹត្តឡើងនៅវត្តអង្គស្រីមាលា និងទីតាំងសម្លាប់មនុស្សព្រៃសុខុន វត្តព្រះនេត្រព្រះនិងទីតាំងដែលពាក់ព័ន្ធនានា មន្ទីរសន្តិសុខភូមិចក្រី ទីតាំងសម្លាប់មនុស្ស ព្រៃតារ៉ុត វត្តចំការខ្នុរ និងការដ្ឋានត្រពាំងថ្ម។

## VII. ការសន្និដ្ឋានលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នៅលើ អ៊ឹម ចែម

### ក. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តឡើង នៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង

៣០៦. យើងបានសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើ អមនុស្សធម៌ដទៃទៀត ត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខភ្នំត្រយោង និងឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរ ឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត ត្រូវបានប្រព្រឹត្តឡើងនៅការដ្ឋានប្រឡាយស្ពាន



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ស្រែង។ យើងក៏បានសម្រេចផងដែរថា អំពើមនុស្សឃាតដោយគិតទុកមុន ត្រូវបានប្រព្រឹត្តឡើងនៅការដ្ឋានប្រឡាយស្ពានស្រែង។

៣០៧. ភស្តុតាងស្តីពីការទទួលខុសត្រូវ ការប្រព្រឹត្តិ និងសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** បានបង្ហាញយ៉ាងរឹងមាំថា គាត់អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ តាមរយៈទម្រង់នៃការទទួលខុសត្រូវដែលមាននៅក្នុងសេចក្ដីជូនដំណឹងអំពីបទចោទ[731]។

៣០៨. ទីមួយ ចាប់តាំងពីខែមីនា ឆ្នាំ១៩៧៧ នៅពេលដែលតាម៉ុក បញ្ជូន **អ៊ឹម ចែម** ទៅតំបន់៥ នៃភូមិភាគពាយ័ព្យ រហូតដល់ពេលបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ នៅដើមខែមករា ឆ្នាំ១៩៧៩ តាម៉ុក **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគពាយ័ព្យដទៃទៀត មានផែនការរួមគ្នាក្នុងការផ្លាស់ប្ដូរកម្មាភិបាលពាយ័ព្យនៅក្នុងរដ្ឋបាលនៃភូមិភាគពាយ័ព្យ និងក្នុងការអនុវត្តគោលនយោបាយរបស់ ប.ក.ក ឱ្យបានជោគជ័យ។ ពួកគេអនុវត្តការងារទាំងនេះតាមរយៈការចាប់ខ្លួន និងសម្លាប់កម្មាភិបាលនៅទីកន្លែងនៅគ្រប់កម្រិតទាំងអស់នៃរដ្ឋបាល ចាប់តាំងពីកម្រិតភូមិភាគ រហូតដល់កម្រិតសហករណ៍។ ពួកគេក៏បានឃុំខ្លួន និងសម្លាប់ពលករដែលគេគិតថាជាខ្មាំង និងអ្នកដែលគេចាត់ទុកថាមានទំនាក់ទំនងជាមួយវៀតណាម ឬជាមួយរដ្ឋាភិបាលលន់ នល់។ លើសពីនេះទៀត ពួកគេបានកំណត់លក្ខខណ្ឌពលកម្មនៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង ដែលយើងយល់ឃើញថាជាការដាក់ឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត។

៣០៩. **អ៊ឹម ចែម** បានរួមចំណែកដល់ផែនការនេះ តាមរយៈការគ្រប់គ្រងលើការដ្ឋាន និងមន្ទីរសន្តិសុខ និងតាមរយៈការចេញបញ្ជាឱ្យចាប់ខ្លួន និងសម្លាប់ ដែលបញ្ជានេះត្រូវបានអនុវត្តដោយកងឈ្លបដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ លើសពីនេះទៀត ការចូលរួមជាបន្តបន្ទាប់របស់គាត់នៅក្នុងការដាក់ឱ្យទៅជាទាសករ ការចាប់ខ្លួន និងការសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ និងមនុស្សដទៃទៀតដែលគេគិតថាប្រឆាំងនឹង ប.ក.ក គឺជាភស្តុតាងអំពីចេតនារបស់គាត់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់នេះ។ ហេតុដូច្នេះ គាត់អាចត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានរកឃើញថាបាន

---

[731] ឯកសារ **D239.1**, *ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទ ប្រឆាំង អ៊ឹម ចែម, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥*។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ ទោះជាយ៉ាងនេះក្តី យើងកត់សម្គាល់ថា ទោះបីជាតួនាទីពីដំបូងរបស់គាត់អាចបង្ហាញថា គាត់គឺជាបុគ្គលដ៏សំខាន់នៅក្នុងផែនការឧក្រិដ្ឋនេះក៏ដោយ (ដោយសារតែគាត់បានដឹកនាំក្រុមកម្មាភិបាលកងទ័ព និងស៊ីវិលដ៏ធំមួយ ទៅភូមិភាគពាយ័ព្យ ក្នុងពាក់កណ្តាលឆ្នាំ១៩៧៧) ប៉ុន្តែ នៅពេលដែលគាត់ផ្លាស់ប្តូរទីកន្លែង ការរួមចំណែករបស់គាត់មានតែនៅស្រុកព្រះនេត្រព្រះទេ (ទោះជាយ៉ាងនេះក្តី គាត់នៅមានអំណាចលើពលករ និងអ្នកទោសនៅស្រុកដទៃទៀត) ហើយគាត់ប្រហែលជាគ្រប់គ្រងទៅលើការដ្ឋានមួយចំនួននៅក្នុងស្រុកដទៃទៀតនៃតំបន់៥។ ទោះបីជាយើងរកឃើញថា គាត់បានក្លាយជាសមាជិកនៅក្នុងគណៈតំបន់ ៥ ក៏ដោយ តែតួនាទី និងសិទ្ធអំណាចរបស់គាត់នៅក្នុងតួនាទីនេះ មិនច្បាស់លាស់ឡើយ ហើយភស្តុតាងមិនបានបង្ហាញថា គាត់បានចូលរួមនៅក្នុងរដ្ឋបាលរបស់តំបន់ទាំងមូលឡើយ។ វិសាលភាពនៃការរួមចំណែករបស់គាត់ចំពោះផែនការឧក្រិដ្ឋនេះ គឺជាអ្វីដែលយើងបានធ្វើការពិចារណា នៅក្នុងការសន្និដ្ឋានរបស់យើងអំពីយុត្តាធិការលើរូបបុគ្គល។

៣១០. តាមរយៈតួនាទី និងសិទ្ធិអំណាចរបស់គាត់ **អ៊ឹម ចែម** បានរៀបចំផែនការការងារនៅមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង។ គាត់បានញុះញង់តាមរយៈការថ្លែងរបស់គាត់ ធ្វើឱ្យមានការដាក់ប្រជាជនឱ្យទៅជាទាសករ និងការដាក់ក្នុងមន្ទីរឃុំឃាំង និងការសម្លាប់អ្នកទាំងឡាយណាដែលគេគិតថាជាខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យ។ គាត់បានបញ្ជាឱ្យដាក់ឱ្យទៅជាទាសករ ឃុំឃាំង និងសម្លាប់ប្រជាជននៅមន្ទីរសន្តិសុខភ្នំត្រយោង និងដាក់ពលករនៅការដ្ឋានប្រឡាយស្ពានស្រែងឱ្យទៅជាទាសករ។

៣១១. តាមរយៈតួនាទី ការថ្លែង និងការគ្រប់គ្រង និងត្រួតពិនិត្យរបស់គាត់ ទៅលើមន្ទីរសន្តិសុខភ្នំត្រយោង និងការដ្ឋានប្រឡាយស្ពានស្រែង គាត់បានរួមចំណែកយ៉ាងសំខាន់ តាមរយៈការផ្តល់ការគាំទ្រផ្នែកសម្ភារៈ និងស្មារតី ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់នេះ។ យើងបានឃើញថា **អ៊ឹម ចែម** បានដឹងអំពីអ្វីដែលបានកើតឡើងនៅការដ្ឋានទាំងអស់នេះតាមរយៈការចុះពិនិត្យផ្ទាល់ កិច្ចប្រជុំ និងរបាយការណ៍។ ហេតុដូច្នេះ យើងជឿថា គាត់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION
200

បានដឹងថាតាមរយៈការប្រព្រឹត្តិរបស់គាត់ គាត់បានជួយ និងជំរុញដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនេះ។

៣១២. ទោះជាយ៉ាងនេះក្តី យើងយល់ឃើញថា អ៊ឹម ចែម មិនស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ឡើយ។

**ខ. សំអាងហេតុដែល អ៊ឹម ចែម មិនស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក**

៣១៣. ការសន្និដ្ឋានរបស់យើងដែលថា **អ៊ឹម ចែម** ស្ថិតនៅក្រៅយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក នោះ ត្រូវបានធ្វើឡើង ដំបូង ដោយពិចារណាអំពីទីតាំងឧក្រិដ្ឋកម្មដែល **អ៊ឹម ចែម** ត្រូវបានចោទប្រកាន់។ ទោះជាយ៉ាងនេះក្តី ចំណុចទីពីរ យើងសម្រេចថា បើទោះបីជាពិចារណាទៅលើភស្តុតាងទាក់ទងនឹងការចោទប្រកាន់ដទៃទៀតរបស់ ស.ព.អ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតមិនបានចោទប្រកាន់នោះក៏ដោយ ក៏គាត់នៅតែស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក ដែរ ចំពោះគ្រប់ទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ទាំងអស់នោះ។ ទោះបីជាគាត់អាចជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនៅទូទាំងភូមិភាគក៏ដោយ តែការរួមចំណែករបស់គាត់មានតែត្រឹមស្រុកមួយតែប៉ុណ្ណោះ ដោយមានភស្តុតាងមិនច្បាស់លាស់អំពីសកម្មភាពរបស់គាត់នៅស្រុកដទៃទៀត និងនៅកម្រិតតំបន់។ ដោយតែមូលហេតុនេះ មិនចាំបាច់ត្រូវចោទប្រកាន់គាត់អំពីបទចោទដែលនៅសល់ដទៃទៀតឡើយ។

៣១៤. មានការចង្អុលបង្ហាញយ៉ាងច្បាស់ថា **អ៊ឹម ចែម** នៅពេលដំបូង ត្រូវបាន ស.ព.អ ចាត់ទុកថាជាមនុស្សម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយបានបញ្ចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយសារតែចំនួនអ្នកស្លាប់តាមការចោទប្រកាន់មានដល់ទៅ ៤០០០០ នាក់ ដែលកើតឡើងតែនៅមន្ទីរសន្តិសុខភ្នំត្រយោងនោះ។ ចំណុចនេះប្រាកដជាការអះអាងដែលអាចជំទាស់បាននៅពេលនោះ ប៉ុន្តែ ចំនួននេះមិនត្រូវបានគាំទ្រដោយភស្តុតាងឡើយ ដោយភស្តុតាងបានបង្ហាញពីចំនួនជនរងគ្រោះដែលទាបជាងនេះឆ្ងាយណាស់ ដូចដែលយើងបានរៀបរាប់ពីខាងលើ ហើយយើងនឹងវិភាគបន្ថែមទៀតនៅផ្នែកខាងក្រោម។



E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៣១៥. ផ្អែកលើការរៀបរាប់អំពីប្រវត្តិរូបរបស់គាត់ អំពីទីតាំងឧក្រិដ្ឋកម្ម និងទំនាក់ទំនងភស្តុតាងដែលពាក់ព័ន្ធខាងលើ អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់ឡើយ។ មានការបង្ហាញខ្លះនៅក្នុងភស្តុតាងដែលថា គាត់ប្រហែលជា "តារាដែលទើបរះ" នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យនៅពេលនោះ ហើយប្រសិនបើកម្ពុជាប្រជាធិបតេយ្យបន្តមានអត្ថិភាពនៅពេលណាមួយគាត់ប្រហែលជាបានចូលរួមជាថ្នាក់លើខ្ពស់បំផុតរបស់ក្រុម ប.ក.ក ហើយក្លាយជាមេដឹកនាំជាន់ខ្ពស់តែម្តង។ ទោះជាយ៉ាងនេះក្តី តាមជាក់ស្តែងផ្អែកលើភស្តុតាង គាត់មិនទាន់ទៅដល់កម្រិតនោះនៅឡើយ ហើយតាមពិតទៅ ឋានៈជាផ្លូវការរបស់គាត់នៅពេលនោះ និងទីកន្លែងដែលស្ថិតក្រោមការស៊ើបអង្កេតនេះ គ្រាន់តែជាលេខាស្រុកព្រះនេត្រព្រះ ហើយនៅពេលក្រោយមក គាត់មានតួនាទីមួយនៅក្នុងគណៈតំបន់៥។ ត្រឹមតែអង្គហេតុដែលថា គាត់ប្រហែលជាជួបផ្ទាល់ជាមួយអ្នកដែលត្រូវបានចាត់ទុកថាជាមេដឹកនាំជាន់ខ្ពស់នៅពេលនោះ មិនអាចចាត់ទុកស្មើនឹងការសន្និដ្ឋានអំពីឋានៈរបស់គាត់ថាជាមេដឹកនាំជាន់ខ្ពស់នោះឡើយ។ ហេតុដូច្នេះ គាត់ស្ថិតក្នុងក្រុមផ្សេងទៀតនៃអ្នកដទៃទៀតដែល "ទទួលខុសត្រូវខ្ពស់បំផុត"។ ទោះជាយ៉ាងណាក៏ដោយ យើងសម្រេចថាភស្តុតាងក៏មិនបានគាំទ្រដល់ការសន្និដ្ឋាននេះដែរ។

៣១៦. នៅក្នុងករណី អ៊ឹម ចែម នៅមានលេខាស្រុកដទៃទៀតចំនួនជាងមួយរយនាក់ក្រៅពីរូបគាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[732] ដូចជា ប្រាក់ យុត និង យាយ វីម ហើយតាមពិតទៅ តួនាទីជាលេខាស្រុកគឺគ្រាន់តែជាឋានៈកម្រិតទីបីរាប់ពីក្រោម នៅក្នុងឋានានុក្រមប៉ុណ្ណោះ (ខ្ពស់ជាងភូមិ និងឃុំ)។ យើងបានដឹងអំពីអង្គហេតុដែលថា ផ្អែកលើភស្តុតាងដែលយើងមាន គាត់មានភារកិច្ចដឹកនាំកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ ដូច្នេះគាត់មានតួនាទីលើសពីលេខាស្រុកទូទៅនោះឡើយ។ ទោះជាយ៉ាងនេះក្តី អង្គហេតុដែលថា គាត់ជាដំបូង ត្រូវបានផ្តល់តួនាទីជាលេខាស្រុក បើទោះបីជាតួនាទីសម្របសម្រួលពីពេលមុន ត្រូវយកមកពិចារណា និង មិនត្រូវសន្និដ្ឋានថាគាត់មានតួនាទីសំខាន់ និងឡើងលឿនជាលំដាប់ទេ។ អង្គហេតុដែលថា អ៊ឹម ចែម ប្រហែលជាកម្មាភិបាលនៅ

[732] សូមមើលត្រង់ចំណុចនេះផងដែរ អំពីការផ្តោះបញ្ចាំងជាពិសេស ទៅលើ អ៊ឹម ចែម ដោយសហចៅក្រមស៊ើបអង្កេតមុន គឺចៅក្រម Marcel Lemonde នៅក្នុងអត្ថបទ Marcel Lemonde និង J. Reynaud, *Un juge face aux Khmers rouges*, 2013, Seuil, 211.

01508477



កម្រិតតំបន់ នៅភូមិភាគនិរតី នៅមុនពេលដែលគាត់មកដល់ភូមិភាគពាយ័ព្យ និងបានចូលរួមពាក់ព័ន្ធម្តងទៀតនៅកម្រិតតំបន់នៅក្នុងភូមិភាគពាយ័ព្យ គឺជាកត្តាពាក់ព័ន្ធមួយដែលត្រូវពិចារណា ប៉ុន្តែ ចុងក្រោយ កត្តានេះមិនអាចជាកត្តាកំណត់សម្រាប់ការវាយតម្លៃទៅលើតួនាទីរបស់គាត់ នៅពេលបោសសម្អាតភូមិភាគពាយ័ព្យ ដែលជាអ្វីដែលគាត់ត្រូវបានគេស៊ើបអង្កេតជាចម្បងនោះឡើយ។

៣១៧. ដើម្បីចាត់ទុកថា អ៊ឹម ចែម គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយរូប ចាំបាច់ត្រូវពិនិត្យមើលឱ្យហួសពីឋានៈជាផ្លូវការរបស់គាត់ និងទៅលើកម្រិតនៃភាពធ្ងន់ធ្ងរនៃសកម្មភាពផ្ទាល់របស់គាត់ ព្រមទាំងផលវិបាកនៃអំពើទាំងអស់នោះ។ វាចាំបាច់ត្រូវពិចារណាអំពីលក្ខណៈ និងចំនួននៃការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់ ស.ព.អ និងអ្វីដែលលេចចេញពីភស្តុតាងដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេត។ ជាចុងក្រោយ ទោះបីជាអ្វីដែលបានកើតឡើងហាក់ដូចជាពិបាកទទួលយក ដូចបានលើកឡើងរួចមកហើយ អ្វីដែលសំខាន់គឺត្រូវតែពិចារណាទៅលើ បរិបទនៃព្យសនកម្មទាំងអស់ដែលបណ្តាលមកពីការអនុវត្តគោលនយោបាយរបស់របបនេះ ហើយដោយចៀសមិនរួចនឹងមានការពិនិត្យទៅលើចំនួនអ្នកស្លាប់សរុប ដែលបណ្តាលមកពីការសម្លាប់ ការបង្អត់អាហារដោយចេតនា ឬដោយការធ្វេសប្រហែស ចំពោះពលករដោយបង្ខំ និងអ្នកទោស ព្រមទាំងសេវាសុខភាពសាធារណៈ ដែលជាទូទៅមិនគ្រប់គ្រាន់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងចំនួនអ្នកដែលត្រូវបានផ្លាស់ទីលំនៅ និងអ្នកដែលត្រូវបានបង្ខំឱ្យធ្វើការធ្ងន់។ល។

៣១៨. ទោះជាយ៉ាងនេះក្តី យើងចង់បញ្ជាក់ឱ្យច្បាស់ម្តងទៀតថា ចំនួនជនរងគ្រោះចាំបាច់ត្រូវពិនិត្យមើលទៅលើបរិបទជារួមនៃភស្តុតាងរបស់សំណុំរឿងនីមួយៗ។ និយាយម្យ៉ាងទៀត ចំនួនដែលបានបង្ហាញផ្នែកលើភស្តុតាង ហើយដែលបានបង្ហាញនៅផ្នែកខាងក្រោម មិនមែនជាលក្ខខណ្ឌដាច់ខាត ដែលត្រូវអនុវត្តដោយស្វ័យប្រវត្តិនៅក្នុងដីកាដំណោះស្រាយនាពេលអនាគតឡើយ ប៉ុន្តែ ចាំបាច់ត្រូវពិនិត្យមើលរួមជាមួយនឹងតួនាទីផ្ទាល់ ការវិវឌ្ឍន៍ និងសកម្មភាពរបស់ អ៊ឹម ចែម។



ECCC * CETC * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៣១៩. ផ្អែកលើមូលដ្ឋាននេះ យើងចាំបាច់ត្រូវធ្វើការសន្និដ្ឋានថា សកម្មភាពរបស់គាត់ និងផលវិបាកនៃសកម្មភាពទាំងនោះ បណ្ដាលឱ្យមានសំណុំរឿងប្រឆាំងរូបគាត់ថាជាអ្នកទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មសាហាវយង់ឃ្នងមួយចំនួន ប៉ុន្តែ ភស្តុតាងទាំងនេះមិនមានគ្រប់គ្រាន់ក្នុងការបំពេញតាមលក្ខខណ្ឌនៃយុត្តាធិការលើរូបបុគ្គលឡើយ។

៣២០. ភស្តុតាងដែលបានរកឃើញនៅក្នុងពេលស៊ើបអង្កេត និងវាយតម្លៃតាមវិធីសាស្ត្រដែលយើងបានរៀបរាប់ពីខាងលើ អនុញ្ញាតឱ្យមានសេចក្ដីសន្និដ្ឋានដូចតទៅ អំពីចំនួនជនរងគ្រោះ។ នៅក្នុងទីតាំងឧក្រិដ្ឋកម្មចំនួនពីរ ចំនួនជនរងគ្រោះសរុបដោយអំពើមនុស្សឃាតមានចន្លោះពី ២០០០ ទៅ ១០៨០០ ក្នុងកម្រិតអតិបរមា។ ករណីនៃការដាក់ក្នុងមន្ទីរឃុំឃាំង មិនអាចបញ្ជាក់ឱ្យបានច្បាស់លើសពីការផ្ដល់ចំនួនអប្បបរមាត្រឹមរាប់រយ ហើយចំនួនអតិបរមា អាចឈានដល់រាប់ពាន់។ ប្រហែលគ្នានេះដែរ ជនរងគ្រោះនៃការដាក់ឱ្យទៅជាទាសករ មិនអាចកំណត់ចំនួនជាក់លាក់ឡើយ ហើយមានគម្លាតពីរាប់ពាន់នាក់ក្នុងតួលេខមួយ ទៅដល់ចំនួនអតិបរមាដែលមិនជាក់លាក់ ដែលមានដល់ទៅរាប់ម៉ឺននាក់។ ចំពោះតួលេខទាំងនេះ យើងប្រើលក្ខខណ្ឌអប្បបរមាកម្រិតទាបប៉ុណ្ណោះ។

៣២១. ចំពោះទីតាំងឧក្រិដ្ឋកម្មផ្សេងៗទៀតដែលមិនត្រូវបានចោទប្រកាន់ រូបភាពរួមនៃទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យ រឹតតែមានភាពមិនច្បាស់លាស់ថែមទៀត ដោយជនរងគ្រោះដោយអំពើមនុស្សឃាត មានចំនួនពីកម្រិតអប្បបរមាដែលបានកំណត់ត្រឹម ១៥០០ នាក់ រហូតដល់កម្រិតអតិបរមាកម្រិតទាបដែលមានដល់ ៨៣០០ នាក់ ផ្អែកទៅលើព័ត៌មានជាក់លាក់របស់សាក្សីមួយរូប ដែលថាមានចំនួន ១០០០ នាក់នៅទីតាំងឧក្រិដ្ឋកម្មមួយ និងចំនួនអតិបរមាដែលបានគណនាចំនួន ៧៣០០ នាក់នៅទីតាំងមួយទៀត។ ចំនួននេះមិនរាប់បញ្ចូលព័ត៌មានមិនច្បាស់លាស់ដែលថាមានដល់ "រាប់រយ" នៅទីតាំងឧក្រិដ្ឋកម្មទីបីផង។ ទីតាំងឧក្រិដ្ឋកម្មចំនួនពីរមិនមានចំនួនជនរងគ្រោះដែលគេបានដឹងឡើយ ហើយទីតាំងមួយ តាមការចោទប្រកាន់ មានអ្នកសម្លាប់មនុស្សត្រឹមពីរនាក់ប៉ុណ្ណោះ ដែលចំនួននេះ យើងយល់ឃើញថា មិនត្រូវបានបង្ហាញ ដោយផ្អែកតាមបទដ្ឋានដែលចាំបាច់ទេ។ ចំនួនសរុបនៃការដាក់ក្នុងមន្ទីរឃុំឃាំង មិនច្បាស់លាស់ទាល់តែសោះ ហើយចំនួននៃការធ្វើឱ្យទៅជាទាសករ មានការប៉ាន់ប្រមាណមួយចំនួនរាប់ពាន់ប៉ុណ្ណោះ។

៣២២. ទីតាំងឧក្រិដ្ឋកម្មមួយនៅភូមិភាគនិរតី ដែលការចូលរួមរបស់ **អ៊ឹម ចែម** មិនត្រូវបានបង្ហាញគ្រប់គ្រាន់ មានចំនួនជនរងគ្រោះក្នុងកម្រិតនៃការគណនា ត្រឹមរាប់រយ ដោយមានសាក្សីតែមួយរូបដែលបានផ្តល់ចំនួនជាក់លាក់ ៤០០០ នាក់ ដែលខុសប្លែកពីគេ។

៣២៣. ការកំណត់ប្រភេទបទល្មើសជាច្រើនដែលអាចមាន សម្រាប់អង្គហេតុតែមួយ (ជាឧទាហរណ៍ ការធ្វើទុក្ខបុកម្នេញ ឬអំពើអមនុស្សធម៌ដទៃទៀត ឬបទល្មើសមនុស្សឃាត តាមច្បាប់ជាតិ) អនុញ្ញាតឱ្យមានបទចោទប្រកាន់ជាច្រើន ហើយអាចនាំដល់ការផ្តន្ទាទោស ប៉ុន្តែ បទចោទទាំងអស់នេះមិនបានបង្កើនភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់ **អ៊ឹម ចែម** ឡើយ។

៣២៤. ទោះបីមានអង្គហេតុដែលថា យោងតាមសាក្សីខ្លះ **អ៊ឹម ចែម** មានឈ្មោះថាជាមនុស្ស "កាចសាហាវ"[733] ក៏មិននាំឱ្យគាត់មានការទទួលខុសត្រូវកើនឡើងឡើយ នៅក្នុងប្រព័ន្ធដែលមានវិវត្ត ទាំងផ្នែកខាងក្រៅ ក៏ដូចជាផ្នែកខាងក្នុង ដោយមានការគ្រប់គ្រងដោយការភ័យខ្លាច និងភាពរន្ធត់ តាមរយៈការប្រើប្រាស់ដោយចេតនានូវអំពើហិង្សា និងភាពសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ។ នេះគឺជាលំនាំដែលមានភាពស៊ីសង្វាក់គ្នានៃចម្លើយ

---

[733] ឯកសារ **D219/128**, កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ លន, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤, KH ERN 01049211 , ទ.៧។ ឯកសារ **D106/3**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ហៀម សាខន, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១២, KH ERN 00780975 , ទ.១៤។ ឯកសារ **D219/384**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ឌឹក គុយ, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥, KH ERN 01113234 , ទ.២៥។ ឯកសារ **D219/433**, កំណត់ហេតុស្តាប់ចម្លើយសាក្សី យង់ ស៊ុន, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១៥, KH ERN 01124148 , ទ.៣២។ ឯកសារ **D219/130**, កំណត់ហេតុស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤, KH ERN 01049252 , ទ.២៦៧។ ឯកសារ **D119/144**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡូត សួយ, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤, KH ERN 01009214 , ទ.៧០។ឯកសារ **D119/96**, កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុម ម៉ន, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៤, KH ERN 00976671 , ទ.៧៨។ ឯកសារ **D119/98**, កំណត់ហេតុស្តាប់ចម្លើយសាក្សី កោ ឡិន, ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ KH ERN00978914 , ទ.៤១។ ឯកសារ **D119/99**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ រស់, ថ្ងៃទី១២ ខែមីនា ឆ្នាំ ២០១៤, KH ERN 00978925 , ទ.៤១។ ឯកសារ **D119/137**, កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ិត អៀត, ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០១៤, KH ERN 01003863 , ទ.៦៤-៦៥។ ឯកសារ **D219/567**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ហែម សឿន, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥, KH ERN 01165955 , ទ.១៤២-១៤៥។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

របស់សាក្សីជាច្រើន ដែលជាអតីតខ្មែរក្រហម រួមទាំង កងទ័ពដែលថា ពួកគេខ្លួនឯងផ្ទាល់ក៏ស្ថិតក្នុងភាពភ័យខ្លាចជាប្រចាំចំពោះជីវិតរបស់ពួកគេ ព្រោះតែការអនុវត្តតាមអំពើចិត្តទាំងស្រុង និងភាពមិនអាចទាយស្មានបាននៃការផ្លាស់ប្តូរចិត្តរបស់ថ្នាក់លើពួកគេ នៅពេលដាក់ទណ្ឌកម្មលើការប្រព្រឹត្តិខុស សូម្បីតែបន្តិចបន្តួច ពីបញ្ហារបស់ពួកគេ ឬពីគោលនយោបាយរបស់អង្គការ[734]។ និយាយម្យ៉ាងទៀត ភាពកាចសាហាវ និងការភ័យខ្លាច គឺជានិយាមទៅហើយ។ ភស្តុតាងដែលប្រមូលបានក្នុងពេលស៊ើបអង្កេត មិនបានគាំទ្រដល់ការសន្និដ្ឋានដែលថា **អ៊ឹម ចែម** មិនបានរស់នៅក្នុងលក្ខណៈមួយខុសពីនិយាមនេះឡើយ ដែលអាចផ្តល់យុត្តិកម្មក្នុងការបញ្ចូលរូបគាត់ទៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះឡើយ។

៣២៥. សរុបមក កត្តានៃលក្ខណៈជាបុគ្គល ឬទម្ងន់រួមគ្នា នៃកត្តាផ្សេងៗដែលត្រូវបានពិចារណា និងបានរៀបរាប់ខាងលើ មិនអនុញ្ញាតឲ្យយើងអាចឈានដល់ការសន្និដ្ឋានមួយដែលថា អ៊ឹម ចែម ស្ថិតក្នុងប្រភេទនៃបុគ្គលដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងអត្ថន័យនៃច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ឡើយ។

ផ្អែកលើចំណុចដែលបានលើកឡើងខាងលើ **យើងសម្រេចថា**[735]៖

---

[734] ឯកសារ **D119/110**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ជុំ កាន់, ថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០១៤, KH ERN 00980394 , ឆ.៧៩-៨០ និងឯកសារ **D219/9**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ឃុន សាមឿន, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤, KH ERN 01025559 , ឆ.២៩-៣០។ឯកសារ **D219/103**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ស៊ុម សល់, ថ្ងៃទី២ ខែធ្នូ ឆ្នាំ ២០១៤, KH ERN 01043244 , ឆ.៦៧។ ឯកសារ **D119/98**, កំណត់ហេតុស្តាប់ចម្លើយសាក្សី កោ ឡិន, ថ្ងៃទី១១ ខែមីនា ឆ្នាំ ២០១៤, KH ERN00978914 , ឆ.៤១។ ឯកសារ **D106/3**, កំណត់ហេតុស្តាប់ចម្លើយសាក្សី ហៀម សាខន, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១២, KH ERN00780975 , ឆ.១៤។

[735] សហចៅក្រមស៊ើបអង្កេតជាតិសូមបញ្ជាក់សារជាថ្មីអំពីការជំទាស់របស់គាត់ទៅនឹងការសម្រេចដោយឯកតោភាគីរបស់អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon ដែលបានសម្រេចដាក់ អ៊ឹម ចែម ស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ។ សហចៅក្រមស៊ើបអង្កេតជាតិ មិនទទួលស្គាល់ និងទទួលយកជាឯកសារមានសុពលភាព ចំពោះរាល់ឯកសារដែលបង្កើតឡើង ឬ ដាក់បញ្ចូលក្នុងសំណុំរឿងដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet និង អាស្រ័យហេតុនេះហើយ ឯកសារដែលមានក្នុងសំណុំរឿងត្រូវតែចុះលេខ ដោយបន្តបន្ទាប់ពីឯកសារចុងក្រោយដែលបានដាក់ចូលក្នុងសំណុំរឿងដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk និង...



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ៖ D308/3

អ៊ុម ចែម មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។

ភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧

សហចៅក្រមស៊ើបអង្កេត

យូ ប៊ុនឡេង Michael BOHLANDER

---

បញ្ចូលនូវរាល់ឯកសារដែលបានដាក់ដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet។ សហចៅក្រមស៊ើបអង្កេតជាតិសូមកត់សម្គាល់បន្ថែមទៀតថា ក្នុងក្របខណ្ឌនៃការអនុវត្តរបស់កម្ពុជា អង្គហេតុដែលមិនបានជូនដំណឹងឬបង្ហាញនៅក្នុងពេលស៊ើបសួរមិនអាចទទួលបាននូវវាចារណកិច្ចគតិយុត្តណាមួយនៅក្នុងដីកាដំណោះស្រាយ ឡើយ។ ទោះយ៉ាងណាក៏ដោយ ដោយសារថាដីកាដំណោះស្រាយនេះលើកលែងការចោទប្រកាន់ ដោយបានផ្អែកតែទៅលើមូលហេតុកង្វះយុត្តាធិការបុគ្គល ដែលជាលក្ខណៈវិនិច្ឆ័យដែលមិនអាចអនុវត្តបាននៅក្នុងច្បាប់ជាតិ សហចៅក្រមស៊ើបអង្កេតជាតិទទួលស្គាល់ថា ក្រៅពីការបរិយាយនូវអង្គហេតុដែលទាក់ទងនឹងការចូលរួមរបស់ជនសង្ស័យ និងភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវបានចោទប្រកាន់ វាចារណកិច្ចគតិយុត្តដោយអន្លើៗទៅលើអង្គហេតុទាំងនោះគឺមានភាពចាំបាច់យ៉ាងហោចណាស់ក៏សម្រាប់ការកំណត់អំពីបញ្ហាថាតើអង្គហេតុទាំងនោះស្ថិតនៅក្រោមយុត្តាធិការរបស់ អវតក និងអាចនាំទៅរកការកំណត់អំពីភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងក្របខណ្ឌនៃយុត្តាធិការបុគ្គល។